ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ លោកអាចារ្យ កៅ-ស៊ុម, អ្នកគ្រូតព្រៃ
សិស្សនៅសាលាបាលីជាន់ខ្ពស់

---

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

លោកអាចារ្យ កៅ-ស៊ុម . . . . . វិទុរធម្មទេសនា កណ្ឌទី ១៥ . . . . . . . ១
លោកអាចារ្យ ឈឹម-ស៊ុំ . . . . . " " ១៦ . . . . . . ១៤
ព្រះមហា សោម-ឡុច . . . . . " " ១៧ . . . . . . ២៩
លោក សង់-ហង់រីហ្សាប . . . . អំពីដំណើរជីវិតនៃសត្វល្អិតៗ . . . . . . . . ៣៦
អ្នកឧកញ៉ាចេស្ដាវិនិច្ឆ័យ កែវ-ហង្ស . ប្រដៅចិត្ត (ពាក្យកាព្យ) . . . . . . . . ៥៨
អ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) . . លោកនេយ្យ ពាក្យកាព្យ (តមក) . . . . ៧៩
ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម . . . . ពង្សាវតារប្រទេសចិន . . . . . . . . . . ១០៥

*ផ្នែកសាសនា*

ដំណឹងអំពីក្រសួងធម្មការ . . . . បញ្ជីរាយនាមមន្ត្រីសង្ឃនឹងចៅអធិការ ដែល
ទើបតាំងឡើងថ្មី . . . . . . . . . . . . ១២៤
" " . . . . . បុណ្យបញ្ចុះសីមានៅវត្តនានា . . . . . . . ១២៩
ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម . . . . ប្រវត្តិសង្ខេបបញ្ចមសង្គាយនា(តមកនឹងចប់). ១៣៣
" " . . . . . ប្រវត្តិព្រះមហាកច្ចាយនត្ថេរ . . . . . . . ១៣៦
លោកអាចារ្យ ឈឹម-ស៊ុំ . . . . ពុទ្ធឃោសប្បវត្តិ . . . . . . . . . . ១៤៣

---

ឆ្នាំទី ១៥ លេខ ១-២-៣ ប្រចាំខែ យ៉ាំងវីយេរ- ហ្វេវ្រីយេរ- ១៩៤៣ ។

Kampujéa Suriya
1943
n°. 1 à 12

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ពោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ កៅ-ស៊ុម អ្នកគ្រូគ្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

ECOLE FRANÇAISE (BIBLIOTHEQUE) D'EXTRÊME-ORIENT

## បញ្ជីរឿង


| | | |
|---|---|---|
| *ផ្នែកអក្សរសាស្ត្រ* | | ទំព័រ |
| លោកអាចារ្យ កៅ-ស៊ុម . . . . | វិទ្យុធម្មទេសនា កណ្ឌទី ១៥ . . . . . . . | ១ |
| លោកអាចារ្យ ឈឹម-ស៊ុំ . . . . | " " ១៦ . . . . . . . | ១៤ |
| ព្រះមហា សោម-ឡុច . . . . . | " " ១៧ . . . . . . . | ២៩ |
| លោក សង់-ហង់រីហ្វាប . . . . | អំពីដំណើរជីវិតនៃសត្វល្អិតៗ . . . . . . . | ៣៦ |
| អ្នកឧកញ៉ាចេស្ដាវិនិច្ឆ័យ កែវ-ហង្ស . | ប្រដៅចិត្ត (ពាក្យកាព្យ) . . . . . . . . | ៥៨ |
| អ្នកឧកញ៉ាវង្សាសារពេជ្រ (នង). . | លោកនេប្បៃ ពាក្យកាព្យ (តមក) . . . . | ៧៩ |
| ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម . . . . | ពង្សាវតារប្រទេសចិន . . . . . . . . . . | ១០៥ |
| *ផ្នែកសាសនា* | | |
| ដំណឹងអំពីក្រសួងធម្មការ . . . . | បញ្ជីរាយនាមមន្ត្រីសង្ឃនិងចៅអធិការ ដែល ទើបតាំងឡើងថ្មី . . . . . . . . . . . | ១២៤ |
| " " . . . . . | បុណ្យបញ្ចុះសីមានៅវត្តនានា . . . . . . . | ១២៩ |
| ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម . . . . | ប្រវត្តិសង្ខេបបញ្ចមសង្គាយនា(តមកនិងចប់). | ១៣៣ |
| " " . . . . . | ប្រវត្តិព្រះមហាកច្ចាយនត្ថេរ . . . . . . . | ១៣៦ |
| លោកអាចារ្យ ឈឹម-ស៊ុំ . . . . | ពុទ្ធឃោសប្បវត្តិ . . . . . . . . . . | ១៤៣ |


ឆ្នាំទី ១៥ លេខ ១-២-៣ ប្រចាំខែយ៉ាំងវិយេរ៍- ហ្វេវ្រីយេរ៍- ម៉ារ្ស ១៩៤៣ ។
XV, 1-2-3, 1943

# KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Khoun Nibandhamantri NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable KAO-SIM, surveillant général de l'Ecole Supérieur de Pāli.

## TABLE DES MATIÈRES

### Partie littéraire


| | | Pages |
|---|---|---|
| Vénérable KAO-SIM...... | Conférences-Radio : "MITTAKATHĀ".. | 1 |
| » CHIM-SOUM.... | "DHAMMĀDHAMMAKATHĀ".......... | 14 |
| » MAHĀ SOM-LOCH | "VIPATTIKATHĀ"................. | 29 |
| JEAN-HENRI FABRE....... | Vie des insectes........................ | 36 |
| Oknha Chesdavinichay KÈO-HANG..... | Prâdaochet (poème)................ | 58 |
| Feu l'Oknha Vongsâsârpejna NONG.... | LOKANEYYA, traduit en vers (suite)... | 79 |
| Khoun Nibandhamantri NHOK-THÈM... | Histoire de Chine.................. | 105 |


### Partie religieuse


| | | |
|---|---|---|
| Informations du Ministère des Cultes..... | Liste des nomminations de nouveaux Chao-Atthikar................ | 124 |
| » «.... | Fêtes religieuses de divers pagodes.. | 129 |
| Khoun Nibandhamantri NHOK-THÈM.... | Conciles bouddhiques antiques (suite et fin)........................ | 133 |
| » «.... | Vie de MAHĀKACCĀYANA (un des grands disciples du Bouddha).......... | 117 |
| Vénérable CHHIM-SOUM... | Vie de BUDDHAGHOSA............... | 143 |


15e année — Nos 1-2-3. Janvier-Février-Mars-1943

Abonnement; un an 10$00.

វិទ្យុធម្មទេសនា ភាណ្ឌទី ១៥

# លោកគ្រូអាចារ្យ កៅ ស៊ុម

អ្នកត្រួតត្រាសិស្សសាលាបាលីជាន់ខ្ពស់

សំដែង កាលពីថ្ងៃសុក្រ ១៤ រោចខែជេស្ឋ ឆ្នាំមមីចត្វាស័ក ពុទ្ធសករាជ ២៤៨៥

( ១២ យូអាំង ១៩៤២ )

## នមត្ថុរតនត្តយស្ស

ខ្ញុំសូមនមស្ការ ថ្វាយបង្គំព្រះរត្នត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដែលជាទីពឹងដ៏ប្រសើរខ្ពង់ខ្ពស់ របស់សត្វលោកជាអនេក សម្រាប់ដឹកនាំសត្វទៅកាន់ព្រះនិព្វាន ដោយសេចក្ដីគោរព ។

តអំពីបទនមស្ការនេះទៅ សូមអញ្ជើញពួកទេវតាទាំងឡាយ ចូរមូលមកអំពីទិសផ្សេងៗ ស្ដាប់ធម៌ទេសនារបស់យើង ហើយសូមទំព្យាយាមប្រឹងប្រែងរក្សាព្រះពុទ្ធសាសនាជាមួយនឹងយើង ។

បណ្ដាសប្បុរសទាំងឡាយឯណា ដែលមានព្រះធម៌ជាទីពឹងដ៏ប្រសើរ បានរម្ងាប់បង់បាបជំរះស្រឡះហើយ សប្បុរសទាំងនោះដែលបានយកកំណើតកើតជាមនុស្សពិត ក៏សូមអញ្ជើញមកអំពីទិសផ្សេងៗ ហើយសូមសេពគប់ប្រសព្វជាមួយនឹងយើង ជាមិត្រស្នេហា ស្ដាប់ធម៌ទេសនារបស់យើង ក្នុងវេលានេះឯង ។

លំដាប់អំពីនេះទៅ សូមលើកយកបទ "មត្តកថា" មកអធិប្បាយតាមការដែលត្រូវសំដែងផ្សាយតាមវិទ្យុនេះ ដើម្បីជាសណ្ដាប់ដល់

អស់លោកសប្បុរសទាំងឡាយ ដែលប្រុងស្តាប់ហើយនឹងប្រតិបត្តិឲ្យបានសមគួរតាមពុទ្ធឱវាទ នឹងបានសម្រេចប្រយោជន៍សេចក្តីសុខចំរើនក្នុងលោកនេះ នឹងលោកខាងមុខ ដោយផលានិសង្សដែលបានប្រព្រឹត្តត្រឹមត្រូវនេះ ។

មុននឹងសំដែងអំពីបទមិត្តកថានេះ សូមនាំយកពុទ្ធភាសិតដែលសំដែងអំពីរបស់នៅឆ្ងាយអំពីគ្នា ៤ យ៉ាងមកផ្តើមជាឧបហេតុសិន ដោយភាសាព្រះបាលីថា:

ឥមានិ ខោ ភិក្ខវេ ចត្តារិ សុវិទូរវិទូរានិ

សេចក្តីថា: ម្នាលភិក្ខុទាំងឡាយ របស់ដែលនៅឆ្ងាយហើយសែនឆ្ងាយអំពីគ្នាមាន ៤ យ៉ាង:

១- អាកាសនឹងផែនដី

២- ត្រើយសមុទ្រខាងអាយនឹងត្រើយសមុទ្រខាងនាយ

៣- ទិសបូព៌ាខាងកើតនឹងទិសបស្ចិមខាងលិច

៤- ធម៌របស់សប្បុរសនឹងធម៌របស់អសប្បុរស ។

បណ្តារបស់ទាំង ៤ យ៉ាង ដែលបានរៀបរាប់មកនេះ ជារបស់នៅឆ្ងាយអំពីគ្នា ពុំដែលបានជួបប្រទះគ្នាដល់ម្តងសោះឡើយ ព្រមទាំងពុំដឹងសេចក្តីសុខទុក្ខ ឬដំណើរកិច្ចការគ្នាទៅវិញទៅមក ទំនទួលអំណរសេចក្តីរុងរឿងអ្វីមួយដល់គ្នាពុំកើត, ដូចអាកាសឬមេឃដែលខ្ពស់ស្រឡះ

ផុតអំពីផែនដីឥតមានបំណងបង្អុរភ្លៀងឲ្យធ្លាក់ចុះមកលើផែនដី ហើយហូរច្រោះបំផ្លាញផែនដីឲ្យដាច់ធ្លាក់ចុះទៅក្នុងមហាសមុទ្រ ឬទន្លេស្ទឹង-ព្រែកនោះឡើយ ឯផែនដីក៏មិនអាចទ្រាំស្រែកប្រាប់ទៅអាកាសថា: "នែ អា-កាស! ឯងកុំបង្អុរភ្លៀងឲ្យធ្លាក់ចុះមកលើអញ ហើយហូរច្រោះនាំឲ្យអញចូលទៅក្នុងមហាសមុទ្រ ឬស្រែកប្រាប់ថា អញស្រេកណាស់ ត្រជាក់ណាស់ ឯទន្លេ-ស្ទឹង-ព្រែក, រុក្ខជាតិ លតាវល្លិជាដើម ដែលអាស្រ័យនឹងអញសោត ក៏លិចលង់ស្លាប់អស់ហើយ ឯងឈប់កុំភ្លៀងមកដូច្នេះពុំបានដែរ"; ពុំនោះសោត កាលបើផែនដីទទួលកំដៅព្រះអាទិត្យក្តៅបែកក្រ-ហែងក្នុងរដូវខែប្រាំង ក៏មិនអាចអង្វរអាកាស សូមឲ្យភ្លៀងធ្លាក់មកជួយការពារកំដៅព្រះអាទិត្យបានឡើយ យ៉ាងនេះបានឈ្មោះថាអាកាសនឹងផែនដីប្រស្រ័យយកគ្នាជាមិត្តសំឡាញ់ឲ្យសមតាមសេចក្តីប្រាថ្នារបស់ខ្លួនពុំកើត ។

ដែលថាត្រើយសមុទ្រខាងអាយនឹងត្រើយសមុទ្រខាងនាយ ជារបស់នៅឆ្ងាយអំពីគ្នានោះ ក៏ដូចអាកាសនឹងផែនដីដែរ គឺថានឹងប្រាប់ដំណឹងទៅវិញទៅមករកគ្នាថា "ត្រើយសមុទ្រខាងនេះ មានភ្នំធំតូចខ្ពស់ទាប ដើមឈើលតាវល្លិធំតូចវែងខ្លីមានពណ៌សណ្ឋានទ្រង់ទ្រាយយ៉ាងនេះ យ៉ាងនោះ ឬត្រីតូចធំសម្បូរនៅកៀនកោះនេះប៉ុណ្ណោះៗ មានចំ

តួបដុះពេលជាដូរតាមមាត់សមុទ្រប៉ុណ្ណោះៗ លោកបក់បោកមកគង់ ១ ថ្ងៃ ប៉ុណ្ណោះៗ" ពុំបានទន់យកគ្នាជាមិត្តសំឡាញ់ជាទីពឹងពាក់ក៏មិនកើត ។

ដែលថា ទិសបូព៌ាខាងកើត នឹងទិសបស្ចិមខាងលិច ជារបស់នៅឆ្ងាយអំពីគ្នានោះ ក៏មិនជាអ្នកជានាជួយការពារប្រាប់ដំណឹងចំពោះហេតុអ្វីមួយ ដែលកើតឡើងដល់គ្នាបានដល់មួងឡើយ សូម្បីតែព្រះអាទិត្យព្រះចន្ទដែលរះឡើងអំពីទិសបូព៌ា ក៏ពុំដែលប្រាប់ទៅទិសបស្ចិមថា: "ព្រះអាទិត្យ ព្រះចន្ទរះឡើងហើយ ពីពេលប៉ុណ្ណោះៗ ក្តៅយ៉ាងនេះត្រជាក់យ៉ាងនេះ មានទំហំវង់មូលប៉ុណ្ណោះៗ ទុកណាជាព្រះអាទិត្យព្រះចន្ទដើរទៅដល់ទិសខាងលិចហើយ ទិសបស្ចិមក៏មិនដែលប្រាប់ត្រឡប់ទៅទិសខាងកើតថា ព្រះអាទិត្យព្រះចន្ទមកដល់កន្លែងខ្ញុំពេលប៉ុណ្ណោះហើយក្តៅយ៉ាងនេះ ត្រជាក់យ៉ាងនេះ មានទំហំវង់មូលប៉ុណ្ណោះៗ លិចបាត់ទៅពេលប៉ុណ្ណោះដែរ" នឹងប្រស្រ័យយកជាមិត្តសំឡាញ់ឲ្យជួយសម្រេចកិច្ចណាមួយពុំបានឡើយ ។

ដែលថា ធម៌របស់សប្បុរស នឹងធម៌របស់អសប្បុរស ជាធម៌ឆ្ងាយអំពីគ្នានោះ គួរជ្រាបថា: លោកដែលជាសប្បុរសអ្នកមានប្រាជ្ញា បានប្រកបដោយធម៌ទាំង ៧ យ៉ាង មានសទ្ធាការជឿកម្មនឹងផលរបស់កម្ម ជឿហេតុដែលគួរជឿជាដើម លោកមិនបានធ្វើអំពើអាក្រក់ដោយ កាយ-វាចា-ចិត្តដែលជាអំពើនាំឲ្យមានទោសទុក្ខក្នុងនាលោកនេះ នឹងបរលោក

ខានមុខមិនដែលចូលទៅសេពគប់សមាគមឲ្យប្រឡូកប្រឡំដោយទុជ៌នជាអសប្បុរសនោះឡើយ ព្រោះថា ជនជាអសប្បុរសតែងប្រព្រឹត្តធ្វើអំពើអាក្រក់ដ៏មោះមុត លោកទុកដូចជាពស់វែកដែលមានពិសដ៏ខ្លាំងក្លា អាចចឹកបុគ្គលដទៃឥតត្រាប្រណីថា នេះមនុស្សប្រុសតូចធំទាំងពួងឡើយ ក៏នឹងធ្វើសេចក្ដីភ័យឲ្យកើតឡើង ដរាបដល់អន្តរាយជីវិតក៏មាន ។

ហេតុនេះឯង ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងថា: "ចជ ទុជ្ជនសំសគ្គំ ភជ សាធុ សមាគមំ" បុគ្គលត្រូវតែលះលែងកុំសេពគប់សមាគមឲ្យប្រឡូកប្រឡំ នឹងទុជ៌នជាអសប្បុរសនោះឡើយ ត្រូវចូលទៅសេពគប់សមាគមនឹងជនជាសប្បុរស យកជាមិត្តស្និទ្ធស្នាល ប្រកបនូវប្រយោជន៍របស់ខ្លួនចុះ នឹងនាំខ្លួនឲ្យកើតសេចក្ដីសុខ-ចំរើនគ្រប់ប្រការ ។

បើតាមសេចក្ដីពិតនោះ ត្រូវតែសេពគប់នឹងមនុស្សដែលខ្លាចមិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ ដែលលោកអ្នកប្រាជ្ញទាំងឡាយតែងរាប់អានសរសើរ គឺមនុស្សណាដែលប្រព្រឹត្តធ្វើអំពើដ៏លាមកអាក្រក់ ហើយមានគំនិតគិតឃើញភ័យ ដែលកើតមកអំពីសេចក្ដីទុក្ខទាល់ក្រលំបាក, នឹកដល់ផលរបស់សេចក្ដីព្យាយាមខំប្រឹងប្រែងនឹកដល់អាជីវៈរបស់សេដ្ឋីគហបតី(១) នឹកដល់អាហារដែលស្វែងរកមកចិញ្ចឹមជីវិត នឹង

---

១ ត្រូវការតែប្រាជ្ញាភោគសម្ប័ទ, ចូលចិត្តត្រិះរិះខាងនូវបញ្ហា តាំងចិត្តខ្ជាប់ខ្ជួនចំពោះទៅរកសិល្បសាស្ត្រ, ចូលចិត្តប្រកាន់មាំធ្វើការងារ, មានការងារធ្វើហើយស្រេចជាទីបំផុត ។

គតក្រាមដេកប្ដូសន្សំដើមទុន កើតឡើងចំពោះមុខទុកជាផលប្រយោជន៍ ក្រុមតាំងត្រិះរិះដល់គុណបុព្វបុរស ដែលលោកបានទំនុកបំរុងរក្សាជីវិត ទឹងវង្សត្រកូលយ៉ាងណា មិនត្រូវសេពគប់នឹងមនុស្សខ្ជិលច្រអូសដែលមានសន្ដានចិត្តដ៏ថោកទាបឡើយ ត្រូវសេពគប់នឹងមនុស្សអ្នកមានព្យាយាមជាគ្រូកន្លា ទឹងត្រូវធ្វើចិត្តឲ្យកើតសេចក្ដីឧស្សាហ៍ជានិរន្តរ៍ ទើបឈ្មោះថាជាមនុស្សមានគំនិតជាសប្បុរស អ្នកប្រាជ្ញលោកមិនដែលសរ-សើរមនុស្សដ៏កៀវក្លាខុសទំនងឡើយ ។

មិត្តកថា គួរសោធជូនទំធ្វើសេចក្ដីសាមគ្គីព្រមព្រៀងគ្នា ពប់អានយកគ្នាជាមិត្តមេត្រី ដើម្បីចៀសវាងកិរិយាអាក្រក់គ្រប់យ៉ាង ទុកជានៅស្រុកទេសឆ្ងាយអំពីគ្នា ផ្សេងដោយជាតិគោត្តត្រកូល ទីលំនៅរបរកេស៊ីក៏ដោយ ទោះមិនដែលបានជួយធុរៈកិច្ចការគ្នាក៏ដោយ វេលាដែលបាននៅជាមួយគ្នា ឬបានជួបប្រទះគ្នាក្នុងទីណាខ្លះៗ ត្រូវធ្វើសេចក្ដីល្អឲ្យប្រាកដ សមភាពជាមនុស្សជាតិមិនត្រូវសំដែងរិទ្ធិឬអំណាចគោងកាចដល់គ្នាឡើយ ។

គួរស្គាល់ឲ្យជាក់ច្បាស់ ចំពោះកិរិយារបស់ដែលមិនមែនជាមិត្តសំឡាញ់ ព្រោះមនុស្សមិនមែនជាមិត្តមែងធ្វើសេចក្ដីភ័យឲ្យកើតឡើងដល់រូបបុរសស្ត្រីក្នុងពិភពលោកនេះ ។ ឯកិរិយានោះគួរស្គាល់ថា បុគ្គលជាសត្រូវនឹងគ្នា កាលបើក្រឡេកឃើញគ្នាកាលណា ក៏ចងចិញ្ចើម

បើកភ្នែកសំឡក់សំឡឹងប្រឹងដំឡើងមុខធ្វើក្រញូវ មិនធ្វើសេចក្ដីត្រេកអរសាទរនឹងគ្នា មិនមើលឲ្យចំមុខ ប្រទះប៉ះភ្នែកគ្នាឡើយ តែងដំឡើងឫកពារខឹងយោរយៅចំពោះគ្នាជាដរាប នេះជាដំណើរកិរិយារបស់បុគ្គលមិនមែនជាមិត្ត ៗ ដូចគ្នានឹងសត្វសុនខ ក៏ធម្មតាសត្វសុនខ តែឃើញគ្នាវាហើយ ពុំដែលមានសេចក្ដីសោមនស្សរីករាយត្រេកអររាប់រកគ្នាវាទេ តែងសំដែងអាការកំហឹងប្រឹងបញ្ចេញធ្មេញបង្ហាញចង្កូមដម្លើងរិទ្ធិអំណាចរបស់វា នេះជាកិរិយារបស់សត្វឆ្កែ ៗ

ក៏ក្នុងមិត្តហាយនៈ ការណ៍ដែលនាំឲ្យបែកមិត្តពីគ្នា នាំមិនឲ្យស្រឡាញ់រាប់រកគ្នានោះ លោកសំដែងថា:

សច្ចាភិក្ខណសំសគ្គា អសមោសរណេន ច

ឯតេ ន មិត្តា ជីរន្តិ អកាលេ យាចនេន ច...

មិត្តសំឡាញ់ណាដែលរករឿងចុះចៀលគ្នាទៅវិញទៅមកឥតអធ្យោគ អធ្យាស្រ័យហួសប្រមាណ ១, មិត្តសំឡាញ់ណាដែលឃ្លាតឃ្លាបែកចាកគ្នា ជាយូរយាររមិនបានជួបមុខគ្នា ១, មិត្តសំឡាញ់ណាដែលសូមរបស់ខ្ញុំកញ្ញា ក្នុងកាលដែលមិនគួរសូម ១, ហេតុទាំង ៣ យ៉ាងនេះកើតឡើងជាញឹកញាយ មនុស្សទាំងឡាយតែងបែកបាក់ចាកគ្នា មិនបានជាមិត្តសំឡាញ់គយូរអង្វែងឡើយ ៗ ហេតុនេះមនុស្សដែលបានយកគ្នាជាសម្ពន្ធមិត្តមេត្រីហើយ គួរគប្បីចៀសវាងហេតុដែលនាំឲ្យជាទំនាស់បែកបាក់មិត្ត

នោះចេញ ហើយត្រូវប្រព្រឹត្តកាន់ចរិយាការចងសម្ពន្ធមិត្តឲ្យបានយូរអង្វែងលែងបែកបាក់គ្នានោះៗ ទៅតាមលំអានពុទ្ធភាសិតថា:

អច្ចា ភិក្ខណំ គច្ឆេ ន ច គច្ឆេ ចិរាចិរំ
កាលេន យាចំ យាចេយ្យ ឯវំ មិត្តា ន ជីយរេ ។

សេចក្តីថា មនុស្សដែលបានចងគ្នាជាមិត្តក្ដបកាន់ចិត្តស្រឡាញ់គប់រកគ្នាដោយមេត្រីហើយ មិនគួរគប្បីទៅមករកគ្នារឿយៗឡើយ យូរៗសឹមទៅម្ដង ពាក្យទំនៀមថា «ស្រឡាញ់កុំទៅញឹកៗ កាលណាលើកសឹមទៅម្ដងៗ»; មែនពិត តែថាមិនគួរបោលគ្នាឲ្យឃ្លាតឃ្លាយពេកដែរ គង់តែយូរៗទៅមករកគ្នាម្ដងទើបគួរ បើសូមរបស់អ្វីដែលគួរសូម ត្រូវសូមគ្នាតាមកាលដែលគួរសូម យ៉ាងនេះបានឈ្មោះថា សម្ពន្ធមិត្តចងចិត្តមេត្រីល្អ ទើបមិនបែកបាក់គ្នាឡើយ ។

មួយទៀត, ការដែលសង្កេតកម្មលក្ខណៈរបស់មិត្តសំឡាញ់ឲ្យឃើញជាក់ច្បាស់ រួចសឹមសេពគប់ស្និទ្ធស្នាលយកជាគៀននោះ បានដោយក្រពេកណាស់ មិនងាយនឹងស្គាល់បាន តែលោកបានពោលទុកថា:

អហិតោ បដិសេធោ ច ហិតេសុ ច និយោជតោ
ព្យសនេ អបរិច្ចាគោ សង្ខេបំ មិត្តលក្ខណំ ។

មិត្តសំឡាញ់ណា ហាមឃាត់គ្នាក្នុងកម្មមិនជាប្រយោជន៍ មិត្តសំ-ឡាញ់ណាដឹកនាំគ្នាឲ្យប្រកបក្នុងកម្មជាប្រយោជន៍ មិត្តសំឡាញ់ណាមិន

លះបង់ចោលគ្នាក្នុងគ្រាដែលមានវិបត្តិ  អាចជានាជួយជ្រោងគ្នាឲ្យបាន
ដំកល់នៅក្នុងឋានៈយសសក្តិស្មើមុខគ្នាដូចដើម  មិត្តសំឡាញ់បែបនោះ
ឯង  បុគ្គលត្រូវយកធ្វើជាមិត្តសំឡាញ់ចុះ  ដែលលោកអ្នកប្រាជ្ញកំណត់
ថាជាមហាមិត្តដ៏ប្រសើរ ។

ជនណាដែលមិនមែនជាញាតិសាច់សាលោហិតរបស់ខ្លួនទេ តែគេ
បានប្រកបប្រយោជន៍ដ៏ល្អចំពោះខ្លួន  គេបានរួបរួមសេចក្តីសុខទុក្ខជា
មួយនឹងខ្លួន  ជននោះឈ្មោះថាជាមិត្តទុកស្មើដោយញាតិសាច់សាលោ-
ហិតផៅពង្សរបស់ខ្លួនពិត,  មិត្តណាមិនមានសេចក្តីឫស្យាច្រណែនគ្នាទេ
គេបេះបីបាច់ចិញ្ចឹមរក្សាខ្លួនល្អ  មិត្តនោះលោកឲ្យឈ្មោះថា  ជាឪពុកម្តាយ
របស់ខ្លួនពិត,  ស្ត្រីណាជាមិត្តស្នេហាក្នុងផ្ទះអាចរំលត់សេចក្តីទុក្ខសោក
គ្រប់យ៉ាងបាន  ស្ត្រីនោះលោកឲ្យឈ្មោះថាភរិយាសុខសួស្តី ។

ភរិយាកាចមានចិត្តប្រទូស្តក្បត់ចិត្តស្វាមីរបស់ខ្លួនក្តី  មិត្តសំឡាញ់
កាចមានចិត្តប្រទូស្តមិត្តផងគ្នាក្តី  ខ្ញុំធំជាងម្ចាស់ក្តី  បុគ្គលជាសប្បុរសត្រូវ
ចៀសវាងវៀរលែងឲ្យស្រឡះ  កុំនៅសេពគប់យកជាគ្នា  ទឹងមានទុក្ខ
ព្រួយលំបាកដល់ខ្លួនពុំខានឡើយ  ដូចគ្នានឹងមនុស្សនៅក្នុងផ្ទះ  ដែល
មានពស់វែកនៅអាស្រ័យជាមួយផង  ទឹងមានតែសេចក្តីស្លាប់តែម្យ៉ាង
ប៉ុណ្ណោះកុំសង្ឃឹមឡើយ ។

ន័យខ្លះលោកបានសំដែងថា:

ន វិស្សសេ អមិត្តស្ស មិត្តស្សាបិ ន វិស្សសេ
កទាចិ កុបិតោ មិត្តោ សព្វទោសំ បកាសយេ ។

បុគ្គលជាសប្បុរសមិនគប្បីស្និទ្ធស្នាលកប់រកនឹងពួកជនជាអសប្បុរស ដែលមិនមែនជាមិត្តល្អ គឺមិត្តណាដែលប្រកាសប្រាប់ទោសទាំងពួងរបស់មិត្តដល់ជនដទៃក្នុងពេលដែលខឹង មិត្តនោះ បុគ្គលជាសប្បុរសមិនត្រូវស្និទ្ធស្នាលកប់រកឡើយ ។

មិត្តសំឡាញ់ណាដែលមានប្រាជ្ញាល្អ ទោះបីខ្លួនដល់សេចក្ដីព្រួយទុក្ខលំបាកដោយខ្លួនឯងយ៉ាងណា គឺមិនត្អូញត្អែរប្រាប់មិត្ត មិនកុហកបញ្ឆោតប្រាប់មិត្តផង មិនមើលងាយមិត្ត មិត្តយ៉ាងនេះ បុគ្គលជាសប្បុរសគប្បីសេពគប់យកជាមិត្តស្និទ្ធស្នាលឲ្យមាំទាំចុះ នឹងបានសេចក្ដីចំរើនប្រយោជន៍គ្រប់យ៉ាង ។

ន័យមួយទៀតថា: ការសេពគប់មិត្តដែលគួរនឹងសេពគប់មាន ១០ ពួកលោកពោលទុកថា :

ពុទ្ធា បច្ចេកពុទ្ធា ច អរហន្តា ពុទ្ធសាវកា
មាតាបិតុគរុកាតា នាយកា ធម្មទេសកា
មិត្តំ ទសវិធំ លោកេ សេវិតព្វំ នយញ្ញុនា ។

សេចក្ដីថា: បុគ្គលជាអ្នកប្រាជ្ញមានប្រាជ្ញាជំនិនូវន័យ គប្បីសេពគប់នូវមិត្ត ១០ យ៉ាងគឺ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ១, ព្រះបច្ចេកពុទ្ធ ១, ព្រះអរហន្តទាំងឡាយ ១, សាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ១, មាតា ១, បិតា ១, គ្រូអាចារ្យ ១, បងប្រុស-ស្រី ១, ញាតិមិត្តសន្ទាន ១, បុគ្គលអ្នកសំដែងធម៌ ១, បុគ្គលទាំងនេះលោកហៅថា មហាមិត្តដ៏ប្រសើរក្នុងលោក ។

មេត្តិកាវេញ្ញ កាវេយ្យ កាតវេទិញ្ញ កាវេយ្យ

ការេយ្យ កាវកោហត្ថំ តេសុ ធម្មំ ធរេសុ តំ

និច្ចភត្តិ យថា សារំ បរត្ថ សុខ ទាយកំ ។

បុគ្គលគួរធ្វើនូវកោតរបស់ខ្លួនឲ្យជាមិត្តមេត្រីផង គួរធ្វើនូវកតវេទិតាធម៌ផង គួរធ្វើនូវកិរិយាបូជាចំពោះមហាមិត្តទាំង ១០ បំពូកនេះផង ផលានិសង្សដែលខ្លួនបានធ្វើបានបូជានោះៗ លោកទុកដូចជាកំណប់ទ្រព្យដ៏មានខ្លឹម រមែងឲ្យផលគឺសេចក្ដីសុខចំរើន ទាំងនាលោកនេះទាំងលោកខាងមុខដោយពិត ។

សត្តិ ទុដ្ឋំ បិយំ មិត្តំ បុន សន្ធាតុមិច្ឆតិ

សោ មច្ចុមុបគណ្ហាតិ គព្ភោ អស្សតរី យថា ។

បុគ្គលប្រាថ្នាទំនុកបំរុងទ្រទ្រង់មិត្តសំឡាញ់ឯណា បើកប្រទុស្តហើយអស់វារៈម្ដងហើយ នឹងយកវាជាមិត្តសំឡាញ់ទៀត (ពុំបានឡើយ)

មិត្តសំឡាញ់នោះ ក៏ទីងនាំខ្លួនឲ្យចូលទៅកាន់សេចក្តីស្លាប់ជាពិតប្រាកដ ដូចគ្នានឹងគតិនៃមេសេះអស្សតរ ដែលសម្លាប់មេក (ជាទំនៀម) ។

ក្នុងទីបំផុតនៃមិត្តកថានេះ សូមនាំយករឿង ១ មកជាឧទាហរណ៍ ដើម្បីនឹងសសេចក្តីនៃមិត្តកថា ឲ្យឃើញជាក់ច្បាស់ត្រង់មិត្តសំឡាញ់ ដែលជាដឹកនាំឲ្យបានសេចក្តីសុខ-ចំរើន ដរាបដល់ឡើងថ្នាក់ទៅជា មហាមិត្តដ៏ប្រសើរ ។

សេចក្តីថា: កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង សោយព្រះជាតិជាជោតិបាលមាណព ក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សប-សម្មាសម្ពុទ្ធជាម្ចាស់ ។

គ្រានោះ មានឃដិការស្មូនឆ្នាំងម្នាក់ជាមិត្តសំឡាញ់ បាននិយាយបបួលជោតិបាលមាណព ៗ ផង ឲ្យចូលទៅគាល់ព្រះពុទ្ធកស្សបជាព្រះអរហន្តសម្មាសម្ពុទ្ធ, ឯជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំង ៗ ដដែលថា: កុំឡើយសំឡាញ់ ចុះឯងចូលទៅគាល់ស្រមណក៏ណានោះ បានជាការអ្វី! បើតែមិនព្រមទៅ ទាល់តែឃដិការស្មូនឆ្នាំងចាប់ទាញ ថ្នក់ទាញសក់ក្បាលកំពុងដុសទឹកក្បាល ហើយក៏ទាក់ចូលទៅគាល់ព្រះពុទ្ធកស្សបទាល់តែបាន ហើយសូមឲ្យព្រះអង្គសំដែងធម៌ប្រោសជោតិបាល-មាណពឲ្យជឿជាក់តែកពយ:ដោយធម្មកថារបស់ព្រះអង្គ ។

ឯជោតិបាលមាណព ក៏លះបង់ឃរាវាសចូលទៅបួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ ឃដិការស្មូនឆ្នាំងនេះ មិនត្រឹមតែមានមិត្តសំឡាញ់នឹងជោតិបាលមាណពជាឃរាវាសដូចគ្នាទេ សូម្បីតែព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សប ព្រះអង្គក៏ទំនុកទុកចិត្តស្និទ្ធស្នាលហាក់ដូចជាមិត្តសំឡាញ់ដែរ, ដូចកាលដែលគាត់មិននៅផ្ទះទៅធ្វើការផ្សេងៗ ទ្រង់ហ៊ានយាងទៅយកបាយអំពីឆ្នាំង យកសម្លអំពីភាជន៍ យកនំកុម្មាសអំពីកឡោទៅឆាន់ ។

ថ្ងៃក្រោយទ្រង់ចាត់ឲ្យភិក្ខុទាំងឡាយទៅរុះរើស្មៅ ដែលប្រក់ផ្ទះរបស់គាត់យកមកប្រក់កុដិ របស់ព្រះអង្គ ដែលលេចភ្លៀង, ទុកចំហផ្ទះនោះចោលទទេ យកអាកាសជាគ្រឿងប្រក់ដរាបអស់ ៣ ខែ ប៉ុន្តែមិនលេចភ្លៀងទេ ។

ឃដិការស្មូនឆ្នាំងមានសេចក្ដីសុខកាយសប្បាយចិត្ត ដែលកើតអំពីបីតិអស់កន្លះខែ ដោយសេចក្ដីពេញចិត្តនឹកថា ព្រះពុទ្ធលោកស្និទ្ធស្នាលនឹងអញពេកណាស់; មនុស្សដូចជាឃដិការស្មូនឆ្នាំងនេះបានឈ្មោះថាមហាមិត្តចិត្តត្រង់ ដឹកនាំសំឡាញ់គ្នាឲ្យបានសម្រេចប្រយោជន៍ដូចជាខ្លួនដែរ គួរសាធុជនទាំងឡាយទំដឹកនាំគ្នាឲ្យបានសម្រេចប្រយោជន៍គ្រប់យ៉ាងចុះ ។ ឯវំ សម្មុតា ទេសនា ។

ធម្មទេសនា សន្តិបាលចប់តែប៉ុណ្ណោះ ។

វិទ្យុធម្មទេសនា លើកទី ១៦

# របស់ព្រះអាចារ្យ ឈឹម-ស៊ុម សទ្ធម្មប្បញ្ញោ

អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

សំដែងពីថ្ងៃសៅរ៍ ៨កើត បឋមាសាឍ មមីចត្វាស័ក ព.ស. ២៤៨៩ (២០ យូហ្វាំង ១៩៤៥)

## ធម្មាធម្មកថា

សំដែងពីធម៌ត្រូវធម៌ខុស

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

វារៈនេះសូមសំដែងអំពីធម៌ត្រូវ ធម៌ខុស និងអំណោយផលនៃធម៌ត្រូវ ធម៌ខុសនោះ តាមបទបាលីពុទ្ធភាសិតថា

ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ
អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតិំ ។

ប្រែថា សភាវៈទាំងឡាយ ២ ប្រការគឺ ធម្មៈ បានដល់ធម៌ត្រូវ ១ អធម្មៈ បានដល់ធម៌ខុស ១ ឲ្យផលពុំស្មើគ្នាទេ, ធម៌ខុសរមែងនាំសត្វទៅកាន់នរក, ធម៌ត្រូវរមែងនាំសត្វទៅកាន់សុគតិ ។

បណ្ដាពាក្យទាំង ២ ម៉ាត់នេះ, សូមអធិប្បាយអំពីពាក្យថាធម៌ត្រូវជាមុន ។ ធម៌ត្រូវចែកចេញជា ៣ ប្រការគឺ:

បរិយត្តិធម៌ បានដល់ធម៌សម្រាប់សិក្សា សម្រាប់ស្ដាប់គឺ ព្រះត្រៃបិដក ដែលចែកចេញជាព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ឬហៅថា

នវង្គសត្ថុសាសនៈ ពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ប្រកបដោយអង្គ ៩ គឺៈ សុត្តៈ គេយ្យៈ, វេយ្យាករណៈ, គាថា, ឧទានៈ, ឥតិវុត្តកៈ ជាតកៈ, អព្ភូតធម្មៈ, វេទល្លៈ ។

បដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិតាម បានដល់អដ្ឋង្គិកមគ្គ ដែលជាផ្លូវនៃសេចក្តីប្រតិបត្តិប្រកបដោយអង្គ ៨ ប្រការគឺ សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ១, សម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវ១, សម្មាវាចា វាចាត្រូវ១, សម្មាកម្មន្តោ ការងារត្រូវ១, សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ១, សម្មាវាយាមោ សេចក្តីព្យាយាមត្រូវ១, សម្មាសតិ ស្មារតីត្រូវ១, សម្មាសមាធិ ចិត្តដំកល់ត្រូវ១ ។

បដិវេធធម៌ ធម៌គឺការត្រាស់ដឹង បានដល់លោកុត្តរធម៌គឺមគ្គ ៤ មានសោតាបត្តិមគ្គជាដើម, ផល ៤ មានសោតាបត្តិផលជាដើម ។

ធម៌ត្រូវទាំង ៣ ផ្នែកនេះ ជាបច្ច័យឲ្យកំឡាំងត ៗ គ្នា គឺបរិយត្តិធម៌ បើកុលបុត្របានសិក្សា បានស្តាប់ដោយការយកចិត្តទុកដាក់ហើយ, ជាពន្លឺភ្លឺឆ្លុះឲ្យយល់ច្បាស់នូវផ្លូវនៃសេចក្តីប្រតិបត្តិ ដែលហៅថា បដិបត្តិធម៌; កាលបើដំណើរកាយវាចាចិត្តប្រព្រឹត្តត្រង់ទៅតាមបដិបត្តិធម៌ហើយ, ជាហេតុឲ្យកើតសេចក្តីត្រាស់ដឹង គឺបដិវេធធម៌ជាលំដាប់ ។

បរិយត្តិធម៌ ១ មិនមែនឲ្យផលត្រឹមតែយល់ផ្លូវប្រតិបត្តិប៉ុណ្ណោះទេ បើកុលបុត្តសិក្សា ស្ដាប់ឲ្យបានសេចក្ដីចេះចាំជាប្រាកដហើយ, ជាគុណមានអានុភាពអាចនាំផលប្រយោជន៍ច្រើន មកប្រគល់ដល់កុលបុត្តអ្នកសិក្សា អ្នកស្ដាប់នោះតាំងពីគង់បច្ចុប្បន្នរៀងទៅជាប្រាកដ; គឺកុលបុត្តអ្នកទ្រទ្រង់បរិយត្តិធម៌ រមែងបានលាភសក្ការៈដោយងាយ, រមែងមានមិត្តទាំងឡាយមូលមកកប់រកគ្រប់ទិស, រមែងបានសេចក្ដីសុខសាន្តក្នុងចិត្តឥតក្ដៅក្រហាយ, រមែងបង្កើតបុណ្យទាំងឡាយដែលជាស្បៀងទៅខាងបរលោក, លុះរលាងខន្ធអំពីឥធលោកនេះបានទៅកើតក្នុងឋានសួគ៌ទេវលោក ឬសម្រេចដល់ឋានសិវៈមោក្ខគឺព្រះនិព្វានជាប្រាកដពុំខាន ។ អស់លោកទាំងឡាយប្រហែលជាបានឃើញដោយជាក់ស្ដែងថា : បរិយត្តិធម៌ អាចជ្រោងស្ទួយកុលបុត្តដែលទ្រទ្រង់ដោយហ្មត់ចត់ ឲ្យអណ្ដែតផុតពីទីទាបទៅដំកល់លើដំណែងដ៏ខ្ពង់ខ្ពស់បាន, ដូចយ៉ាងកុលបុត្រខ្លះ ដែលកើតក្នុងត្រកូលថោកទាបសោះទេ, ប៉ុន្តែបានសិក្សាបរិយត្តិធម៌ជ្រៅជ្រះ, ធម៌នោះអាចឈោងទាញប្រមូលយកបណ្ដាជនដទៃអំពីទីតំបន់ផ្សេងៗឲ្យចូលមកកាន់កុលបុត្តនោះឯងដោយសេចក្ដីគោរព, ឲ្យចូលមកទទួលយ៉ាមខ្លួនជាអ្នកស្ដាប់បង្គាប់កុលបុត្តនោះដោយស្មោះអស់ពីចិត្ត; ហេតុដូច្នោះបានជាមានសុភាសិតជាសេចក្ដីឧបមាលោកប្រៀបទុកមកថា

ស្បក័ផ្សេគុប្បលរត្តុប្បលៈ លូតលាស់ផុះផុលពីក្នុងភក់
ផុតផែនប្រឋពីទឹកក្រក់ កន្ទ៌ក្រុកក្រៃបកេសរ ។

នេះជាគូឧបមាថា: មនុស្សជាតិគ្រប់គ្នា នោះបើកើតក្នុងត្រកូលថោកទាបយ៉ាងណាក៏ដោយ ឲ្យតែកាន់បរិយត្តិធម៌ដោយមុតមាំ ក៏ប្រាកដជានឹងបានជាទីនិយមរាប់អាននៃជនានុជនទ្រេនគ្នា, ដូចជាផ្កាឈូកទុកណាជាដុះក្នុងភក់ទឹកក្រក់មិនស្អាតយ៉ាងណាក៏ដោយ ឲ្យតែលូតចេញផុតពីភក់មក ប្រាកដជាទីត្រូវការនៃភមរជាតិទាំងឡាយមានកន្ទួង, ម្រោម, ឃ្មុំ ជាដើម ដូច្នោះឯង ។ នេះត្រឹមតែកុលបុត្តដែលកើតក្នុងត្រកូលថោកទាបផង ម្ដេចគង់បណ្ដាជនស្រឡាញ់ប្ដូរចិត្តគំនិត ផ្ញើអាយុជីវិតដល់ម៉្លេះទៅហើយ, ចាំបាច់និយាយថ្វីឡើយ ដល់កុលបុត្តដែលកើតក្នុងត្រកូលខ្ពង់ខ្ពស់ស្រាប់ ។ បើប្រសិនជាមានកុលបុត្តរបស់មហាត្រកូលណាមួយសិក្សាបរិយត្តិធម៌ឲ្យច្បាស់លាស់ ប្រតិបត្តិតាមឲ្យត្រឹមត្រូវដល់កំរិត ម៉្លេះសមបណ្ដាជនស្រឡាញ់ស្ងប់ចិត្តឥតរើងរូសឡើយ ហើយប្រហែលជាឥតមានមនុស្សពាលនៅឲ្យទើសទែងក្នុងស្រុកក្នុងប្រទេសទេ ។

ក្នុងឧបមាខាងដើមនេះ មានសេចក្ដីសមគ្នានឹងរឿងនិទាន ដែលព្រះគន្ថរចនាចារ្យរៀបរៀងទុកមកថា: កាលព្រះសព្វញ្ញូបរមគ្រូជាម្ចាស់បានត្រាស់ហើយទ្រង់ត្រាច់ប្រកាសព្រះពុទ្ធសាសនា ទ្រង់ស្ដេចទៅដល់

ឧតរកោសម្ពី ជារាជធានីនៃព្រះបាទឧទេន, មានទាសីម្នាក់ខ្ទឹតឈ្មោះ នាងខុជ្ជុត្តរា ដែលនាងសាមាវតីជាអគ្គមហេសីនៃព្រះបាទឧទេន បានប្រើឲ្យទៅទិញផ្កា ចេញដំណើរទៅស្រាប់តែបានជួបប្រទះនឹងព្រះអង្គកំពុងសំដែងធម៌ទេសនា នាងបានចូលទៅស្តាប់អស់វេលាជាច្រើន, បានចាំជាក់គ្រប់បទល្មមសំដែងប្រាប់គេតទៅទៀតកើត ទើបហួសទៅទិញផ្កាយកមកជូននាងសាមាវតីជាខាងក្រោយ ដោយដំណើរយឺតយូរហួសកាលវេលា ។ នាងសាមាវតីបន្ទោសថា ម្តេចហាង! សព្វដងហាងឯងទៅទិញផ្កាត្រឡប់មកវិញភ្លាម ៗ, ម្តងនេះជាប់ទាក់ទាមដោយកិច្ចអ្វី បានជាយឺតយូរដល់ម៉្លេះ ? នាងខុជ្ជុត្តរា ជំរាបថា: ខ្ញុំចេញដំណើរទៅ ជួនជាបានជួបនឹងព្រះសម្មាសម្ពុទ្ធ កំពុងសំដែងធម៌ទេសនា; សេចក្តីធម៌អាថ៌ពីរោះពីសាណាស់ គួរឲ្យចង់ស្តាប់; ខ្ញុំជាប់ស្តាប់ធម៌ទេសនាបានជាអាក់ដំណើរយឺតយូរយ៉ាងនេះ, ក្នុងរឿងនេះ សូមព្រះនាងអភ័យទោស ។ នាងសាមាវតីនឹងស្រីទាំង ៥០០ ឮដំណឹងដូច្នោះក៏ចង់ស្តាប់ដែរ, ប៉ុន្តែទាល់គំនិតនឹងសុំព្រះរាជានុញ្ញាតចេញទៅស្តាប់ផងពុំបាន ទើបអញ្ជើញនាងខុជ្ជុត្តរាឲ្យសំដែងធម៌ទេសនាឲ្យស្តាប់, បានរៀបចំគ្រឿងប្រដាប់តុបតែងទីធម្មាសនៈដ៏ខ្ពង់ខ្ពស់ ឲ្យនាងខុជ្ជុត្តរានោះឡើងអង្គុយសំដែងធម៌ទេសនា ។ កាលបើនាងសាមាវតី នឹងស្រីទាំង៥០០ ស្តាប់បាន មានសេចក្តីជ្រះថ្លា, ក៏ធ្វើនាងខុជ្ជុត្តរាឲ្យជាអ្នកជា រួចខ្លួនអំពីនាទីជាទាសី ហើយតាំងនាង

ខុជ្ជុត្តរាឲ្យជាអាចារ្យសម្រាប់រៀនធម៌នឹងសំដែងធម៌ឲ្យស្ដាប់, បានទាំងបូជានាងខុជ្ជុត្តរាដោយគ្រឿងសក្ការបូជាផ្សេងៗ ច្រើនជាអនេក ។

រឿងនេះគួរឲ្យយល់ថា បរិយត្តិធម៌មានគុណអស្ចារ្យក្រៃពេក អាចស្រុយកុលបុត្តកុលធីតាអ្នកចេះចាំនោះឲ្យរំលោភឡើងកាន់ដំណែងដ៏ខ្ពង់ខ្ពស់បំផ្លៃរកជាងធម៌ឯទៀតៗ ។

នាងខុជ្ជុត្តរាដែលចេះសំដែងធម៌ក្ដី នាងសាមាវតីនឹងស្រីទាំង ៥០០ ដែលបូលចិត្តស្ដាប់ធម៌ក្ដី បានសម្រេចសោតាបត្តិផលខ្លះ សកទាគាមិផលខ្លះ អនាគាមិផលខ្លះ; លុះលែងជាតិអំពីអត្តភាពនេះទៅ បានទៅកើតក្នុងសុគតិសួគ៌ទេវលោកទាំងអស់គ្នា ។

ហេតុដូច្នេះ បានជាព្រះដ៏ឈ្នះមារទ្រង់ត្រាស់សំដែងថា ធម្មោ ចាបេតិ សុគតឹ ធម៌ត្រូវ រមែងនាំសត្វទៅកាន់សុគតិ ។

ចប់ធម៌ត្រូវក្នុងផ្នែកទី ១ ។

ចំណែកខាងធម៌ខុសវិញសោត ក៏មាន ៣ ផ្នែកទន្ទឹមគ្នានឹងធម៌ត្រូវនេះដែរ; គួរសប្បុរសទាំងឡាយសន្និដ្ឋានថា: ធម៌ខុសនោះគឺបរិយត្តិអធម៌ ១ បដិបត្តិអធម៌ ១ បដិវេធអធម៌ ១ ។

បរិយត្តិអធម៌ ប្រែថា: ធម៌ខុសដែលជនពាលតែងសិក្សាតែងស្ដាប់ បានដល់ធម៌ខុសដូចយ៉ាងមន្តអាគមផ្សេងៗ ជាខាងក្រៅផុតពុទ្ធសាសនា មានមន្តសណ្ដំ, មន្តស្នេហ៍ផ្ចិតមនុស្សឲ្យប្រព្រឹត្តកាយខុសក្រិត្យ

បវេណី, មន្តបន់ចំណែន, មន្តធ្មប់ជាដើម ជាគូបដិបក្ខនឹងបរិយត្តិធម៌ដែលសំដែងរួចមកហើយនេះ ។ ធម៌ខុសទាំងនេះរមែងនាំជនពាលដែលសិក្សាឲ្យសំយុងក្បាលចុះទៅកាន់នរក, សមដូចពុទ្ធភាសិតថា: អធម្មោ និរយំ នេតិ ដូច្នេះពិត ។

ចប់ធម៌ខុសក្នុងផ្នែកទី១ ។

ធម៌ត្រូវក្នុងផ្នែកទី ២ ហៅថាបដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិតាមពីអដ្ឋង្គិកមគ្គទាំង ៨ ប្រការ មានសម្មាទិដ្ឋិជាដើមដូចបានសំដែងរាប់ឈ្មោះគ្រប់ចំនួនរួចមកហើយ ។ អដ្ឋង្គិកមគ្គនេះ មានសេចក្តីប្រាកដក្នុងសុត្តន្តបិដក ១: អភិធម្មបិដក ១: កំណត់ឲ្យឈ្មោះថាសម្មត្តនិយតាធម៌ប្រែថា "ធម៌ទៀងក្នុងផ្លូវត្រូវឬថាធម៌ប្រាកដជាត្រូវ" ដែលជាគូបដិបក្ខនឹងមិច្ឆត្តនិយតាធម៌ ប្រែថា "ធម៌ទៀងក្នុងផ្លូវខុស ឬធម៌ប្រាកដជាខុស" ដូចពុទ្ធភាសិតដែលមានប្រាកដមកក្នុងបទមាតិកាអភិធម្មថា "សម្មត្ត-និយតា ធម្មា មិច្ឆត្តនិយតា ធម្មា" ដូច្នេះជាដើម ។

បដិបត្តិធម៌គឺ អដ្ឋង្គិកមគ្គទាំង ៨ ប្រការនេះ ជាបច្ច័យឲ្យកំឡាំងតៗគ្នា បើបុគ្គលណាប្រតិបត្តិធ្វើសម្មាទិដ្ឋិសេចក្តីយល់ត្រូវឲ្យកើតឡើងបានហើយ ជាហេតុឲ្យកើតសម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវជាដើមតមកទៀត ជាលំដាប់ហូតដល់សម្មាសមាធិជាទីបំផុតពុំខាន ។

គន្លងនៃសេចក្តីប្រតិបត្តិទាំង ៨ ខនេះ ជាធម៌សម្រាប់ផ្តាច់ផ្តិលនូវគំនរនៃសេចក្តីទុក្ខ ហើយប្រមូលយកនូវសេចក្តីសុខមកប្រគល់ឲ្យ ជាអំណោយដ៏វិសេសជាងអំណោយនៃមនុស្ស ទេពតា មារ ព្រហ្មទាំងពួង, សមដូចពុទ្ធភាសិតថា

ន តំ មាតា បិតា កយិរា អញ្ញេ វា ប ច ញាតកា

សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

ប្រែថា ប្រយោជន៍គឺសេចក្តីសុខសេចក្តីចំរើន ដែលមាតាបិតាញាតកាធ្វើឲ្យសម្រេចដល់ខ្លួន ឬដល់បងប្អូនពុំបាន នោះមានតែចិត្តដែលបុគ្គលផ្គងឡើងត្រូវ ហៅថាសម្មាទិដ្ឋិនេះ ទើបអាចធ្វើឲ្យសម្រេចបាន ឬធ្វើឲ្យសម្រេចវិសេសហួសពីនោះទៅទៀតក៏សឹងបាន ដោយឥតទើសទាល់ ។

បណ្តាជនដែលស្រឡាញ់រាប់អានយើងទាំងប៉ុន្មាន នោះបំផុតត្រឹមលោកអ្នកដ៏មានគុណគឺមាតាបិតាគ្រូអាចារ្យជាដើមប៉ុណ្ណោះ, ប៉ុន្តែទុកជាមាតាបិតាដែលមានបុណ្យច្រើន ដូចមាតាបិតារបស់នាងវិសាខាជាដើម ក៏អាចចែកផលប្រយោជន៍ឲ្យកូនបាន ត្រឹមតែសម្បត្តិដែលខ្លួនមានស្រាប់ប៉ុណ្ណោះ, ដែលនឹងក្រសោបយកសម្បត្តិក្នុងមហាទ្វីបទាំង ៤ មកចែកឲ្យកូនផង នោះពុំបានជាដាច់ខាត ។ បើត្រឹមតែសម្បត្តិមនុស្សក្នុងមហាទ្វីបទាំង ៤ មាតាបិតាប្រមូលយកមកចែកកូនពុំបានទៅហើយ, ចាំបាច់

និយាយថ្វីឡើយដល់សម្បត្តិទេពតាក្នុងឋានសួគ៌ ៗ មានតែចិត្តដែលបុគ្គលផ្គងឡើងត្រូវគឺសម្មាទិដ្ឋិនេះ ទើបអាចប្រគល់សម្បត្តិមនុស្សក្នុងមហាទ្វីបទាំង ៤ ទឹងសម្បត្តិទេពតាក្នុងឆកាមាវចរសួគ៌ ៦ ជាន់ទឹងសម្បត្តិក្នុងព្រហ្មលោក ១៦ ជាន់ ព្រមទាំងលោកុត្តរសម្បត្តិ គឺមគ្គ ផល និព្វាន ឲ្យដល់ជនទាំងពួងបានជាប្រាកដ ៗ ហេតុដូច្នេះ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា ធម្មោ បាបេតិ សុគតឹ ធម៌ត្រូវរមែងញុំាងសត្វឲ្យដល់នូវសុគតិ គឺធ្វើបណ្ដាជនអ្នកប្រតិបត្តិឲ្យមានដំណើរល្អទៅខាងមុខ ៗ

ចប់ធម៌ត្រូវក្នុងផ្នែកទី ២ ។

ឯធម៌ខុសក្នុងផ្នែកទី ២ ហៅថាបដិបត្តិអធម៌ ដែលជាគូបដិបក្ខនឹងបដិបត្តិធម៌នោះ ក៏មាន ៨ ប្រការដូចគ្នាដែរ គឺមិច្ឆាទិដ្ឋិ សេចក្ដីយល់ខុស ១, មិច្ឆាសង្កប្បោ សេចក្ដីត្រិះរិះខុស ១, មិច្ឆាវាចា វាចាខុស ១, មិច្ឆាកម្មន្តោ ការងារខុស ១, មិច្ឆាអាជីវោ ការចិញ្ចឹមជីវិតខុស ១, មិច្ឆាវាយាមោ សេចក្ដីព្យាយាមខុស ១, មិច្ឆាសតិ ស្មារតីខុស ១, មិច្ឆាសមាធិ ចិត្តដំកល់ខុស ១, ធម៌ទាំង ៨ ប្រការនេះ មានសេចក្ដីប្រាកដក្នុងសុត្តន្តបិដកខ្លះ អភិធម្មបិដកខ្លះ កំណត់ឲ្យឈ្មោះថា "មិច្ឆត្តនិយតាធម៌" ប្រែថា ធម៌ទៀងក្នុងផ្លូវខុស ឬថាធម៌ប្រាកដជាខុស" ។ បើមិច្ឆាទិដ្ឋិ សេចក្ដីយល់ខុសមានហើយ ជាបច្ច័យឲ្យកើតធម៌ខុសមានមិច្ឆា-

សង្កប្បោ សេចក្តីត្រិះរិះខុសជាដើម តៗគ្នាជាលំដាប់ ហេតុដល់មិច្ឆាសមាធិ ជាទីបំផុត ។

មិច្ឆាទិដ្ឋិ សេចក្តីយល់ខុសនោះ ចែកចេញជាប្រភេទយ៉ាងសង្ខេប មាន ២ យ៉ាង; ចែកចេញយ៉ាងកណ្តាលមាន ៣ ប្រការ ចែកចេញដោយពិស្តារមាន ៦២ ប្រភេទ ។

ឥឡូវនេះ សូមចែកក្នុងប្រភេទយ៉ាងកណ្តាលថា: សេចក្តីយល់ខុសមាន ៣ ប្រការនោះគឺ អកិរិយទិដ្ឋិ សេចក្តីយល់ឃើញថា អំពើអាក្រក់ដែលគេសន្មតថាបាប ដូចយ៉ាងបៀតបៀនគំរាមអ្នកដទៃដោយអាជ្ញាជាដើមក្តី ប្រព្រឹត្តក្បត់ស្វាមីភរិយារបស់អ្នកដទៃជាដើមក្តី, និយាយកុហក ទ្រគោះ បោកបោះ ស៊កសៀត ញុះញង់ជាដើមក្តី ដែលគេសន្មតថាបាប នោះទុកជាបុគ្គលបានធ្វើហើយ ក៏ហើយៗទៅទេ មិនជាបាបអ្វីទេ, ដូច្នេះ ១; អហេតុកទិដ្ឋិ សេចក្តីយល់ឃើញថា គ្មានហេតុដែលនាំសត្វឲ្យសៅហ្មង ឬបរិសុទ្ធទេ សត្វទាំងឡាយ សៅហ្មងឯងៗ បរិសុទ្ធឯងៗ ដូច្នេះ ១, នត្ថិកទិដ្ឋិ សេចក្តីយល់ឃើញថា ឲ្យទានគ្មានផល បូជាគ្មានផល ឬយល់ថា កិច្ចដែលគេសន្មតថាបុណ្យ បើបុគ្គលណាបានធ្វើហើយ ក៏គ្រាន់តែឲ្យមនុស្សពោលសរសើរក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ, ដែលនឹងឲ្យផលទៅក្នុងលោកខាងមុខ ដូចសំដីដែលជនពាលថាបញ្ឆោតមកនោះ ពុំមានដោយដាច់ខាតដូច្នេះ ១ ។ នត្ថិកទិដ្ឋិ ៣ នេះនឹងហៅថា ឧច្ឆេ-

ទិដ្ឋិ ដូច្នេះវិញក៏បាន គឺសេចក្ដីយល់ឃើញថា សត្វទាំងឡាយកាល ទម្លាយរាងកាយទៅហើយ សូន្យទេ វិនាសឈឹង ខាងទាយ អំពីសេចក្ដីស្លាប់ទៅមិនមានអ្វីទៀតទេ ។ បុគ្គលណាយល់ដូច្នេះហើយ នោះមុខជាលែងធ្វើបុណ្យ ព្រោះគិតថាមិនដឹងយកបុណ្យទៅប្រើការឯណា ហើយឥតញញើតនឹងអំពើបាប ព្រោះគិតឃើញថា បើធ្វើបាប ក៏បាបឥតតាមទៅផ្ដន្ទាដល់ជាតិណាទៀតដែរ ។ យោបល់យ៉ាងនេះពេញជាខុសខ្លាំងណាស់! មានទោសច្រើនជាទីបំផុត! សមដូចព្រះពុទ្ធដីកាព្រះសម្មាសម្ពុទ្ធដែលឃើញប្រាកដក្នុងគម្ពីរអង្គុត្តរនិកាយឯកនិបាត ថា ម្នាលភិក្ខុទាំងឡាយ, តថាគតស្រាវជ្រាវរកអំពើដែលមានទោសច្រើនដូចមិច្ឆាទិដ្ឋិ មិនឃើញមានសោះ, មានតែមិច្ឆាទិដ្ឋិនេះឯង ដែលមានទោសច្រើនជាងគេបំផុត ។ អម្បាលអនន្តរិយកម្មគឺការសម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្ត បំបែកសង្ឃ និងធ្វើលោហិតព្រះពុទ្ធឲ្យពុះពង់ឡើង ទាំង ៥ ប្រការនេះ ជាអំពើមានទោសច្រើនដល់ម្ល៉េះម្ដេចក៏ពុំទាន់ស្មើនឹងទោសនៃមិច្ឆាទិដ្ឋិនៅឡើយ ។ ព្រោះហេតុអ្វី? ព្រោះតែអនន្តរិយកម្មមានទោសនាំឲ្យចុះនរកកំណត់ត្រឹមមួយកប្បប៉ុណ្ណោះ ឯមិច្ឆាទិដ្ឋិនោះបើជានិយតប្រកាន់ទៀងដូច្នោះហើយ មានទោសនាំឲ្យចុះនរកកំណត់ថាប៉ុន្មានកប្បពុំបានឡើយ ។ មិច្ឆាទិដ្ឋិនេះអាចធ្វើបុរសបុគ្គលអ្នកប្រកាន់ខ្ជាប់ ឲ្យវិនាស[illegible]យ៉ាងសេចក្ដីផ្ដន្ទារបស់មនុស្សនឹង

ទេពតាទាំងឡាយខ្លាំង[illegible]ប្រមាណណាស់, សមដូចព្រះពុទ្ធដីកា ព្រះសាស្តាជាម្ចាស់ត្រាស់សំដែងថា

ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ

មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។

ចោរហើយនិងចោរ ជាបុគ្គលមានចិត្តអាក្រក់ក្រៃលែងស្រាប់ ថែមទាំងមានស្អប់គំនុំគ្នាទៅវិញទៅមកទៀត ពុំនោះសោតទេ បុគ្គលមានពៀរ ហើយនិងបុគ្គលមានពៀរ ដែលធ្លាប់ចងពៀរនឹងគ្នាជាយូរអង្វែងមកហើយ បុគ្គលទាំងពីរពួកនេះ បានជួបប្រទះគ្នាហើយ រមែងធ្វើសេចក្តីវិនាសឲ្យកើតឡើងដល់គ្នានិងគ្នាយ៉ាងខ្លាំង គឺត្រូវចាក់គ្នាក៏ចាក់ កាប់គ្នាក៏កាប់ បាញ់គ្នាក៏បាញ់ ឬតែងធ្វើឲ្យអន្តរាយដោយឧបាយផ្សេងៗ គួរស្ញើមពុំខាន, ប៉ុន្តែនៅពុំទាន់ស្មើនឹងចិត្តដែលបុគ្គលដំកល់ខុសនៅឡើយទេ, គឺសេចក្តីយល់ខុសដែលហៅថាមិច្ឆាទិដ្ឋិនោះ អាចធ្វើបុគ្គលអ្នកយល់ខុសនោះឲ្យវិនាសខ្លាំងក្រៃលែងជាងនោះទៅទៀត ព្រោះថាបុគ្គលជាសត្រូវនឹងគ្នាទាំងពីរពួកនេះ ធ្វើសេចក្តីវិនាសឲ្យកើតឡើងត្រឹមតែមួយជាតិ ឬពីរជាតិប៉ុណ្ណោះ, ឯសេចក្តីយល់ខុស អាចធ្វើឲ្យវិនាសក្នុងបច្ចុប្បន្នជាតិនេះផង ឲ្យវិនាសទៅខាងអនាគតកំណត់ជាតិកំណើតថាប៉ុណ្ណោះប៉ុណ្ណោះពុំបានឯណោះទៀតផង គឺថាបើស្លាប់វិនាសពីជាតិនេះទៅ

ទៀនតែទៅកើតក្នុងនរក, សមនឹងពុទ្ធភាសិត ដែលទ្រង់សំដែងថា អធម្មោ និរយំ នេតិ ធម៌ខុសតែងនាំសត្វចុះនរក ។

ចប់ធម៌ខុសក្នុងផ្នែកទី ២ ។

ឯធម៌ត្រូវក្នុងផ្នែកទី ៣ ហៅថាបដិវេធធម៌ ធម៌គឺសេចក្ដីត្រាស់ដឹង របស់ព្រះអរិយបុគ្គលទាំងឡាយ ឬថាធម៌ដែលព្រះអរិយបុគ្គលទាំងឡាយ បានត្រាស់ដឹងផ្ទាល់ខ្លួន ដោយបានប្រតិបត្តិតាមបដិបត្តិធម៌គ្រប់គ្រាន់ ទាំង ៨ ថ្នាក់, គឺថាបុរសបុគ្គលដែលមាន សម្មាទិដ្ឋិ, សម្មាសង្កប្បោ, សម្មាវាចា, សម្មាកម្មន្តោ, សម្មាអាជីវោ, សម្មាវាយាមោ, សម្មាសតិ, សម្មាសមាធិ ហើយចំរើនវិបស្សនាបញ្ញាតទៅទៀត ក៏នឹងបានត្រាស់ដឹងជាក់ច្បាស់នូវបដិវេធធម៌ គឺមគ្គញាណ ៤ ផលញាណ ៤ ជាធម៌ល្អបំផុតថ្នាក់ ដែលហៅថាលោកុត្តរធម៌ដូច្នេះផងក៏បាន ព្រោះធម៌នេះមិនត្រឹមតែធ្វើសត្វឲ្យទៅកាន់សុគតិប៉ុណ្ណោះទេ អាចញ៉ាំងសត្វឲ្យឆ្លងផុតចាកលោកទៀតផង ។

ត្រង់ពាក្យថាលោកៗ នេះ បានសេចក្ដីថាប្រទេសដែលប្រកបដោយសេចក្ដីវិនាស ឬថាប្រទេសដែលត្រូវតែលិចអណ្ដែត លិចអណ្ដែត ចែកចេញជាបីកន្លែងគឺ **កាមលោក** បានដល់ឋាននរក ប្រេត អសុរកាយ តិរច្ឆាន មនុស្សនឹងកាមាវចរសួគ៌ ៦ ជាន់ ១ **រូបលោក** បានដល់ឋានរូបព្រហ្ម ១៦ ជាន់ ១, **អរូបលោក** បានដល់ឋានអរូបព្រហ្ម ៤ ជាន់ ១ ។ ប្រទេសទាំងបីអន្លើនេះ ប្រកបដោយសេចក្ដីវិនាសកល់ទិពកត្រីដូចបណ្ដា

ផនប្រុសស្រីជាមនុស្សជាតិ ដែលកើតមកក្នុងលោកគឺបានមនុស្សនេះ សុទ្ធតែត្រូវរ៉ាប់រងសេចក្ដីវិនាសជាច្រើនប្រការគ្រប់គ្នា គឺអ្នកខ្លះកំពុងតែទៅជាសុខ ស្រាប់តែវិនាសបាត់ញាតិ, អ្នកខ្លះកំពុងរីករាយដោយពួកញាតិស្រាប់តែវិនាសបាត់ទ្រព្យសម្បត្តិ អ្នកខ្លះទើបតែនឹងសន្សំទ្រព្យសម្បត្តិបានបន្តិចបន្តួចស្រាប់តែវិនាសបាត់សេចក្ដីសុខ គឺត្រូវរងគ្រោះដោយជម្ងឺឈឺចាប់ ដោយគេចាក់គេកាប់ ដោយគេបណ្ដេញបំបរ ដោយគេសង្កត់សង្កិន ឲ្យបាក់បបខ្ចបខ្ចាចនៅក្រោមអំណាចគេក៏សឹងមាន ៗ កាលបើយ៉ាងដូច្នេះ តើសេចក្ដីសុខមាននៅត្រង់ណា ? សេចក្ដីវិនាសបុដំណើរលិចអណ្ដែតយ៉ាងនេះ រមែងមានជាធម្មតា ក្នុងកន្លែងដែលសត្វកើត ហេតុដូច្នោះ បានជាកន្លែងនោះឈ្មោះថាលោក ៗ ដូច្នេះ ៗ សេចក្ដីត្រាស់ដឹង ដែលហៅថាបដិវេធធម៌របស់ក្រុមអ្នកប្រាជ្ញ អាចស្ទួយខ្លួនឲ្យឆ្លងផុតចាកលោកទាំងបីនេះទៅប្រតិស្ឋានក្នុងព្រះនិព្វានដែលឥតមានសេចក្ដីវិនាសបាន បានជាហៅថា លោកុត្តរធម៌ដូច្នេះផង ៗ បដិវេធធម៌នេះ ជាធម៌ត្រូវធម៌ល្អបណ្ដាចបណ្ដូលកំពូលធម៌ទាំងអស់ ។

ចប់ធម៌ត្រូវក្នុងផ្នែកទី ៣ ។

ចំណែកខាងធម៌ខុសក្នុងផ្នែកទីបី ហៅថាបដិវេធអធម៌ បានដល់សេចក្ដីត្រាស់ដឹងខុស ចេះខុស គឺសេចក្ដីត្រាស់ដឹងខាងការប្រកបខ្លួនក្នុងលោក ធ្វើខ្លួនឯងនិងជនទាំងពួងឲ្យរងគ្រោះរងវិនាស, ធម៌ខុស

ថ្នាក់នេះ ក៏កើតតគ្នាអំពីបដិបត្តិអធម្មិកធម៌ថ្នាក់ទីពីរនោះមកដែរ គឺបុរសបុគ្គលរូបណាដែលមានមិច្ឆាទិដ្ឋិសេចក្តីយល់ខុសហើយ ប្រាកដជាមានកំហុសតៗគ្នា រហូតដល់មិច្ឆាសមាធិ ការផ្តោតចិត្តស៊ប់នៅក្នុងអារម្មណ៍ណាមួយខុសទៀត, បើមានការតាំងចិត្តខុសស៊ប់ហើយ មុខជានឹងកើតបដិវេធអធម្ម គឺសេចក្តីត្រាស់ដឹងខុស ដែលជាគ្រឿងធ្វើនូវទាំងសត្វទាំងពួងមិនឲ្យរួចពីលោកទាំងបីបានជាប្រាកដ ។ ម្យ៉ាងទៀតថា មនុស្សដែលមានបដិវេធអធម្មនេះ តែងបង្កសេចក្តីវិនាសដែលមិនទាន់កើតឲ្យកើតឡើង តែងបង្កើតសេចក្តីវិនាសដែលកើតមានស្រាប់ហើយឲ្យរឹងរឹតតែវិនាសតទៅទៀត, បុគ្គលនោះស្លាប់ទៅ ទៀងតែទៅកើតក្នុងនរកទៀត ។

ចប់ធម៌ខុសក្នុងផ្នែកទី ៣ ។

ធម្មាធម្មកថា សង្ខេបេន សមត្តា ការសំដែងអំពីធម៌ត្រូវធម៌ខុសសន្មតថាចប់ដោយសង្ខេបប៉ុណ្ណោះ ។

សូមសិរីសួស្តីកើតមានដល់ក្រុមសប្បុរសអ្នកស្តាប់ អ្នកប្រតិបត្តិតាមទាំងអស់គ្នា សព្វកាលរហូតជាដរាបទៅ ។

ស៊ុមង៍ ៚

វិទ្យុជាតិខេមរភាសា ភាគទី ១៧

## ព្រះមហាសោម-ឡុប ក្រុមជំនុំព្រះត្រៃបិដក

សំដែងនៅថ្ងៃសៅរ៍ ១៥ កើតខែវិសាខ ឆ្នាំខាលចត្វាស័ក ពុទ្ធសករាជ ២៤៨៥

(២៣ ឧសភា ១៩៤២)

## វិបត្តិកថា

១

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

លំដាប់អំពីនមស្ការមក សូមស្រង់លើកយកវិបត្តិ ៦ ប្រការ ដែលព្រះបរមសាស្ដាទ្រង់សំដែងទុក ដើម្បីនឹងផ្សាយចែកជូនដល់អស់លោកអ្នកសប្បុរសទាំងឡាយ បានជ្រាប ។

ក៏ពាក្យដែលហៅថា វិបត្តិ នេះ ប្រែថាវិនាសទៅ ថាប្រែប្រួលទៅមិនបានតាំងទីនៅដូចធម្មតា គឺថារបស់ណាធ្លាប់មាន ត្រឡប់ទៅជាគ្មាន ធ្លាប់សុខត្រឡប់ទៅជាទុក្ខ ធ្លាប់ធំត្រឡប់ទៅជាតូច ធ្លាប់ខ្ពស់ត្រឡប់ទៅជាទាប ប៉ុណ្ណោះជាដើមហៅថាវិបត្តិ ។

ឯវិបត្តិទាំង ៦ ប្រការនោះគឺ គតិវិបត្តិ វិបត្តិគតិ ១ កាលវិបត្តិ វិបត្តិពេលវេលា ១ ទេសវិបត្តិ វិបត្តិស្រុកទេស ១ កុលវិបត្តិ វិបត្តិត្រកូល ១ ឧបធិវិបត្តិ វិបត្តិរាងកាយ ១ ទិដ្ឋិវិបត្តិ វិបត្តិទិដ្ឋិ ១ ។

ត្រង់គតិវិបត្តិទី ១ សេចក្ដីអធិប្បាយថា បុរសបុគ្គលក្នុងលោកនេះ ក្រមមានគតិគឺដំណើរដែលនឹងធ្វើមរណកាលទៅវិញឲ្យបានទីស្ថានសុខ

ស្រួលពេកណាស់ ព្រោះវិបត្តិប្រែប្រួលអត្តភាពពីកាយក្លាយទៅកើតក្នុងអបាយភូមិ ៤ គឺនរក ប្រេត អសុរកាយ តិរច្ឆាន គ្រប់ជាតិនានា ។

ចំណែកខាងនរក ប្រេត អសុរកាយ ទាំង ៣ អស់លោក-អ្នកទាំង-ឡាយគ្រាន់តែបានឮតៗមក មិនដែលបានឃើញជាក់ច្បាស់ដោយនេត្រា ម្ល៉ោះហើយជនខ្លះក៏មានវិចិកិច្ឆា សន្ទិះសង្ស័យក្នុងចិត្ត ព្រោះគិតមិនស្រ-ឡះ មានជនពួកខ្លះក៏លែងជឿដោយដាច់ខាត ដោយជវនចិត្តចុះស៊ប់ក្នុងសេចក្តីប្រមាទជាដើមហេតុ បានជាប្រកាន់ថាគ្មាន នរក ប្រេត អសុរ-កាយ នេះព្រោះចំហាយមោហ មកបិទបាំងបញ្ញា បើនឹងពោលដោយពិតតាមគម្ពីរបើកព្រះពុទ្ធសាសនា ព្រះពុទ្ធដីកាទ្រង់សំដែងថា ប្រាកដជាមានលុះតែជនណា មានញាណដូចព្រះអរហន្តមិនភាន់ច្រឡំទើបអាចឃើញពួកអទិស្សមានកាយទាំងនោះបាន ឯសត្វដែលទៅកើតក្នុងអបាយទាំងប៉ុន្មាន ក៏ឥតបានសប្បាយបន្តិចបន្តួចសោះ មានតែសេចក្តីទុក្ខមកគ្របសង្កត់សព្វពេលវេលា មិនឈ្នះនឹងពណ៌នាឲ្យពិស្តារបាន ។

វេលានេះ សូមលើកយកតែពួកតិរច្ឆានមកសំដែង ព្រោះសត្វទាំងនោះឯង អស់លោក-អ្នកធ្លាប់បានឃើញច្បាស់ដោយចក្ខុគ្រប់គ្នា ឯសត្វតិរច្ឆានទាំងនោះគឺ ឆ្កែ, ឆ្មា, មាន់, ទា, ជ្រូក, គោ, ក្របី, ដំរី, សេះ, ប៉ុណ្ណេះជាដើម ជាសត្វថោកទាបបំផុត មិនស្គាល់ខុសត្រូវគុណទោស បុណ្យបាបកុំឡើយ ហើយទាំងមិនមានចេតនាជ្រះថ្លាក្នុងព្រះពុទ្ធព្រះធម៌ ព្រះ

សិក្សា នឹងមានសីលការនោ ទាំងចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ក៏ឥតបានចេះ ដឹងបន្តិចបន្តួច ចំណែកខាងឯនាមឈ្មោះក៏បាត់ពិរោះពិសា សព្វថ្ងៃនេះ មនុស្សលោកច្រើនហៅមី ហៅអា ដេរប្រទេចផ្តាសាតាមទំនើងចិត្តឥតមានខ្មាច នេះដោយអំណាចអំពើទុច្ចរិត ដែលខ្លួនប្រព្រឹត្តធ្វើពីឥឡូវបុព្វជាតិមុនមកទាំងប៉ុន្មាន ទើបផលកម្មនោះដឹកនាំឲ្យកើតជាតិរច្ឆាន កម្រនឹងបានប្រមកកើតជាមនុស្សវិញឡើយ នេះឯងហើយហៅថាគតិវិបត្តិ ។

ត្រង់កាលវិបត្តិទី២សេចក្តីអធិប្បាយថា កាលវិបត្តិពេលវេលា ពេលវេលាណា មានព្រះពុទ្ធត្រាស់ក្នុងលោក សំដែងធម៌ទេសនាប្រោសពួកពុទ្ធបរិស័ទនានា ជនទាំងនោះក៏កើតសទ្ធាជ្រះថ្លាបានសម្រេចមគ្គផលពុំអាចនឹងពណ៌នាបាន ចំណែកពួកជនដែលឥតភ័ព្វ ឥតសំណាងទាំងប៉ុន្មាន ក៏អាក់ខានមិនបានកើតទាន់ពេលវេលា ដែលព្រះពុទ្ធត្រាស់នោះឡើយ ត្រឡប់ទៅកើតក្នុងអបាយភូមិ ឬក៏កើតក្នុងសុញ្ញកាលទៅវិញ គឺកាលដ៏សូន្យ គ្មានព្រះពុទ្ធ បច្ចេកពុទ្ធ ស្តេចចក្រ ពួកមនុស្សក្នុងពេលនោះ លោកហៅថាកាលវិបត្តិ ។ ពុំនោះសោតទេ ដូចកាលពីដើមមុន ៤០ ឆ្នាំមកក្នុងកម្ពុជរដ្ឋយើងនេះ មិនសូវមានលោកអ្នកប្រាជ្ញណាចេះដឹងខាងផ្លូវព្រះពុទ្ធសាសនានឹងពន្យល់ធម៌អាថ៌សិក្ខាវិន័យ ទាំងចំណេះវិជ្ជាទំនើបថ្មីក៏ពុំសូវមាន ម្ល៉ោះហើយមនុស្សក្នុងពេលនោះ ច្រើនខ្សត់ខ្សោយចំណេះវិជ្ជា បើនឹងពាក់តាមពេលវេលា ក៏ហៅថាវិបត្តិមួយដែរ តែឥឡូវពជការ

បានទាំទុកបំរុងរៀបចំគ្រប់នាទីដំណែងឲ្យបានរៀបរយ មិនឲ្យមានឃ្លៀងឃ្លាត ពួកខេមរជាតិក៏កាន់តែបានចេះដឹងច្រើនគ្នា ជនអ្នកមានភ័ព្វមានសំណាង កើតមកច្រើនបានជួបប្រទះនឹងពេលវេលាល្អ ជនណាដែលគ្មានភ័ព្វគ្មានសំណាងទេ ជននោះច្រើនកើតមកជួបប្រទះនឹងពេលវេលាមិនល្អ ដូចបានថ្លែងរៀបរាប់មកពីខាងដើមមិនសូវបានសេចក្ដីសុខសេចក្ដីចំរើនឡើយ នេះហើយហៅថាកាលវិបត្តិ ។

ត្រង់ទេសវិបត្តិទី ៣ នោះ សេចក្ដីអធិប្បាយថា ស្រុកទេសណាដែលសូន្យចាកព្រះពុទ្ធសាសនា គឺគ្មានធម៌អាថ៌ិសិក្ខាវិន័យ ទាំងគ្មានច្បាប់សម្រាប់ផែនដី ដើម្បីនឹងបំភ្លឺជនទាំងពួងឲ្យបានចេះដឹងសេចក្ដីខុសត្រូវ ស្រុកទេសនោះៗហៅថាទេសវិបត្តិ ។

ពុំនោះសោតទេ ស្រុកទេសនោះៗមានព្រះពុទ្ធសាសនា បរិបូណ៌ត្រឹមត្រូវជាផ្លូវល្អមឲ្យអ្នកផងប្រតិបត្តិមិនឲ្យលំអៀងឃ្លៀងឃ្លាតទាំងច្បាប់សម្រាប់គ្រប់ប្រទេសជាតិ ក៏មានគ្រប់គ្រាន់ទាំងអស់ ប៉ុន្តែមកមានទំនាស់ដោយសេចក្ដីអន្តរាយគឺកើតចំបាំងពាំងផល់ឬកើតទុរ្ភិក្សអត់បាយ ប្រជា-ជនទាំងឡាយធ្វើស្រែចំការក៏ពុំសូវបានផលបរិបូណ៌ ចំណែកខាងពួកអ្នកធ្វើជំនួញដូញលក់ដូរក៏ច្រើនតែខាតមិនចំណេញ បើទុកណាជាទំរកធនធានបានតិចច្រើន ក៏លំបាកព្រួយចិត្តនឹងថែទាំរក្សាគ្រប់ពេលវេលា ជួនកាលពួកចោរវាន់នាំគ្នាមកលួច ប្លន់ ឆក់ ប្រវ័ញ្ចដណ្ដើមយកឥតមាន

កំណត់ វិបត្តិទី៣និយាយឲ្យឃើញដាក់ច្បាស់ប្រាកដដូចកម្ពុជរដ្ឋប្រទេសយើងនេះពីដើមមក អ្នកក្រុង អ្នកចំការ អ្នកស្រែ ច្រើនត្អូញត្អែរពីរឿងចោរលួច ចោរប្លន់ ពួករាស្ត្រទាំងប្រុសស្រីក៏កើតទុក្ខព្រួយចិត្តគ្រប់ពេលវេលា ដោយសារឥតការជួយការពារ ទើបរាស្ត្ររាល់គ្នាបានសេចក្តីសុខស្រួល ។

ពុំនោះសោត ស្រុកទេសនោះៗ ពីដើមធ្លាប់បានសេចក្តីសុខសប្បាយថ្កុំថ្កើងរុងរឿងហឹកហាក់ លុះដល់គ្រាក្រោយមកទទួលគ្រោះថ្នាក់ដោយសត្រូវមកបៀតបៀនធ្វើឲ្យវិនាសអន្តរាយ ដរាបទាល់តែក្លាយទៅជាស្រុកដុនដាបរងទុក្ខវេទនាក្រៃលែង ជនដែលកើតមកជួបប្រទះនឹងសម័យស្រុកទេសបែបនោះឯង ក៏រមែងបានសេចក្តីលំបាកវេទនាកម្រនឹងបានស្រាកស្រាន្តឡើយ នោះឯងហើយហៅថាទេសវិបត្តិ ។

ត្រង់កុលវិបត្តិទី ៤ សេចក្តីអធិប្បាយថា វិបត្តិត្រកូលក្នុងគ្រាពុទ្ធ-សម័យលោកចែកត្រកូលទាំងនោះទៅជា ៤ យ៉ាងគឺខត្តិយកុល ត្រកូលក្សត្រិយ៍ ១ ព្រាហ្មណកុល ត្រកូលព្រាហ្មណ៍ ១ វេស្សកុល ត្រកូលអ្នកធ្វើស្រែចំការនឹងការលក់ដូរ ១ សុទ្ទកុល ត្រកូលស៊ីឈ្នួល ១ ។

បណ្តាត្រកូលទាំង៤នោះ ត្រកូលក្សត្រិយ៍ នឹងត្រកូលព្រាហ្មណ៍ចាត់ថាជាត្រកូលខ្ពង់ខ្ពស់ប្រសើរ ឯជាតិព្រាហ្មណ៍នោះមិនសូវជឿព្រះពុទ្ធសាសនាទេ ច្រើនជឿតែលទ្ធិក្រៅព្រះពុទ្ធសាសនា ដូចសាសនា

ព្រហ្មជាដើម ព្រាហ្មណ៍ចូលចិត្តជាបំផុតដោយយល់ថាព្រហ្មសាបបង្កើតដី ទឹក ភ្លើង ខ្យល់ ឲ្យសព្វសត្វអាស្រ័យនៅបាន ហើយទាំងបានប្រកាន់ថា ជាតិព្រាហ្មណ៍ទាំងប៉ុន្មានសុទ្ធតែកើតមកពីព្រះឧស្ឋព្រហ្ម ជាតិក្សត្រិយ៍ កើតមកពីទ្រូងព្រហ្ម ជាតិវៃស្យអ្នកស្រែចំការកើតមកពីស្នងជើងព្រហ្ម ជាតិសុទ្រអ្នកស៊ីឈ្នួលកើតមកពីខ្នងជើងព្រហ្ម ជាតិសមណៈអ្នកបួសកើតមកពីបាទជើងព្រហ្ម ព្រោះហេតុនោះ បានជាពួកព្រាហ្មណ៍ច្រើនគោរពរាប់អានព្រហ្មដូចព្រះ ។

ចំណែកខាងត្រកូលដែលថោកទាបជាងគេបំផុតនោះគឺ ត្រកូលសុទ្រអ្នកស៊ីឈ្នួល បង្គ្រោះយកទាំងត្រកូលចណ្ឌាល ត្រកូលបុក្កុសៈអ្នកបោសសម្រាមប៉ុណ្ណោះជាដើម ចាត់ជាថោកទាបដូចគ្នា ថោកទាបទាំងបុគ្គលមារយាទទាំងដេកដើរឈរអង្គុយនិយាយស្ដីគ្រប់យ៉ាង ហើយច្រើនខ្សត់ខ្សោយទ្រព្យសម្បត្តិមិនសូវបានបរិបូណ៌គ្រប់គ្រាន់ ទាំងមិនសូវមានគេរាប់អានជាមុខជាមាត់ឡើយ នេះហើយហៅថា កុលវិបត្តិ ។

ត្រង់ឧបធិវិបត្តិទី ៥ សេចក្ដីអធិប្បាយថា ជនចំពួកខ្លះក្នុងលោកនេះ មានរូបកាយមិនបរិបូណ៌ ច្រើនតែវិបត្តិខ្វះខាតអាយតនឥន្ទ្រិយ មិនពេញជាប្រុសជាស្រីកើតកែលកោរៈផ្សេងៗ ខ្លះទៅជាមនុស្សខ្ទើយ មនុស្សគេចពារ មនុស្សគ ថ្លង់ ខ្វាក់ ខ្វិន ក្លែងក្លង់ កំពឹកកំពក ក្រញូក្រពិត សាក្រក់លាមកដូចតាដួក ខ្លះកើតឃ្លង់ ស្រែង ហឹតរបេង កំបុតជើង

កំបុតដៃ កំបុតស្ទឹកត្រចៀក កំបុតច្រមុះ ប៉ុណ្ណោះជាដើម មនុស្សបែបនេះលោកហៅថា បរិសទូសកៈ មនុស្សទ្រុស្តបរិស័ទ គឺគ្មានបរិស័ទណាចូលចិត្តស្រឡាញ់រាប់អានឡើយ នេះហើយហៅថា ឧបធិវិបត្តិ ។

ត្រង់ទិដ្ឋិវិបត្តិទី ៦ សេចក្តីអធិប្បាយថា ជនបំពួកខ្លះក្នុងលោកនេះច្រើនប្រើគំនិតជ្រុលខុសផ្លូវមិនត្រូវតាមទំនងព្រះពុទ្ធដីកាបានជាគឹង ៗ ពេក ធូរៗ ពេក ធ្ងន់ៗ ពេក ស្តាំៗ ពេក ឥតបានត្រូវលើផ្លូវល្អត្រង់ណា ទិដ្ឋិនេះបើចាត់ចែកតាមបទមាតិកាលោកប្រាប់ថាមានអង្គ ៨ គឺ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្បោ ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តោ ១ មិច្ឆាអាជីវោ ១ មិច្ឆាវាយាមោ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។

សេចក្តីថា កាលបើគំនិតយល់ខុសហើយ ត្រិះរិះក៏ខុស កាលបើត្រិះរិះខុសហើយ និយាយក៏ខុស កាលបើនិយាយខុសហើយ ធ្វើអំពើអ្វីក៏ខុស កាលបើធ្វើអំពើអ្វីខុសហើយ ចិញ្ចឹមជីវិតក៏ខុស កាលបើចិញ្ចឹមជីវិតខុសហើយ ព្យាយាមក៏ខុស កាលបើព្យាយាមខុសហើយ សតិក៏ខុស កាលបើសតិខុសហើយ សមាធិ ការដំកល់ចិត្តឲ្យនឹងនៅក្នុងអារម្មណ៍នោះៗ ក៏ខុសទៀត សេចក្តីដូចបានរៀបរាប់មកប៉ុណ្ណោះជាដើម ហៅថាទិដ្ឋិវិបត្តិ ។

សំដែងមកអំពីរឿងវិបត្តិទាំង ៦ ប្រការ ក៏សន្មតិថាចប់ដោយសង្ខេប, សូមឲ្យព្រះពុទ្ធសាសនាទ័ងពុទ្ធបរិសទ្យអ្នកស្តាប់ធម៌បានសេចក្តីចំរើនសព្វៗ កាលរៀងទៅ ឯវំ សមគួរតាមវេលាប៉ុណ្ណោះឯង ។

## អំពីដំណើរជីវិតនៃពពួកសត្វល្អិតៗ

### តាមសេចក្ដីពិនិត្យរបស់អ្នកប្រាជ្ញធំជាតិបារាំងសែសម្នាក់

លោកអ្នកប្រាជ្ញនេះឈ្មោះ សង់-ហង់រី-ហ្វាប្រ៍(*Jean Henri Fabre*) កើតក្នុងឆ្នាំ ១៨២៣ អនិច្ចកម្មក្នុងឆ្នាំ ១៩១៥ ។ លោកជាអ្នកប្រាជ្ញធំមួយ ដែលបានទុកជីវិតរបស់លោក ក្នុងការពិនិត្យពីដំណើរជីវិតនៃសត្វល្អិតៗ ។ នៅឱកាសធ្វើបុណ្យអាយុរបស់លោកគំរប់ ១០០ ឆ្នាំ គេបានចាត់បោះពុម្ពអស់ទាំងរឿងរ៉ាវ ដែលជាសេចក្ដីពិនិត្យរបស់លោក ហើយមានសម្លាញ់របស់លោកម្នាក់ បានតែងប្រវត្តិដ៏ថ្លៃថ្លាប្រសើរនេះ ដែលធ្វើការងារដោយមិនប្រាថ្នាមាសប្រាក់ទេ តែជាប្រយោជន៍ដល់វិទ្យាសាស្ត្រទាំងមូល ។ កាលលោកនៅជាកុមារនោះ លោកតោងធ្វើការជាកម្មករសម្រាប់ចិញ្ចឹមជីវិត ហើយគិតតែខាងសប្បាយរីករាយជាច្រើន ប៉ុន្តែនៅឱកាសទំនេរ លោកបានពិនិត្យពិចារណាមើលពពួកសត្វល្អិតៗ ដែលមាននៅក្បែរខាងលោក ។ លុះលោកសិក្សាពិនិត្យសព្វគ្រប់ហើយ ទើបប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ សម្រេចហើយទើបបានធ្វើជាគ្រូបង្រៀនក្នុងឆ្នាំ ១៨៤២ ឬក្នុងពុទ្ធសករាជ ២៣៨៥ ដោយបានទទួលបៀវត្សក្នុង ១ ឆ្នាំ ៧០ រៀល ឥតមានបៀវត្សរ៉ឺត្រែតផង ។ សេចក្ដីស្រឡាញ់ការពិនិត្យនេះហើយ ដែលនាំឲ្យលោកខិតខំព្យាយាមស្វែងរកចំណេះចេះដឹង ដោយមិនកង្វល់ដល់របរចិញ្ចឹមជីវិតរបស់ខ្លួនប៉ុន្មានឡើយ

ដូចលោកបានសរសេរសំបុត្រមួយដល់បងលោកថា "វិទ្យាសាស្ត្ររមែងមានសព្វគ្រប់ទាំងអស់" លុះលោកប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាពីរថ្នាក់ រួចទើបប្រឡងយកសញ្ញាប័ត្រឧត្តមសិក្សាផ្នែកវិជ្ជាលេខ និងវិទ្យាសាស្ត្រហ្វីស៊ិក ។ តមកលោកមានគ្រួសារ ការចិញ្ចឹមជីវិតក៏លំបាកពន់ពេក (ដោយមិនបានផលប្រយោជន៍គ្រប់គ្រាន់) ។ គេបានបាត់បញ្ជូនលោកទៅនៅកោះកក្ស នៅខាងត្បូងមហានគរបារាំងសែស ដើម្បីបង្រៀនវិជ្ជាហ្វីស៊ិកនៅវិទ្យាល័យ ក្នុងទីក្រុងអាស័កស្យូ ។ លោកនៅទីនោះ ក្រៅពីការបង្រៀនលោកបានពិនិត្យសិក្សា អំពីព្រឹក្សជាតិនៅកោះកក្ស លោកនៅក្នុងកោះនេះជាវេលា ៤ ឆ្នាំ ។ កាលលោកត្រឡប់មកមហានគរបារាំងសែសវិញ លោកប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ ផ្នែកវិទ្យាសាស្ត្រធម្មជាតិជាប់ថ្នាក់ខ្ពស់ ព្រមទាំងសេចក្តីសរសើរជាអនេកប្រការ ។ លោកនេះមិនបានឈប់បង្អង់ នៅត្រឹមកិត្តិយសទឹងសញ្ញាប័ត្រដែលលោកបានទទួល លោកនៅខំធ្វើការពិនិត្យសិក្សាតទៅទៀត ហើយលោកជាប់ចិត្តបែរទៅខំសិក្សា អំពីដំណើរជីវិតនៃសត្វល្អិតៗ ដែលមិនទាន់មានគេចេះដឹងច្រើននៅឡើយក្នុងសម័យនោះ ។

ដល់មកក្នុងឆ្នាំ ១៨៥៥ លោកមានអាយុគ្រប់ ៣២ ឆ្នាំ បានបោះពុម្ពផ្សាយរឿង ១ ក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ និយាយពីឱម៉ាល់ខ្នាតធំ រឿងនេះហើយដែលនាំឲ្យអ្នកប្រាជ្ញធំៗ ងាកមកយកចិត្តទុកដាក់ទឹង

លោក ៗ ទុកជាយ៉ាងណាក៏ដោយលោកនៅតែធ្វើគ្រូជួយ នៅវិទ្យាល័យអាវិញ៉ុងជាវេលា ២០ ឆ្នាំ ៗ នៅខណៈនោះ ការចិញ្ចឹមគ្រួសាររបស់លោកលំបាកច្រើន ទើបលោកត្រូវតែទៅធ្វើការបង្រៀនខាងក្រៅទៀតផង ការនេះពុំរាំងមិនឲ្យលោកសិក្សាវិទ្យាសាស្ត្ររបស់លោកតទៅទៀត ៗ លោកបានចូលទៅក្រុងប៉ារីសជាដំបូង ដើម្បីប្រឡងយកសញ្ញាបត្រដុកតូរ៉ាត់នៃវិទ្យាសាស្ត្រធម្មជាតិ ៗ ក្រោយដែលបានពិនិត្យយ៉ាងពិតប្រាកដហើយ ទើបគេកំណត់ឲ្យថ្នាក់យ៉ាងខ្ពស់មួយឲ្យលោកជាថ្នាក់ដែលអ្នកប្រាជ្ញត្រូវបាន ៗ តអំពីនោះមក ទើបលោកមានសិស្សគណៈពេញពេមគោរពបូជាលោក ៗ គេបានបំពាក់មេដៃឡេស៊ីយុង-ដូណេរ៍ឲ្យលោក ហើយគេនាំលោកចូលគាល់ព្រះចៅអធិរាជ ៗ ឯខ្លួនលោកនៅតែស្ម័គ្រចិត្តទៅនៅក្នុងចំណោមសត្វល្អិតៗ ហើយនៅទីបំផុតនៃជីវិតរបស់លោកៗ ដកខ្លួនថយទៅនៅស្រុកស្រែ ៗ

ឯសៀវភៅរបស់លោកជាដំបូងហៅថា ទីរលឹកនៃជីវិតនិងលទ្ធិទំនៀមនៃសត្វល្អិតៗ ជាសៀវភៅយ៉ាងសំខាន់ ១ ក្នុងប្រវត្តិការណ៍នៃវិទ្យាសាស្ត្ររបស់លោក ៗ ដើម្បីបង្ហាញឲ្យឃើញថ្វីដៃរបស់លោកអ្នកប្រាជ្ញធំនេះ យើងសូមស្រង់យកសេចក្ដីពិនិត្យខ្លះរបស់លោក ដែលនិយាយអំពីសត្វល្អិត ១ ចំពួកខ្លះមកពោលទុកក្នុងទីនេះ :

# អំពីពីងពាងក្អាម

ដែលគេហៅឈ្មោះដូច្នេះ ព្រោះដងខ្លួនវាមានទ្រង់ទ្រាយដូចដងខ្លួនរបស់ក្អាម វាដើរទៅទទឹង ៗ ខ្លួនដូចជាក្អាមដែរ ជើងមុខវាមានសណ្ឋានដូចក្អាម ហើយធំមួនជាងជើងក្រោយ ៗ វាតែងទៅសម្ងំចាំនៅកណ្ដាលចំណោមផ្កាឈើ ចាប់សត្វដែលជាអាហារចំណីរបស់វាជាតិសត្វល្អិត ៗ ដែលវាចូលចិត្តជាងគេគឺសត្វឃ្មុំ វាតែងចាប់ឃ្មុំមិនឲ្យឃ្មុំកំរើកកន្ទុយបាន ដ្បិតកន្ទុយឃ្មុំមានទ្រនិចអាចទិចវាឲ្យស្លាប់បាន លុះវាជញ្ជក់យកឈាមឃ្មុំអស់ហើយ ទើបវាទម្លាក់ខ្មោចឃ្មុំដែលស្លាប់ហើយចោលទៅ ៗ តាមធម្មតា ពីងពាងតែងមានពោះធំជានិច្ច ដែលមានសរសៃមងសម្រាប់ធ្វើសំបុករបស់វា ៗ ពីងពាងប្រភេទនេះ មិនចូលចិត្តអាកាសត្រជាក់ទេ ទើបគេឃើញមានសត្វបំពួកនេះនៅតែក្នុងប្រទេសបារាំងសែសខាងត្បូង ហើយវាចូលចិត្តទៅនៅតែកន្លែងណាដែលសម្បូរផ្កា ហើយពួកសត្វឃ្មុំតែងនាំគ្នាមកជញ្ជក់ជាតិផ្កា ៗ ឯស្បែករបស់ពីងពាងប្រភេទនេះមានព័ណ៌សម្បុរលឿង ជើងវាជាកង់មូល ៗ ព័ណ៌សុកុលាប ហើយលើទ្រនុងខ្នងមានក្រឡាជាក្បាច់ចាក់ក្រហមចាស់ ហើយនៅខាងៗដើមទ្រូងមានក្រឡាសំណាញ់ស្ដើងៗ មានព័ណ៌ខៀវដូចផ្លែទៀប ៗ

ក្នុងរដូវដែលសត្វពីងពាងនេះមានពង ក៏តែងរើសរកទីនៅលើផ្កា ជាទីទួលខ្ពស់ៗ មានស្លឹកឈើស្លាប់ខ្លះផង ឬស្វិតដោយកំដៅថ្ងៃ ទើបពីងពាងក្ដាមនេះឡើងៗ ចុះៗ ហើយមានសរសៃនៅនឹងពោះរបស់វា ធ្វើផ្ដោកមួយមានព័ណ៌សសាអែមៗ កាលវាមានពងឡើង ទើបមានជាគំរបមួយបិទមាត់ផ្ដោកយ៉ាងជិតស្និទ្ធ រួចវាទាញសរសៃមងពីរបីសរសៃពីខាងលើពង ធ្វើជាបន្ទប់ខ្នាតតូចសម្រាប់មេវា ដ្បិតនៅឱកាសមានពងនេះមានសេចក្ដីនឿយហត់ច្រើន ដោយហេតុវាយមង់ធ្វើសំបុកនឹងកន្លែងជ្រករបស់វា ហើយមេពីងពាងនេះ ក៏តែងរក្សាមិនឲ្យសត្វដទៃមកបៀតបៀនពងវាបានៗ លុះដល់ដាច់ខែមេ៉ កិច្ចពងក៏អស់ត្រឹមនេះ ដល់កិច្ចក្រាស់ពងគេទៅ ខណៈនោះ មេពីងពាងមិនចេញពីទីកន្លែងទេ ចាំងមិនបរិភោគអាហារសោះឡើយ ហើយខ្លួនមេវាជិតនឹងដាច់ខ្យល់ស្លាប់ផង លុះតែកាលណាកូនតូចៗនឹងចេញពីសំបុក ទើបមេវាបើកសំបុកឲ្យកូនតូចៗចេញមក ហើយនៅវេលា ៥ ដល់ ៦ អាទិត្យ មេវាបានរង់ចាំមិនកំរើកខ្លួន មិនថាមានអ្វីមកប៉ះពាល់ដល់ខ្លួនវា ហេតុដល់ខែស្ប៊ូយេត ទើបកូនតូចៗចេញ (ពីសំបុកពង) ហើយ ឡើងចុះទៅរកផ្កាឈើដោយកំដៅថ្ងៃ ទើបកូនតូចៗ នាំគ្នាធ្វើមងពីងពាង រាល់ៗដងតែងមានពីងពាង ៣-៤ ចេញទៅចងមងព្រមគ្នា ក៏តែងឡើងទៅទម្លាក់

ខ្លួនបន្ទាយសរសៃមឥទ្ធរទៅជាមួយ ហើយរត់ឆ្ពោះទៅពាសពេញ រត់ទៅចូលតាមគុម្ពស្មៅបាត់អស់ទៅក៏មាន ។

## អំពីសត្វវៃនឹងស្រមោច

ក្នុងខែស្ពយេត - វេលាថ្ងៃត្រង់ជាក់ - ជាវេលាស្ងុះស្ងាប់ លុះដល់រសៀល ទើបសត្វវៃនាំគ្នាស្រែកច្រៀងទ្រហឹងអឺងកងជានិច្ច នៅលើមែកនៃដើមឈើតូចៗ ដែលវាចោះស្រូបយកឈើឲ្យប៉ោងចេញទឹកជមប្លុង ទើបវាយកទ្រនិចជញ្ជក់ជ័រឬទឹកជមដែលហូរចេញមក ទឹកជមនេះហើយដែលនាំឲ្យសត្វល្អិតៗជាច្រើន ដែលស្រេកទឹកដែរនោះមកហោមពេមផឹក ក្នុងចំពួកសត្វអស់នេះ មានស្រមោចមកចូលផង ។ ស្រមោចវាខាំវៃតាមដើងឬតាមស្លាប វាឡើងទៅលើខ្នងហើយខាំទ្រនិចវៃ ឯវៃត្រូវស្រមោចបៀតបៀនខ្លាំង ក៏ខាតចេញពីកន្លែងនោះលេចនោមផង ។ លុះ ៥-៦ អាទិត្យ វៃក៏ធ្លាក់ចុះពីចុងឈើខស់មកស្លាប់ទៅ ហើយថ្ងៃក៏ក្តៅខ្លោចវៃឲ្យស្ងួតទៅ ស្រមោចក៏មកខាំកាត់ជាចំរៀកល្អិតៗ ហើយដឹកនាំទៅទុកធ្វើជាស្បៀងអាហាររបស់វាតទៅថ្ងៃក្រោយ ។

## អំពីសិទ្ធេឡងវៃឃិ

ដើមទ្រូងសត្វវៃភាគក្រោយមានជើងមុខក្រោយ នៅចំណែកខាងក្រោយមានអវយវៈមួយ មានសណ្ឋានជាកង់កាត់មួយកំណាត់ ខាង

ឆ្វេងពាក់កងលើកណ្តាត់ខាងស្តាំបន្តិច ៗ កាលណាបង្ហើបអវយវៈនេះឡើង ទើបគេសង្កេតឃើញរណ្តៅខ្វងមួយទល់នឹងភាគខាងមុខ ដែលមានអវយវៈស្តើងទន់មានពណ៌លឿងចាស់ ហើយនៅខាងក្រោយរណ្តៅនេះមានស្បែកស្តើងដែរ ហើយមានពណ៌ក្រហមមានសណ្ឋានដូចជាពពុះទឹកត្រូវពន្លឺថ្ងៃ ។ អវយវៈអស់នេះហើយ ដែលបង្កើតឲ្យមានសូរសម្លេងឡើង ។ ត្រង់កន្លែងពោះនឹងខ្នងជាប់គ្នានោះមានទន្ទួលមួយ ហើយមានជាផ្លូវចូលទៅក្នុងរណ្តៅខ្វងមួយទៀត កន្លែងនេះហើយដែលជាគ្រឿងបង្កើតឲ្យមានសូរសំឡេងឡើង ត្រង់នេះជាអវយវៈមួយជ្រីវៗពណ៌ស កោងខុលចេញក្រៅក្អិកក្អក់ នៅខាងចុងសរសៃប្រសាទធ្វើឲ្យញ័ររញ្ជួយតប៉ុតប៉ោងបាន នេះហើយដែលធ្វើឲ្យកើតសូរសំឡេងកងរំពង ហើយធ្វើឲ្យកង់ទាំងពីរញ័រផង ៗ

ប្រសិនបើអាកាសស្ងប់ហើយក្តៅផង សូរសំឡេងរៃយំមានឃ្លាមានល្បះល្អស្តាប់ ក្នុង ១០ វិនាទីយំឡើងម្តងហើយឈប់ម្តងហើយយំសានឡើងដល់ទៅចុងបង្ហើយកាន់តែស្រែកខ្លាំងឡើង ៗ ហើយកាន់តែញាប់ណាស់ផង ហើយតមក ១០ នាទីទើបបន្ធូរស្បូវស្រែកឲ្យតិច ៗ ទាល់តែពោះរលែងបើកបិទតទៅទៀតទើបសម្រាក ៗ រួចតមកសត្វរៃក៏ចាប់ផ្តើមស្រែកសានឡើងវិញ ដល់ទៅវេលាល្ងាចយប់ស្ងប់ស្ងាត់ សូរស្រែកយំនៃសត្វរៃតែងតែមានជានិច្ចដែរ តែសំឡេងយំតឹងៗ ធូរៗ ខ្លីៗ វែងៗ ៗ ប៉ុន្តែប្រសិនបើ

មេឃទួទឹមបើខ្យល់ត្រជាក់បក់មកខ្លាំង សត្វវាមិនដែលយំទេ ។ ចុះហេតុអ្វីទើបសត្វវាយំដូច្នេះ អ្នកប្រាជ្ញដែលរកហេតុផលតាំងពីដើមរហូតមកដល់ឥឡូវនេះ ក៏ពុំទាន់មានអ្នកប្រាជ្ញណាមួយអធិប្បាយឲ្យជាក់ច្បាស់បានឡើយ ។

## អំពីសេចក្ដីមេត្រីនៃសត្វកណ្ដូបសេះ

តាមធម្មតា សត្វកណ្ដូបសេះជាសត្វស្លូត តែងមានមេត្រីចិត្តនឹងសត្វដទៃ គេមិនដែលឃើញកណ្ដូបសេះ សំដែងអាការសាហាវដូចជាសត្វពីងពាងដែលកាចៗ នុះទេ ។ កណ្ដូបសេះគ្រប់ៗគូ តែងចាប់ស៊ីរបស់ដែលនៅជិតៗខ្លួន ឥតចេញទៅរុករកកោសរូសញាតិមិត្រជិតខាងឡើយ ប៉ុន្តែកាលណាមេវាមានពងនៅក្នុងពោះហើយមានផ្ទៃពោះចាស់ផង ។ ខណៈដែលមេកណ្ដូបសេះជិតចេញពងតាមផ្លូវរបស់វា នេះហើយដែលកណ្ដូបសេះគ្រប់ៗគូទៅជាសត្វកាច វាតែងបង្ហិលក្បាលងាកឆ្វេងងាកស្ដាំ វាតែងតទល់នឹងសត្វជិតខាង វាយារជើងផ្ទាត់ទៅខាងៗ ឲ្យប៉ះដងខ្លួនរបស់សត្វជាសត្រូវ រួចវាលាជើង ១ លើកឡើងឆាកប្រែ ទៅគូសត្រូវវាជាច្រើនជើង ខាងសត្រូវវាក៏តបតទល់វាមកវិញដូចគ្នាដែរ ដល់ត្រូវរបួសជាដំបូងទើបវាដកខ្លួនថយចេញទៅ ។ មានចួនកាលការតទល់គ្នានេះមានដល់ស្លាប់ក៏មាន ហើយកណ្ដូបដែលឈ្នះក៏ផ្ដើមស៊ីកន្ទុយជាមុន ។ កណ្ដូបសេះញី ក្រោយដែលបានរួមសេពមេថុននឹងកណ្ដូបសេះឈ្មោលរួចហើយ

នៅថ្ងៃនោះឬថ្ងៃស្អែកឡើង មេញីក៏ចាប់គូឈ្មោលហើយពោះកន្ទុយ
ហើយក៏ស៊ីគូឈ្មោលទាំងមូល លើកលែងតែស្លាបចេញ មេកណ្ដូបញី
តែងធ្វើដូច្នេះទឹងគូឈ្មោលឯទៀត ៗ ដែលវាបានរួមមេថុនកិច្ចជាមួយផង
វាច្រើនធ្វើដូច្នេះនៅឱកាសថ្ងៃក្ដៅខ្លាំង ៗ

## អំពីសត្វដង្កូវនៅនឹងដើមឈើតូចៗ

មេអំបៅសតែងមានក្រឡាមូល ៗ នៅនឹងពោះវាពណ៌ក្រមៅថ្លា
ហើយវាពងកើតជាដង្កូវម្យ៉ាងបំផ្លាញដើមឈើដែលវាទំនៅ ៗ រដូវមាន
ពងនៅក្នុងខែសេបតម្ប្រ៍ ឯស្លឹកដែលវាពងដាក់នោះមានពណ៌ខ្មៅ មុខ
សន្ទឹកម្ខាងទៀតទៅជារីងស្ងួត ហើយមានតែសរសៃទ្រនុងស្លឹកឈើ ៗ
កូនដង្កូវល្អិតក៏នាំគ្នាស៊ីមុខសន្ទឹកខាងលើតាមផ្លូវដែលវាវារទៅទាល់តែនៅ
សល់តែកងសន្ទឹកទទេ លុះវានាំគ្នាស៊ីសន្ទឹកឈើដើមតូចៗអស់ហើយ ទើប
វានាំគ្នាទៅទីដទៃ លុះដល់រដូវរងាទើបសត្វដង្កូវអស់នេះរួបរួមគ្នាទៅនៅ
ចុងមែកឈើ ដែលមានសន្ទឹកស៊ុមទ្រុមលុមជាទីជ្រកការពាររងាក្នុងរដូវ
រងាជាវេលា ៣-៤ ខែ ៗ ក្នុងខណៈវេលានេះ ពួកដង្កូវមិនចេញទៅ
ណាទេ លុះដល់ខែម៉ារ្ស ទើបវានាំគ្នាចេញទៅស្វែងរកចំណីអាហារ ៗ
ខណៈនេះពួកសត្វដង្កូវអស់នេះ កំពុងឃ្លានខ្លាំងណាស់ ទើបវានាំគ្នាស៊ី
ស្លឹកឈើទាំងអស់ ដូច្នេះហើយបានជាដើមឈើតូច ៗ ដែលវាចោមស៊ី
ស្ទើរតែគ្មានមានសន្ទឹកឡើយ ៗ លុះវានាំគ្នាស៊ីស្លឹកឈើកាន់តែរេចរិល

ដកអស់ហើយ ទើបវានាំគ្នាចេញពីដើមឈើនោះទៅ ៗ កូនដែលស៊ីមេតដង្កូវនេះកចេញពីដើមឈើតូច ៗ នោះហើយចុះមកដី ដើម្បីធ្វើសំបុកនៅកណ្តាលស្លឹកឈើស្ងួត ៗ ឯសត្វដង្កូវនេះ កាលណាវាវារមកលើស្បែកដៃឬកបេស់មនុស្សយើង វាធ្វើឲ្យមានស្នាមក្រហមហើយហើមធ្វើឲ្យឈឺចាប់ជាខ្លាំង ៗ ដល់៥ថ្ងៃតមក ទើបស្បែកដែលវាកេលស្លុតទៅហើយបែកស្រកា ៗ

## អំពីសត្វឱម៉ាល់

កូនសំបុកឱម៉ាល់មួយនោះមានស្រទាប់ៗ ចំនួន ១០ ស្រទាប់ជាន់គ្នាលើគ្នា រូមទាំងរន្ធតូចៗ ទាំងអស់ ១១.៩០០ ៗ នៅខែដេសមប្រែកំពុងរងាខ្លាំង សត្វឱម៉ាល់ត្រូវរងាធ្វើឲ្យស្តូកសាច់ជាខ្លាំង ទើបគេមើលឃើញនៅខាងក្រោមសំបុក មានខ្មោចសត្វឱម៉ាល់ជាចំនួនច្រើន ៗ តែកាលណាមានសត្វឱម៉ាល់មួយដួតដល់ជាចខ្យល់ស្លាប់ ទើបមានសត្វឱម៉ាល់មួយខាំជើងអូសទៅ ដាក់ភាគខាងក្រោមសំបុកដែលជាកន្លែងសម្រាប់ដាក់ខ្មោចពួកវា ៗ គេបានពិនិត្យឃើញសត្វឱម៉ាល់នេះមាន ៣ ចំពូកគឺពួកអលិង្គ (ឥតភេទ) ពួកបុំលិង្គ (ឈ្មោល) និងពួកឥត្ថីលិង្គ (ញី) ពួកអលិង្គមានចំនួនស្លាប់ជាច្រើនបំផុត បន្ទាប់មកពួកបុំលិង្គ ឯពួកឥត្ថីលិង្គក៏មានស្លាប់ដែរ ៗ ពេលកើតទុរ្ភិក្សនិងរងាជាហេតុធ្វើឲ្យចំនួនឱម៉ាល់ថយតិចពីសំបុករបស់វា ៗ តែកាលណាអាកាសមិនរងា ពួក

ឪម៉ាល់តែងដែកដេកនៅចន្លោះស្រទាប់ៗ នៃសំបុកវាក្នុងវេលាយប់ ៗ លុះដល់ថ្ងៃរះឡើងទើបវានាំគ្នាចេញពីសំបុកទៅ ខាងក្នុងសំបុកក៏ភ្លឺអ៊ឹក-ធឹកឡើង ៗ ពួកអលិង្គនាំគ្នាហើរប្រវាត់ ពួកបុំលិង្គក៏ចំធ្វើការយ៉ាងរំ-ឃោត ឯពួកឥត្ថីលិង្គក៏សម្ងំស្ងៀមទៅ ៗ

លុះតែកាលណាពួកអលិង្គ ពួកបុំលិង្គនិងពួកឥត្ថីលិង្គធ្វើកិច្ចការតាមមុខក្រសួងវាសព្វគ្រប់ហើយក៏ស្លាប់ទៅ ៗ ប៉ុន្តែពួកឥត្ថីលិង្គដែលកើតក្រោយ ៗ មក ក៏មានកំឡាំងរឹងប៉ឹងចំណាប់ប្រហែលនឹងពួកបុំលិង្គដែរ ៗ ឯការចាំគន់មើលឪម៉ាល់មេដោះកំពុងបញ្ចុកបំប៉នចំណីឲ្យកូនវានោះ ឥតនរណាធុញទ្រាន់ទេ មានឪម៉ាល់មេដោះមួយបានទឹកឃ្មុំមកប៉ោងពោះ ហើយលបចូលទៅខាងមុខល្វែងរន្ធតូចមួយ ហើយវាឱនក្បាលបែរមាត់ទៅ ហើយកូនវា (នៅជាដង្កូវ) ក៏កំរើកក្បាលងើងើ វាមិនទាន់បើកភ្នែកទេ មេឪម៉ាល់ក៏ដាក់មាត់វាទៅប៉ះនឹងមាត់របស់កូនវា ហើយបញ្ច្រាកទឹកឃ្មុំ ១ ដំណក់ទៅ រួចមេដោះនេះក៏ចេញពីល្វែងរន្ធនេះ ទៅកាន់ល្វែងរន្ធឯទៀត ៗ ធ្វើដូច្នេះទៀត ៗ ឯកូនវាក៏លេបទឹកឃ្មុំដែលធ្លាក់ចូលទៅក្នុងបំពង់ករបស់វាទៅ រួចបន្តិចមកវាក៏ដេកលក់ទៅ ៗ ប្រសិនបើមេដោះរកទឹកឃ្មុំឲ្យកូនវាមិនបាន វាក៏ចាប់សម្លាប់សត្វល្អិត ៗ បានហើយវាក៏កំទេចឲ្យល្អិតខ្ទិចហើយ ទើបយកទៅឲ្យកូនវា ៗ ប្រសិនបើស្រាំងបុត្តាន មកដណ្ដើមអាហារចំណីរបស់ពួកមេដោះវា ក៏ត្រូវវា

សម្លាប់មួយរំពេច ដោយមានមេដោះមួយស្ទុះចេញទៅចាប់កន្ទុយវាដាប់ ហើយចាក់ទឹងលំពែងឲ្យចំដើមទ្រូងស្លាប់ទៅ ទើបមានឪម៉ាល់ពីរទៀត នាំគ្នាសែងខ្មោចសត្វនោះអូសទៅចោលក្រៅទៅ លុះកាលណាមេដោះសង្កេតឃើញកូនវាបំរុងនឹងស្លាប់ហើយ វាក៏យកទៅដាក់ក្រៅសំបុកទៅ ៗ ដល់រដូវខែរងា ពួកមេដោះមិនសូវទំលើកាមែងម៉ាត់ដូចកាលពីមុនទេ ទើបពួកអលិង្គនាំគ្នាស៊ីដង្កូវដែលក្រញាស់អស់នោះទៅ ហើយតមកដល់វារៈខ្លួនវាត្រូវស្លាប់ដោយពួកបុំលិង្គសម្លាប់ក្នុងរដូវរងានេះឯង ៗ

## អំពីសត្វឃ្មុំ

សត្វឃ្មុំកើតឡើងក្នុងរដូវក្ដៅពល់តែល្ងាចព្រលប់ សត្វអស់នេះតែងឡើងទំលើដើមឈើ ៗ ឃ្មុំឈ្មោលមានពុកមាត់វែង ១ ចាប់គោងមែកឈើតូច ៗ ដែលពួកមេឃ្មុំនៅចាំជួបនឹងវា ៗ លុះព្រឹកស្អែកឡើងទាំងឈ្មោលទាំងញីនាំគ្នាទៅមែកឈើខាងក្រោម ហើយវាបោះស៊ុស្លឹកឈើហើយដេកលក់ទៅទាំងមានស្លឹកឈើនៅក្នុងមាត់ ដល់វេលាល្ងាចវានាំគ្នាសប្បាយរីករាយតាមនិស្ស័យសត្វ ៗ ទាំងឃ្មុំឈ្មោលទាំងឃ្មុំញីមានគ្រឿងក្នុងសម្រាប់លេងកំសាន្ត នៅនឹងសាច់ខ្លួនត្រង់ពោះវានោះកម្រើកញ័រ សម្រាប់ធ្វើឲ្យមានសូរសព្ទសំឡេងឡើងបាន ៗ ឃ្មុំឈ្មោលនេះកាលបើគេចាប់វាហើយច្របាច់វាបន្តិច ក្នុងខណៈនុ៎ះឯង គ្រឿងសំឡេងក៏លាន់ឮឡើង ៗ ក្នុង ១៥ ថ្ងៃដំបូងក្នុងខែស៊ីយេក ឃ្មុំឈ្មោល ៗ

ដកខ្លួនថយទៅនៅដោយឡែក ហើយសន្សឹមៗ ស្លាប់ទៅតាមកំណត់អាយុ ។ ឯមេខ្លួនពេលដែលមានពង វាតែងកកាយដីហើយចុះទៅនៅក្នុងដីត្រឹមស្មាវា ហើយវាពងចេញមកចំនួន ២០ ពង ហើយវាដាក់ពងនិមួយៗ តាមក្រហូងដីនិមួយៗដែរ ពងវានេះមានព័ណ៌សសាអែម មានសរសៃធ្មារគ្របបាំង លុះ ១ ខែតមកទើបពងវានេះ ញាស់ចេញជាដង្កូវៗ នេះស៊ីស្លឹកឈើស្អុយ ៗ នៅទឹងដី ហើយសត្វដង្កូវនេះ ជាពួកសត្វចូលចិត្តចោះស៊ីឬសឈើខ្ចីៗ ហើយជាពួកសត្វបំផ្លាញដំណាំរបស់អ្នកស្រុកផង ។

## អំពីសត្វរុយក្បាលខៀវ

ជារុយខ្នាតធំមានព័ណ៌ខៀវស្រងាត់ ចូលចិត្តចាប់ទំនៅលើចំណីអាហាររបស់យើង ហើយវាហើរទៅហាលថ្ងៃ ៗ ក្នុងវេលាដែលអាកាសត្រជាក់ខ្លាំង ស្រាប់តែបាត់រុយអស់ទៅ តែគ្រាលណាមានថ្ងៃឡើង រុយត្រឡប់ជាមានឡើងវិញ ។ ក្នុងខែអាព្រិល គេច្រើនតែឃើញរុយទំនៅទឹងផ្កា ។ ក្នុងរដូវក្តៅ រុយចេញទៅនៅក្រៅ ដល់រដូវស្លឹកឈើជ្រុះ វាត្រឡប់ចូលទៅក្នុងផ្ទះវិញ ដរាបដល់ឱកាសរងាជាខ្លាំងតែម្តង ។ សត្វរុយក្បាលខៀវនេះ ច្រើនតែរើសរករបស់ស្អុយស្មោកគ្រោក សម្រាប់ដាក់ពងរបស់វា វារកតែកន្លែងណាដែលងងឹត ៗ ហើយមានសត្វស្លាប់ ឬដុំសាច់នៅក្នុងទីនោះផង គេបានឃើញវាពងជាច្រើនផង បានចំនួនពងដល់ ៣០០ ក្នុង ១ ដុំ ហើយអស់វេលាជាច្រើនម៉ោងផង ។

វាពងម្ដងរួចទៅហើយ រុយមិនត្រូវប៉ះមកទំលើដុំសាច់នេះទៀតឡើយ ពីព្រោះតែដល់ព្រឹកស្អែកឡើងវាស្លាប់ទៅហើយ ។ សត្វរុយដម្រះពងដាក់ជាវេលាពីរបីថ្ងៃ ក៏កើតជាដង្កូវតាក់ក្រើមរវាមនៅទីដុំសាច់នោះ ។ ប្រសិនបើសត្វស្លាប់ឬដុំសាច់ដាក់ទុកក្នុងថង់រ៉ូនិមួយ មិនឲ្យរុយហោះចូលទៅទំសាច់នោះបាន ។ សត្វឬសាច់នេះរលួយកើតឡើង ដោយគ្មានគ្រឿងការពាររុយពេមឬពងដាក់ទីដុំសាច់នោះ ហេតុនេះហើយបានជាការសំដិលគ្រឿងសាច់លក់នៅផ្សារ អាចនាំឲ្យកើតអន្តរាយជាច្រើន ដោយហេតុរុយហើរមកពេមទំដុះដាក់ មួយវិញទៀត ដុំសាច់ដែលមើលឃើញល្អតែខាងក្រៅ តែមានដង្កូវហោះពីខាងក្នុង ក៏នាំឲ្យមានអន្តរាយដល់អ្នកទិញទៅបរិភោគដែរ ។ ប្រសិនបើបិទបាំងរុំខ្ចប់មិនឲ្យរុយពេមបាន ទើបយើងចៀសផុតពីជម្ងឺផ្សេងៗបាន ដូច្នេះវិធីការពារដែលងាយបំផុត គឺយកដុំសាច់ខ្ចប់ក្រដាសឲ្យជិត កុំឲ្យរុយក្បាលខៀវហោះពងដាក់បាន ។ ឯរុយក្បាលខៀវតែងហើរមកពេម ហើយដុះពងដាក់ត្រង់កន្លែងដែលមានក្លិននៅក្បែរខាងនោះ ប្រសិនបើវាមិនពងដាក់ឲ្យចំ ៗ នឹងកន្លែងដែលមានក្លិនស្អុយនោះទេ វាក៏រើសរកកន្លែងណាមួយដែលមេពេគល្មមច្រៀតច្រែកចូលទៅទំទីងរបស់នោះបាន ហើយរកកន្លែងរន្ធយ៉ាងតូចដែលយើងមើលដោយភ្នែកទទេពុំឃើញ ។

ក្នុងរដូវក្តៅ ពពួករុយក៏ញាស់ចេញមកជាដង្កូវល្អិតៗ ក្នុងកំណត់ពីរថ្ងៃ ដង្កូវរុយនេះ វាមិនបំបែកអាហាររបស់វាទេ វាចេះតែរុកឆ្កៀលទៅមុខ ដោយមាត់វាមានទំពក់ថ្ពក់ទៅមុខ ហើយផ្ទាត់ខ្លួនវាតាមគ្នាទៅទៀត ដូច្នេះហើយបានជាដង្កូវវារុកចូលទៅបានដោយស្រួលក្នុងដុំសាច់ ដង្កូវនេះ វាមិនស៊ីរបស់រឹងទេ ចូលចិត្តតែរបស់ទន់ជ្រាយ ដុំសាច់ដែលដង្កូវរុកឆ្កៀលចូលទៅនោះ ក្លាយជារបស់ជ្រាយពរជាទឹកហូរស្រក់ទៅ ។ សត្វរុយក្បាលខៀវនេះ វាចូលចិត្តសាកអសុភជាខ្មោចសត្វក្តី ខ្មោចត្រីក្តី ប៉ុន្តែដុំសាច់ដែលលក់នៅផ្សារ ធាប់រលួយរហ័សជាងសាកអសុភដែលស្លាប់តាមធម្មតា ។ សត្វរុយក្បាលខៀវ កាលណាវាពងដាក់ល្មមធ្វើឲ្យរបស់ស្អុយខូច ហើយវាក៏ហើរទៅទំហើយពងដាក់នៅទីដទៃទៀត ហើយនាំយកមេជម្ងឺទាំងពួងទៅផ្សាយផង ។ បណ្តាំដ៏ប្រសើរដែលយើងត្រូវប្រតិបត្តិដូច្នេះ "ចូរលោក-អ្នកគ្របបិទអាហារភោជនដោយគ្រជាសគ្មានរហែកបន្តិច ដើម្បីការពារអាហាររបស់យើងឲ្យស្អាតជានិច្ច" ។

(នៅស្រុកខ្មែរយើង សត្វចំពួកនេះសំបូរណាស់ មានច្រើនបំផុតក្នុងរដូវស្វាយទុំ គ្រាប់ស្វាយទុំដែលយើងបរិភោគសាច់អស់ហើយ បោះចោលគ្រាប់ទៅដី តែងមានរុយក្បាលខៀវមកពេមចោមស៊ីជាចំនួនច្រើន ឬមានកាកអំពៅ ក្បាលត្រី ។ល។ នៅទីណា ក៏មានសត្វរុយ

ចំពួកនេះនៅទីនោះជាច្រើន មួយវិញទៀត នៅទីបន្ទន់ដែលមិនស្អាត ក៏មានសត្វរុយមកចោមរោមពង់ដាក់លាមកជាច្រើនណាស់ដែរ ។

តាមធម្មតា សត្វរុយនេះយើងយល់ថា ជាសត្វល្អិតៗឥតពិសអ្វី មិនដូចសត្វឃ្មុំ តាទុ ឪម៉ាល់ទេ ទើបយើងមិនសូវរវល់នឹងសត្វរុយប៉ុន្មានទៀយ បណ្ដោយវាពោមចំណីអាហារតាមចិត្តវាក៏មាន តែតាមវិជ្ជាពេទ្យវិញយល់ឃើញច្បាស់ថា សត្វរុយជាសត្វសាហាវក្រៃលែង ជានិច្ចាជំនៅតាមព្រៃតូចក្រមចាំទោទៀត ព្រោះវាហើរទៅទំលើលាមកប្ញរបស់ស្មោកគ្រោក ដើងវាប្រឡាក់គ្រឿងស្មោកគ្រោក ដែលជាមេជម្ងឺ រួចវាហើរមកទំលើខ្លួនយើងក្ដី សំពត់អាវយើងក្ដី អាហារចំណីយើងក្ដី សុទ្ធតែនាំបង្កើតជម្ងឺផ្សេងៗ ដកបដល់ក្ស័យជីវិតជាទីបំផុត ។ ដូច្នេះ យើងត្រូវតែការពារអាហារភោជន គ្រឿងប្រើប្រាស់ ទីលំនៅជាដើមកុំឲ្យរុយពោមពេក យើងដឹងច្បាស់ហើយថា សត្វរុយចូលចិត្តគ្រឿងស្មោកគ្រោក ដូច្នេះ យើងត្រូវថែរក្សាផ្ទះសំបែងរបស់យើង ផ្ទះបាយ ជុំវិញផ្ទះយើងកុំឲ្យមានសម្រាមបូទឹកដក់ខាំងនៅក្បែរផ្ទះ ត្រូវចាក់ដីបំពេញថ្លុកត្រពាំងនឹងប្រាបដីឲ្យរាបស្មើគ្នា ហើយបោសសំអាតជានិច្ច ទើបមូសរុយមិនមកបៀតៈបៀនយើងបាន ហើយខ្លួនយើងវង្សត្រកូលយើងនឹងមានសេចក្ដីសុខសប្បាយជាដរាប ។ ប.ក.)

# អំពិលអំពែក

ក្នុងរដូវក្ដៅវេលាថ្ងៃល្ងាច សត្វអំពិលអំពែក តែងមានពន្លឺមួយចុះចេញពីក្រោមពោះខាងក្នុយរបស់វា ។ គេនិយាយថា បំណែកពន្លឺមួយធ្លាក់ចុះមកពីព្រះចន្ទ្រាពេញបូណ៌មី អ្នកប្រាជ្ញក្រិកសម័យបុរាណតាំងឈ្មោះសត្វនេះថា " សត្វកាន់ចង្កៀងចុះពន្លឺពីខាងក្រោយខ្លួន" ។ សត្វនេះមានជើង ៦ សម្រាប់ប្រើដើរឬរត់ក៏បាន លុះធំពេញរូបរាងឡើងចំពោះតួឈ្មោលទើបមានស្លាប ឯតួញីឥតស្លាបទេ ។ ឯដងខ្លួនតួឈ្មោលសំបុរត្នោតពោះសំបុរផ្កាកុឡាប ។ សត្វនេះតែងស៊ីសាច់សត្វ សាច់ដែលវាចូលចិត្តណាស់គឺសាច់ខ្យងក្អកតូចៗ កាលណាវាស៊ី សត្វខ្យងវាលែងដឹងខ្លួន បើកាលណាវាជួបនឹងខ្យងមួយនៅក្នុងស្រែ វាក៏ហើរជុំវិញហើយវាក៏យកទ្រនិចដូចចំពាក់ មានសណ្ឋានធារប៉ុនចុងសក់ ហើយសន្សឹមៗចាក់ទាញ ហើយតួខ្យងក៏លៀនចេញមកពីស្រោម ហើយវាព្រួសពិស ២-៣ ដងទៅត្រូវសាច់ខ្យងៗ ក៏សន្លប់បាត់ស្មារតី ហើយវាស៊ីសាច់ខ្យងតាមអំពើចិត្ត លុះពីរបីថ្ងៃមកទើបខ្យងដឹងខ្លួនឡើងវិញដូចដើម ។ ឯសត្វអំពិលអំពែកដែលវាស៊ីសាច់ខ្យងនេះស៊ីយ៉ាងប្រយ័ត្នប្រើនមិនឲ្យសត្វខ្យងជ្រះចេញពីទីកន្លែងផង គឺវាមិនបានស៊ីទាំងដុំៗទេ គ្រាន់តែជញ្ជក់ទៅៗ ទាល់តែអស់សាច់ខ្យង នៅតែសំបកខ្យង ។

ឯប្រដាប់សម្រាប់ផ្ទុះពន្លឺនោះ នៅពីក្រោយដុំវិញពោះវា ត្រង់អន្លង់ៗបត់ៗ របស់ប្រដាប់ផ្ទុះពន្លឺនៅខាងមុខពីស្រទាប់ ហើយមានស្បែកគ្របពីលើមួយជាន់ទៀត ឯស្រទាប់ទី ៣ ទើបមានពន្លឺផ្ទុះចេញទៅភ្លឺច្រើន នៅខាងលើខ្នងវាមានផ្ទត់តូចៗបត់ពាក់ពីលើ សឹងមើលឃើញដោយភ្នែកទទេ ឯផ្ទាំងកន្ទ្រង់តូចៗ និងផ្ទត់នេះហើយ ដែលសម្រាប់បញ្ចេញពន្លឺមានពណ៌សលាយខៀវបន្តិច ។ ឯផ្ទាំងកន្ទ្រង់ទាំងពីរនេះហើយ ដែលមានពន្លឺខ្លាំងបំផុតហើយមានតែតួញីផង ។ មេអំពិលអំពែកពន្លឺដែលភ្លឺខ្លាំងនេះហើយ ជាគ្រឿងសំគាល់ថាវាប្រុងនឹងក្លាយទៅជាសត្វឯទៀត ។ តួឈ្មោលនោះ ក្រោយដែលក្លាយខ្លួនពីដង្កូវមកវាក៏ដុះស្លាប វាមានពន្លឺស្មើនៅខាងក្រោយដងខ្លួនវា ប្រដាប់សម្រាប់ផ្ទុះពន្លឺឃើញមាន នៅខាងក្រោមប្រដាប់សម្រាប់ដកដង្ហើម ។ កាលណាវាទៅសេពមេថុនជាមួយនឹងតួញី វាបញ្ចេញពន្លឺដែរ តែភ្លឺខ្សោយជាងធម្មតា ។ ដើម្បីកូតហៅតួឈ្មោល នៅវេលាល្ងាចៗនោះ តួញីវាបង្ហាញពោះវាបញ្ចេញពន្លឺឲ្យតួឈ្មោលឃើញហើយសេពមេថុនជាមួយគ្នា តមកមិនយូរប៉ុន្មានតួញីក៏មានពងឡើង ។ ឯពងនេះមានសណ្ឋានមូល មានពណ៌សពេយពយទៅពាសពេញ ហើយមានពន្លឺផ្ទុះដែរ តមកមិនយូរប៉ុន្មានពងក៏ញាស់ ។

# អំពីដង្កូវក្រានៅនឹងស្ពៃ

តួក្រានេះចូលចិត្តស៊ីស្លឹកស្ពៃណាស់ ហើយមិនដើរចេញទៅណាទេ វាស៊ីស្លឹកស្ពៃឲ្យដាច់ធ្លុះ នៅកន្ទុងដែលវាកើតហ្នឹងឯង ៗ ពងវាតម្រៀបគ្នាជាជួរៗ ដោយពួកៗ ក្នុង ១ អាទិត្យវាក៏ញាស់ចេញជាដង្កូវក្រា កាលមានដង្កូវក្រា ១ ចេញពីពងវា តួឯទៀតៗ ក៏ចេញមកតាមគ្នាជាច្រើន ហើយវានាំគ្នាចោះស្លឹកស្ពៃត្រង់ពងវាហ្នឹងឯង ៗ ក្នុងវេលាពីរបីម៉ោង ពងដង្កូវក្រាទាំងអស់ក៏ញាស់ចេញមកយ៉ាងណែនណាន់តាន់តាប់ ហើយស៊ីស្លឹកស្ពៃ វាទាញសរសៃខ្សែមង ដើម្បីឲ្យបានស្រួលដើរទៅមកតាមស្លឹកស្ពៃ ៗ ឯកូនដង្កូវក្រាតូចៗ នោះ មានសំបុរលឿងប្រផេះ ពេមក្នុកស ក្បាលខ្មៅ ៗ ដង្កូវល្អិតៗ នេះឆាប់ធំណាស់ ៗ ហើយផ្លាស់ស្បែកវាជាថ្មីមានចុចខ្មៅ ៗ មានពេមក្នុកសវាតែងឈប់សម្រាកជាវេលា ៣ - ៤ ថ្ងៃមិនស៊ីអាហារ តមកទើបចាប់ផ្ដើមស៊ីស្ពៃជាវេលា ២ - ៣ អាទិត្យ បន្លែស្ពៃស្ទើរតែអស់ឥតសល់ សត្វចំពួកនេះធ្វើឲ្យសូន្យបន្លែវិនាសខូចខាតយ៉ាងសំបើម ៗ មានថ្នាំម្យ៉ាងសម្រាប់បំបាត់ពងនិងដង្កូវក្រាឲ្យវិនាសបាន ការប្រើថ្នាំបែបនេះត្រឹម ១ ខែពួកដង្កូវក្រានឹងគេចេញ ហើយទៅលាក់ខ្លួនពួននៅទីដទៃ សត្វចំពួកនេះខ្លាចកំដៅ

ថ្ងៃខ្ទាំងបុត្រផាក់ខ្ទាំង ២ ក្នុងការផ្លាស់ប្រែរូបរាងវា វាតែងរត់ទៅចូលជ្រកនៅទីស្ងួត ៗ ៗ

ដង្កូវស្វានេះមានសត្រូវ ១ ពួក ជាពួកសត្វល្អិតហៅឈ្មោះតាមធម្មតាថា "សត្វពោះតូច" ដ្បិតសត្វនេះស្ទើរតែឥតពោះពុង ៗ ក្នុងរដូវស្លឹកឈើជ្រុះ គេសង្កេតមើលតាមដើមរបង ឃើញមានសំបុកសត្វតូចៗ ពណ៌លឿងនៅជិតៗ គ្នា នៅក្បែរខាងនោះមានដង្កូវស្វាដេកស្លាប់ ឬស្លាប់ទៅហើយ ដោយដង្កូវល្អិត "ពោះតូច" នាំគ្នាស៊ីដង្កូវស្វា ៗ ក្នុងខែមេ ពួកដង្កូវល្អិតក៏ក្លាយជាសត្វល្អិត ៗ មានលក្ខណៈដូចមមង់ គេមើលឃើញសត្វពួកនេះហើរព្រោងព្រាត ក្នុងពន្លឺថ្ងៃដោយស្លាបទាំង៤របស់វា ៗ

តួឈ្មោលទីងតួញីមានខ្លួនខ្មៅ ទីងមានជើងស្ទើរក្រហម ពោះតួឈ្មោលមានសាច់ទន់ៗ បន្តិច ហើយចុងពោះងបន្តិចផង ឯតួញីមុនពងមានពោះផ្សេង លុះដល់ខែយូរកុំង មេដង្កូវអស់នេះ ក៏ចេញទៅរៀបចំធ្វើសំបុកក្នុងចំណោមនេះមានមេដង្កូវឈឺ គេអាចទាយបានថា មេដង្កូវមានជម្ងឺ ប្រសិនបើគេយកចុងម្ជុលចាក់បើកពោះវាចេញ ទីងឃើញអវយវៈគ្រឿងពោះវៀនវាមានទឹកលឿងថ្លា ដែលជាឈាមរបស់មេដង្កូវ ហើយមានសត្វដង្កូវយ៉ាងល្អិតៗ នៅក្នុងពោះវៀន មេដង្កូវយ៉ាងល្អិតៗ វាផញ្ញក់

ឈាមមេដង្កូវ ហើយក៏ចេញពីពោះមេដង្កូវទៅ ដើម្បីធ្វើជាសំបុករបស់ក៏ដង្កូវល្អិតៗនៃសត្វពោះតូចនេះមានសំបុរស ខាងមុខដងខ្លួនក៏ស្រួចបាយពីណាទៅ ៗ ក៏មិនបាច់ផ្លាស់ចេញពីទឹកខ្ទង់ទេ ក៏គ្រាន់តែកំរើកក្តិត មិនបាច់ថ្លក់ មិនបាច់ថ្លៀប មិនបាច់ទំពាទេ ក៏គ្រាន់តែជញ្ជក់ឈាមប៉ុណ្ណោះ គេអាចពោលបានថា មេដង្កូវនឹងស្លាប់ដោយដង្កូវល្អិតជញ្ជក់យកឈាមមិនខាន ។ ឯមេក្របីជ្រើសៗ ក៏ជ្រះចេញពីខ្លួនមេដង្កូវដែលស្លាប់នេះអស់ទៅ លុះដល់ខែយូរ៉ាំងក្នុងវេលាយប់ សត្វដង្កូវល្អិតៗ ក៏បោះពោះមេដង្កូវឲ្យមានរន្ធចូលទៅខាងក្នុង ហើយដល់ព្រឹកចេញវិញ មានចំនួនគ្នាក៏ស្អេកស្កាសតែម្តង ៗ លុះដល់កណ្តាលខែយូរ៉ាំង សត្វពោះតូចក៏ធំពេញរូបឡើង មានត្បូញជាច្រើនទៅរកពន្លឺភ្លឺ ហើយទាំងត្បូញឈ្មោលនឹងត្បូញក៏ជាន់គ្នាហើយលែងៗ ហើយត្រឡប់ជាន់គ្នាទៀត ៗ ចុះពួកដង្កូវល្អិតៗក៏ចូលទៅក្នុងមេដង្កូវដូចម្តេចបាន ? មេដង្កូវឥតដឹងខ្លួនទេ (ដង្កូវល្អិតៗ) គ្រាន់តែចាក់ចុចទំងន់នាំមេជម្ងឺចូលទៅប៉ុណ្ណោះ សត្វពោះតូចក៏ឥតបានខាំកកេរមេដង្កូវដែរ ៗ មេដង្កូវមានពងក៏ក្រាបនៅលើពង ដែលនៅខាងចុងពោះមានសណ្ឋានស្រួចផងបន្តិច ហេតុនេះហើយបានជា មេពងចាក់ជាតិជម្ងឺទៅក្នុងមេដង្កូវបាន ហើយមេមានពងមិនមួយក៏ចំរើនគ្នាក៏កាន់តែច្រើនឡើង ហើយក៏ស្រែះស្រួលធ្វើការនេះ នៅលើមេដង្កូវជាមួយគ្នា ៗ

ការល្បងមើលគ្រប់បែប ដែលអ្នកប្រាជ្ញហ្វាបបានអធិប្បាយពន្យល់មកនេះ សុទ្ធតែជាការដែលលោកបានធ្វើក្នុងមន្ទីរពិនិត្យវិជ្ជាវិទ្យាសាស្ត្ររបស់លោក លោកបានធ្វើការពិនិត្យមើលមកឥតឈប់ឈរ អំពីដំណើរជីវិតរបស់សត្វល្អិតៗ ដោយកែវយឺត និងកែវឆ្លុះមេក្រូប ដើម្បីសង្កេតមើលផ្នែកផ្សេងៗ ឲ្យសព្វគ្រប់ សូម្បីតែវត្ថុដែលមើលដោយកែវយឺតមិនឃើញ ក៏ត្រូវតែឲ្យស្គាល់សរីរសាស្ត្រនិងដំណើរជីវិតរបស់សត្វល្អិតៗ នៅក្នុងសួនច្បាររបស់មហានគរបារាំងសែសប៉ែកខាងត្បូង ។

---

## ប្រដៅចិត្ត

# អ្នកឧកញ៉ាបេស្តារិនិច្ឆ័យ កែវ-ហង់

រៀបរៀង

អញខ្ញុំឧនកាយថ្វាយវន្ទា សម្តេចកតវារ័តន៍ថ្លាថ្លៃ ចមមកុដកំពូលលើកពាក្រៃ ជាម្ហូឥស្សូរសោស្តាចារ្យ ។ ទ្រង់ប្រោសអស់សត្វផងទាំងឡាយ ស្ថានអាយទ័ងសួគ៌តុសិតា ឲ្យបានរួចចាកវដ្តសង្សារ ទេវតាមនុស្សសត្វផងទាំងឡាយ ។ ព្រមទាំងព្រះធម៌ល្អបរិសុទ្ធ ថ្លាផុតជម្រះសុរិលកាយ ញុាំងចិត្តឲ្យចាកផ្លូវអបាយ នាំសត្វទាំងឡាយបានសុខា ។ ជាធម៌របស់ព្រះសម្ពុទ្ធ ផ្ទះមុតភ្លឺច្បាស់ល្អថ្លៃថ្លា ទ្រង់សំដែងទុកជាសាសនា ឲ្យអស់មហាជនទាំងឡាយ ។ ប្រតិបត្តិធ្វើតាមពាក្យប្រដៅ មិនឲ្យហួងសៅដិតអន្តកាយ ជាផ្លូវនាំសត្វបៀសអបាយ ឲ្យសត្វទាំង-ឡាយផុតទុក្ខា ។ ព្រមទាំងព្រះសង្ឃអគ្គសាវក លោកអ្នកផ្តិលផ្តាច់កង់តណ្ហា រំលត់កិលេសផុតសិក្ខា បុត្រព្រះសាស្តាករុណាគុណ ។ លោកជាបុញ្ញាក្ខេត្តទក្ខិណេយ្យ សត្វពឹងប្រស្រ័យជាស្រែបុណ្យ ជាយានផុតទានជាដើមទុន សូមរំលឹកគុណដោយសិរសា ។

ជាបទដើមអាទិ៍ខ្ញុំប្រារព្ធ លើករឿងក្នុងកពពីរូបា កើតមកក្នុងវដ្ត-សង្សារ ដូចបានពណ៌នាជាសេចក្តី ។ បកិណ្ណកៈថ្នាក់ដោយបទ

កំណាត់ប្អូនឃ្លាកាត់ខ្លី ៗ ត្រង់ចិត្តមនុស្សយើងជាន់លោកិយ៍ ទាំងប្រុសទាំងស្រីដូច្នេះណា ។

ខ្ញុំថ្លែងពីសត្វក្នុងត្រៃលោក កើតមកតែងស្លាប់ជាធម្មតា វិលវល់ក្នុងវដ្តសង្សារ មិនដែលសត្វណានៅថេរបិត ៗ ទាំងប្រុសទាំងស្រីទាំងក្មេងចាស់ គ្រប់សាសន៍ក្នុងដែនឥតគាប់ចិត្ត ព្រោះមានតណ្ហាមកបាំងបិទកិលេសរុំរឹតឥតគណនា ។ ខ្លះមានកុសលដែលកសាង ដោយភ័ព្វសំណាងកើតសួគ៌ា ខ្លះសាងអកុសលមានវេរា ឲ្យទៅកើតនាស្ថានទុក្ខ ៗ កាលមកបដិសន្ធិកត លំបាកទាំងគ្រប់គួរអនិច្ចំ តូចស្តួចរៀវស្ដើងកើតដុំផ្លុំង យូរថ្ងៃបែកអង្គបញ្ចសាខា ។ លុះដល់កំណត់ជួបវេលា វេទនាសត្វទនតាមមាសា បង្កើតលំបាកក្នុងអាត្មា ភ័យស្លុតតក្កមាដោយក-យោ ។ ខ្យល់កម្មជវិតអកិធម្ម បក់ផ្សប់ផ្ទិលឲ្យទន់ទោ វិលក្បាលសំយុងគួរអាសូរ ទុក្ខោទុរបុក្ខទាំងឡាយ ។ កាលនៅក្នុងផ្ទៃនៃមាតា វេទនាលំបាកពល់រូបកាយ អង្គុយលើលាមកក្បាលទូលបាយ ដែលម្តាយបរិភោគនៅចុះ ៗ បែរមុខទៅខ្នងដូចចង្រួត ហើយឱបទងសួតទងសុកសែ កំព្រាត់កំព្រួនតែសព្វថ្ងៃ សាច់ឈាមសរសៃសែនខ្លោចផ្សា ៗ ប៉ះពាល់លើម្ហូបដែលដូរប្រែ មាតាប្រណីលោកមេត្តា បរិភោគចំណីឬផលា មានរសពីសាកាយាសុខ ។ ឧបមេយ្យដូចនៃសត្វពានរ ត្រូវគៀងត្រូវផ្គរប្រឹងតក្រុក ដែកក្នុងរូងឈើព្រៃជាទុក្ខ មិនដែលបានសុខធុក

ចុះទៅ ៗ បើមានកុសលពីអតីត កសាងប្រសិទ្ធិជួយកែរ ឲ្យរូបចេញ
មកមិនអ៊ូទេ ចាកពីទ្វារមាសនៃមាតា ៗ បើមានអកុសលដែលជាប់ដិត
ប្រកិតមកតាមដោយយថា មិនបានចេញចាកផ្ទៃឡើយណា មរណា
ដោយកម្មតាមមកផ្តល់ ៗ រៀបចេញពីផ្ទៃនៃមាតា ក័យស្មុគគ្គមាក្មេប
គ្មានសល់ វង្វេងស្មារតីវិលតាមខ្យល់ វិញ្ញាណគ្មានសល់សូន្យសោះ
ឈឹង ៗ ដូចជាក្សិណក្ស័យប្រល័យហើយ គ្មានដឹងតិចឡើយបាត់ព្រលឹង
លុះគេស្រោចទឹកទើបបានដឹង ផ្កាទ្រោចស្បែកផ្អឹងដែលនៅខ្ចី ៗ ក្រ-
ហល់ក្រហាយដូចដុតអគ្គី លោកពុះពេញអស់សរីរ៍ កល់រូបកងកាយចេញ
ពីផ្ទៃ មានភ័យមានទុក្ខជាធម្មតា ៗ បើមានកុសលផលកសាង ដោយ
ក៏ត្រូវសំណាងតាមពាសនា រស់រូបជីវិតគ្រានោះណា គង់មានជកតទៅ
មុខ ៗ សង្ខារខ្ទេខ្ទួដែលបកកើត ចាប់យកកំណើតសឹងជាទុក្ខ មាន
រូបកងកាយក៏មិនសុខ តែងតែទល់ទុក្ខវេទនា ៗ ពីតូចរហូតដល់
ចាស់ស្លាប់ លំបាកឈឺចាប់ទឹងពេកា មិនដែលចៀសរួចពីជក កល់
គ្នាប្រុសស្រីទាំងក្មេងចាស់ ៗ កំណើតកើតរូបពីសង្ខារ តណ្ហាអវិជ្ជាជាន់
សង់ផ្ទះ កិលេសជកចិត្តមានះ រុះរើគ្រឿងផ្ទះកល់វេលា ៗ ផ្លាស់ប្តូររូប
កន់ឲ្យគាក្រក់ សាច់សក់ធ្មេញបាក់ក្អែកដក ឲ្យរូបកងកាយចាស់គ្រាំគ្រា
ព្រួតគ្នាចាប់ថ្វាយមច្ចុពជ ។ ឲ្យធ្វើទោសាគ្មានប្រណី ទាំងប្រុសទាំងស្រី
គន្លងអំណាច បំបាត់រូបចេញក៏ឥតខ្លាច សង្គ្រាមអង់អាចមានថ្វីដៃ ៗ

ទោះបីអ្នកមានទីអ្នកក្រ  រូបអាក្រក់ល្អស័ក្តិធំក្រៃ  មច្ចុរាជគ្មានយល់
ត្រាស់ច័យ  អាស្រ័យប្រាក់មាសជួយពុំបាន ។ ទុកជាមហាក្សត្រ
ស្តេចសោយរាជ្យ  លោកមានអំណាចត្រង់រាជស្ថាន  មានពលសេនា
ទាំងប៉ុន្មាន  ការពារគ្រប់ប្រាណគ្រៀងចម្បាំង ។ មិនអាចតតាំង
សង្គ្រាមសឹក  មច្ចុរាជពន្ធឹករទេះខ្លាំង  បាក់បបខ្ទប់ខ្ទាពជយកំទ្បាំង  កុំអួត
កតាំងមរណៈធំ ។ អំណាចដកក្រប់សង្កត់  គ្មានប្រាប់កំណត់ដូចទាលទំ
ប៉ុណ្ណោះប៉ុណ្ណោះក្មេងចាស់ទុំ  ជរាចិត្តធំឥតកោតក្រែង ។ ចាប់តាំងពី
គួបរហូតទៅ  ចាប់ហើយចង់នៅមិនដែលលែង  ដេញពួកកំទ្បាំងគ្រឿង
ភាគតែង  រត់បោលរូបឯងជាអសារ ។ កំទ្បាំងរត់បោលនៅតែចិត្ត
វិញ្ញាណជាមិត្តគិតតក់  ដោះរូបឲ្យរួចពីសង្ខារ  ព្យាធិគ្រៀវក្លាគ្មានប្រណី ។
ដេញទាំងវិញ្ញាណព្រមទាំងចិត្ត  ភ័យភិតរត់បោលទៅទីទៃ  អំណាចដក
រទ្ទេះខ្លាំងក្រៃ  គ្មានអ្វីតទល់ទប់ឲ្យបាន ។ វិញ្ញាណក៏រង់ភិតភ័យខ្លាំង
ភាន់ភាំងក្មេចគិតត្រង់រូបប្រាណ  រត់ចេញបោលនៅតែវិញ្ញាណ  មិន
បានស្ថានសុខដោយវិស័យ ។ បើមានកុសលពីអតីត  ផលតាមប្រកិត
កាលសម័យ  ដែលផុតសង្ខារជាបច្ច័យ  បានទៅកើតឰស្ថានសួគ៌ា ។
បើជាប្រព្រឹត្តកងបច្ចុប្បន្ន  អាក្រក់ពេកពន់យើងពល់គ្នា  ប្រកបកុង
បញ្ចវេរ  នឹងទៅកើតនាស្ថាននរក ។ រអ្នកសាងល្អពីអតីត  បច្ចុប្បន្ន
នេះពិតក៏ជាទុក្ខ  មិនសុខតែល្អហើយបានសុខ  គង់ផ្លាក់នរកក៏ដូចគ្នា ។

តែពោលយ៉ាងនេះនៅសង្ស័យ ហេតុអ្វីប្រឹងធ្វើបុណ្យលោកលា ឲ្យរួចពី
ទោសទុក្ខវេទនា ធ្វើអ្វីទើបជាបានសុខ ៗ កុំមានពិភាល់ធ្ងល់ក្នុងចិត្ត ដោយ
មានអតីតលោកតែងតាំង ព្រោះចិត្តវិញ្ញាណនាំគាន់តាំង កុសលយ៉ាង
ទាំងគង់ក្អាត់ជាតិ ៗ ទិដ្ឋានកាលស្តេចអសោកៈ សាងផលឥតអាក់ប្រឹង
ខ្ញីឃ្នាត លើកអដ្ឋព្រះសារីរិកធាតុ ព្រះបរមលោកនាថសាស្តាចារ្យ ៗ
កសាងចេតិយទីងអាពម ពប់តាមវិន័យទីងសិក្ខា ប្រាំបីម៉ឺនបួនពាន់
ក្នុងលោកា អស់ប្រាក់គណនាពប់មិនបាន ៗ ជាមហាសទ្ធាក្នុងកុសល
គង់វល់ក្អាត់ជាតិជាតិវប្បាន ពីព្រោះទោសៈជាប់ដោយដាន ចិត្តវាក្អាបាន
នាំតែផ្កាស ៗ កាលស្តេចផុតពូលសង្កត់ ទេវតាកំណត់បិទប្រកាស
ឲ្យផងទាំងឡាយឃើញដេរដាស់ ប្រាប់ថាព្រះបាទអសោកៈ ៗ ប្រាំពីរ
ថ្ងៃទៀតទិវង្គត មានព្រះពជរថទទួលដាក់ យកទៅស្ថានសួគ៌ប្រាកដ
ជាក់ ដល់លោកសន្និរសួឡដ៏វែង ៗ អស់ទាំងអាមាត្យគង់យោធា ទាំង
រាស្ត្រប្រជាទាំងណែនណាន់ មិនឃើញពជរថមកដាក់ស្បាន់ មិនដឹង
ជាស្តេចទៅស្ថានណា ៗ តែមានពជបុត្រពីរព្រះអង្គ ជាសង្ឃសម្រេច
អរហត្តា ហោះធ្យានតាមរកមើលបិតា ស្ថានតុសិតាក៏មិនយល់ ៗ ទៅ
មើលគេដល់ស្ថានគេ ក្រែងក្អាត់គតិនាំវិលវល់ មិនឃើញគ្រប់ស្ថានធ្ងល់
ពិភាល់ វិលមកមណ្ឌលទីស្ថានអាយ ៗ គេឃើញកើតជាសត្វតិរច្ឆាន
ពស់ថ្លាន់មែនមានធំកងកាយ កំពុងទប់ទឹកប្រឹងខ្វល់ខ្វាយ យកត្រី

ទាំងឡាយបបរិភោគ ៗ តែដោយអំណាចសាងកុសល បុត្រពីរៈទៅដល់ស្គាល់ហៅថាៈ "ម្តេចទ្រង់មកធ្វើដូច្នេះណា" បិតាដឹងខ្លួនលូនចូលជិត ៗ ឱនក្បាលដាក់លើបាទថេរៈ ទឹកនេត្រស្រស្រាក់ព្រួយក្នុងចិត្ត ដឹងខ្លួនថាភ្លាត់ជាតិមកពិត បុត្រទាល់គំនិតនឹងបិតា ៗ តែបានទូន្មានឲ្យបងចាំរក្សាសីលប្រាំជាធម្មតា ជីវិតតិរច្ឆានអត់អាហារ ប្រាំពីរទិវាសូន្យក្សិណក្ស័យ ៗ បានទៅបង្កើតស្ថានសួគ៌ា អស់យើងរាល់គ្នាកុំសង្ស័យ ពីព្រោះតែចិត្តខូចប្រែ កម្រមានអ្នកឃាត់ទាំងបាន ៗ សារដើមពីស្តេចអសោកៈ កើតធ្លាក់ភ្លាត់ជាតិជាតិរច្ឆាន ពីព្រោះហេតុចិត្តទប់មិនបាន នាំប្រាណឲ្យព្រាត់ចាកសុខា ៗ កាលស្តេចអាពាធជាទម្ងន់ ទ្រង់ចាយទ្រព្យធនសាងផលា ជាបច្ចិមកាលពេលនោះណា បុត្រាសេនីបិទព្រះឃ្លាំង ៗ មិនឲ្យចំណាយចាយទ្រព្យធន ពេកពន់នឹងអស់ពីក្នុងវាំង ព្រះទ័យទាស់ខ្វល់ប្រកាន់ខ្លាំង ទ្រង់តាំងក្នុងចិត្តនឹកគិតថា ៗ "ចាំអញបានជានឹងមើលវា អ្នកទាំងអស់គ្នាដែលឫស្យា" កំពុងតែនឹកដូច្នេះណា សង្ខាររលត់ផុតសូន្យឈឹង ៗ បានជាទៅកើតសត្វតិរច្ឆានក្របានឃាត់ចិត្តទប់ឲ្យនឹង ពិបាករក្សាប្រែទីពឹង ចិត្តនឹងសោយសុខទាំងទុក្ខា ៗ មានធម៌សំដែងពីឥន្ទ្រិយ ទាំងពីរចក្ខុនឹងសោតា ឃានៈបន្ទាប់ជាប់ជិវ្ហា កាយារហូតដល់ចិត្ត ៗ ចក្ខុសោតប្រៀបដូចសត្វពស់ គឺមោះតាប់ចិត្តទីកំបាំង កៀនកោះស្តុកស្តាញបាំងរនាំង ជ្រកជ្រៀតបៀតកាំងកំ-

ចាំងលាក់ ៗ សោតាប្រៀបដូចសត្វក្រពើ គាប់ចិត្តតែលើទីត្រជាក់ មិន
ដែលរកក្តៅជាទីស្នាក់ ជំពាក់ជាប់សាច់ឲ្យហ្មងសៅ ៗ ឃានៈប្រៀបដូច
សត្វជាប់ទ្រុង ចង្អៀតលុងក៏គន់ក្តៅ ចង់ចេញពីទ្រុងមកខាងក្រៅ ហ្មង
សៅដោយមានទ្រុងកំណយាត់ ៗ ជីវ្ហាប្រៀបដូចជាឆ្កែឆ្កួត ថែមព្រួតបង្ហើរ
ហៀរទឹកមាត់ មិនដែលឈប់ខានឬទៀនទាត់ កំណត់ហូរចេញច្រើនពេក
ពន់ ៗ កាយាប្រៀបដូចឆ្កែបបក រកច្រកទីណាក្តៅអ៊ុនៗ គ្មានគិតខ្លាចប៉ះ
ឬស៊កស៊ុន ទម្រន់រុកពនគ្មានដែលដៀម ៗ ឯចិត្តប្រៀបដូចជាសត្វស្វា
រតំសណា សំណាមិនដែលស្ងៀម ចាប់នេះបេះនោះឥតលាក់លៀម បួញ
បៀមក្រុមក្រាមគ្មានប្រាកដ ៗ ប្រមូលឥន្ទ្រិយប្រាំមួយហ្នឹង យកមួយជាតាង
មកសន្មត គ្រង់ចិត្តមិនបានទឹងតាមបទ កំណត់យកមកប្រើគ្រប់ប្រាណ ៗ
ព្រោះចិត្តនេះល្អិតច្រើនប្រការ រាប់ដោយពិស្តារមានតាមស្ថាន មួយ
ពេលថ្ងៃមួយជាប្រមាណ សន្ទើបបានប៉ែតសិបប្រាំបួន ៗ បើបង់ដឹងច្បាស់
ទំសក់ក្បា មើលអភិធម្មាខចំនួន ទឹងឃើញញែកល្អិតពេញគ្រប់ជួន
ចិត្តពួនចិត្តផ្ទុកល់រូបប្រាណ ៗ ចូរអស់មហាជនបរិស័ទ ខំហាត់
ទំប្រើចិត្តឲ្យបាន ឃាត់ទាំងកំណត់ដោយប្រមាណ ទើបបានទីស្ថានជា
សុខា ៗ តែទំបណ្តោយតាមតែចិត្ត រក់គ្មានការណ៍គិតដល់រូបា រៀបផុត
រលត់នៃសង្ខារ ដូចជាព្រះបាទអសោកៈ ៗ ពិបាកត្រង់ហៀបទឹង
រលក់ បំផុតបានស្ថានប្រាកដជាក់ ដូចមានពណ៌នាក្នុងត្រៃលក្ខណ៍

ចិត្តនាំប្រែបក្សាចេញពាក្យខ្លួន ។ ឱអស់លោក-អ្នកនេះនឹងខ្ញុំ គួរកុំប្រព្រឹត្ត ឲ្យជួនៗ គួរចោលមានះគេបរត្ពួន ព្រោះខ្លួនមិនមែនផងយើងទេ ។ អាការៈសាមសិបនឹងពីរផង មិនមែនខ្លួនហោងនៅទំនេរ កុំថាផងអញ របស់គេ ទទេគ្មានបានប្រយោជន៍អ្វី ។ ឆ្អឹងស្បែកសរសៃហទៈយៈ បែក ធ្លាក់ខ្ទាត់ខ្ចាយទៅជាដី មិនមែនផងយើងទេសព្វថ្ងៃ តែចិត្តចង្រៃស្រ-ឡាញ់ណាស់ ។ ស្រឡាញ់សាច់ស្បែកហើយទឹងសក់ រូបល្អអា-ក្រក់ទាំងក្មេងចាស់ ប្រឹងថែមិនឲ្យមានពាល់ប៉ះ សក់លាស់កាត់ចេញ ស្លវជកចោល ។ ខ្ទះយករមៀតនឹងម្សៅ លាបនូវសាច់មុខដុះស្រ-មោល ដំរើមដើងសក់កោរត្រងោល បើធាត់ក្រឡុលចង់តូចស្តើង ។ បើក្អកផងធឹតពាក់វ៉ែនតា បើបាក់ទន្តប្រឹងដូសឡើង ពេលដើរអង្គុយ ខំដំកើង ស្បែកជើងកៅស៊ូកង្រែជេក ។ ស្រឡាញ់ខ្លួនឯងចិត្តមិន អស់ ឃើញរូបប្លែកស្រស់យកមកផ្តេក កៀកកើយស្នេហាតាមចិត្ត-ត្រេក ដរមែកស្បិបូរផលជីវិត ។ ចិត្តស្រីក៏ដូចជាចិត្តប្រុស មិនខុស គ្នាទេកុំបាច់គិត បែកធ្លាយមិនបានចង់តែជិត តាមដោយគំនិតគិតលេប ប្រាណ ។ ហេតុតែមិនគិតឲ្យបានយល់ អំពល់តែខ្វល់ក្នុងសន្តាន រូបគេយើងខ្ញុំទាំងប៉ុន្មាន ជាព្រៃស្មសានស្ពានដង្កូវ ។ ដែលមាន ក្នុងរូបយើងសព្វថ្ងៃ ជាទីប្រស្រ័យស្ពានវានៅ វាដុះវានោមដាក់ដោក ដៅ វាស្លាប់កប់នៅក្នុងរូបប្រាណ ។ រូបយើងអាក្រក់ណាស់ពេកពន់

ស្រីប្រុសគ្រប់ជនទាំងប៉ុន្មាន ជាទីដង្កូវនៅជាស្ថាន អសោច៍ក្នុងប្រាណ
មានទាំងគ្រប់ ៗ រូបយើងល្អគ្រាន់តែខាងក្រៅ មិនគួរនឹងទៅសេព
សមគប់ ប្រឹងតែកដេកឧបរូបអសុភ ទាំងថ្ងៃទាំងយប់ជាប្រក្រតី ៗ
បែកមុខពីគ្នាក៏ពុំបាន កើតចិត្តប្រកាន់ស៊ើរគ្រៀណក្រយ៍ ទាក់កាប់ដណ្ដើម
កើតអប្រិយ ទាំងប្រុសទាំងស្រីពោះស្រឡាញ់ ៗ ដណ្ដើមស្រឡាញ់
រូបអសុភ ហេតុតែសេពគប់នាំឲ្យខ្ញាញ់ មិនយល់គុណរូបយ៉ាងណាមិញ
ប្រឹងចំអេម្ញញឲ្យខ្វាចផ្កា ៗ ដល់ផុតសង្ខារជីវិតចេញ ពោលរូបនោះ
មិញជាអសារ ឡប់ប្រែជាខ្មោចឥតឧបមា ពល់រូបអាត្មាមិនហ៊ានជិត ៗ
ស្អុំគេស្ដីងងឹមកកំដរ កុះករគ្នាប្រឹងមកជុំជិត ខ្មោចរូបប្ដីឯងប្រពន្ធពិត
មិនឃើញរួមតែជួបសោះនៅ ៗ កាលសោះស្អុចមិនហៅគ្នា បិទទ្វារមិន
ឲ្យអ្នកណាទៅ រួមកេស្នេហាការពារក់ប្រើ អ្នកគង់គេទៅជិតមិនបាន ៗ
ដល់ស្លាប់យំសោកជាកាល័យ រៀបរាប់សេចក្ដីធ្ងោកទាំងប្រាណ បីខែ
ទៅមុខទុក្ខសោកស្រាន្ត ចង់បានអសុភមកឧបទៀត ៗ ពោះម៉ាយ
មេម៉ាយកល់រូបប្រាណ មិនមែនអត់បានគង់តែឆ្ងៀត រករូបអសុភមកថី
ទៀត អសុភនោះទៀតមិនមែនសាច់ ៗ ប្ដូរញាតិសន្ដានខ្លួនក៏ទេ ចង់
បានតែគេមកសំរេច ស្រឡាញ់យ៉ាងនេះស៊ីប្បុរសផ្ដាច់ គ្មានគិតត្រង់ត្រប
ត្រង់ៈវេទនា ៗ មិនព្រមសុខចិត្តនៅម្នាក់ឯង ប្រុសស្រីចាស់ក្មេង
កល់តែគ្នា ឃ្លានជាងអាហារប្ដូរភោជនា គ្មានពេលវេលាជាប្រក្រតី ៗ

មិនបេះមានផ្អែតបុគ្គញទ្រាន់ គ្មានខ្មាសអៀនអន់ទាំងប្រុសស្រី ដល់ចាស់រូបផ្លាស់តែពល់ថ្ងៃ កើតទុក្ខធំក្រៃទ្រឹងដក ៗ ពីក្មេងសាច់ស្បែកម៉ដ្ឋផូរផង់ ត្របង់ដល់ចាស់ស្បែកយុរយារ ឃើញគេទៅក្មេងឡើងវេទនា ឃាត់ថាកុំឲ្យចាស់មិនបាន ៗ ធ្មេញបាក់សក់សរក្លោកធំត ត្រចៀកថ្លង់ពិតពេកកង់ប្រាណ កំឡាំងវ័យថយពន់ប្រមាណ តែចិត្តតណ្ហាបានទាំងពេកក្រៃ ៗ ឃើញរូបារម្មណ៍ស្ទះចាប់ជាប់ ចិត្តចង់ប្រញាប់ព្រួតចូលដៃ អួសទាញទៅមកតែសព្វថ្ងៃ ភ្នែកគន់រំពៃរកមើលទៀត ៗ បើបានតើបពុះព្រួះពាល់ អារម្មណ៍ខ្វាយខ្វល់ចិត្តជក់ជ្រៀត គ្មានគិតថាចាស់តណ្ហាបានទៀត ប្រឹងចៀតរកតែរបស់ថ្មី ៗ មានធម៌ព្រះពុទ្ធទ្រង់ត្រាស់ថា ឲ្យអស់ពួកមហាជនប្រុសស្រី ឲ្យខំឃាត់ចិត្តជាប្រក្រតី យូរថ្ងៃគង់បានខះមិនខាន ៗ ខំរក្សាសីលទៅតាមគេ ជាហេតុឃាត់ចិត្តទាំងប៉ុន្មាន ដូចដាំរុក្ខាគង់តែបាន ផ្លែផ្កាមិនខានព្រោះស្រោចទឹក ៗ បើខំព្យាយាមថែរក្សា រុក្ខាទំងលូតលាស់សន្ធឹក ចេញផ្លែចេញផ្កាជាពន្លឹក ស្រោចទឹកកុំខកខានថ្ងៃណា ៗ ឧបមាយដូចនៃអ្នកឃាត់ចិត្ត ខំព្យាយាមពិតដូចរុក្ខា គង់តែលូតលាស់មានផ្លែផ្កា ល្បីទូទិសាសព្វផែនដី ៗ អ្នកប្រាជ្ញពីបុរាណចារ ចារិកពុទ្ធដីកាជាបាលី អ្នកប្រាជ្ញបច្ចុប្បន្នជាន់ថ្មី ៗ ប្រែពីបាលីឲ្យដឹងច្បាស់ ៗ ឲ្យពត់ឲ្យឃាត់ចិត្តឲ្យបាន ខំប្រឹងកល់ប្រាណកុំក្រឡាស់ ព្រោះចិត្តមានតណ្ហាហានណាស់ នាំផ្តួសនាំផ្តាស

ខូចអស់ ៗ លោកឲ្យគោរពព្រះកម្មដ្ឋាន សែសិបឲ្យបានតាមបញ្ញា

ញាណចិត្តឲ្យទន់ដោយអាចារ ចរិតកិរិយាតាំងប្រាំមួយ ៗ "រាគចរិតជា

ដើមអាទិ៍ កំណត់បទបាទជាទីមួយ ច្រើនតែប្រើក្តីគំនិតព្រួយ ផ្សែង

ផ្សែយវត្តតាម ៗ ទី ២ ជាទោសចរិត គំនិតអន្ធនោះច្រើនជាន់ជាម

បន្តិចបន្តួចក៏ខឹងក្តាម លលាមលលើគ្រើគុណគេ ៗ ទី ៣ មោហចរិត

កិរិយាមិនទៅមាំមួនទេ សន្ទុះសង្ស័យច្រើនជាងគេ ប្រែប្រួលកាយខ្ជិល

ពន់ពេក ៗ ចរិតទី ៤ គឺសទ្ធា មានចិត្តជ្រះថ្លាជាអនេក បុណ្យ

អ្វីមិនទុកទៅដល់ស្អែក ចង់ឃើញទាន់ភ្នែកដាច់ស្រេច ៗ ពុទ្ធិចរិត

ជាទី ៥ រៀនសូត្រចេះចាំក៏ឆាប់គ្រាន់ មិនចង់ឲ្យគេចេះដឹងទាន់ អ្វីៗ

គេត្រូវគាត់យល់ផ្លូវចាស់ ៗ ប្រាំមួយវិតក្កចរិត ច្រើនគិតការផ្តាសឥតបន្ទោះ

ចិត្តនោះល្អិលល្អបជាងគេណាស់ ពេលយប់ចេញអស់ហុយដូចផ្សែង ៗ

ពេលថ្ងៃប្រាព្ធដល់ការងារ ពល់ពេលវេលាចាប់មិនលែង អារម្មណ៍

ស្ទុះទៅឥតគោលត្រែង អន្ទះអន្ទែងនេះដូចក្មេង" ៗ ចរិតប្រាំមួយខ្ញុំ

អធិប្បាយ មិនមែនក្លែងក្លាយប្រឌិតឡើង តែតាមសាសនាដ៏ថ្កុំថ្កើង

ព្រះពុទ្ធត្រូវយើងសំដែងមក ៗ សំដៅសេចក្តីដែលឆ្ងាយ តែខ្ញុំអធិប្បាយ

ស្រួលៗយក ទៅសល់សេចក្តីច្រើនគរគោក អញ្ជើញពួកគេមកមើលចុះ ៗ

ឯអ្នកចំរើនព្រះកម្មដ្ឋាន កុំមានគំនិតគិតគះគុះ សិញ្ញាប្រញាប់ចំរើនតែចំរុះ

ទាំងត្រូវតាំងខ្លួនស្គាល់អ្វីអាង ៗ អ្នកជាកតចរិត ឲ្យគោរពចិត្តជាដំណាង

អស់កំលាំងដប់សព្វគ្រប់យ៉ាង ឈាមចិត្តឃើញអាងធ្ងន់សេចក្តី ៗ អ្នកជាទោសចរិត ការនាំឲ្យពិតតាមបាលី មិនបានចែកញែកសព្វសេចក្តី កាត់យកបទខ្លីត្រូវការនោះ ៗ ឲ្យកៀងឲ្យដេញប្រមូលចិត្ត កុំឲ្យខ្ចាត់ភ្ញាត់ក្រែងប៉ះពារ ដល់ទៀបទីងផុតឡើយមរណា ក្រែងគន្ធះរកទប មិនបាន ៗ

## ចាស់នឹងក្មេងជជែកគ្នាពីធម៌កម្មដ្ឋាន

ចាស់សួរទៅក្មេងថា នែអ្នក ខានថាក់កម្មដ្ឋានមូលប៉ុន្មាន ព្រោះគានៅចូលស្តាប់មិនបាន កម្មដ្ឋានធម៌ពិតនោះយ៉ាងណា ៗ ខ្ញុំតា បានរៀនកម្មដ្ឋានខ្លះ ក្រែងខ្លះខុសពីធម៌អ្នកជា · គារៀនដំណពីអាចារ្យ ឧបាសកទេណាទើបនឹងបាន ៗ គារៀនកម្មដ្ឋានជាន់សម័យ ដូចចៅក្តុលឿតទ់ប្រមាណ ការនាកាលណាចូលក្នុងប្រាណ ឆាប់បានជាន់ញាក់ដូចការគ្រូ ៗ គ្រីគ្រៃញែងខ្លះរេក៌ តាមដោយលំនាំជាចង្អាក់ ញ័រជើងញ័រដៃដូចកន្ត្រាក់ ខ្លះញាក់ស្មើរតែនឹងដាច់ខ្យល់ ៗ ខ្លះស្រែកលាន់មាត់ព្រួសព៉ស ខ្លះប្រឹងអត់ណាសព្វខល់ៗ ខ្លះមិនបានញាក់នៅពិគាល់ តាកត់គ្នានសល់កាលការនោ ៗ កត់ពីញាក់ក្តែកបុឈើពោះ បុមានរមាស់ក្តៅរងា ចុកជើងចុកដៃកែពល់គា កត់គ្រប់វេលាជាសំគាល់ ៗ យកទៅជូនគ្រូបកប្រាប់ថា នេះណាជាគ្រូមិនភាន់ដល់ ដូចពានឈើពោះ ឬបេញខ្យល់ គ្រូប្រាប់ថាផាក់ថ្នាក់ឲ្យទៀត ៗ ចូរទៅប្រាប់តាកុំបាលាក់

បើដាក់ជាច្បាប់ចង្អៀត គាត់នឹងគិតមើលរៀនទៅទៀត កុំឲ្យមានស្នៀត សល់ទំនេរ ៗ ហៅក្មេងថាធម៌របស់គា ត្រង់ណា ខ្ញុំមិនបានរៀនទេ ធម៌គាថប្លែកប្លែកជាងគេ ខ្ញុំប្រាប់គាដេរខ្ញុំទេដឹង ៗ ចាស់ថាអ្នកហៅចូរប្រាប់ ចុះ ត្រូវខុសគាមិនប្រកាន់ទេ ក្រែងមានកម្មដ្ឋានខុសពីនឹង ព្រោះគាចង់ដឹងឥតមុសា ៗ ក្មេងថាកម្មដ្ឋានព្រះសម្ពុទ្ធ ចមមកុដនៃព្រះលោកជាសាស្តា មិនឃើញសំដែងដូចធម៌គា អាចារ្យបែបនេះបេះថ្មី ៗ ដូច្នេះគ្នាកុំអាលថាខុស ក្រែងលោបានប៉ះច្បាស់បាលី ពីគម្ពីរណាសល់សេចក្តីកម្មដ្ឋានបែបថ្មីល្បីសុះសាយ ៗ លោកគាដែលបានរៀនកម្មដ្ឋានចាស់ពីបុរាណចិនៅអាយ គាត់ប្រើគិតជាឆ្ងាយ ខុសត្រូវទាំងឡាយខ្ញុំមិនថា ៗ កម្មដ្ឋានរបស់ព្រះសម្ពុទ្ធ សន្មតិឲ្យម្ចាស់ដួងចេតនា ដំកល់ឲ្យនឹងដោយបញ្ញា បើដូច្នេះណាថាម្តេចបាន ៗ សមាធិគឺឲ្យដំកល់ចិត្តឲ្យមាំនៅនិត្យជិតក្នុងប្រាណ សម្រេចត្រៃយជាតិញ្ញាណ ឲ្យបានសម្រេចដោយអាល័យ ៗ ចុះបើកម្មដ្ឋានជាន់ទំនើប ដ៏ត្រើបរៀបបានញ៉ោរជើងដៃជាន់ដូចគារក្រញាក់សរសៃ កម្មដ្ឋានសម័យដូច្នេះណា ៗ ឃើញប្លែកពាក្យជាងធម៌ព្រះ ប្រមួយបានច្បាស់ព្រះពុទ្ធដីកា ព្រះអង្គបានត្រាស់សាស្តាចារ្យ ជាត្រូវទេតាមនុស្សស្រុកថ្មី ៗ ចាស់ស្តាប់ក្មេងប្រាប់ជាទំ-នង ចាស់ផ្គងក្នុងចិត្តគិតសង្ស័យ គប្បីជាទៃលោះថ្មីថ្មី ធម៌គាសព្វថ្ងៃប្លែកយ៉ាងណា ៗ ចូរប្រាប់មកតែប្លែកយ៉ាងម្តេច កុំគេចត្រឡប់ពាក្យ

មុសា ប្រាប់មកតាមត្រង់អស់សង្កា កម្មដ្ឋានផងតាជាន់សម័យ ៗ ក្មេង
សបស្បូរចាស់ទៅវិញថា លោកតាខ្ញុំនៅមានសង្ស័យ កម្មដ្ឋានតារៀនតែ
សព្វថ្ងៃ មានរបៀបអ្វីខ្លះជូនអាចារ្យ ៗ ចូរតាកុំលាក់ប្រាប់ឲ្យត្រង់ តាចង់
ឲ្យខ្ញុំប្រាប់ធម៌តា ដែលប្លែកពីធម៌ព្រះសាស្ដា រណ្ដាប់ធម៌តានោះតើអ្វី ៗ
ចាស់ថាធម៌តាបើរៀនចប់ ត្រប់សព្វគ្រូប្រាប់ឲ្យថ្វាយត្រៃ ត្រប់សិស្ស
ម្នាក់ៗមានបច្ច័យ អមត្រៃប្រាំរៀលតែកល់គ្នា ៗ មានសិស្សប្រុសកន្ទង
លោកសង្ឃ ប្រុសស្រីផ្គួងរៀបម្ហា បំរុងចាំដល់ពេលវេលា ខានគ្នា
ចំនួនដល់ដាច់រយ ៗ កូនម្នាក់ចេញប្រាក់ប្រាំរៀលដាក់ បើអ្នកទាល់ក្រ
ឲ្យចេញក្រោយ លើកត្រៃបំពេញធម៌នោះឲ្យ ប្រាក់នេះឯងហើយជូនអា-
ចារ្យ ៗ ក្មេងស្ដាប់ពាក្យចាស់ប្រាប់សេចក្ដី ធម៌អ្វីជួរឈ្មោះណា លោកតា
ពោលពាក្យកើងនេះគួរមុសា ត្រូកម្មដ្ឋានណាប្រាប់តាឯង ៗ ចាស់ថា
នែះចៅតាពិតត្រង់ តាមិនចង់កួតករពាក្យស្ទួង តាមិនបង្ខិចគ្រូចងឯង
គឺពិតជាក់ស្ដែងបានតាថា ៗ ចៅអើយកិច្ចម្យ៉ាងសេចចង្អៀត អាចារ្យមាន
ស្មៀតយកបុត្រា ជាកូនផងខ្លួននៅកុមារ ចងដៃបុត្រានោះថែមទៀត ៗ
ជូនដល់ម្ដេសាមសិបរៀល សិស្សណាដែលទាល់ខំប្រឹងធ្វៀត ចងការ
បញ្ចាំទ្រព្យនឹងញាតិ គិតតាតឲ្យបានដូចនឹងគេ ៗ ក្រែងមិនបានពេញ
ធម៌កម្មដ្ឋាន បើខុសខកខាននៅទទេ ប្រឹងគិតប្រឹងកែខំរិះរេ ឲ្យបានដូច
គេស៊ូជំពាក់ ៗ ក្មេងថាកម្មដ្ឋានរបស់តា អស្ចារ្យមានលាភប្រាកដជាក់

ប្រសិនបានសិស្សច្រើនពាន់នាក់ បានប្រាក់ច្រើនក្រៃដូចគាថា ៗ ខ្ញុំបាទ ចង់រៀនទឹងគាថង បំណងឃើញបានលាភសក្ការ បើមិនបានចេះដល់ អាចារ្យ ប្រាថ្នាឲ្យបានដឹងដូចគេ ៗ ឯធម៌កម្មដ្ឋានចំណែកខ្ញុំ គាត់សង្ស័យ គ្មានលាភទេ មានគ្នាច្រើននាក់ខ្ញុំទឹងគេ រៀនតែទទេច្រើនបែបណាស់ ៗ ចាស់ឆ្លើយថាបើចៅចង់រៀន កុំអៀនមួយយប់បានហើយ ទោះទាំងប្រុស ស្រីក្មេងទឹងចាស់ ឆាប់ណាស់នែចៅដូចគាថា ៗ តែភាចង់ដឹងកម្មដ្ឋាន ចៅ សំដៅយកថ្នាក់មូលគ្រឹះណា ដែលចៅថាមានច្រើនប្រការ អធិ-ប្បាយពិស្តារបាកុំលាក់ ៗ ក្មេងថាកម្មដ្ឋានព្រះសាស្តា ទ្រង់ប្រោសមេត្តា អស់សាវក ឲ្យចំរើនទៅបានតាមថ្នាក់ ខ្លះអស់កិលេសៈបានបោះធ្យាន ៗ មិនត្រូវមិនឃើញឲ្យថ្វាយក្រៃ ឲ្យដាក់ប្រាក់អ្វីមិនឃើញមាន គម្ពីរសាស្ត្រា ជាប្រធាន អ្នកប្រាជ្ញលោកអានជាសេចក្តី ៗ ចារិកទុកមកថាដូច្នេះ យើង គេបានចេះជាប្រក្រតី បើគួរចោទខ្លះតែស្រង់ ម្តេចគ្មានសង្ស័យទៅទាំង ស្រាង ៗ កម្មដ្ឋានរបស់ព្រះសម្ពុទ្ធ ជាធំបំផុតលើចតុរ្គ មានថ្នាក់តាម ស្ថានបាត់ជាអង្គ ដូចក្នុងគម្ពីរវិសុទ្ធិមគ្គ ៗ អ្នកប្រាជ្ញអាចធ្វើគម្ពីរនោះ នាមឈ្មោះព្រះពុទ្ធឃោសៈ លោកស្រង់ពីពុទ្ធវចនៈ រៀបរៀងតាមថ្នាក់ បនិទ្ទេស ៗ វគ្គដើមសំដែងអំពីសីល ជម្រះស៊ីលដោយវិសេស ពត់ កាយវាចាតាមច្បាប់នេះ បានហើយសិមរិះរៀនតទៅ ៗ សមាធិនិទ្ទេស ជាទី ២ សំដែងវិធីទុកជាធ្នូរ ពកល់ចិត្តខ្លួនឲ្យទឹងនៅ កុំឲ្យត្រាច់ទៅ

តាមអារម្មណ៍ ៗ នេះហើយសំដែងពីកម្មដ្ឋាន អញ្ជើញអានមើលទៅ
ទើបឃើញចំ កុំគិតតែជឿៗ សម្ដី ទោះសមមិនសមគឺជឿស្លុង ៗ
ខ្វះអានទៀតអានថាចេះមូល បណ្ដូលកម្មដ្ឋានធម៌ផ្ទេកន សុទ្ធខ្ទមគ្មាន
ស្រាយដូចខ្ទមជ្ជន ម្ដេចៗក៏ប្រែងនុកក្នុងកាយ ៗ ឯត្រង់អង្គប្រាំរបស់
ឈាន វិសុទ្ធិមគ្គមានអធិប្បាយ វិតក្កវិចារៈទាំងឡាយ បីតិវិការយប្អូន
សុខា ៗ ប្រាំឯកគ្គតាចិត្ត មិនបានផ្ដេកផ្ដួតទៅខាងណា ប៉ុណ្ណោះ
លោកហៅអង្គឈាន នា គម្ពីរពិស្ដារទៅទៀតហោង ៗ រីឯបីតិម្អូលផ្អែក
ចិត្ត បណ្ឌិតលោកចាត់ជាប្រាំកង សំដែងសះជាតាមទំនង ប្រាជ្ញផង
ប្រែមកពីបាលី ៗ ខុទ្ទកាបីតិជាទី ១ ជម្រុយជាព្រឺអស់សរីរ៍ ព្រឺភេម
ព្រឺស្បែកល្ហួតកេសី ប្រក្រតីស្របកាលភាវនា ៗ ខណិកាបីតិជាទី ២
ក្នុងចក្ខុន្ទ្រិយប្រាកដជា ដូចផ្លេកបន្ទោរមកប៉ះពារ កុំឲ្យរញ្ញោភឲ្យកំណត់ ៗ
ឱក្កន្តិកាបីតិជាទី ៣ សេចក្ដីត្រេកអរជាក់ប្រាកដ អាការដូចទឹកហូរសង្កត់
បែបបក់លេកបោកមកប៉ះ ៗ ឧព្វេង្គាបីតិជាទី ៤ ត្រេកអរផ្ដុនៗពន់
ពេកណាស់ អាចញ៉ាំងកាយាឲ្យស្រឡះ អណ្ដែតឡើងច្បាស់ពីអា-
សនា ៗ ផរណាបីតិជាទី ៥ ចំណាំឲ្យឃើញជាអស្ចារ្យ ធ្វើឲ្យត្រជាក់ក្នុង
អាត្មា ជ្រួតជ្រាបកាយាសព្វសព៌ាង្គ ៗ នេះមូលកម្មដ្ឋានព្រះសាស្ដា
គ្មានអ្នកឯណាចេះលើសជាង ទ្រង់ប្រោសសំដែងជាបែបយ៉ាង ឧបចារៈ
អានតែប៉ុណ្ណោះ ៗ កើតដោយអំណាចនៃភាវនា ឲ្យឃើញជាក់ជាយ៉ាង

ដូច្នេះ តាមដោយបីតិទាំង ៥ នេះ ប៉ុណ្ណោះទេតើចូរសិក្សា ៗ ឈាន ៤ ឈាន ៥ តាមចិត្តស្ម័គ្រ សិដែងគ្មានលាក់ក្នុងសាស្ត្រ អធិប្បាយវែងឆ្ងាយជាពិស្តារ ព្រះពុទ្ធឃោសាធ្វើទុកឲ្យ ៗ បើរៀនចេះហើយត្រូវតែស្ទាត់ វសី ៥ ប្រាកដជាខាងក្រោយ វិធីៈចេញចូលកុំបណ្តោយ បានឈានមិនធ្លាយឲ្យជំនាញ ៗ អាវជ្ជនវសីទី ១ ពេលក៏ឡើងបំណាន់ស្ទាត់ស្រាវជាញ ដកចិត្តឲ្យផុតចាកបណ្ដាញ កុំឲ្យស្អុតស្អាញនឹងកិលេស ៗ សមាបជ្ជនវសីទី ២ គឺស្ទាត់វិធីចូលឈាននេះ ប្រសប់ជំនាញដូចអ្នកចេះ ស្ទាត់បរិច្ចេះចូលក្នុងគ្រង ៗ អធិដ្ឋានវសីជាទី ៣ កត្តីកក្សាចិត្តខាងក្នុង ដែលចូលឈានហើយក៏ឲ្យប្រុង បំរុងគ្រប់គ្រងឈាននោះទៅ ៗ វុដ្ឋានវសីជាទី ៤ គឺខ្វួនជំនាញស្ទាត់ក្នុងផ្លូវ ចេញចាកឈានមកនៅខាងក្រៅ សំដៅយកចិត្តនឹងចេតនា ៗ បច្ចវេក្ខណវសីទី ៥ គឺចាំចេះស្ទាត់ទៅក្នុងការជំនាញខាងផ្លូវពិចារណា ធម៌ដែលសិក្សាឥតៈទិសចាល់ ៗ កុលបុត្រអ្នករៀនព្រះកម្មដ្ឋាន ល្ហុតបានវល់ឈានកុំពីគាល់ ឲ្យស្ទាត់វសីជាសំគាល់ ឲ្យស្គាល់ចូលចេញយើងចាំចេះ ៗ កើតដោយអំណាចសមាធិ បីតិទាំង ៥ យ៉ាងដូច្នេះ វសី ៥ នឹងអង្គឈាន ៥ នេះ ដូច្នេះទេតើណាលោកតា ៗ ចុះបើកម្មដ្ឋានប្លែកទីទៃ ខុសនឹងសេចក្ដីព្រះពុទ្ធដីកា ខ្វះជាន់ខ្វះញាក់ស្រែកឡូឡា ក្បួនថាមានឆ្គួតជាប្រក្រតី ៗ ចាស់ថាតាក្បួនពាក្យទៅឯង ចេះថែងការសេក្ដូសក្តូសេចក្ដី កម្មដ្ឋានរបស់ព្រះជិនស្រី សេចក្ដីត្រូវណាស់ណា

ចៅតា ៗ ចៅអើយចៅកុំមានសង្ស័យ សព្វថ្ងៃពិតណាស់ សង្ឃចៅថា ម្ដេច
ចៅចង់រៀនកម្មដ្ឋានតា មិនកើតទេណាខូចស្មារតី ៗ ក្រែងថាលោកតាកំ-
ណាញ់ធម៌ ត្រង់ល្អតាលាក់ទុកធ្វើអ្វី តែកូរៀនផងធម៌ពុល្បី កុំភ័យខ្ញុំ
មិនដែនមុខតា ៗ ចាស់ថាតាមិនគិតដូច្នោះ ធម៌ខុសពីធម៌ព្រះសាស្ដា
តាមិនឲ្យចៅរៀនទេណា ចៅចូរស្ដាប់តាប្រាប់សេចក្ដី ៗ ឧបាសកទឹង
សង្ស័យក៏ខូចក្រិត្យ វិបត្តិចរិតដាច់ៗ វង្វេងសតិគ្មានដឹងអ្វី រកគ្រូសព្វថ្ងៃ
មកមើលឆ្លត ៗ ខ្លួនក្រចង់បេះធម៌កម្មដ្ឋាន ខូចប្រាណហើយក្រថែម
ព្រួតៗ ប្រាក់បង់ថ្លៃខ្លួនពន្លឺគ្រូ ខ្លួនឆ្លតអស់ប្រាក់ខូចទាំងស្រែ ៗ
តាប្រាប់ចៅឯងដោយពិតត្រង់ ព្រោះចង់ដឹងច្បាស់ឃើញឪម៉ែ ដែល
ស្លាប់កន្លងទៅយូរខែ បានតែខំរៀនធម៌កម្មដ្ឋាន ៗ ដល់រៀនគ្រូប្រាប់
ឲ្យថ្វាយតែ អរក្រពគ្រូប្រាប់ថាបាន ម៉ែឪដែលស្លាប់ទាំងប៉ុន្មាន មិន
ដែលបានឃើញផលមួយទេ ៗ តែគ្រូថាចប់ក៏ជឿជាក់ ប្រឹងលាក់មិន
ហ៊ានប្រាប់អស់គេ តែគ្មានបានអ្វីខ្លួនទទេ ខូចប្រាក់អស់ស្រែចេញ
ថ្លៃត្រែ ៗ ឧះឧព្ធទោណា ចៅអើយ ម្ដេចឡើយក៏ដោតពន់ពេកក្រែ
អ្នកស្លាប់ទៅមុនតែសព្វថ្ងៃ មិនដែលសម័យទៅស្ថានណា ៗ កាល
យើងមកកើតក៏មិនដឹង ចំណោរ៉ៈបរិធចាកសង្ខារ មកពីនរកឬទេវតា
ប្រាជ្ញាញោយញាណទើបជ្រាបដល់ ៗ បើបានដឹងមែនដោយខ្លួនឯង

ប្រាកដជាក់ស្តែងត្រឹមកម្មផល កុំជឿអ្នកណាថាទៅដល់ ឃើញស្ថានមណ្ឌលនៃដូនតា ។ កាលអង្គសម្តេចព្រះទ្រង់ញាណ ហានចូលទិញានផុតសង្ខារ មានព្រះអនុរុទ្ធឈ្លាសអស្ចារ្យ ញានកេសាស្តាក៏មិនយល់ ។ លោកបានរំលត់ផុតកិលេស គ្មានសល់ជង់ដែរក្នុងកាយពល ចូលឈានតាមកេសព្វមណ្ឌល មិនឃើញទេសពលសាស្តាចារ្យ ។ ឯត្រង់អ្នកនៅសេក្ខបុគ្គល វិលវល់រមៃតែដោយតណ្ហា ម្តេចអ្នកថាឃើញខ្មោចដូនតា ឃើញមែនដូចថាក៏មិនដឹង ។ តាតាំងអនុរុទ្ធយកមកដាក់ ឲ្យជាក់ទៅឃើញជាដំណឹង កុំជឿប្រកាន់រឹងរឹង ធម៌ហ្នឹងនាំឲ្យខូចបញ្ញា ។ ក្មេងថាលោកតាវរឹកហើយ ម្តេចឡើយកុហកខ្ញុំទៀតណា ខ្ញុំឮអ្នកផងគេពោលថា កម្មដ្ឋានផងតាឃើញគ្មានសល់ ។ ឃើញម៉ែឃើញឪដឹងដូនតា កាលណាតានោះបានទៅដល់ ស្តាប់យូរអង្វែងគង់បានយល់ ខ្ញុំឆ្ងល់ពាក្យតាថាដូច្នេះ ។ តាសឆ្លើយថាអើអ្នកចៅក្មេង ចៅឯងស្តាប់តាបានរៀនចេះ តាប្រាប់ឲ្យដឹងរឿងទាំងនេះ គ្មានដែរឃើញទេចៅកុំឆ្ងល់ ។ ធម៌ល្បែបនេះតាចេះគ្រប់ កុំភប់កើតព្រួយខូចកំណាល់ ចិត្តគិត៖បាយតាមកិច្ចកល ថាបានទៅដល់ស្ថានដូនតា ។ ខ្លះអ្នកថាឃើញអស់ម៉ែឪ ស្តាប់ទៅអង្វែងឆ្ងាំអស្ចារ្យ ថាខ្លួនគាត់បានស្ថានសុខា ឬថាបានស្ថាននៅទុក្ខ ។ ខ្លះថាឃើញមែនគ្មានចំឡោះ តែទ័លអធិប្បាយគ្មាន

ទីតាំង ឲ្យអស់កូនចៅដែលទុកខ្ទាំង ឃើញគាងបានមកពីដូនតា ។ បើ
ឃើញមិនប្រាប់គាត់ឲ្យគិត អាណិតកូនចៅដែលសោកា អាឡោះអាល័យ
ពេកណាស់សា ទោះកើតស្មានណាគួរអាណិត ។ ឲ្យឃើញបានម្តង
សោះអាល័យ ចង្រៃដូនតាគាត់មិនស្បិត យើងប្រឹងយំសោកខ្លោចផ្សា
ចិត្ត គាត់មិនអាណិតយើងតិចសោះ ។ ឲ្យឃើញតែគេមិនមែនញាតិ
ខំឃ្មាតឯងប្រឹងគ្មានចន្លោះ ធ្វើបុណ្យធ្វើទានដូនតាំងអស់ ឲ្យលោក
រំដោះពាក់ទុក្ខា ។ រដូវភ្ជុំបិណ្ឌភ្ជុំគាសែន សំណែនសំណល់នៅត្រៀប
ត្រា អន្សមនំគមបេកណាំ ក៏ ជូនលោកពិសាតាមចំណង់ ។ ទាំងព្រឹក
ទាំងល្ងាចផាប្រកែត ចំណីផ្កាសម្ហូបចំផិតផ្ទង់ សំពះលុតក្រាបខ្ទនអស់
អង្គ ចិត្តចង់ឲ្យច្បាស់បានឃើញម្តង ។ ប៉ុណ្ណោះក្រែងមិនដល់ដូនតា
ទក្ខិណា នុប្បទានធ្វើជូនផង ថ្វាយសង្ឃគ្រប់អង្គគ្មានខ្វះហោង បំណាង
បាញ់ត្រង់ទៅដូនតា ។ បំណាច់ខំធ្វើយ៉ាងខំឃ្មាត ឲ្យគេឥតញាតិពូជ
ពង្សា ឃើញរូបឃើញរាងទាំងកាយា គេប្រាប់ច្រើនគ្រាថាឃើញ
ច្បាស់ ។ យើងគួរតែជឿប្រាកដជាក់ អស់អ្នកវៃឆ្លាតប្រាជ្ញឈ្លៀវឆ្លាស់
អ្នកក្រៅដទៃឃើញពិតណាស់ គេរិលក្រឡាស់ប្រាប់កូនចៅ ។ ម៉ែឪ
ដូនតាយើងពេញខ្លួន គេគ្មានជាប់ពូជជាញាតិផៅ ឲ្យគេឃើញច្បាស់
ជាងកូនចៅ ព្រោះតែល្ងង់ខ្លៅមិនចេះក្បួន ។ បានជាមិនបានឃើញ
ដូចគេ ម៉ែឪវេះវង្វាចអៀនខ្លួន ទឹងកូនចៅឯងគេចវេះពួន ស្លូបឆ្ងាញ់

ខ្ញុំខអ្នកដទៃ ៗ ខ្លះថាម៉ែឪរបស់គេ គ្មានគេបេះគិតឈ្លាសកសៃ
មិនឲ្យអ្នកផងឃើញឡើយនៃ កប់ទុកក្នុងដីក្រោកមកបាន ៗ គេរៀប
សំណែនជូនពីសា ជូនតាគោក្តាគស់ពីបាន អន្សមទំតមតាំងប៉ុន្មាន
យកគ្នានរស់ទាន ១ ទុកទៅ ៗ ញាតិសាលោហិតឃើញគ្រប់គ្នា
គាត់លាក្នុងចេញទៅ វិលវិនទីស្ថានដែលធ្លាប់នៅ ក្រៅពីញាតិ
ផៅមិនឃើញទេ ៗ ចុះម៉ែបុះឪជូនតាឯង ធ្វើឲ្យចំបែងមិនដូចគេ
ឯងទំព្រឹងសែនខ្វាចគាត់ដេរ ឡប់ជាទទេមិនឃើញសោះ ៗ មួយដែល
សែនសល់នៅពេញបាន ទំនែកប៉ុន្មាននៅតាំងអស់ ហេតុតែជូនតា
មិនសប្បាយ របស់បានសត្វស៊ីទទេ ៗ ម៉ែឪមិនយកក៏ហើយទៅ ដំរូវ
សុំឃើញម៉ែឪគេ ម្តេចក៏សួឲ្យសុំង៉ូម៉េះទេ កោតតែក្មេកគេធ្វើមុតវៃ ៗ
ជូនកាលគេមិនស្គាល់យាយតា យើងទាំងអស់គ្នានោះឡើយនៃ គេបេះ
តាយត្រូវទាំងក្នុងដី ខ្មោចកប់បាស់ពីស្គាល់គ្មានរបស់ ៗ យាយតា
ទំនុកតាល្អគណា យើងទាំងអស់គ្នាជួនមិនដល់ គេប្រាប់ត្រូវណាស់
ត្រូវតែឆ្ងល់ ចៅតាមិនយល់ចំណោះថ្មី ៗ ដូចខ្លះបេះធ្វើមើលកំណប់
ដែលកប់បាសប្រាក់នៅក្នុងដី បេះវាក់បេះទាញមានសត្វថ្លៃ យើង
វិតទិញ្ញាល្អគ្មានទំនេរ ៗ អ្នកព្រើបរើលបង់មានខ្ទាប់ គ្រឡប់វិលទៅ
ជាខ្ញុំគេ ព្រោះគ្មានគំនិតគំហើរ ខ្ញុំប្រាក់មាសគេដាក់កំណប់ ៗ

(នៅមានត)

# លោភការពេប្យាក្យគ្រាញ

(តចក)

បទព្រហ្មគីតថ្ងៃ ចរចៅចែងគាំទ្រង ពោធិសត្វបក្សសប្បក ទូអ្នក ប្រាជ្ញទាំងប៉ុន្នុះ ៗ ឡើងទៅគាល់ក្សត្រា សព្វទិវាដើរឡើងចុះ អាចារ្យ ទាំងបីនោះ ប្រឹងខ្លាចខុសទង់ក្សត្រា ៗ ពុំអាចទឹងស្រដី ការស្ញៀវ បើព្រះ មហា បុរសរ័តន៍ចរចា ទើបស្រដីឆ្លរនោះនៃ ៗ បើពោធិសត្វ សម្ង សាត់ដែនទូទាំងថ្ងៃ ពេងរម្យកាលនោះនៃ ចាប់ទោសអ្នកពុំបាន ឡើយ ៗ គាប់កាលជួនមួយថ្ងៃ ស្តេចគង់ឮថ្ងៃពេងហើយ កំសាន្ត ព្រះទ័យហើយ ទុក្ខទោសផងទាំងបម្លាយ ៗ មន្ត្រីគង់គាល់ជុំ ថ្ងៃពេង ធំពលនិកាយ អាមាត្យផងទាំងឡាយ សឹងឡើងគាល់ក្សត្រជេស្ឋជ័យ ៗ អាចារ្យទាំងបួនទៅ គង់គាល់ហៀបដូចសព្វថ្ងៃ ស្តេចបន្ទូលថាហៃ អា-ចារ្យអើយចូរចរចា ៗ ម្តេចឡើយស្ងៀមមមឹង ដូចគេខឹងពីកាលណា ស្រដីពាក្យអ៊ីជា មង្គលមួយគ្រាន់អញស្តាប់ ៗ ពោធិសត្វគិតថា អញនេះណាស្រដីគាប់ តាមធម៌ច្បាប់ទំលាប់ ស្តេចនាំពាក្យថាខុសវិញ បើអញពុំចរចា ទូលក្សត្រាពីមុនមិញ យល់ខុសព្រោះគួរអញ ស្រដី នោះគាប់គួរជា ៗ គិតព្រោះទើបអ្នកទូល ក្សត្រឥស្សរលើសសោ ព្រះ សម្មតិទេពជា ម្ចាស់ឥស្សរច្រើនសួស្តីសល់ ៗ ឯអាចារ្យទាំងបី ទ្រង់

ស្រដីពិតពុំយល់ ខ្លាចខ្លួនខុសរវល់ ថាលោកមិត្រឆ្លើយដូច្នោះ(១) ៗ ទោះខុសទោះគាប់ក្តី យើងស្រដីតាមលោកស្មោះ ទោះលោកខុសលោកដោះ ទោះលោកគាប់យើងគាប់ផង ៗ គិតដូច្នោះស្រេចហើយ ពុំលង់ឡើយដោះសាសង ទូលព្រមគ្នាជាម្តង ថាព្រះសម្មតិទេព ៗ ស្តេចស្តាប់សព្វដូច្នោះ អ្នកប្រាជ្ញនោះឆ្លើយសង្ខេប ថាសម្មតិទេព ដែលៗដូចគ្នាជាម្តង ៗ ស្តេចស្តាប់សព្វដូច្នោះហើយ ពុំលង់ឡើយបន្ទូលស្នង អស់ទាំងអាចារ្យផង ឆ្លើយដូចម្តេចព្រមៗ គ្នា ៗ អាចារ្យទាំងបីទូល ក្សត្រឥស្សូរលើសរសោ បពិត្រហេតុទេក និម្មិតឲ្យក្សត្រឥស្សូរ ៗ ជាម្ចាស់លើបើងខ្ញុំ មកជួបជុំចូលមិត្រមូល ក្រសួងផងសឹងចុះចូល ទោះខុសស្តេចផ្ចុះទោសបាន ៗ ស្តេចជាតិជាកំពូល ជាឥស្សូរក្រស្តសព្វស្ថានទៀងទើបព្រះអង្គបាន ជាសម្មតិទេពនោះ ៗ ស្តេចស្តាប់ហើយក្សត្រថ្លៃត្រាស់ថាហៃធនញ្ជ័យនោះ ថាម្តេចថាឲ្យស្មោះ អញនឹងដឹងប្រាជ្ញា ៗ ពោធិសត្វក្រាបទូល ក្សត្រឥស្សូរលើសរសោ ឯខ្ញុំក្រាបទូលថា ព្រះសម្មតិទេពនោះ ៗ ត្រូវលើព្រះអង្គឯង ពុំថាលេងជាក់ចំពោះ ខ្ញុំទូលព្រះអង្គនោះ ជាឧបមាថ្វាយក្សត្រា ៗ ព្រះបើកបន្ទូលទេស-នាពិសេសជាគាថា ថាមាននគរ មានស្តេចមួយសោយរាជ្យត្រង ៗ ហើយមានឯកឧបរាជ មានទាំងរាជសេនាផង អ្នកប្រសើរមួយហោង

---

១ លោកថាមត់ឆ្លើយដូច្នោះ (?) ។

មានរាជទូតឯកអគ្គ ៗ មានអ្នកទាំង ៤ ចាំ ដោយផ្លូវ ៥ មានមហា
អាមាត្យ ៥០ ជា ជំនែកលែងអ្នកដទៃ ៗ មានអ្នកប្រាជ្ញ ២៥ តែង
ទឹងឃុំទោសសព្វថ្ងៃ មានបុរសកាចក្រៃ ទាំង ១៤ នាក់នោះណា ៗ
មានទាំងអ្នកឡេះឡោះ ៧ នោះបិត្តបុស្សា អាមាត្យ ៦ ណា អ្នក
បម្រើស្តេចនោះនៃ ៗ អាមាត្យបិត្តបុស្សា មានកាលវាប្រែវិលវៃ
ចូលអ្នកប្រាជ្ញនោះនៃ ហើយវាប្រែចូលមនុស្សកាច ៗ រីឯអ្នក
ឡេះឡោះ ៧ នោះកុលឯរាជ- បណ្ឌិតតែងគិតកាច ហើយចូល
បុរសកាចផង ៗ ឯស្តេចសោតសឹងខ្លាច បុរសកាចនោះឯងហោង
ខ្លាចទាំងអ្នកប្រាជ្ញផង តាមតែវាធ្វើទោសា ៗ វាជាន់លើព្រះកេស
ថ្ងៃវិសេសទង់ហត្ថា ហើយកើបទាញបុាទា ដូចខ្ញុំវាវិស័យហោង ៗ
ពោធិសត្វទូលហើយ ពុំលង់ឡើយសើចសាសង ស្នានជាក្សត្រប្បាស
ប្បង ស្តេចផ្តួតផ្តាបអាថិប្រស្នា ៗ

បទពំនោលកាលក្សត្រា ស្តេចស្តាប់វាថា ក៏ក្រេវក្រោធក្រៃកន្លង ៗ
ថាធនញ្ជ័យចៅទ្រើសឃ្នង់ ស្រដីលេងលង ព្រះស្នងជារាជបណ្ឌិត ៗ
ជាន់លើក្បាលស្តេចពិត ៗ ហើយព្រះស្នងគិត ទឹងជាន់ព្រះកេសអញ-
វិញ ៗ អញមានទោសអ្វីទឹងមឹង ឲ្យអាក់ចិត្តខឹង ក៏មឹងចិត្តធំដល់ម៉្លេះ ៗ
មឹងអាងមឹងមានបំណោះ មឹងតើមឹងបេះ បំណោះមឹងតើប៉ុន្មាន ៗ
ពោធិសត្វឆ្លើយរំដែងថ្កាន បពិត្រសូមទាន អញខ្ញុំក្រាបទូលក្សត្រា ៗ

និទានជាអាថ៌ឧបមា ខ្ញុំពុំប្រាថ្នា ទឹងជាន់ព្រះកេសក្សត្រថ្លៃ ។ ស្ដេច
ស្ដាប់រឹងក្រេវក្រោធក្រៃ ថាអញសព្វថ្ងៃ ដឹងចិត្តព្រះស្នែងហើយណា ។
ព្រះស្នែងមានគុណមហិមា មួយសែនគ្គណា គឺមោះមឹងចិត្តធំក្រៃ ។
ប្រយោជន៍អ្វីទៅធនញ្ជ័យ រឹងថ្កឹងពេកក្រៃ មើលងាយចង់ជាន់សិរសា ។
អញជាម្ចាស់វានេះណា វាមានប្រាថ្នា វាកៀសវាជេរអញវិញ ។
តពីដើមអញស្រឡាញ់ ឥឡូវប្រែចេញ ទៅជាសត្រូវព្រងើយ ។
ពោធិសត្វស្ដាប់ដូច្នោះហើយ ពិតពុំលង់ឡើយ អ្នកសូត្រជាបទគាថា ។
គោសពិសុគណា គុណោធិស្វា វាសវាជិត្តិយោ ។
វិចារិចព្ភា បសលោគោ លេញ្ញូជំឧត្ដិតិ ។ ទុះទ
មនុស្សក្នុងលោកិយ រីអ្នកផងក្តី គុណមានហើយទោសមានផង ។
លោករៀបចំគុណជាមួង លោកយកទោសចង ចងពុំយង់យល់ជាក់
ច្បាស់ ។ ព្រះធម៌ព្រះពុទ្ធស្ដេចត្រាស់ ថាអ្នកមួយពាស់ ស្រដី
ពាក្យខុសតាប់ក្ដី ។ លោកវៀរពាក្យខុសអប្រិយ យកតែសេចក្ដី
ពាក្យត្រូវនោះទុកជាច្បាប់ ។ លោកវៀរទោសខុសពុំគាប់ យកគុណ
គំនាប់ មកទុកជាច្បាប់ថាត្រូវ ។ ដូចពពាងស្រុះស្រូវ គោជសា·
បើក្ខូវ ជញ្ជាប់យកគ្រីរចោលត្រាច់ ។ ចោលសំបកបង់ឥតសព្ទ
សោកស៊ីងជញ្ជាប់ តែគ្រីរហើយបរិភោគ ។ រីលោកទាំងឡាយ
ក៏ដឹងថា មានគុណសហស្ស តែបើទោស ១ ចូលទៅ ។ លោយ

គុណបាត់ពុំនៅ ហេតុជាអ្នកខ្លៅ ពុំដឹងជាគុណឡើយណា ។ រីអ្នកប្រាជ្ញលោកពុំថា ដូច្នោះឡើយណា ទោះមានទោសមួយពាន់ក្តី ។ បើគុណមួយចូលទៅខ្ទី. បំបាត់សេចក្តី ទោសទុក្ខទាំងពួងទីទេស ។ បីដូចកំណើតការកេស រំពេកពិសេស មានដើមស្អុកសឹងបន្ទា ។ លោកអាស្រ័យយកតែផ្កា ពិដោរផ្សំផា គ្រឿងគ្រប់ប្រដាប់សិរសី ។ អ្នកប្រាជ្ញស្នេហ៍ប្រយោជន៍ក្តី ឲ្យសត្វលោកក្តី ឲ្យមិត្តសំឡាញ់ស្នេហា ។ ស្នែងឲ្យអ្នកប្រាជ្ញផងគ្នា ឲ្យមហាក្សត្រា ហើយឲ្យអស់មហាជនផងៈ ។ អ្នកទាំងអម្បាលនេះហោង ក្រយល់គុណស្នង សងគុណនៃអ្នកប្រាជ្ញឡើយ ។ រីអ្នកប្រាជ្ញនោះឯងហើយ ជាថ្នាំសះស្បើយ ដំកាត់ជម្ងឺសះជា ។ ឯអ្នកទីរគុណនោះណា យកតែទោសា ចះឱអសារឥតត្រើយ ។ មានគុណទឹងអ្នកកាចហើយ គុណៈនោះឥតត្រើយ រលត់រលាយទៅខ្ទី ។ រីឯសេនាបតី ស្តាប់ព្រះពោធិ-សត្វគិតអាណិតអនិច្ចា ។ ក៏សើចក៏លេងក៏ថា ហៃធនញ្ជ័យជា អ្នកប្រាជ្ញម្តេចឡើយឥឡូវ ។ ចៅថាចៅខ្លាកទោសទៅ ចោលបង់សៀតនៅឥឡូវះចៅមានទោសអ្វី ។ ពោធិសត្វឆ្លើយរំងខ្ទី សេនាបតី ធម្មតាអស់មនុស្សទាំងឡាយ ។ ពុំដែលទឹងវៀរទ័ងណាយ ឲ្យរួចចេញឆ្ងាយអំពីគុណទោសនោះណា ។ ដូចដើមឈូកឈរសោខា នៅកង់គង្គាត្រជាក់ស្រណុកសប្បាយ ។ ទងដើមបន្ទាវៀងកាយ គួរអ៊ុអកអាយ

ទើបមានបន្ទាដូច្នោះ ៗ មួយទីព្រះស្តេចមើលមោះ លោកធ្វើគុណស្នោះ
ទើបអ្នកសប្បុរសនោះណា ៗ គិតតួចប៉ុនចុងកេសា គុណនោះសឹងគង់
ស្ថិតដូចថ្នាក់ថ្កូនិត្យនៅ ៗ រីធ្វើគុណទើបអ្នកខ្លៅ អនុពាលកំឡៅ ប៉ុន្មានៗ
សឹងបាត់ ៗ បីដូចគេគូសកាប់កាត់ ចូលជិតរឹងថ្ងាត់ ចូលបិតៗ ថេរ
រឹងហោង ៗ ព្រះស្តេចមើលឃើញនេះម្តង ប្រាជ្ញប្រាយគន្ធង ពុំ
ដែលគគ្រើកកកុច ៗ ពុំភ្ញាចអ្នកកាចថយថុច ពុំមានផុច ពាក្យ
ពាលពាះពើចពោ ៗ ឃើញលោតដូចព្រៃព្រឹក្សា ស្រោងស្រាងសាខា
ព្រះស្តេចទើបបារម្ភថ្វី ៗ ឯសម្បត្តិសួគ៌ពីសី ពិសេសជាទី ពុំទាក់
សំណាក់សព្វថ្ងៃ ៗ ពុំនោះដូចអណ្តើកថ្ងៃ ចិត្តលោកនាយនៃ ព្រះ
ស្តេចប្រាជ្ញាម្តេចបាន ៗ ព្រះស្តេចដូចក្តៃសាមាន្យ នាំកូនចូលក្តាន.
មកព្រៃសដានដំរីសារ ៗ ឃើញដូចគ្រុឌកាជ៩ទារ នាគកជដាសដា
ទើបខ្លាចម្តេចអាហាងឯង ៗ ម្នាលមហាសេនាព្រះស្តេច រីអ្នកកាច
តែង មុតដូចបន្លាជាប់ជើង ៗ មុតដូចបន្លាឈើឡើង ពុំដែលដូច
ក្ដើង ទើបគេះកលដាលឡើយណា ៗ អ្នកកាចទោសកុំងអាត្មា
ប៉ុនគន្តិគជសា សឹងសោះសូន្យសុងពុំយល់ ៗ ទុហេតុតែឥតយោ-
បល់ ដូចខ្លាក់ឆ្ងាយឆ្ងល់ ពុំយល់ព្រះស្តេចឯងឡើយ ៗ ទោស
គេប៉ុនគ្រាប់ស្ពៃហើយ ថែងជាក់ជាត្រើយ យល់ច្បាស់ប្រាកដក្តាត់
ណា ៗ មហាក្សត្រស្តេចស្តាប់ពាថា ក្រោកក្រាធសោះសា ត្រាស់

ថាម្នាលអ្នកតាំងឡាយ ។ ធនញ្ជ័យរង់ចាំមើលឆ្ងាយ អញឯងអញ
ស្ដាយ អញយកប្ដីធនញ្ជ័យនោះ ។ ពន្លឺជាន់ក្បាលអញស្មោះ
ចូរទន់កចុះ ទៅដល់ដីធ្វើទោសា ។ ឯអាមាត្យយោធា មានមហា-
សេនា- បតីជាធំសង្ខាច ។ អានុភាពប្តូរអំណាច សោតសង្ខប
ខ្លាច អំណាចពន្ធ្រពោធិសត្វ ។ សង់សៀមឈប់ឈរស្ងប់ស្ងាត់
ដូចគេកាន់កាត់ ប្រមាត់ចេញពីអាត្មា ។ កាលនោះព្រះពន្ធ្រពុទ្ធា
ដ៏ទ្រង់ចិន្តា ថាមហាក្សត្រខ្ញាល់ពេកក្រៃ ។ ឥតនរណាមួយភិតភ័យ
ធ្វើទោសឡើយនៃ តាមដូចបង្គាប់ក្សត្រា ។ ស្ដេចជាម្ចាស់លើសិរសា
ឲ្យយសសក្កា ជាធំលើសគេតាំងឡាយ ។ បើអញពុំចៀសចេញឆ្ងាយ
ខុបទ្រពសម្លាយ កើតទុក្ខព្រះទ័យក្សត្រា ។ គិតហើយថ្វាយបង្គំលា
ចុះពីប្រាង្គប្រា- សាទសួស្ដីមកបានលំនៅ ។ ឯមហាក្សត្រស្ដេចចូល
ទៅ ប្រាសាទលំនៅ ពិតពុំក្រសាលបន្ទោ ។ ឯកពាបព្រហ្ម-វិន្ទុគោ
ពាក្យមួយបែងចប់ប្រែស្នា ។

នេះបទកំណត់ពាណីនា ភូជង្គលីលា ថាថ្ងៃចំនួន ។ ពោធិសត្វ
វិសេសបវរ អ្នកបរបុះផ្គង់ ដើរដល់គ្រឹហា ។ ស្រេចស្រង់ព្រះអង្គ
សុខសា-ប្បាយបរិភោគ្គា ស្រេចហើយចូលផ្ទុំ ។ លង់លុះអមុងជាសំ
ស្វាត់សូន្យស្រង់ អ្នកដោះឡើងវិញ ។ គន់គិតក្នុងចិត្តថាអញ ទោសពាស់
នេះមិញ ស្ដេចខ្ញាល់បន្ទុំ ។ ស្ដេចប្រើគេធ្វើទោសខ្ញុំ សម្លាប់អញឥ-

ឡើងពិតប្តូរម្តេច ៗ បើធ្វើអំពើកលកិច្ច អ្នកណាដូចពេជ្រ គេនឹងចាប់
បាន ៗ គឺមោះបើបោះក្សត្រក្សាន្ត ឲ្យយសសក្តិប្រាណ (ជាធំ) លើស
គេទាំងឡាយ ៗ ម្តេចស្តេចហ៊ានជាមើលងាយ ប្រៀបក្សត្រពណ្ណ-
កយ ពុំគួរក្តាត់ណា ៗ អ្នកគ្រិះរករិះអធ្យា - ស្រ័យតាមគាថា
សត្តធម្មវិតក្ក ៗ អ្នកយល់ពុំទួលប៉ុនសក់ មែនមិនឲ្យថ្លស់ ទោស
ទើសចិន្តា ៗ ដៀងជាក់ជាអ្នកជាតិជា សប្បុរសថ្លៃថ្លា ប្រាជ្ញប្រុសពង
វៃ ៗ ព្រះពុទ្ធជាមកុដជ្រើងត្រៃ ទេសនាថាហៃ អស់ជនទាំងឡាយ ៗ
អ្នកណាគោក្តានូវបាយ ផុះអ្នកទៀបឆ្ងាយ គេខឹងពុំស្រត់ ៗ បង្គាប់ឲ្យ
ចាប់ប្រាកដ ធ្វើទោសខំអត់ សង្កត់ចិន្តា ៗ គេដេរត្រឹតឯតណានា ប្រទេច
ផ្តាសា ពុំខំងតបស្នង ៗ សរសើរដំណើរខំខង នៃអ្នកនោះហោង
ហៅអ្នកឧត្តម ៗ ហេតុខ្លាចអំណាចកម្មធំ ត្រែងធ្លាក់ទៅលំ- នៅស្ថាន
នរក ៗ អ្នកគិតគំនិតយកទុក ត្រែងពុំបានសុខ ទៅបរលោកនាយ ៗ
គ្រប់គ្រាធ្លាក់ពេញសម្ពាយ សោតសឹងរលាយ ផុំលក់ក្តាត់ណា ៗ

បទពំនោលថ្ងៃងចរហា ពិតពីសេនា- បតីកំណាចកាចក្រៃ ៗ
លុះព្រឹកស្រាងស្រេចហើយនៃ យកដំរីជ័យ ឈ្មោះអ្នកយាត្រ ៗ ចុះ
ប្រើងកាចក្ខត់អប្រិយ ឥតដុំមច្ចុ ប្រទះមុខព្រាចខ្លាត់ខ្លាយ ៗ ទោះបី
ដំរីសម្ពាយ ខ្លាចបៀសចេញឆ្ងាយ ពុំហ៊ានប្រទះឡើយណា ៗ ទាំង
មនុស្សទាំងមោសខ្លា សឹងខ្លាចបេស្កា ទោះទាំងកេសរាជសីហ៍ ៗ

សោកសង្កាខ្លាចបុទ្ធី ទោះរួចហើយក្តី សឹងព្រួចល់ឥតខ្លាតខ្លាយ ។
សេនាបតីហៅនាយ ពលផងទាំងឡាយ ឲ្យរៀបអស់គ្រឿងការុជ ។
ក៏កាន់ដោយដៃប្រកិត ណាសណាទៃណានជិត ពាសពេញចន្លោះផ្លូវផ្កា ។
នឹងទៅប៉ុនប៉ងប្រាថ្នា ពិឃាដជន្មា ព្រះពោធិសត្វសេដ្ឋា ។ កាលនោះ
ឯអគ្គពង្សពោ- ធិសត្វវាក ដោះឡើងស្រង់ស្រេចហើយណា ។ ទើបអ្នក
សោយព្រះក្រយា- ស្ងោយសោយអស់អា- ហារផងមានរសប្រពៃ ។
ហើយលាបគ្រឿងពិដោរថ្ងៃ ស្រាប់ស្រេចហើយនៃ អ្នកទ្រង់អម្ពរ
ពស្រ្តា ។ ស្តេចចរចេញចាកគ្រឹហា ប៉ុនប៉ងយាត្រា ឆ្ពោះទៅគាល់
ព្រះបក្រឹ ។ កាលនោះសេនាបតី យល់ព្រះពោធិ- សត្វឡើងទៅគាល់
ក្សត្រថ្ងៃ ។ បើកបរដំរីអភ័យ-កហាត្ថដ័យ ចូលចោមព្រះពង្សពុទ្ធរតន៍ ។
ឯអាមាត្យពោធិសត្វ ៥០០ខាំងក្តាត់ កំឡាំងស្មើដំរីសារ ។ ពុំអាចទប់
ទល់ពុះពារ សោតសឹងរេក រួញរាត់ចោលពោធិ ។ ឯអគ្គពុជពង្សមុនី
សពេជ្ជជិនស្រី ឈរនៅតែឯងឯកា ។ ទ្រង់ព្រះស្មារតីភាវនា ចំរើន
មេត្តា ឥតភ្ញាក់ឥតកោតកកុប ។ ដំរីពេទរត់ថយថុប ទោទាល់ទៀប
ទុប ខ្ទបខ្លាចអំណាចមេត្រី ។ ពុំហ៊ានចូលជិតពោធិ ទប់ទុចទៀប
ទី ក្រៅក្រៀលសំទៀរទ្រហឹង ។ សេនាបតីខេរខឹង ខាខែងប្រែ
ប្រឹង ក៏កាន់កន្ទេវចាក់ចូល ។ ដំរីខ្លាចពុទ្ធក្រឹល មចមុជពុំចូល
ពុំហ៊ានបៀតជិតព្រះអគ្គ ។ សេនាបតីទ្រទង់ កៀរកៀកកាន់កង់-វេវិល

កាប់កាផុតអាក់ ៗ អ្នកកន្ទ្រោតសឹងចាក់ ឈាមហូរសស្រាក់
ញ័រញាក់អស់អង្គរន្ធត់ ៗ ដំរីភ្លាចព្រះពង្សពុទ្ធ រួញរពេទន់រត់
វិលវិលបង្វិលជើងជុំ ៗ ពោធិសត្វអ្នកយល់ជំ- រំពេងនៅដំណំ ព្រះ
ទ័យអាសូរករុណា ៗ រំពឹងដញ្ញឹងគិតថា បើអត់ឲ្យរាំ ដំរីនេះ
សឹងស្លាប់ពិត ៗ ប្រេះគ្រូអញសំផែងឫទ្ធិ ពាលបំបំភិត បំភ័យ៖ផុក-
សេនា ៗ ទើបពោធិសត្វថ្លែងថា រួតរត់បំពារ បំពានដម្រង់
ត្រង់មុខ ៗ ឈរឈប់ឈានឈានចាប់ក្លុក ងើយងស់រុក សំរុញ
អង្គុយប្រងើរ ៗ សេនាបតីពាលោ យល់ព្រះពង្សពោ - ធិសត្វ
ទើរសទ្រង់ឫទ្ធី ៗ ភ័យភិតភ័ព្វឥតស្មារតី ធ្លាក់ពីដំរី ដូចគេក្រវែង
បោកបោះ ៗ ដល់ដីដំដិតដាចជេរ រួតរត់ផ្ទុកផ្ទោះ ទៅពួនកន្ទ
ព្រះកជរាំង ៗ ស្តេចរតយល់ហើយភ័តភាំង បើកបន្ទូលខ្លាំង ថា
ហៃសេនាបតី ៗ មានបើភ័យភិតនឹងអ្វី យល់អង្គក្តី ពុំដូចរៀនមក
សព្វដង ៗ សេនាបតីទូលស្នង ថ្លែងដោយទំនង ដំណើរដំណាលផុត
ធ្លុះ ៗ ស្តេចស្តាប់ត្រិព្រួចព្រួយព្រះ - ទ័យទើបថាអះ ឥឡូវធេន·
ញ៉ុយបណ្ឌិត ៗ ក្លួចកើតកំហឹងចង់ចិត្ត ទឹងទំដំដិត ពិឃាដអង្គអញ
ពុំលែង ៗ ស្តេចគិតបារម្ភក្រវែង ត្រូវត្រង់អង្គឯង ទើបទៅពួន
លើប្រាសាទ ៗ បើកបង្អួចតែងស្អាងស្អាត កែមកែវព្រាងព្រាត
រតទៅព្រះពោធិសត្វ ៗ ឯអង្គពួចពង្សពុទ្ធរត់ មានបារមីក្លាត់

ប្រាកដប្រកបឫទ្ធិ ។ គិតថាទោសទាំងនេះពី សេនាបតី បង្អុបបង្អាល ទៅមក ។ បើអញចាប់វាកំឡោ ចោះពោលទៅក្រៅ បន្ទាយឲ្យស្លាប់ក៏បាន ។ គឺមោះអញនៅក្សេត្រក្សាន្ត សមនឹងកើតមាន ទោសត្រណាក់ អាក់អន់ចិត្ត ។ ហេតុនោះអញពុំគួរគិត បៀតបៀនជីវិត សេនាបតី នោះណា ។ អញនៅយកកៀសខ្លួនជា អ្នកខ្សត់យាត្រា ទៅរកប្រទេស ទៀតនៅ ។ ជៀតសពេជ្រុទ្ធទៅ ចៀសអ្នកកុំឡោ កំហឹងជាបទគាថា ។ គោធបរិវសយា តិឆរកា ឥតោមហាទុគ្គោ ។ អធិប្បាយ បទបន្ទូ ទិតានថាឯ អ្នកណាមួយមានចិត្តខឹង ។ កាចកល់កហល់កំហឹង នាអ្នកនោះទើប ទៅកើតនៅនានរក ។ កន្លល់អំពល់ពុំសុខ រូបរង ទោសទុក្ខ ជូនពន់ពេកពុំស្រឡះ ។ បើបានអត់ធុនលៃងលះ លោក ទោសមានះ មានោក៏បាក់បបបាន ។ ទើងទៅកើតនៅនាស្ថាន សួគ៌ សុខពិមាន មូលមួយបរិពារត្រៀបត្រា ។ ឥឡូវចិត្តចោរមោហា នោះ នឹងពុះពារ បៀតបៀនអង្គអញនេះណាស់ ។ គិតគួរអញនឹងរលាស់ ទោសទល់ទុក្ខទាស់ ក្រឡាស់ក្រឡាប់ចោលចេញ ។ រំពោធិសត្វមុន មិញ សោតសឹងបៀសចេញ អំពីអំពល់ខេះខឹង ។ លោកលះកំហុស កំហឹង នាអ្នកនោះទើប បានបុណ្យបរិបូណ៌ប្រាកដ ។ បើចិត្តបង់ជា ព្រះពុទ្ធ បានផាប់ចំហុត ដូចប៉ងបំណងប្រាថ្នា ។ បើចិត្តចាប់ចង់ទោសា ពិតពុំបានជា ព្រះពុទ្ធប្រសើរបរិបូណ៌ ។ គិតគាប់គួរអញចរចា

ទៀតទូលទៅថា ព្រះមហាក្សត្រក្សត្តបរមពៅ ៗ ក្រាបលាទាំងចរចេញ
ទៅ ទទួលស្រុកក្រៅ លំនៅប្រទេសជនបទ ៗ ប្រែប្រាណជាអ្នក
កំសត់ លំបាកទុគត៌ សន្សំសេពសាងសីលទាន ៗ

នេះបទកាកគ- តិ ទើបព្រះមហា- បុរសថ្កើងថ្កាន ចរចូលទៅ
ដល់ មណ្ឌលព្រះលាន ក្រេញក្រាបបញ្ចប្រាណ ថ្វាត់ថ្វាយបង្គំ ៗ
ទើបទូលទៅថា បពិត្រព្រះមហា- ពជរីអញខ្ញុំ អង្វរព្រះទ័យ ក្សត្រថ្ងៃ
សូមសុំ លាព្រះអង្គអ- ម្ចាស់ចរចេញទៅ ៗ ដ្បិតមានធម៌ថា ប្រទេស
ឯណា ឥតញាតិឥតផៅ ឥតប្រាជ្ញឥតមិត្រ ឥតក្សត្របរមពៅ លោកពុំ
ឲ្យនៅ ឲ្យចរចៀសចេញ ៗ មួយសោតបើស្រុក ណានៅពុំសុខ មួយ
ខានមិត្រមិញ ទ្រស្ដទ្រើសមុជិន ប្រពន្ធសំឡាញ់ ចិត្តចោរបើកចេញ
កាចកិច្ចជាផិត ៗ កូនកាចប្រាប់ប្រ- ដៅពុំយក៍ ពាក្យអាពុកពិត
មួយមហាក្សត្រា មោហាគនគិត កាចកាន់ទុច្ចរិត ពុំពិចារណា ៗ
មេវបរយេ បើប្រាណប្រាសប្រែ ចៀសចាកចេញជា កុំចូលចងចិត្ត
ស្នាលស្និទ្ធស្នេហា ទូរគោលោកថា ឲ្យឆ្ងាយឲ្យណាស់ ៗ មួយ
សោតស្រុកណា ច្រើនអ្នកប្រាជ្ញ ច្រើនស្ដេចជាម្ចាស់ កើតគិតប្រាស
ប្រែ បំបែរបំបះ បំបែករោសភាស់ តាំងទទល់ទ័ព ៗ កើតការចម្បាំង
តែងត្រួតតាំង ប្រកួតប្រកាប់ ប្រកាន់ប្រកឹង ពស្ដ្រឹងស្លុតស្លាប់ ខូច
ភាយភាតទ្រព្យ ប្រាសកូនប្រពន្ធ ៗ ដូចកលកើតព្រះ សូរ្យសែន

រឿងរ៉ះ ៧ អង្គអន់ ទសអស់ព្រឹក្សព្រៃ ស្លោមស្លឹកស្រពាន់ ស្រពោន
ល្អិតល្អន់ ល្អិតល្អោចឆ្លុះឆេះ ៗ មួយសោតលោកថា ប្រទេសឯណា
មានអ្នកចំណោះ ដណ្ដើមជាធំ ខាំចង់ចេះ អាងអាចចំណោះ ពុំឲ្យ
គេស្មើ ៗ ស្ទុះស្ទែងទោសទុក្ខ លបលោកលួចលក់ រឹងរករ៉ះរើ
ពាក្យពោលពុំពិត គំនិតសើរើ ចង់ជាធំលើ គេគិតកាន់កាច ៗ
ប្រទេសនោះទឹង កើតក្ដីកំដឹង បទបិត្តកំណាច បៀតបៀនបំបាត់
ខ្លាយខ្លាត់អ្នកប្រាជ្ញ ហេតុនោះខ្ញុំខ្លាច ខ្ញុំលាព្រះអង្គ ៗ ពោធិសត្វ
សំ- ដែងដោយក្រិត្យក្រម ក្រួញក្រាបបាទប- ង្គំគាលនោះណា
កាព្រះអង្គ ពុទ្ធទាំងក្រុង ឥន្ទបត្តនគរ ៗ ដោយអានុភាពពោ-
ធិសត្វសេដ្ឋ លើសលោកាករ ប្រួញប្រាណប្រណិប័ត្ន មហាក្សត្រ
បវរ លុតលាចេញចរ វិលវឹងស្ពានស្ពិត ៗ អ្នកបៅអស់អា-
មាត្យមកទាំងហា- រយផ្ដែផ្ដាំផ្ដិត ជាអ្នកទាំងឡាយ នៅកាយគួរគិត
ចូរចាំចងចិត្ត ជូនចំណីយក្ស ៗ ព្រឹកល្ងាចប្រក្រតី សត្វថ្ងៃកុំបី ឲ្យ
ភ្លេចភ្លាំងអត់ ឲ្យអន់ដំនូទ ពុំជូនក្រុងយក្ស ចូរចាំជៀងជាក់ ដ្បិតអញ
ទឹងទៅ ៗ កាន់ម្ដាយអាពុក អញនៅនាស្រុក បច្ចន្តគាមក្រៅ ប្រាយ
ប្រាប់អំពី សេចក្ដីពក់ព្រៅ ហើយហួសឆ្ពោះទៅ កប្បាសគ្រាមា ៗ
ស្រុកនោះមាំមួន តាមតែបង់បួន ត្រូវត្រង់ស្រុកណា សុខសាន្ត
សប្បាយ ណោះលាយចិន្ដា អង្គអញឯងអា- ស្រ័យស្រុកនោះនៅ ៗ

ផ្ដាំប្រាប់ស្រេច ពន្ធកសពេជ្រ ពូជពង្សព្រុទ្ធហៅ ឯកអគ្គសីហនាទ
យានបាតាទៅ ទាល់ទីលំនៅ បច្ចន្តគាមា ។ មហាបុរសរ័ត្ន ចរចូល
ប្រណិប័តន៍ មាតាបិតា ប្រាប់សព្វសេចក្ដី អំពីព្រះមហា- ក្សត្រក្រេវ
ក្រោធា អស់ឥតឯខ្លះ ។ មាតាបិតា ស្ដាប់ហើយសោកា គគក់ខ្ញក
ថាហ្នោះកូនស្ងួន ពីងពួនទៅផ្ទះ រិះរង់ក្រែងព្រះ មហាក្សត្រគេ្យមកក្រន្ត ។
អ្នកឆ្លើយទៀតទៅ ថាខ្ញុំទឹងនៅ ស្ថាននេះពុំបាន ក្រែងម្ដាយអាពុក
កើតទុក្ខព្រួយប្រាណ សព្វសាប់សន្ដាន ជាទុក្ខដ្បិតខ្ញុំ ។ ពុំគួរទើង
នៅ គិតគួរតែទៅ ទីទៀតលះលំ- នៅនេះទើបបាន រកស្ថានគួរកំ-
បាំងបាត់បេញចំ- បែងបង់ឲ្យឆ្ងាយ ។ ទៅទើបបានសុខ មិនមាន
ទោសទុក្ខ ដល់អាពុកម្ដាយ សាប់សន្ដានផៅ ទិត្យនៅឯកាយ សឹង
សុខសប្បាយ អគ្គឥតអំពល់ ។ រីពង្សសេដ្ឋី ស្ដាប់ពាក្យពោធិ-
សត្វហោយសោកសល់ ថាហៃកូនស្ងួន ខ្ញុំមខ្ញួនទិម៌ល បើបាជួបដល់
ប្រទេសវិទៀត ។ យើងទំងតាមទៅ ពុំគួរទើងនៅ ព្រោះបាបង្បៀត
ទោះក្រទោះឆ្ងាយ ទូលាយបង្អៀត គិតគួរតែចៀត ទៅតាមកំដរ ។
អ្នកជាអគ្គអ- ម្ចាស់ចង់តាមខ្ញុំ ពុំបានក្រែងក្រ បើមហាក្សត្រដឹង
ដំណឹងព្រួមក៍ ថាខ្ញុំនាំយក៍ អម្ចាស់ចរចេញ ។ សមគ្រាស់បើព្រះ
គាថ្វាមកផ្ទះ ញាតិសាប់សំឡាញ់ ធ្វើទោសធ្វើទុក្ខ បែនបុកលំគេញ
ជាទុក្ខកម្មេញ វិនាសន្តាត់ខ្លាយ ។ បោតុទោះខ្ញុំថា កូនកាចឯណា

ទ្រើសទ្រស្តមហាក្សត្រ ទោះទាំងសន្តាន ធនធានបង់បាត់ វិនាសប្រាស
ប្រាត់ ចិន្តាព្រួយសល់ ៗ រញ្ញាតិទាំងឡាយ ពុំសុខសប្បាយ កើតក្ដីកង្វល់
ដ្បិតមានញាតិកាច កំណាចដិតដល់ ទោសទុក្ខអំពល់ អំពីញាតិឯង ៗ
មួយសោតដ្បិតមាន ព្រះធម៌ប្រធាន ព្រះពុទ្ធថ្លៃថ្លែង វែងទុកជាច្បាប់
សណ្ដាប់តំរែង អ្នកប្រាជ្ញតារវែង ជាបទគាថា ៗ ចដេឃកំ កុល-
សគំ បើបង់អ្នកឯណា មួយមោះលែងគន់ ពូជពង្សមេបា គុណញាតិកា
សព្វសាច់សន្តាន ៗ តាមសូត្រ កុលំបដេ ជាបើពុំបាន គុណ-
ពីសាច់ញាតិ ឃ្លាឃ្លាតឆ្ងាយឋាន លែងតែឲ្យបាន គន់ស្រកលំនៅ ៗ
តាមជនំ បទសូត្រ បើបង់ស្រកទៅ លែងគង់ជនបទ កំណត់ទីនៅ
ជួបជុំគ្នាទៅ រកស៊ីសាទរ ៗ បឋវីជ- ជេតិអគ្គ: បើបង់នគរ លែង
គង់មហា- ក្សត្រជាជំហារ ពស្ត្រផងត្រែកអរ ចុះចូលពំនាក់ ៗ ធន-
ញ្ជ័យសេដ្ឋី ស្ដាប់ពាក្យពោធិ - សត្វថ្លៃវរល័ក្ខណ៍ ស៊ើបសួរទៀតថា
ព្រះមហាក្សត្រអាក់ អៀនអន់តើអ្នក - ណាបំបែកបាក់ ៗ ពោធិ-
សត្វឆ្លើយ ឥតអ្នកណាឡើយ គឺកម្មពេរ អង្គឯងវាកាច ឲ្យស្ដេចក្រោធា
ទឹងខ្ញុំឲ្យជា អន់អាក់ព្រះទ័យ ៗ ធម្មតាសព្វសត្វ អន្ទោលកងវដ្ដ-
សង្សារកើតក្រៃ សឹងមានពេរ កម្មជាបច្ច័យ តែងតាមគង្គ ៗ ស៊ុវិល
សព្វសត្វ ៗ ហេតុនោះធម៌ថា នរអ្នកណា មានយសសម្បត្តិ គឺពីបុរណ
ដ្បិតបានកាន់កាត់ ធនធានសម្បត្តិ ឲ្យមានពីមុន ៗ ទោះនូវបាត់យស

សម្បត្តិធ្លាក់ថ្មស់ ខ្លាត់ខ្លាយទ្រព្យធន ខូចខាតវិនាស ព្រាត់ប្រាស
ស័ក្តិបុណ្យ គឺកម្មពីមុន តែងតាមអាត្មា ៗ ទោះអ្នកណាមាន
វិញ្ញាញញៀយញ្ញាណ ដឹងដោយប្រាជ្ញា យល់សព្វសេចក្តី ឥតបីសង្កា
បៀសបាតវេក កម្មកាយពុំបាន ៗ ពីរពង្សសេដ្ឋី ស្តាប់ហើយស្រដី
ផណ្តឹងទៅក្កាន ថាហៃកូនស្ងួន ខ្ញុំម្ខូនគលព្រាណ អ្នកនឹងឈប់ខាន
ប៉ុទៅថ្ងៃណា ៗ ហើយនឹងយកខ្ញុំ បរិពារតូចធំ ប៉ុន្មានអង្គា ទៅ
ត្រាច់ស្រុករ កំដរអាត្មា កែងក្រគប់គ្រា ប្រយ័ត្នប្រឹងប្រាណ ៗ
ពោធិសត្វថា ខ្ញុំនឹងយាត្រា ថ្ងៃនេះពុំខាន បរិពារពលខ្ញុំ តូចធំ
ប៉ុន្មាន ខ្ញុំទុកពុំបាន យកទៅជាមួយ ៗ មាតាបិតា ស្តាប់បុត្រចរចា
ព្រួចព្រឹព្រួញព្រួយ ចិត្តតាប់ក្នុងថ្ងើម ដង្ហើមត្រួលត្រួយ ដូចគេ
ផ្ងួនផ្ងួយ បេះបោចបោះបង់ ៗ បទបុត្រឃ្លាតទៅ ទទួលលំនៅ
ម្នាក់ឯងឯកអង្គ ស្រយាកស្រយុត នុះបុត្រាទ្រង់ កន្ទ្រើលទន់លន់
លន់លោចទួញថា ៗ ឱបុត្របណ្តូល មាសមកមិត្តមូល ប្រែ
ប្រាសឃ្លាតឃ្លា យើងជាទុក្ខក្តាត់ បទបាត់បង់បា អួលអន់ឱរា ឱរសេ
ត្រៀមត្រំ ៗ ព្រះពង្សពោធិ៍ យល់ព្រះជននី ជនកទួញទំ- ទួញ
អ្នកសឹងសោក គាំមោក្ខថាខ្ញុំ បោះបង់អង្គអ- ម្ចាស់ចរចាកឋាន ៗ
បងមិនដឹងគុណា អម្ចាស់មហាធ្ងន់ ឥតអង្គមាន ខ្ញុំទៅប្រាជ្ញា ឲ្យ
មហាក្សត្រគ្រាន្ត គ្រោធគ្រាន់ស្រាកស្រាន្ត ស្រេនស្រួលពុំខ្វល់ ៗ

រីគុណអម្ចាស់ ទាំងពីរក្រៃក្រាស់ ខ្ញុំដឹងខ្ញុំស្គាល់ ខ្ញុំគិតសព្វថ្ងៃ ឥតអ្វីផ្ទឹម-
ផ្ទាល់ ដ្បិតមានព្រះធម៌ ព្រះពុទ្ធទេសនា ។ លោកថារីក្តី ព្រះសុមេរុធំ
ខ្ពង់ខ្ពស់គណនា ៨ម៉ឺនស្បាន់ ៤ពាន់យោជន៍ប្រា- កដគុណមាតា ខ្ពស់
លើសលែងនោះ ៗ រីចក្រវាឡ ទូលាយពិស្តារ ធំធេងទៀងទោះ ទូលាយ
លើសក្រៃ ឥតអ្វីស្មើស្មោះ លើកយកគុណនោះ មកផ្ទឹមពុំបាន ៗ
រីមហាសមុទ្រ ជ្រាលជ្រៅចំហុត ពេកពន់ប្រមាណ បោះគុណមាតា
រក្សាព្រួយប្រាណ ជ្រៅក្រៃផលស្ថាន ផល់សាគរវិញ ៗ រីមហា-
ប្រថពី ភារភពផែនដី ក្រាស់ក្រៃពាសពេញ ទូទាំងចក្រវាឡ ថា
ស្រាលស្តើងវិញ គុណម្តាយនោះមិញ ក្រាស់ក្រគណនា ៗ
កាលអ្នកម្តាយទ្រង់ គភ៌កូនចិត្តបង់ បរិភោគអស់អា- ហារហ៊ឺរពុំបាន
ពុំហ៊ានភោក្តា សព្វថ្ងៃសាំងជា ទុក្ខទៀងសព្វកាល ៗ ទោះដើរ
ទោះដេក ពុំមានចិត្តត្រេក ពិតពុំត្រអាល អាចអត់ការជួន ទម្ងន់
សព្វសា- រពើកិច្ចការ ក្រិត្យយកភស ៗ អាចអត់ជម្ងឺ ដំកាត់
ថ្កាត់ឈឺ ទៀងតាល់ទសមាស លង់លុះសម្រាល ឈឺដាលដូចដាស
ដិតដល់តាប់តាស ស្លួសព្វសរសៃ ៗ ឈឺចៀបសព្វសាយ គាន
តឹងស្មើរក្លាយ ដោយដំបៅផ្ទៃ ខ្ញុំដេកខ្ញុំគិត ក្នុងចិត្តសព្វថ្ងៃ គុណ
ម្ចាស់ក្រាស់ក្រៃ ឥតឯថ្លៃងថ្លឹង ៗ លុះប្រឹងប្រសូត រួចពល់របួត
បបក់ព្រលឹង អណ្តែលឧបអគ្គ ផ្តេកក្នុងអង្រឹង បំពោរអឺអឹង- ក្នុងកើត

ជាទុក្ខ ៗ នៅក្នុងក្រឡា ភ្លើងភ្លឺឆ្លោចផ្សា ក្តៅក្តាត់ពុំសុខ ស្រាប់
ស្រស់ អំពល់ជាទុក្ខ ដល់ដេកពុំលក់ បរិភោគពុំបាន ៗ ដេកដិត
លាមក អាចមអាក្រក់ ប្រឡាក់អស់ប្រាណ ចិត្តចង់ស្អាតស្អាង
រូបកាយពុំបាន ពុំដែលសុខសាន្ត ផ្ទះផ្អាបអស់អង្គ ៗ ឯអស់អង្គកាយ
ធាតុខ្ញុំទាំងឡាយ គឺឈាមនៅក្នុង ខ្លួនខ្ញុំជៀងជាក់ នេះអ្នកបម្រុង
ចំរើនឲ្យគង់ រូបរស់វិញ្ញាណ ៗ ធាតុបឋវី គឺកេសី ជាតិជាប្រធាន
អាបោធាតុគុណ ទឹកប្រមាត់មាន ជាដើមសំងបាន កើតដោយក្សីរ
អ្នក ៗ វាយោធាតុមាន ខ្យល់ជាប្រធាន វិញចូលឥតអាក់ តេជោធាតុ
ខ្ញុំ គឺកំលាំងជាក់ ជាដើមក្សីរអ្នក ឯងអាចចំរើន ៗ ចិត្តចេតសិក
វិញ្ញាណខ្ញុំនឹក ខ្ញុំគិតក្រវេង យង់យល់ជាងជា ក្សីរអ្នកចំរើន មានគុណ
នោះច្រើន ឥតឧបមា ៗ គុណអ្នកឥតគូ ខ្ញុំដឹងហើយកូរ ខ្ញុំពុំទាន់បាន
សងព្រះគុណថ្លៃ ប្រពៃថ្កើងថ្កាន ទើបអ្នកនិទាន ពីគុណបិតា ៗ
បពិត្រព្រះជី- នកអ្នកជាទី ពំនាក់អាត្មា ទោះខ្ញុំថ្កាត់ឈើ ជម្ពូពេតា
អម្ចាស់ព្រួយបា- រម្ភពីជាទុក្ខ ៗ គាត់តែងរកថ្នាំ រកពេទ្យប្រចាំ ប្រ-
ឈមមើលមុខ ពិភ័ក្តិគ្រូ លុះជាសាន្តសុខ ទៀងទើបស្បើយទុក្ខ ទោ-
មនស្សាសល់ ៗ មួយម្ចាស់គាត់តែង ធ្វើការបន្ទែង ជាទុក្ខឆ្ងាយខ្វល់
ឲ្យអញខ្ញុំលេង ជាល្បែងដោយកល កិច្ចកើតអំពល់ អំពីព្រោះខ្ញុំ ៗ
គុណមួយចទប- ឆ្កើតកបអស់អង្គ រក្សាថ្មើះជាំ ប្រាប់ប្រាមប្រយ៉ា

ដោយនូវក្រិត្យក្រម ឲ្យបានសុខស- ម្បត្តិបុណ្យប្រថ្កើងថ្កាន ។ ហេតុ
នោះព្រះគុណ ព្រះជនកជួន ឥតឯប្រមាណ ឥឡូវនេះខ្ញុំ ពិតពុំ
ទាន់បាន សងគុណសូមទាន ឲ្យអត់ទោសខ្ញុំ ។ ពីរពង្សសេដ្ឋី ស្ដាប់
ពាក្យពោធិ-សត្វសរសើរសំ-ដែងដោយសុចរិត ធម៌ពិតពេកពុំ អាច
អត់ទុក្ខទំ- នួញនោះពុំបាន ។ សេដ្ឋីពីរពង្ស គគក់ទ្រូងទ្រូង កន្ទ្រង
ប្រះប្រាណ ទង្គិះខ្សឹកខ្សួល អាក់អួលពុំក្សាន្ត ឧបបុត្រកល្យាណ
ពិលាបទូញថា ។ កាលកូនសំឡាញ់ បំបង់បាត់ចេញ ផ្គាប់ផ្គុនក្សត្រា
យើងរីងរេក ណាស់នឹកដល់បា សព្វថ្ងៃសោកា នៅនឹងទុកភ្នក ។
ទល់ទុក្ខទន្ទឹង បានបារិលវឹង ឥឡូវបាបែក ប្រោះបង់ទូរទៅ លំនៅ
ឆ្ងាយពេក ទៅតែឯងឯក អង្គឥតគ្នីគ្នា ។ កូនអើយកង្ទើម សាច់
ស្ងួតដង្ហើម ទ្រូងត្រូតផ្សាយផ្សា ទល់ទុក្ខទោមនស្ស ម្រាងរសរូបា បទ
ចាស់ជរា រូបរឹងថែថប់ ។ នាងសុខុមាលី ទូញព្រះពោធិ- សត្វសរ-
សើរសព្វ អស់អង្គសព្វាង្គ រូបរាងគ្រាន់គ្រប់ សញ្ចឹងសញ្ចប់ ខ្សឹកខ្សួល
អួលអាក់ ។ ពោធិសត្វយល់ ព្រះកន្ទ្រងទល់ ទុក្ខទើបអ្នកយក និច្ចធម៌
សម្ដាធម្មាជៀងជាក់ នាំខិតទានទាក់ ពាស់ពៅទៀតថា ។ បពិត្រអម្ចាស់ កុំ
សោយសោកណាស់ គួរគិតអនិច្ចា កំណើតសព្វសត្វ រង្គត់នៅនា
វដ្តសំសា- គាគម្ភីរជ្រៅ ។ ពិតពុំទៀងទាត់ ប្រែប្រួលប្រាសព្រាត់
ទីទៃទូរទៅ សឹងសោកខ្សឹកខ្សួល រំដួលក្ដាត់ក្ដៅ ទល់ទុក្ខនិត្យនៅ ពិតពុំ

យៀងឃ្លាត ៗ ពង្សពោធិសត្វ ទុនអង្គប្រណិប័តន៍ ក្រញូំក្រាបអភិវាទ
លាព្រះបិតា ថ្លៃថ្លានរនាថ នូវព្រះវរមា- តាដើរចរចេញ ៗ ប្រែប្រាណ
ប្រទ័- ក្សិណ ៣ ជុំជាក់ អួលអន់អម្ចេញ ឯព្រះជននី ពោធិសត្វវិញ
ចរចុះចាកចេញ ជូនកូនដល់ក្រៅ ៗ នាងឲ្យដំណើរ បុត្រប្រុសប្រសើរ
ទ្រូងត្រឹតអួលក្តៅ សោយសោកាគិត បុត្រតែនិចមរៅ សន្ទប់ដួលទៅ
ដេកដិតពសុធា ៗ ពោធិសត្វអ្នក ប្រឹងប្រែព្រះភ័ក្ត្រ យល់ព្រះមាតា
សោកសន្ទប់លង់ ព្រះអង្គមិញា វិលវិងប្រកា លើកព្រះជននី ៗ ករកាន់
គង្គា ក្បង់ក្បិតភ័ក្ត្រា ភ្ញាក់ស្មារតី លោមថាអ្នកកុំ ទ្រួញយំសោកថ្វី
អ្នកដឹងឫទ្ធី អានុភាពខ្ញុំស្រាប់ ៗ អម្បាលនទ្ធិ- យ័ក្សយង់ឫទ្ធី ខ្ញុំ
អាចរំលាប់ ដោយតេជមេត្រី ស្រដីបង្ខាប់ ចូលចិត្តក្រឡាប់ ក្រ-
ឡាស់តាមខ្ញុំ ៗ ហេតុនោះខ្ញុំឃាត់ កុំអ្នកព្រួយចិត្ត សង្កិះអារម្មណ៍
កុំសោយសោកសល់ អំពល់ពីខ្ញុំ ចូរលះលាភលំ- ហែហាវយា ៗ
នាងនាដព្ទពាក្យ កូនកូវស្រាលស្រាក ស្រួលស្រន់សោកា លំហែ
លំហើយ ផ្អាសឆ្លើយទៅថា បើដោះថ្វីឬ មិនបង់មេត្រី ៗ ទៅ
ទូលរំលាប់ សំដែងសណ្តាប់ ក្សត្រាធិបតី ក្សិណទ្រង់ព្រះក្រោធ
ប្រាសោកកុំបី ចរចេញទៅទី- វៃទៀតទូរហាន ៗ ព្រះពង្សពោធិ-
ស្តាប់ព្រះជននី អ្នកចង់ដឹងជាទ អ្នកឆ្លើយថាខ្ញុំ រិះរំលាប់បាន ពេកពិត
ពុំមាន កម្រងល់តិច ៗ គឺមោះឥតភ័ស្តុ ប្រយោជន៍តិចណាស់ ។

ពាក្យកុំភ្លេច បើមានបើក្រ កម្រម្តេចៗ ត្រូវព្រះទ័យស្តេច ឲ្យគេរក
ខ្ញុំ ៗ នោះគួរអស្ចារ្យ ភ្លឺទូទ័រ កើតកេរ្តិ៍ជាធំ សាយសព្វសកល
មណ្ឌលទីជ– មន្ទីបថាខ្ញុំ ជាក់ជាអ្នកប្រាជ្ញ ៗ មួយទីនាអ្នក ប្រាជ្ញប្រុស
ប្រត្យក្ស ទ្រង់ធមិឯងអាច ទោះទៅឋានណា ទេពតាបិសាច អារក្ស
ខ្មោច ជៀងជួយរក្សា ៗ ទោះមនុស្សសត្វក៏ មើលមកមេត្រី
ចាប់ចិត្តស្នេហា កើតកួបកានកោះ ហេតុនោះខ្ញុំថា ខ្ញុំបានយាត្រា
វិលវិញមកឆាប់ ៗ ព្រះវរមាតា ស្ដាប់បុត្របរា ចាយថែងប្រាយ-
ប្រាប់ នាងជឿប្រាជ្ញ បុត្រាគិតគាប់ ដោយធម៌គំនាប់ គំនិតធ្ងន់ធ្ង ៗ
នាងបន្ទោទុក្ខ ស្រយាលសាន្តសុខ សោមនស្សរាទរ ថាបុត្រព្រលឹង
អ្នកនឹងចាកចរ យកទ្រព្យព្រួករ អ្វីខ្លះទៅផង ៗ ព្រះពោធិសត្វ
ក្រញូក្រាបប្រណិប័តន៍ ធ្លាសឆ្លើយសាសង បពិត្រអម្ចាស់ គុណ
ក្រាស់កន្លង ចិត្តខ្ញុំប៉ុនប៉ង ពុំយកទ្រព្យអ្វី ៗ សុំតែមណីរ័តន៍ ល្អល្អះពិ-
បិត្រ សម្រាប់សេដ្ឋី ទាំងប្រាំពីរមក ខ្ញុំយកទៅខ្ចី នឹងផងដាក់បុ កំណាន់
តែផ្ទុំ ៗ ព្រះមាតាស្ដាប់ បុត្របានប្រាប់ប្រាប់ ប្រែប្រាណបើខ្ញុំ
ស្រែស្រុតទៅខ្ចី យកប៉ុមកផ្ទុំ នូវរ័តន៍ឧត្តម ប្រាំពីរប្រការ ៗ សម្រាប់
សេដ្ឋី គឺត្បូងពេជ្រពី – ទូរ្យមុក្តាហា ផ្ករ័តន៍ស្រស់ស្រី មហានិល
ប្រពាល រ័តន៍រឿងរន្ទាល បទុមពគរ័តន៍ ៗ ឲ្យស្រីទៅយក ហើយហក់
វិលមក ឲ្យពោធិសត្វ ព្រះអង្គស្រាកស្រួល ទទួលយកថ្វាត់ ក្រញូក្រាប

ប្រណីប័តន៍ ព្រះវរមាតា ។ ស្រេចឲ្យដំណើរ ព្រះមាតាដើរ ទៅដល់ត្រីហា ទើបអ្នកបរពោក លះលាកគ្រាមា សីហនាទយាត្រា ឆ្ពោះបូព៌ទិសទី ។ វិយោគកក្កល្ហំ ចង់ដ្ឋឹត កាលពន្សពោធ លីលា លាគលះ ព្រាត់ព្រះជននី ចែងចប់សេចក្តី អស់អាថ៌ប្រស្នា ។

បទបែរប្រាសប្រែចង្កា កូដង្គលីហោ និទានទៀតទៅ ។ ពិតពី ពោធិចមទៅ ចេញចាកលំនៅ ប្រែប្រាណជាតិជា ។ អ្នកខ្សត់ទូគិត កំព្រា ផ្លាស់ពណ៌ពស្ត្រា ទិព្វទេសវេចទុក ។ យកពស្ត្រាចាស់អាក្រក់ សម្បុរជ្រលក់ ជាពណ៌ហង្សបាទ ។ មកស្លៀកសំលៀកសុទ្ធសាត ហាក់ខ្សត់ជាក់ជាតិ ជួតចងកេសា ។ ស្រេចស្រាប់ប្រដាប់ប្រដា យាង យាសយាត្រា បរចូលព្រឹក្សព្រៃ ។ សោងស្រឹងទ្រឈឹងទ្រឈៃ ឈើ ឈរក្រាស់ក្រែ ណាស់ណាន់ណែនណាស់ ។ ដុះដិតប្រកិតធ្ងុកធ្ងាស់ លាយលេចល្អូតលាស់ លំពាធ់ពកពៃ ។ ស្គាស្គួយប្រែសជ្រួយជ្រែជ្រៃ បេងបាយម៉ាតម៉ៃ- ស័កសោមសេសេច ។ ផ្ទួសព្រឹងព្រួសព្រៀលព្រេច ស្វៃស្វែស្វោងស្វាច់ អង្កោលអង្កាញ់ ។ សណ្តាន់ញាញញេញ ជ្វង់ ជ្វាជ្វៃជ្វេញ- គ្រីគ្រស់គ្រៀកគ្រាច ។ ឃ្មៃឃ្មែពោធរំពែងកជ ផ្តឹសព្ទួច លៀបលាជ ផ្ទុះផ្ទាលផ្ទុំផ្ទាត់ ។ បោះបាសទៀវទាសសោមសត្វ ត្បា- ត្បែងផ្ទាត់- ដៃដឹសដងដឹង ។ ខ្ទីតខ្ទាវខ្ទិតខ្ទារខ្ទុំខ្ទឹង កាកោកក្ទឹង យុក្ខាផ្កាថ្ងូរ ។ លង្វិលត្វមង្ស្រុតត្វុយត្វូ- លែនលោតក្ទូងក្ទូ ស្វាស្វាត

ស្រាំងស្បែង ៗ ដកពាយខ្លួតឃ្លាយខ្លុនខ្លែង– គង់គរស្មុតស្មែង
ស្ពៃស្ពឹស្ពង់ ៗ ច័ន្ទន៍តារក្រេង្កាពេដែព– ផ្សែរពេគព្រួលរង់ ស្កុកស្កុល
ស្គីស្គៅ ៗ ស្គាតស្គាយស្ពុលស្គាយផ្គៀកផ្គៅ បង្គាវបង្គៅ ពពេល
ពពូល ៗ ខ្យាខ្យារស្រម្ពរស្រម្ពល សម៉ស្រល់ស្រួល រកាក្តាំងក្ពួច ៗ
កាតក្តុលទ្រមុលទ្រមួច ទ្រមូងសង្ឃួច សង្ឃ័រសង្ឃារ ៗ ផ្អាវផ្អុងគ្រែល
គ្រុងគ្រូបគ្រែ– រាំងវ័ល្លិ៍បែងបែ– តាកដូងព្រះព្រហ្ម ៗ សព្វសត្វ
ប្រវាត់ទៅទំ ចាប់ជាទ្រនំ លេងលើសាខា ៗ គ្រួចក្រៀលទៀរទោច
ទទា សេកសោមសារិកា ដីវាកជីវក់ ៗ បគារឆៅរកកកុក ទទុយទោម
ទុក- ទ្រូទ្រមាក់ខ្លា ៗ ក្អែកក្អាតចចាតអកអា– អួតឡស្វា· បេកបង្ហៀល
ខ្យង ៗ ចាបចាកក្រពាកត្រយង ត្រលែងវែកកង– កេងកុកគ្រោង
គ្រែង ៗ ទៅទំយាសយំប្រឡង ប្រចឹកគ្នាលេង ហើយហើររេក ៗ
អ្នកត្រាច់លុះលេចមគ៌ា ៣ យោជន៍គណនា ត្រាច់ត្រង់សំដៅ ៗ ដើរ
ដល់មណ្ឌលលំនៅ ទួលទីស្រែក្រៅ កប្បាសគ្រាមា ៗ ក្រៅឋាន
នោះមានសាលា គេសង់រក្សា ទ្រពក្សដើមផ្កុល ៗ ព្រះអង្គ
ពូជពង្សទេសពល លីលាដើរដល់ ទីឋានសាលា ៗ ចុះស្រង់កម្មុង
គង្គា ទីទាបទឹកថ្លា ប្រាំងជ្រាលជ្រោះជ្រៅ ៗ ស្រង់ស្រេចបាន
គិបទើបទៅ ចូលបតទិត្យនៅ សាលាឯកអង្គ ៗ ត្រមោច
លន្ទោចលន្ទង់ យកបុប្ផាថង់ ផ្ទុំលើសាលា ៗ គេជះហេតុព្រះចេស្តា

ស្ងូរសព្ទបូជា ព្រះធម៌គាថ ៗ សុខកាតវ័ត្តំ កោណ្ឌាសុរំ សុរិតំ យោ ៗ ស្នេហាមេត្តិឃកោ សមាគមោ សម្ពុដ្ឋិតា ៗ សុ-ខត្តិកាបិណ្ឌា មោឆសុខា ករសេរី ៗ បរិយាយថែនពាយបាលី បន្ទេស្ដេចក្ដី ថាម្នាលទេព្រក្ស ៗ រឹងរិទ្ធិសឹងសិទ្ធិស័ក ឥត្យទៅសំណាក់ ទីឋានានា ៗ ចូលជុំជំនុំគិតគ្នា បង្កើតមេត្តា សព្វសត្វទាំងឡាយ ៗ កុំព្រួយបៀនឲ្យអន្តរាយ ទំនងកើតកម្មកាយ ពៀរពាន់ពេកពិត ៗ ផ្ដែផ្ដាំ ចូរចាំចងចិត្ត ចូរចាប់ជាមិត្រ ទំនងគ្នាជាសុខ ៗ លោកិយព័ន្ធពីទោស ទុក្ខ ទៀងតាល់ទៅមុខ ហើយសុខសួស្តី ៗ គេជះហេតុព្រះបេស្ដា ទេព្ដាក្រា ដើមផ្កុលពុំក្រាន្ត ៗ គន់គិតនិម្មិតថែប្រាណ ជាតាបសបាន ដើរដល់សាលា ៗ ក្រឡឹងដណ្ដឹងទៅថា នៃអ្នកឯណា ជុំប៉ុនៅនេះ ៗ តោធីស្រុដីសំណេះ ថាអញឯងគេះ អ្នកឯកស្ដាប់ក៏ ៗ ទេព្រក្ស ស្ដាប់ជាក់ឆ្លើយថា អញមកប្រាថ្នា ចង់ស្ដាប់ស័ព្ទប៉ុ ៗ ថាម៉្លោះឡើងលុះ លើទី សាលាស្រដី ស្នូរថាបៅបេះ ៗ ប៉ុតែងជុំក្មេងនៅនេះ ឬមួយទៅ បេះ ឯទៀតខ្វះវិញ ៗ អ្នកឆ្លើយតាអើយអែញ ជុំប៉ុនេះមិញ បេះតែ ប៉ុណ្ណោះ ៗ និយាយបរិយាយអញបេះ ច្រើនដោយបំណេះ ចំណាំ គាត្ថា ៗ ទេព្រក្សជឿជាក់ឆ្លើយថា ចូរទៅចរចា អង្គអញចង់ស្ដាប់ ៗ តោធិសត្វវិសេសប្រាប់ ថាបើចង់ស្ដាប់ និយាយឲ្យបាន ៗ គឺមោះបទ ចោះបង់ឋាន អត់អាហារឃ្លាន អញឥតកម្លាំង ៗ ទេព្រក្សចុះបោកកំបាំង

និម្មិតអស់ទាំង អាហារទិព្វថ្លៃ ៗ យកភាជន៍មាសស្អាតប្រពៃ ថ្កល់
ស្រេចរៀបរៃ មកថ្វាយពោធិ ៗ អ្នកយកភក្តាហារចំណី ទិព្វទេសពីសី
ដឹងជាទេព្តា ៗ អ្នកសួរទទួលទៅថា អ្នកជាទេវតា ឬជាគ្រុឌរាជ ៗ ឬជា
យក្សអំណាច ឬជានាគរាជ ប្រាយប្រាប់ខ្ញុំ" ៗ ទេព្រក្យស្តាប់ជាក់
ឆ្លើយថា អញជាទេព្តា បិតហាននេះឯង ៗ ចៅឈ្មោះអ្វីនោះចូរថែង បរបា
សំដែង ឲ្យដឹងដើមអាទ៏ ៗ អ្នកថាអញជាអាមាត្យ ជំនិតព្រះបាទ ធនញ្ជ័យ
ស្តេចក្សេត្រ ៗ អម្តអញចរចេញមកលេង រីឈ្មោះអញឯង ជ័យបុរស
ជាក់ ៗ ទេព្តាឆ្លើយថាចូរអ្នក បរិភោគភាជន៍ភក្ត្រ ហើយអ្នកនិយាយ ៗ

## ពាក្យរាជមន្ត្រី[1]

នេះបទកាកគា- តិទើបព្រះមហា- បុរសប្រាជ្ញប្រាយ សោយភោជន៍
អាហារ ភក្តាហារទាំងឡាយ ស្រេចអ្នកនិយាយ ដោយនូវសរញាណ ៗ
ជាហៃទេព្តា កាលកើតសាសនា ព្រះកកុសន្ធបាន ត្រាស់ស្រេចបរិបូណ៌
ស្តេចចូលនិព្វាន ទៅទើបមកមាន ទមាក់ដំរី ៗ ១ ឈ្មោះសោនមា-
ណពមានទ្រព្យ មានខ្ញុំប្រុសស្រី ក្របីគោសេះ រទេះដំរី មានចិត្តមេត្រី
ត្រេកត្រងសត្វា ៗ ធ្វើបុណ្យឲ្យទាន ពិព្យាយាមបាន លុះត្រៃសរណា-
គមន៍គិតពឹងពាក់ ពំនាក់សាសនា មានថ្ងៃ១មា- ណពនៅពុំក្សាន្ត ៗ
ជិះដំរីញី ឯងឥតគ្នាគ្នី ជាពីរទើងប្រាណ បរចូលទៅព្ធ ក្នុងព្រៃស្មសាន្ត

១ ពអំពីនេះទៅជាពាក្យមន្ត្រី ។

យល់ដើមល្ហុមាន ផ្លែទុំទាល់ចុង ៗ មាណពឡើងបេះ ផ្លែល្ហុប្រឡេះ ធ្លាក់ថ្មក់ពុំលង់ តើបពះពស់វែក កាចប្លែកទ្រទង់ ចឹងចាំត្រូវត្រង់ ដើម ដោះមាណព ៗ ធ្លាក់ចុះអំពី ចុងល្ហុដល់ដី ដួលដេកផ្កាលផ្ងប់ ផ្អៀងផ្អែក ផ្អកផ្អើស ទន្ទិះថែថប់ សញ្ជឹងសញ្ជប់ គន់គិតថែថា ៗ ចុះខុអគ្គអញ ឥឡូវនេះមិញ មិនមានទេណា មួយមកកំដរ ស្រែកកោលក្រោ ក្រែគ្រាន់ ជួយជា ពំនាក់អញបាន ៗ ទោះអញមានទ្រព្យ សារពើប្រដាប់ មាស ប្រាក់ធនធាន ប្រពន្ធកូនចៅ ញាតិផៅសន្តាន សោតសឹងមិនមាន មួយមកកំដរ ៗ មានតែព្រះគុណ ព្រះកែវរ័តនតន់ គិតគាប់គួរយក ពំនាក់អាត្មា កាលគ្រាកម្រ ទៀងទើបសូត្រសរ- សើរព្រះបារមី ៗ ឥតិបិសោ ចប់ដល់ពុទ្ធោ កតក់តី ហេតុតែតេជះ នៃព្រះបារមី សម្ដេច ជិនស្រី សព៌ជ្ញញ្ញេយ្យញ្ញាណ ៗ ឯអង្គទេព្តា រក្សាដើមល្ហុ នៅនោះ ពុំក្សាន្ត យកថ្នាំទិព្វទេស ពិសេសថ្កើងថ្កាន ចរចុះពាក់បាន មកមើលមា- ណព ៗ លាយលាបអស់អ- ង្គកាយគួរគង់ ជន្មជាតិជួយជប់ រលត់ រហាយ រសាយសុះសព្វ ជម្ងឺគ្រាន់ស្ងប់ ស្រាលស្រាន្តស្រាកស្រាន្ត ៗ ទោះទេព្តានោះ ពិតពុំជួយដោះ ដប់ជន្មឲ្យបាន មាណពនោះជា ទេព្តា សព្វបាន ដំទុំពុំក្សាន្ត ព្រោមព្រៃផងបណ្តាញ ៗ ពិតពីពីមាន មណ្ឌល បិតបាន ចរចុះពាកបេញ ហេតុនោះទេព្តា ដើមល្ហុបំពេញ ថ្នាំបាន នោះមិញ មកមើលទុកនាប់ ៗ (នៅមានត)

# ប្រវត្តិសាស្ត្រប្រទេសចិន

## ភាគទី ១

ឃ. និពន្ធមន្ត្រី ប្រែពិនិត្យរៀបរៀង ជាខេមរភាសា

## វគ្គទី ១

## ប្រវត្តិសាស្ត្រខាងដើមរបស់ចិន

ប្រសិនបើយើងពោលថា "ឥណ្ឌា" ទុកដូចជា "ក្រិក" របស់ទ្វីបអាស៊ី ៗ យើងក៏ត្រូវតែពោលថា "ចិន" ក៏ទុកដូចជា "រោម" របស់ទ្វីបអាស៊ីដែរ ៗ ព្រោះថា "ឥណ្ឌា" ដែលគេទុកដូចជា "ក្រិក" នោះ ដោយហេតុបានបណ្ដុះបណ្ដាលបង្កើតឲ្យមានសេចក្ដីចំរើន ខាងសិល្បកម្ម (ការរចនា) អក្សរសាស្ត្រនឹងសីលធម៌ដល់ប្រជាជននៅទ្វីបអាស៊ីទូទៅ ៗ ឯចិនក៏ត្រូវទុកជា "រោម" របស់អាស៊ី ព្រោះបានបណ្ដុះបណ្ដាលបង្កើតសេចក្ដីចំរើនខាងវិជ្ជាចម្បាំង, វិជ្ជានិយាយ នឹងវិជ្ជាប្រសាសនោបាយ ដល់ទ្វីបអាស៊ីច្រើនជាអនេកដែរ ៗ

មួយវិញទៀត ប្រទេសឥណ្ឌាមានលក្ខណៈដូចប្រទេសក្រិក ព្រោះបំបែកការគ្រប់គ្រងជាអាណាចក្រតូច ៗ ពេញទៅជាច្រើនអាណាចក្រណាស់ សឹងមានឥស្សរៈក្នុងការត្រួតត្រាស្រុកទេសដោយខ្លួនឯង ៗ ប្រទេសចិនមានលក្ខណៈដូចជារោម ព្រោះបានរួបរួមប្រទេសតូច ៗ ទៅ

ជាមហាណាចក្រយ៉ាងធំសំបើមក្រៃលែងជាងមហាណាចក្រពេម អំពីសម័យព្រេងនាយទៅទៀត ។

ទើបអ្នកប្រាជ្ញប្រវត្តិសាស្ត្រទាំងឡាយ មានសេចក្តីយល់ស្របគ្នាថា ការសិក្សាពង្សាវតាររបស់ប្រទេសទាំង ២ គឺចិនទឹងឥណ្ឌានេះ ត្រូវតែសិក្សាព្រមៗគ្នា ។

មានសេចក្តីអស្ចារ្យចំឡែកម្យ៉ាងទៀត ក៏គឺចិន ជាជាតិបុរាណមួយក្នុងលោកដែលមិនធ្លាក់ទៅជាប្រទេសកដរបស់ជាតិដទៃ ឬរលំរលាយជាតិដូចជាជនជាតិបុរាណចំពួកខ្លះនោះឡើយ ឬមានសេចក្តីរៀវពេយសាបសូន្យដល់ទៅតាំងប្រទេសជាតិមិនកើតនោះទេ ទុកជាកើតចលាចលវឹកវរខាងក្នុងស្រុក ដោយហេតុជាប្រទេសធំសំបើម លំបាកដល់ការត្រួតត្រាគ្រប់គ្រង ឬត្រូវជាតិដទៃសង្កត់សង្កិនយ៉ាងណាក៏ដោយ ចិនក៏មិនដែលសាបសូន្យរលត់រលាយជាតិទៅឡើយ គង់នៅជាចិនដដែលរហូតមក ។

ហេតុដែលនាំឲ្យជនជាតិចិនរឹងប៉ឹងដល់ម្លេះ ព្រោះចិនមានលក្ខណៈសំខាន់ ៣ ប្រការ គឺ: ១- សេចក្តីអត់ធន់ ២- សេចក្តីព្យាយាមខ្នះខ្នែង ៣- សេចក្តីស្រឡាញ់គ្រួសារ ។ លក្ខណៈទាំង ៣ ប្រការនេះ មិនមានជាតិណាស៊ូចិនបានឡើយ ។

ឯហេតុដែលនាំឲ្យជនជាតិចិន ប្រកបព្រមដោយលក្ខណៈទាំង ៣ ប្រការនោះ យើងគោងពិនិត្យពិចារណាមើលភូមិប្រទេសចិនឲ្យល្អិតល្អ បន្តិចសិន ព្រោះភូមិប្រទេសជាគ្រឿងអធិប្បាយពន្យល់បានជាក់ច្បាស់ ជាងហេតុដទៃទៀត ។

ប្រទេសចិននោះ ជាភូមិប្រទេសដ៏ធំទូលាយយ៉ាងសំបើម មាន ទំហំដីពាសពីជើងទៅត្បូងដល់ ៣.៥០០ គីឡូម៉ែត្រ ពាសពីទិសខាងកើត ទៅទិសខាងលិចដល់ ៥.០០០ គីឡូម៉ែត្រ ព្រំប្រទល់ទិសខាងជើងទល់ នឹងប្រទេសរុស្ស៊ីនិងទួរគីស្តង់ ទិសខាងកើតទល់នឹងសមុទ្រជប៉ុន ទិស ខាងត្បូងទល់នឹងប្រទេសយួន (តុងកឹង) ប្រទេសលាវ ប្រទេសភូមា ទិសខាងលិចទល់នឹងទួរគីស្តង់ ។ ឯភូមិប្រទេសខាងក្នុងនោះ មុនដំបូង យើងត្រូវស្គាល់ទន្លេធំៗ ពីរ គឺទន្លេហ្វាង-ហូនិងទន្លេយ៉ាងសេ ។

ទន្លេទាំង ២ នេះ មានដើមទឹកតាំងនៅជិតៗគ្នា នៅលើភ្នំខ្ពស់នៃ ប្រទេសទីបេត៍ ។ ខ្សែទឹកហូរធ្លាក់ចុះមកពីទិសខាងលិចទៅទិសខាងកើត លុះមកដល់ជង់ភ្នំស៊ិងលិងនិងជង់ភ្នំសេឆួន ទន្លេទាំង ២ នេះ ក៏បែកខ្វែក ឃ្លាតឆ្ងាយពីគ្នា ។ ទន្លេហ្វាង-ហូ បែកទៅខាងទិសខាងលិចខៀងខាង ជើង ទន្លេយ៉ាងសេ បត់ចុះមកទិសខាងកើតខៀងខាងត្បូង លុះទៅ ដល់ពាក់កណ្តាលវេងទិសខាងលិច និងទិសខាងកើតទន្លេហ្វាង-ហូក៏បត់ ត្រឡប់ចុះមកទិសខាងត្បូង ហើយមានសណ្ឋានគោងជាកែងដៃបត់ទៅ

រកទិសខាងកើត ឯទន្លេយ៉ាំង-សេ ក៏បត់ឡើងមករកគ្នា ហើយទន្លេទាំង ២ ក៏ហូរទន្ទឹមគ្នាពីទិសខាងលិចសំដៅទៅទិសខាងកើតទាំងគូ ចំណែកនេះផ្ទៃផែនដីនៅចន្លោះទន្លេទាំង ២ ក៏រៀវតូចទៅ ហើយមានព្រែកជ្រោះជ្រ-លងដងស៊ីង បឹង ត្រពាំងច្រើនឡើង ធ្វើឲ្យដីចំណែកនេះមានដីជាតិល្អបំផុត ទាល់តែបាក់ងសន្មតហៅថា "មេស្តូប៉ូតាមី-ចិន" ហើយនៅទីបំផុត ទន្លេទាំង ២ នេះក៏ហូរធ្លាក់ទៅក្នុងសមុទ្រលឿងជាមួយគ្នា ។

ទន្លេហ្វាង-ហូនិងទន្លេយ៉ាំងសេនេះ ជាទីកើតនៃអារ្យធម៌របស់ចិន ពោលគឺសេចក្ដីចំរើនរបស់ចិន ដែលមានដំណើរមកពីទិសខាងលិចទៅខាងកើតនោះ សឹងផុះផាលចំរើនឡើងតាមដងទន្លេទាំងពីរនេះឯង ។

ជាន់ដំបូងបង្អស់ ជនជាតិចិនបានតាំងឡាក់ឋាននៅត្រង់កណ្ដាលនៃទ្វីបអាស៊ី ហើយក៏សន្សឹមលើកចេញទៅខាងបូព៌ាទិសបន្តិចម្ដងៗ ហើយចូលទៅតាំងទីកន្លែងនៅតានស៊ុ, ហូណាន, ហូប៉េ, និងកៀងណាំជាដំបូង ។ រួចពីមកមាន ១ ពួកទៀត លើកចេញទៅត្រង់ផែនដីដែលមានក្ដៅហើយសំ-ដៅទៅទិសខាងត្បូង មាន ១ ពួកទៀតបត់ឡើងទៅខាងប៉េចិល៊ី ដែលនៅជាចំណែកទិសខាងជើង ។ ពួកដែលឡើងទៅខាងប៉េចិល៊ីនិងពួកទៅនៅទិសខាងត្បូង ក៏ក្លាយទៅជាពួកដោយខ្លួនទៅ មិនបានសេពគប់រកគ្នាជាវេលាយូរអង្វែង ដោយហេតុនេះហើយបានជាវេលាតមកក្នុងសម័យក្រោយ កាលដែលបានរួបរួមគ្នាជាអាណាចក្រតែមួយហើយ

ពួកចិនដែលនៅទិសខាងជើងនិងចិនដែលនៅទិសខាងត្បូង ទើបមានលក្ខណៈខុសគ្នាឆ្ងាយ ដូចមានបរិយាយក្នុងប្រវត្តិសាស្ត្រនេះតទៅ ។

ផែនដីដែលនៅត្រង់ភាគកណ្តាលនៃដងទន្លេទាំង ២ នេះជាទីដីមានដីជាតិបំផុត ទីទំនាបបំណែកនេះ តាំងពីភាគខាងជើងចុះមកដល់ភាគកណ្តាល ជាទីដែលហៅថា "ដីលឿង" ជាទីមានដីជាតិល្អណាស់ សម្រាប់ដាំដំណាំពោត, ស្រូវ និងបន្លែនានា គ្រប់ប្រការសឹងដុះលូតលាស់ល្អណាស់ រហូតដល់ទីទំនាបនៃដងទន្លេហ្វាង-ហូ និងយ៉ាំងសេ ស្ទើរតែមិនបាច់ដាំក៏ដុះល្អដែរ ។ កាលបើពួកចិន មកតាំងនៅត្រង់ទីកន្លែងដែលមានដីដីជាតិល្អ ក៏អាស្រ័យរបរក្សេត្រកម្មជាគ្រឿងចិញ្ចឹមជីវិត ទើបតាំងភូមិលំនៅជាឡាក់ហានតវង្សត្រកូលជាតំណតគ្នាជាច្រើនដំណមនុស្ស មិនផ្លាស់ប្តូរប្រែប្រួល ទើបនាំឲ្យជាតិចិនជាមនុស្សមានសេចក្តីពេញចិត្តស្រឡាញ់ទីកន្លែង ហើយដោយហេតុធ្វើរបរស្រែចម្ការច្បារដំណាំជានិច្ច ទើបធ្វើឲ្យចិនទៅជាមនុស្សមានអំណត់អត់ធន់, មានមានះ, ព្យាយាម, ក្លាហាន ថែរក្សាទំនៀមទម្លាប់របស់ខ្លួន ហើយចេះគោរពរាប់អានបុព្វបុរសរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ។ មួយវិញទៀតដោយហេតុលទ្ធិខុងជឺ បានជ្រាបចូលក្នុងចិត្តគំនិតរបស់ចិនទូទៅតាំងពីដំបូងមក ទើបធ្វើឲ្យចិនចេះជ្រើសរើសធ្វើការដែលមានប្រយោជន៍ទាន់ភ្នែកឃើញ ហើយមិនព្រមធ្វើការដែលសំឡឹងមើលមិនឃើញប្រយោជន៍នោះឡើយ ។ ទុកជាលទ្ធិតាវអ៊ីស្មបានទូន្មាន

ជាតិចិនបំពួកខ្លះឲ្យបេះបន់ស្រន់ឬបួងសួងទេពតាជាច្រើនក៏ដោយ ផង ជាតិចិនជាចំនួនច្រើន ក៏នៅតែមានលក្ខណៈ ខ្លាំងពួកមិនគិតសាសនាមានលើអាកាស ដូចយ៉ាងពួកមនុស្សបុរាណចំពួកខ្លះនោះទេ ។

កាលពីជាន់ដំបូង ៗ នៅឡើយ ចិនមានចំនួនមនុស្សនៅតិចនៅឡើយ ទើបចិនចំតែធ្វើស្រែចម្ការច្បារដំណាំមួយមុខបានស្រួលសប្បាយ ហើយអាចស្វែងរកសេចក្ដីសុខសប្បាយបានគ្រប់គ្រាន់មិនខ្វះខាត ខនេះ ជាហេតុនាំឲ្យចិនយល់ថា ស្រុកចិនជាប្រទេសចំរើនរុងរឿងល្អបំផុតក្នុងលោក កំឡាំងនៃសេចក្ដីស្រឡាញ់ជាតិភូមិ មានអំណាចជ្រួតជ្រាបសព្វសាច់សរសៃឈាម ចិនមិនត្រូវការប្រើភាសាឬរបស់ប្រើប្រាស់ពីប្រទេសក្រៅឡើយ ដោយយល់ថា មិនមានអ្វីរបស់ជាតិដទៃវិសេសជាងចិនទេ គោលគឺភាសាចិនជាភាសាល្អបំផុតក្នុងលោក, បន្លែចម្ការច្បារដំណាំ នៅស្រុកចិនជារបស់ល្អបំផុតក្នុងលោក ហេតុដូច្នេះហើយបានជាចិនមានសេចក្ដីស្រឡាញ់ពេញចិត្តនឹងជាតិ នឹងភូមិប្រទេសនឹងរបស់គ្រប់យ៉ាងដែលជារបស់ចិន ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រខ្លះ ដូចជាលោករ៉ឺនេ-គ្រុសេ្សត៍ មានសេចក្ដីយល់ថា របរដាំដំណាំនោះឯង នាំឲ្យមនុស្សនេះស្រឡាញ់ជាតិល្អបំផុត ព្រោះគេនឹកស្រយ័យព្រះធរណីជាគ្រឿងចិញ្ចឹមជីវិត ។

# អំពីជាតិកំណើតចិន

ភូមិប្រទេសដែលចិនតាំងនៅក្នុងសព្វថ្ងៃនេះ មិនមែនជាទឹកដែនដើមរបស់ចិនទេ ភូមិប្រទេសចិនសព្វថ្ងៃនេះ ចិនបានមកដោយច្បាំងតស៊ូទំនឹងពួកម្ចាស់ស្រុកជាន់ដើម ដោយវិធីរុករានទន្ទ្រានចូលបន្តិចម្តងៗត្រាតែតាំងនៅដោយខ្ជាប់ខ្ជួនបាន ។ ចុះពួកចិននេះមកអំពីទិសដំបន់ណា? ប្រស្នានេះ អ្នកប្រាជ្ញប្រវត្តិសាស្ត្រនៅដដែកគ្នាមិនទាន់ដាច់ស្រេច ខ្លះពោលថា ពួកចិនចេញមកពីស៊ីបេរី ខ្លះថាមកពីអឺរង់ ខ្លះថាមកពីមេសូប៉ូតាមីជាពូជខ្សែស្រឡាយស៊ីលពេ ។ តែដែលពោលត្រូវគ្នាដោយច្រើននោះ ថាពួកជាតិចិនចេញមកពីទន្លេសាបកាស្ពីយ៉ែន ឫសគល់កំណើតដើមរបស់ចិននៅតាមតំបន់ទន្លេសាបកាស្ពីយ៉ែននេះ ប្រហែលក្នុងឆ្នាំ ១៩១០ មុនព្រះពុទ្ធសករាជ ពួកចិនបាននាំគ្នាលើកចេញមកពីទន្លេសាបកាស្ពីយ៉ែន ចូលមកតាំងនៅក្នុងតំបន់កុចគារី ហើយលើកចេញពីកុចគារីមកតាំងនៅក្នុងដែនដីដែលហៅថា ប្រទេសចិនសព្វថ្ងៃនេះ ។ ឯស្រុកដែលចិនចូលទៅតាំងទីលំនៅជាឡាក់ហានក្នុងគ្រាដំបូងនោះ គេយល់ថា ជាស្រុកចាន់-ស៊ី និងប៉េចិលី តមកទើបពង្រីកអាណាខេត្តចេញទៅដល់ចេន-ស៊ី, ហ៊ូ-ណាននិងចន-ទុង ដែលតាំងនៅទិសខាងជើងនៃទន្លេហ្វាង-ហូ ហើយទើបឆ្លងទន្លេហ្វាង-ហូចូលមកតាំងនៅចន្លោះទន្លេហ្វាង-ហូ និងយ៉ាំងសេ ដែលជាភូមិប្រទេសមានដីជាតិបំផុតដូចពោលរួចមកហើយ ។

តាមដោយពិតនោះ ផែនដីដែលចិនលើកមកតាំងនៅថ្ងៃនេះ មិនមានទីណាឥតមនុស្សនៅទេ គ្រប់ៗតំបន់ សឹងមានប្រជាជនជាម្ចាស់ដើមគ្រប់គ្រងក្រញាំងអស់ ហេតុនេះហើយ ទើបត្រូវតែចិនច្បាំងតស៊ូនឹងម្ចាស់ស្រុក ដែលនៅមុនជាវេលាច្រើនឆ្នាំហើយជាច្រើនជំណមនុស្សណាស់ ៗ ឯពួកមនុស្សជាម្ចាស់ដើមក្នុងផែនដីដែលចិនរុកចូលមកនោះ គឺពួកជាតិទីបេតាំង ដែលថយចុះទៅទិសខាងត្បូង ហើយក្លាយទៅជាជនជាតិឥណ្ឌូស៊ីន មន, ខ្មែរ, ភូមា, កូឡា, ថៃ, យួន ៗ ផែនដីនៅទិសខាងលិចឆៀងខាងជើងនោះ ដាច់ដើមមានពួកជាតិស៊ីងតាំងនៅ ជនពួកនេះជាពួកអ្នកចម្បាំងកាន់លំពែងនិងធ្នូ ដែលជាអាវុធសំខាន់មួយរបស់ចិនក្នុងសម័យបុរាណ ផែនដីចំណែកនេះជាទីតាំងនៃស្រុកទេន-ស៊ី កាលដែលពួកចិនដណ្តើមយកស្រុកទេន - ស៊ីទៅបាន ពួកស៊ីងក៏ក្លាយទៅជាសត្រូវយ៉ាងសំខាន់របស់ចិន លុះដល់មកឆ្នាំមុនពុទ្ធសករាជ ២២៧ ពួកស៊ីងក៏ចាប់តាំងប្រទូស្សរាយពួកចិន ទាល់តែចិនត្រាំនៅមិនបានតោងផ្លាស់ទីក្រុងចេញពីស្រុកទេន-ស៊ី មកតាំងក្រុងនៅស្រុកហ៊ូ-ណាន់ ៗ ចំណែកឯផែនដីដែលមានដីជាតិល្អនៅត្រង់ចន្លោះកណ្តាលទន្លេទាំង ២ ហើយមានស្រុកដ៏ស្តុកស្តម្ភហៅថាហ៊ូ-ប៉េ ពីដើមនោះជាស្រុករបស់ជាតិមន, ថៃ ៗ កាលពួកចិនរុករានទន្ទ្រានចូលមកដល់តំបន់នេះហើយ ពួកមន-ថៃក៏ថយទៅខាងទន្លេយ៉ាំងសេ

ទីនទាងខេត្តដែនហ៊ូ-ណានទីបានតាំងនៅក្នុងដែនដីអស់នេះ ទីនគ្រ ពស្សក្រោពតមកបានរហូតដល់ពុទ្ធសករាជ ៥០០ ហើយគមកទើបចុះមក នៅខេត្តដែនយុន-ណាន់ ហើយតាំងជាអាណាចក្រទឹងមានទាហាន សម្រាប់ការពារគ្រស្រុកហៅថា អាណាចក្រណាន-ចៅ ។ ចំណែក ខាងក្នុងតុង ក្នុងសម័យដែលពួកចិនរុកកានទន្ទ្រានមកនោះ ជាន់ដើម ជាដែនដីរបស់ជាតិយួន ។ ជាម្ចាស់ស្រុកលើដែនដីចំណែកនេះរហូតដល់ ព្រះពុទ្ធសករាជ ៤៣២ ។

ពួកចិនដែលលុកលុយចូលមកក្នុងដែនដីនេះ ក្នុងជាន់ដំបូងនោះ ពេញដោយចម្បាំងរាំងដល់កាប់សម្លាប់គ្នាយ៉ាងសំបើម ទើបពួកចិន ទន្ទ្រានចូលទៅបានយ៉ាងយឺត ៗ ។ មានអ្នកប្រាជ្ញប្រវត្តិសាស្ត្រគិត ប្រមាណថា រាប់តាំងពីវេលាដែលពួកចិនលើកចេញពីភ័ពគារ មកតាំងនៅ ក្នុងចាន់-ស៊ីក្នុងអំណាចមហាក្សត្រព្រះនាមយៅនោះ ជាវេលា ៦០០ ឆ្នាំ ទើបបានតាំងនៅខ្ទាប់ខ្ទួនក្នុងដែនចាន់-ស៊ី កាលប្រមាណមុនព្រះពុទ្ធ-សករាជ ១៨០០ ឆ្នាំ រួចមកតាំងនៅក្នុងដែនហ៊ូ-ណាន់ ក្នុងអំណាចព្រះ មហាក្សត្រព្រះនាមដុន កាលរាង់មុនព្រះពុទ្ធសករាជ ១៧០០ ឆ្នាំតមក ទៀតប្រមាណ ៥០ ឆ្នាំ ទើបព្រះមហាក្សត្រព្រះនាមយូ វាយរាតអាណា-ខេត្តបានស្រុកផ្សេងៗ នៅទិសខាងត្បូងនៃទន្លេលឿង (គឺទន្លេហ្វាង-ហូ) ។ សករាជដែលប្រាប់មកនេះគ្រាន់តែជាគ្រឿងសន្និដ្ឋាន មិនទាន់មានឡាក់

បានជាពិតប្រាកដទេ តែតាំងពីនោះទៅ ទើបសករាជមានទំនងទៀងទាត់ ល្មមជឿប្រកាន់បាន គឺចាប់តាំងពីពួកចិនលើកទៅតាំងនៅសាំងហាយ កាលមុនព្រះពុទ្ធសករាជ ៥៧៩ ឆ្នាំ ហើយតមកទៀតប្រហែល ២០០ ឆ្នាំ គឺក្នុងរវាងពុទ្ធសករាជ ១៧០ ទើបចូលទន្លេយ៉ាំង-សេ ទៅបានរហូតដល់ព្រះពុទ្ធសករាជ ៣០០ ឆ្នាំ ទើបចិនលុកលុយទន្ទ្រានយកបានរហូតដែនដីដែលហៅថា ប្រទេសចិនសព្វថ្ងៃនេះ ។

ពង្សាវតារចិនក្នុងចំណែកនេះ ក៏មានរឿងរ៉ាវកម្រនឹងជឿថា មានសេចក្តីពិតនៅត្រឹមណាទេ ប៉ុន្តែមានឈ្មោះមនុស្សសំខាន់ៗ ដែលគួរប្រកាន់យកជាការពិតបាន គឺ: ហ្វូ-អ៊ី ជាអ្នកគិតបង្កើតអក្សរចិនឡើង ចិន-នុង ជាអ្នកគិតធ្វើយានមានកង់ឡើង រ៉ុង-ទី ជាអ្នកកសាងតម្រាភាពសាស្ត្រឡើង ហើយមានក្សត្រដែលជាមហាអំណាច ៣ ព្រះអង្គ គឺព្រះមហាក្សត្រព្រះនាម យ៉ៅ, ជុន, យូ ដែលជាមហាក្សត្រ ៣ ព្រះអង្គដំបូងក្នុងពង្សាវតារចិន ។

## ស្រុកចិនកើតអ្នកប្រាជ្ញសីលធម៌

ពង្សាវតារនៃរាជវង្សក្សត្រចិនដំបូងៗ ដូចជារាជវង្សហៀ ដែលមានសេចក្តីដំណាលថា ទ្រង់គ្រងរាជសម្បត្តិនៅក្នុងរវាងមុនព្រះពុទ្ធសករាជ ១៦៦២ ឆ្នាំ ដល់មុនពុទ្ធសករាជ ១២២៣ ឆ្នាំ នឹងរាជវង្សតាង ដែលគ្រងរាជសម្បត្តិនៅក្នុងរវាងមុនពុទ្ធសករាជ ១២២៣ ឆ្នាំ

ដល់មុនពុទ្ធសករាជ ៥៧៩ ឆ្នាំ នោះមានទំនងជារឿងនិទានច្រើនជាងសាច់ប្រវត្តិសាស្ត្រ ។ ឯប្រវត្តិសាស្ត្រដែលទៀងទាត់នោះ ទើបនឹងចាប់មានឡើងតាំងពីផែនដីរាជវង្សចៅ ដែលគ្រងរាជសម្បត្តិមុនពុទ្ធ-សករាជ ៥៧៩ ឆ្នាំ រហូតមកដល់ពុទ្ធសករាជ ៦៨៨ ។ រាជវង្សនេះមានខ្សែស្រឡាយចេញមកពីចេន-ស៊ី តែកាលត្រូវពួកមនុស្សព្រៃ គឺពួកទ័ពតាំង ប៉ុហ្វូន ប៉ុគាត (ពួកចិន តាមធម្មតា ហៅជនជាតិដទៃក្រៅពីចិនជាមនុស្សព្រៃទាំងអស់) រុករានចូលមក ក៏ផ្លាស់ស្រុកក្រុងពីចេន-ស៊ី ទៅតាំងក្រុងនៅស្រុក ហ៊ូ-ណានវិញ វេលានេះចិនហៅថា ហូ-ណានហ្វូ ។ របៀបគ្រប់គ្រងស្រុកទេសក្នុងសម័យនោះជារបៀបស្តេចត្រាញ់គ្រប់គ្រងនគរតូច ៗ ដាច់ ៗ ដោយឡែកពីគ្នា ឯព្រះមហាក្សត្រដ៏ជាធំនោះគ្រាន់តែជាប្រមុខទុកដូចរូបអក្គា មិនមានអំណាចត្រួតត្រាស្រុកទេសរហូតដែនដីរបស់ព្រះអង្គបានទេ ។ ពង្សាវតារចិនក្នុងសម័យនេះ មិនមែនមានរឿងសំខាន់ ៗ កើតមកពីមហាក្សត្រឡើយ ។ ហេតុសំខាន់ដែលកើតឡើង គឺកើតអ្នកប្រាជ្ញខាងសីលធម៌មានឈ្មោះថា ខុងជឺ ជាដើម ។

ពាក្យថា "ខុងជឺ, ខុងជូ, កុងស៊ុ, ប៉ុកុងកូស៊ុ" ជាឈ្មោះរបស់អ្នកប្រាជ្ញចិនម្នាក់ ជាដំបូងបំផុតដែលបានចាត់របៀបរៀបចំសីលធម៌ ទូន្មានដល់ប្រជាជនជាតិចិន លោកអ្នកប្រាជ្ញនេះធ្លាប់ហៅថា "កុងហ៊ុយស៊ុ-

យុស" ។ លោកអ្នកប្រាជ្ញនេះកើតឡើងបានអាយុ ៨ ខួប ទើបព្រះសម្មាសម្ពុទ្ធរបស់យើងបរិនិព្វានទៅ ស្រុកកំណើតរបស់លោកជាភូមិមួយតូច ក្នុងខេត្តចាន់ ទុងឬសង់-ទុង ជាចំណុះអាណាចក្រលូ ចាប់ផ្តើមសិក្សារៀនសូត្រតាំងពីអាយុបាន ១៥ ឆ្នាំ ដល់មានអាយុបាន ២២ ឆ្នាំ ទើបតាំងខ្លួនជាគ្រូបាអាចារ្យ បានទេសនាប្រដៅខ្លួនមហាជនរហូតដល់មកអាយុ ៥០ ឆ្នាំ ទើបបានទទួលនាទីធ្វើជាចៅហ្វាយស្រុកនៅស្រុកមួយ ហើយតមកទៀតទើបឡើងជាទី អគ្គមហាសេនាបតី (សេនាបតីទី ១ ឬនាយករដ្ឋមន្ត្រី) នៃអាណាចក្រលូ ។ មានសេចក្តីដំណាលថា: ខុងជឺបានប្រាប់ប្រាមកំចាត់ពួកអាមាត្យទុច្ចរិត (ដែលធ្លាប់តែមានមិនសូវមានក្នុងពង្សាវតារចិន) ចេញអស់ជាច្រើន ។ តមកមានសេចក្តីដំណាលថា សម្តេចព្រះមហាក្សត្រលូ ទ្រង់ជឿស្តាប់ពាក្យញុះញង់នាងព្រះស្នំឯករបស់ទ្រង់ មិនយកព្រះទ័យទុកដាក់នឹងពាក្យសំដីទាំងមិនគួរការឲ្យខុងជឺជួយទំនុកបំរុងទ្រង់តទៅទៀតទេ ទើបខុងជឺគៀសដោះខ្លួនចេញទៅនៅយ៉ាងស្ងាត់ៗឯស្រុកវេគី ហើយបានចាប់ផ្តើមសរសេរកម្រាប់កម្រាសំដែងពីលទ្ធិរបស់លោកទុកជាកេរ្តិ៍មត៌កតមក រួចលោកត្រឡប់មកអាណាចក្រលូវិញ ហើយអនិច្ចកម្មទៅ ក្នុងជន្មាយុកំណត់ ៧៩ ឆ្នាំ ។

លទ្ធិរបស់ខុងជឺនេះ ប្រជាជនជាតិចិនមានសេចក្តីគោរពរាប់អានតាំងពីបុរាណរហូតមកដល់សម័យសព្វថ្ងៃនេះ ទើបគួរចាត់ទុកលោកនេះ

ជាមហាបុរសមួយ ដែលបានចាត់របៀបសីលធម៌យ៉ាងសាមញ្ញនឹងទៀងទាត់ល្អណាស់ ៗ លទ្ធិរបស់ខុងជឺមានគោលសំខាន់សំដែងថា "បើអ្នកមិនត្រូវការឲ្យអ្នកដទៃធ្វើដល់អ្នកយ៉ាងណា កុំអ្នកធ្វើដល់គេយ៉ាងនោះ, អ្នកត្រូវការឲ្យអ្នកដទៃធ្វើដល់អ្នកយ៉ាងណា អ្នកត្រូវធ្វើដល់គេយ៉ាងនោះ, គប្បីស្រឡាញ់អ្នកដទៃដូចជាខ្លួនរបស់អ្នកឯង" គោលសីលធម៌នេះ ស្តាប់មើលក៏ឃើញថាងាយៗ មិនមែនជាការកម្របូរជ្រាលជ្រៅអ្វីឡើយ ប៉ុន្តែប្រសិនបើមនុស្សលោកប្រតិបត្តិតាមបានគ្រប់ ៗ រូបហើយ ពិភពលោកនេះ នឹងប្រកបដោយសេចក្តីសុខក្សេមក្សាន្តក្រៃលែង ជាងសព្វថ្ងៃនេះជាច្រើនរយភាគ ៗ ប៉ុន្តែខុងជឺមិនមានលក្ខណៈជាអ្នកតាំងបង្កើតសាសនាថ្មី ដូចជាសាស្តាទាំងឡាយ ព្រោះគោលសីលធម៌របស់ខុងជឺនោះ មិនមែនខុងជឺជាអ្នកបញ្ញត្តិ ឬគិតរកបានដោយខ្លួនឯងទេ គ្រាន់តែជាអ្នកប្រមូលរួបរួមទំនៀមទម្លាប់ ប្រពៃណី, ដំបូន្មាន, សុភាសិតនឹងគំនិតគិតគូ របស់អ្នកប្រាជ្ញដែលជាចាស់បុរាណមុនសម័យខុងជឺឡើងទៅ ហើយយកមកចងក្រងទុកជាបញ្ញាប់តមក ៗ ខុងជឺជាអ្នកប្រាជ្ញដែលមិនពោលអាងដល់ស្ថានសួគ៌ឡើយ ហើយបើមានគេមកចោទសួរលោកអំពីរឿងស្ថានសួគ៌ លោកតបថា "សូម្បីតែរឿងការនៅលើផែនដីកម្រនឹងដឹងបានសព្វគ្រប់ទៅហើយ ទំងដឹងដល់ទៅរឿងការក្នុងស្ថានសួគ៌ដូចម្តេចបាន" ៗ ប្រការមួយទៀត ខុងជឺមានលក្ខណៈវិសេសម្យ៉ាង ដែល

គួរសរសើរយ៉ាងក្រៃលែង នៅក្នុងចំណោមគណាចារ្យជាអ្នកបង្កើតលទ្ធិទាំងឡាយ គឺថា ខុងជឺមិនដឹងការអ្វី ក៏ពោលត្រង់ៗថាមិនដឹង ទាំងបានបញ្ញត្តិជាសុភាសិតប្រចាំខ្លួនលោកថា "ការអ្វីដែលដឹងត្រូវពោលថាដឹង, ការអ្វីដែលមិនដឹងត្រូវពោលថាមិនដឹង, នេះហើយដែលហៅថាជាអ្នកដឹងតាមពិត" ។ តាមទំនងនេះទើបឃើញថា ខុងជឺខុសនឹងសាស្តាដទៃៗជាច្រើន ប៉ុន្តែឱវាទរបស់ខុងជឺក៏មិនសូវជាពេញលេញបរិបូណ៌ទេ គឺថា ព្រះសម្មាសម្ពុទ្ធរបស់យើងទ្រង់ទូន្មានដល់ប្រយោជន៍ ៣ យ៉ាង គឺ: ទិដ្ឋធម្មិកត្ថប្រយោជន៍ ប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ១ សម្បរាយិកត្ថប្រយោជន៍ ប្រយោជន៍ទៅជាតិមុខទៀត១ បរមត្ថប្រយោជន៍ ប្រយោជន៍យ៉ាងធំក្រៃលែង គឺព្រះនិព្វាន ១ ។ ព្រះយេស៊ូទូន្មានត្រឹមប្រយោជន៍ ២ យ៉ាងគឺ: ទិដ្ឋធម្មិកត្ថប្រយោជន៍និងសម្បរាយិកត្ថប្រយោជន៍ប៉ុណ្ណោះ មិនដល់ទៅបរមត្ថប្រយោជន៍ដូចព្រះពុទ្ធជាម្ចាស់នៃយើងទេ ឯខុងជឺកាន់តែរួញខ្លីជាងនេះទៅទៀត គឺសេចក្តីទូន្មានប្រៀនប្រដៅរបស់លោកតែត្រឹមទិដ្ឋធម្មិកត្ថប្រយោជន៍ប៉ុណ្ណោះ ។ ទុកជាពាក្យប្រៀនប្រដៅរបស់ខុងជឺ មិនមានវង់ធំទូលាយដូចជាសាស្តាឯទៀតៗក៏ដោយ តែអ្នកប្រាជ្ញទាំងឡាយសឹងមានយោបល់យល់ត្រូវគ្នាថា ខុងជឺជាមហាបុរសមួយរបស់ទ្វីបអាស៊ី ដោយបានរៀបចំគោលសីលធម៌យ៉ាងប្រពៃទុកឲ្យប្រទេសចិន ហើយបានផ្សាយចេញទៅក្រៅប្រទេសចិន

ជាច្រើនផង ៗ តមកមានអ្នកប្រាជ្ញម្នាក់ទៀតហៅថា "ម៉េង-ស៊ុ" ដែលគួររាប់ថាជាសាវករបស់ខុងជឺយ៉ាងសំខាន់មួយ តែមិនបានទាន់ឃើញខុងជឺទេ ព្រោះម៉េង-ស៊ឺ កើតក្នុងពុទ្ធសករាជ ១៧១ (ខុងជឺអនិច្ចកម្មទៅហើយបាន ១០០ ឆ្នាំ) នៅក្នុងអាណាចក្រលូវែរ ៗ ម៉េង-ស៊ុ បានសិក្សារៀនសូត្រលទ្ធិរបស់ខុងជឺពីចៅរបស់ខុងជឺ ហើយបានប្រកាសផ្សាយលទ្ធិរបស់ខុងជឺ បានទទួលដំណែងក្នុងរាជការជាអគ្គមហាសេនាដូចជាខុងជឺ បានប្រកាសផ្សាយលទ្ធិរបស់ខុងជឺឲ្យកាន់តែរីកចំរើនឡើងតទៅទៀត ប៉ុន្តែសេចក្តីទូន្មានរបស់ ម៉េង-ស៊ុ ខុសគ្នានឹង ខុងជឺបន្តិច គឺម៉េង-ស៊ីយកចិត្តទុកដាក់ទូន្មាន ខាងគោលវិជ្ជាការផែនដីច្រើនជាងច្បាប់សីលធម៌ ម៉េង-ស៊ុ អនិច្ចកម្មកាលអាយុបាន ៨៣ ឆ្នាំ អាយុយឺនយូរជាងខុងជឺ ៤ ឆ្នាំ ។

លទ្ធិសាសនាចិន ក្រៅពីដែលពោលមកនេះ នៅមានលទ្ធិមួយទៀតដែលពួកចិននៅកាន់គោរពរាប់អានតមកដល់សម័យនេះ គឺលទ្ធិតៅអ៊ីស្ម លោកអ្នកប្រាជ្ញដែលបង្កើតលទ្ធិនេះហៅថា ឡៅស៊ុ កើតមុនខុងជឺ ៥៣ ឆ្នាំ គឺកើតមុនពុទ្ធសករាជ ៦១ ឆ្នាំ ៗ ការអនិច្ចកម្មរបស់លោកអ្នកប្រាជ្ញនេះ ជាការចំឡែកអស្ចារ្យ គឺបាត់ទៅឯងមិនមានដានស្នាមលំអានអ្វីឡើយ ក្នុងខណៈដែលលោកត្រាច់ចារិកទៅក្នុងអាណាចក្រផ្សេង ៗ នៅទិសខាងកើតនៃប្រទេសចិន ៗ លទ្ធិតៅអ៊ីស្មនេះប្រកាន់ថាមានព្រះជាម្ចាស់ដ៏ជាធំ ត្រូវធ្វើពិធីបន់ស្រន់បួងសួងអង្វរ ទើបព្រះដ៏ជា

ធំ ទ្រង់សព្វព្រះទ័យប្រោសប្រាណ ។ តមកលទ្ធិនេះក្លាយទៅជាកប់អានខ្មោចបិសាច ទេវតា ទីងសំពះកប់អានអ្នកតា ដែលពួកចិនចំពួកខ្លះជាប់កប់អានតមកដល់សម័យនេះ ។

ក្នុងសម័យដែលស្រុកចិនកំពុងកើតសំបូរអ្នកប្រាជ្ញសីលធម៌ ដែលស្វែងរកសេចក្ដីចំរើនខាងផ្លូវសតិបញ្ញា នឹងខាត់រៀបសីលធម៌ដល់ប្រជា-ជនជាតិចិននោះ ប្រទេសចិនបានបែកខ្ញែកចេញទៅជាច្រើនអាណាចក្រ សឹងមានក្សត្រគ្រប់គ្រងដាច់ដោយឡែកៗ ទើបកើតចម្បាំងទាំងកាប់សម្លាប់គ្នាឥតស្រាក កាលបើកើតចម្បាំងកាំងដល់ដូច្នោះហើយ បណ្ដាអាណាចក្រតូចៗ ក៏រលំរលាយបាត់អស់ទៅ ដោយការរួបរួមជាមួយនឹងអាណាចក្រធំៗ នៅទីបំផុតនៅសល់តែត្រឹមពីរអាណាចក្រ ដែលមានទីក្រុងឃ្លាតឆ្ងាយពីគ្នាច្រើន គឺអាណាចក្រ ១ ហៅថា ចិន (ជិន · ស៊ិន) តាំងទីក្រុងនៅស្រុកចេន – ស៊ី អាណាចក្រមួយទៀតហៅថា ជូ (ចូ · ស៊ូ) តាំងទីក្រុងនៅហូ – ប៉េ ។ អាណាចក្រទាំងពីរនេះ បានច្បាំងកាប់សម្លាប់ប្រជាជនពួកឯទៀតៗ ទាល់តែវិនាស ឬថយរត់អស់ទៅ ឬចូលមកជាចំណុះក្រោមត្រួតត្រា ហើយតមកទៀត អាណាចក្រទាំងពីរ គឺចិននឹងជូកើតចម្បាំងនឹងគ្នាទៀត នៅទីបំផុត ពួកចិនមានជ័យជំនះ ព្រះមហាក្សត្រចិនទ្រង់ព្រះនាម ហ៊ាង-ឈិង បានតាំងព្រះអង្គគ្រប់គ្រងមហា-អាណាចក្រចិនទាំងមូល កាលពីព្រះពុទ្ធសករាជ ២៩៧ មានព្រះនាមថា

វ៉ុង-ទី (ឱរសរបស់ស្ថានសួគ៌) ដែលជាដំណែងប្រហែលនឹងសេសាររបស់ក្រុងរោម ។ ឯព្រះរាជវង្សរបស់ព្រះអង្គហៅថារាជវង្សឆិនឬចិន ។ ទីក្រុងថ្មីនៃព្រះរាជាធិរាជព្រះអង្គនេះ តាំងនៅក្នុងទីក្រុមិលនៅដើមរបស់ព្រះអង្គគឺស្រុកហៀន-ហុង នៅទិសខាងកើតនៃស្រុក ស៊ុ-ង៉ាន ក្នុងនៃត្រេបន-ស៊ី ។

វ៉ុង-ទីអង្គនេះ ជាអ្នកគ្រប់គ្រងរាជអាណាចក្រ ជាមេទ័ព បានគ្រប់គ្រងស្រុកចិនទាំងមូល ដែលគួរកប់ថាជាសេសារអង្គដំបូងនៃទ្វីបអាស៊ីទិសខាងកើត ។ ទ្រង់បានគ្រប់គ្រងរាជសម្បត្តិបាន ៣៦ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ២៩៧ ដល់ពុទ្ធសករាជ ៣៣៣ ។ តាមដោយពិតរាជអាណាចក្រថ្មីនេះ មិនមែនជារូបភូមិប្រទេសថ្មីទេ ព្រោះតាំងពី ២៥០ ឆ្នាំមកហើយ ខុងជឺបានព្យាយាមកែប្រែទំនៀមទម្លាប់ប្រពៃណី ហើយប្រកាសទូន្មានផ្សាយសីលធម៌ទុកមកជាច្រើនណាស់មកហើយ ទើបធ្វើឲ្យលទ្ធិរបស់ខុងជឺជាប់នៅស្អិតក្នុងចិត្តរបស់ពួកមល្លុក្សត្រ (ស្ដេចត្រាញ់) នឹងចិត្តគំនិតរបស់ប្រជាជនទាំងឡាយ ដោយបុព្វបុរសរបស់ខ្លួនបានទទួលដំបូន្មានផ្ដាល់មកអំពីខុងជឺ ហើយទទួលអប់រំតាមបែបមល្លុក្សត្រមកអំពីបុរាណកាល ។ ឯព្រះបាទវ៉ុង-ទី ដែលទ្រង់បានរួបរួមអាណាចក្រចូលជាមួយគ្នានោះ មិនត្រូវការឲ្យមានមល្លុក្សត្រគ្រងនគរតូច ៗ តទៅទៀត ប៉ុន្តែបើទ្រង់ចាត់ចែងកែប្រែត្រាណា ក៏ត្រូវពួករាជអាមាត្យទទឹងទាស់មិន

យល់ព្រមផង ដោយអាងផលលទ្ធិរបស់ខុងជឺជាមហាអ្នកប្រាជ្ញជានិច្ច ។ ព្រះបាទវុង-ទី ទ្រង់មិនដែលឃើញរូបកាយខុង-ជឺដូចម្តេចទេ គ្រាន់តែទ្រង់ធ្លាប់តែឃើញក្បួនខ្នាត ដែលពួកអ្នកកាន់លទ្ធិខុងជឺ បានរៀបចំតែងឡើងទើបជាហេតុនាំឲ្យព្រះបាទវុង-ទី ទ្រង់ស្អប់លទ្ធិខុងជឺពន់ពេក ព្រោះជាហេតុចំទាស់នឹងប្រសាសនោបាយរបស់ព្រះអង្គ ហើយទ្រង់មិនសព្វព្រះទ័យឲ្យអ្នកណាកាន់លទ្ធិនេះតទៅទៀត ទើបទ្រង់ឲ្យដុតបំផ្លាញសៀវភៅក្បួនខ្នាតផ្សេងៗជាច្រើន ដែលពួកអ្នកប្រាជ្ញអស់នោះបានតែងទុកមក រឿងដុតសៀវភៅក្បួនខ្នាតនេះ ជារឿងសំខាន់មួយក្នុងប្រវត្តិ-សាស្ត្ររបស់ចិន តែសេចក្តីប្រាថ្នារបស់ព្រះអង្គមិនសម្រេច ដ្បិតប្រទេសចិន កាលដែលនៅគ្រប់គ្រងជារបៀបមល្លក្សត្រ ញែកបំបែកត្រួតស្រុកដាច់ដោយឡែកៗនោះ ចិត្តគំនិតរបស់ប្រជាជន ប្រកបដោយសេចក្តីគោរពបូជាយ៉ាងជាប់ស្អិតក្នុងលទ្ធិខុងជឺមកហើយ លុះត្រាតែណាក្សត្រសក្តិសិទ្ធិដូច្នោះ គួរតែនាំគ្នាគោរពខ្លាចព្រះបរមតេជានុភាពរបស់មហាក្សត្រ ត្រឡប់ជាខឹងនឹងព្រះមហាក្សត្រហើយកាន់តែគោរពបូជាលទ្ធិខុងជឺច្រើនឡើងថែមទៀត ទើបកើតទៅជាចលាចលកាប់សម្លាប់គ្នាកើតឡើង លុះអស់បុណ្យព្រះមហាក្សត្រអង្គនេះហើយ លទ្ធិខុងជឺត្រឡប់ជាចំរើនរុងរឿងឡើងវិញ ដោយព្រះមហាក្សត្រក្រោយៗ មកទ្រង់ជួយឧបត្ថម្ភពេញបន្ទុក ។

ក្នុងសម័យដែលពួកចិនតាំងឡាក់ហានបានខ្ជាប់ខ្ជួនហើយ មានរបៀបគ្រប់គ្រងត្រួតត្រាស្រុកមាំមួន ទីងមានសេចក្ដីចំរើនរុងរឿងដូច្នោះ ពួកហ្វូនឬពួកមង្គុលក៏រុករានទន្ទ្រានរកទីកន្លែងសម្រាប់តាំងឡាក់ហានខ្លះដែរ ។ កាលពីក្នុងសម័យរ៉ុង-ទី ពួកហ្វូន ដែលចិនហៅថាហាង-នូ ហៀង-នូ នោះ ចូលទៅទន្ទ្រានយកដែនដីខាងសមុទ្រជប៉ុន ។ ព្រោះចៅកជាធិកដរ៉ុង-ទី ទ្រង់ព្យាយាមតស៊ូបណ្ដេញពួកនេះជាវេលាយូរ នៅទីបំផុតទ្រង់កសាងកំពែងយ៉ាងធំសំបើមសម្រាប់ស្រុកចិនឡើង កាលពីពុទ្ធសករាជ ៣២៩ ជារយៈវែងដល់ ៣.៣០០ គីឡូម៉ែត្រ គួរចាត់ជាការកសាងយ៉ាងសំបើមបំផុត ដែលមានជាប់តរហូតមកដល់ឥឡូវនេះ កំពែងបានកសាងឡើងសម្រាប់ការពារការលុកលុយនៃពួកហ្វូន តែមិនសូវជាការពារបានចំណាប់ប៉ុន្មានទេ ។ ឯដែនដីនៅពាក់កណ្ដាលទ្វីបអាស៊ី ពួកហ្វូនក៏រុករានទន្ទ្រានចូលទៅ ត្រាតែពួកយូអេជីគោងថយចូលទៅក្នុងប្រទេសឥណ្ឌា ទៅត្រដែនមង្គុលក៏ធ្លាក់ទៅនៅក្នុងអំណាចពួកហ្វូនទាំងអស់ ។

(នៅមានត)

---

## បញ្ជីរាយនាមមន្ត្រីសង្ឃនិងចៅអធិការ

ដែលសម្តេចសង្ឃនាយកគណៈមហានិកាយបានតែងតាំងឡើងក្នុងខែដេសំប្រ៍ឆ្នាំ ១៩៤២

១— សញ្ញាប័ត្រលេខ ១១៤ ចុះថ្ងៃ ១៧-១២-៤២ តាំងគ្រូសូត្រ អេង-ឈុន កើតឆ្នាំកុរ អាយុ ៦៨ វស្សា ៣៨ នាមឆាយា ធម្មត្ថេរ ជាចៅអធិការវត្តសំរិទ្ធិជោគ ឃុំចុងកោះសំពេង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

២— សញ្ញាប័ត្រលេខ ១១៥ ចុះថ្ងៃ ១៧-១២-៤២ តាំងគ្រូសូត្រ សៅ-មៀច កើតឆ្នាំរោង អាយុ ៣៩ វស្សា ១៩ នាមឆាយា ឥន្ទត្ថេរ ជាចៅអធិការវត្តអន្ទង់ស្វែង ឃុំដៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល ។

៣— សញ្ញាប័ត្រលេខ ១១៦ ចុះថ្ងៃ ១៧-១២-៤២ តាំងគ្រូសូត្រ ឡុង-សុិម កើតឆ្នាំឆ្លូវ អាយុ ៣០ វស្សា ៩ នាមឆាយា ចន្ទត្ថេរ ជាចៅអធិការវត្តអំពិល ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង ។

៤— សញ្ញាប័ត្រលេខ ១១៧ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ គូច-កង កើតឆ្នាំមមី អាយុ ៥៩ វស្សា ៣៨ នាមឆាយា ព្រហ្មជោត ជាចៅអធិការវត្តសម្ពោធិញាណ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ។

៥— សញ្ញាប័ត្រលេខ ១១៨ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ សុក-យុន កើតឆ្នាំជូត អាយុ ៤៥ វស្សា ២៥ នាមឆាយា សុវណ្ណត្ថេរ ជាចៅអធិការវត្តតូទុំ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ។

៦— សញ្ញាប័ត្រលេខ ១១៩ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ មាស-ផាន់ កើតឆ្នាំមមី អាយុ ៣៦ វស្សា ១៧ នាមឆាយា ចន្ទសរ ជាចៅអធិការវត្តដីក្រហម ឃុំចំបី ស្រុកបាទី ខេត្តតាកែវ ។

៧— សញ្ញាប័ត្រលេខ ១២០ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ តូច-ឈុយ កើតឆ្នាំរោង អាយុ ៦៣ វស្សា ៤០ នាមឆាយា ចន្ទត្ថេរ ជាចៅអធិការវត្តប្រាសាទ ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ។

៨— សញ្ញាប័ត្រលេខ ១២១ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ គួប-នៅ កើតឆ្នាំមមី អាយុ ២៥ វស្សា ៥ នាមឆាយា ឧទ្ទជោត ជាចៅអធិការវត្តថ្មី ឃុំកំពង់តាវេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

៩— សញ្ញាប័ត្រលេខ ១២២ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ ម៉ុក-តន់ កើតឆ្នាំខាល អាយុ ២៩ វស្សា ៩ នាមឆាយា បញ្ញាវិន័យ ជាចៅអធិការវត្តត្រពាំងផ្ទុំ ឃុំសែប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

១០.- សញ្ញាប័ត្រលេខ ១២៣ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ អ៊ូ-អៀ កើតឆ្នាំរកា អាយុ ៣៤ វស្សា ១១ នាមឆាយា ឥន្ទបញ្ញា ជាចៅអធិការវត្តឈូក ឃុំឆ្នុកទ្រូ ស្រុកកំពង់ឆ្នាំង ។

១១.- សញ្ញាប័ត្រលេខ ១២៤ ចុះថ្ងៃ ២១-១២-៤២. តាំងគ្រូសូត្រ ញ៉ក-ជូរ កើតឆ្នាំថោះ អាយុ ៥២ វស្សា ៣២ នាមឆាយា គន្ធត្ថេរ ជាចៅអធិការវត្តពានី ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

១២.- សញ្ញាប័ត្រលេខ ១២៥ ចុះថ្ងៃ ២១-១២-៤២ តាំងគ្រូសូត្រ ហ៊ុន-អ៊ុក កើតឆ្នាំរោង អាយុ ២៧ វស្សា ៧ នាមឆាយា សុធម្ម-បញ្ញា ជាចៅអធិការវត្តប្រាសាទ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

១៣.- សញ្ញាប័ត្រលេខ ១២៦ ចុះថ្ងៃ២១-១២-៤២តាំងគ្រូសូត្រ ជិន-ខាត កើតឆ្នាំរោង អាយុ ៤០ វស្សា ២០ នាមឆាយា ឥន្ទគោត្ត ជាចៅអធិការ វត្តអង្គសូភី ឃុំកក្តោរ ស្រុកកំពង់ត្រាច ខេត្តកំពត ។

១៤.- សញ្ញាប័ត្រលេខ ១២៧ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ រស់-តៅ កើតឆ្នាំឆ្លូវ អាយុ ៤២ វស្សា ១៥ នាមឆាយា ឥន្ទមុនី ជាចៅអធិការវត្តបន្ទាយចាស់ ឃុំគោកដុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

១៥.- សញ្ញាប័ត្រលេខ ១២៨ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ ប្រាក់-ម៉ម កើតឆ្នាំម្សាញ់ អាយុ ៥២ វស្សា ៤២ នាមឆាយា ចន្ទគោត្ត ជាចៅអធិការវត្តគោកដុំ ឃុំគោកដុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

១៦.- សញ្ញាប័ត្រលេខ ១២៩ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ ហេង-ស៊ុន កើតឆ្នាំម្សាញ់ អាយុ ២៦ វស្សា ៤ នាមឆាយា សុទ្ធបញ្ញា ជាចៅអធិការ វត្តកងមាស ឃុំគោកដុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

១៧.- សញ្ញាប័ត្រលេខ ១៣០ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ ជិម-ខ្វុត កើតឆ្នាំរោង អាយុ ៣៧ វស្សា ១៦ នាមឆាយា ខលុគធម្ម

ជាចៅអធិការវត្តការមហា ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

១៨.- សញ្ញាបត្រលេខ១៣១ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ សេ-ខាត កើតឆ្នាំខាល អាយុ ២៩ វស្សា ៩ នាមឆាយា ធម្មបញ្ញា ជាចៅអធិការវត្តឈូកខ្សាច់ ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

១៩.- សញ្ញាបត្រលេខ១៣២ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ ចាន់-នុម កើតឆ្នាំជូត អាយុ ៤៣ វស្សា ២២ នាមឆាយា ព្រហ្មបញ្ញា ជាចៅអធិការវត្តណោនឆម ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

២០- សញ្ញាបត្រលេខ ១៣៣ ចុះថ្ងៃ ២៣-១២-៤២ តាំង-គ្រូសូត្រ មៀន-កប កើតឆ្នាំមមី អាយុ ៤៩ វស្សា ២៩ នាមឆាយា វិនយគ្តោ ជាចៅអធិការវត្តប្រាសាទ ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

២១— សញ្ញាបត្រលេខ ១៣៤ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ ចាន់-ឈិត កើតឆ្នាំមមែ អាយុ ៤៨ វស្សា ២៤ នាមឆាយា ព្រហ្មគ្តោ ជាចៅអធិការវត្តស្វាយ ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

២២—សញ្ញាបត្រលេខ ១៣៥ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រ ព្រំ-មិន កើតឆ្នាំថោះ អាយុ ៤០ វស្សា ១៧ នាមឆាយា ធម្មសុវណ្ណបញ្ញា ជាចៅអធិការវត្តជ្រៃ ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

២៣—សញ្ញាប័ត្រលេខ ១៣៦ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រខោល-អៀង កើតឆ្នាំមមែ អាយុ ៤៨ វស្សា ២៧ នាមឆាយា សុវណ្ណមុនី ជាចៅអធិការវត្តពោធិ៍គុម្ព ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្រកំពង់ធំ ។

២៤— សញ្ញាប័ត្រលេខ ១៣៧ ចុះថ្ងៃ ២៣-២២-៤២ តាំងគ្រូ-សូត្រស្រី-ដុក កើតឆ្នាំមមែ អាយុ ២៤ វស្សា ៣ នាមឆាយា ធម្មសុវណ្ណោ ជាចៅអធិការវត្តរូង ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្រកំពង់ធំ ។

២៥—សញ្ញាប័ត្រលេខ ១៣៨ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រកែវ-មុី កើតឆ្នាំមមី អាយុ ៤៩ វស្សា ២៩ នាមឆាយា ជោតបញ្ញា ជាចៅអធិការវត្តក្រវ៉ា ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្រកំពង់ធំ ។

២៦— សញ្ញាប័ត្រលេខ ១៣៩ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូ-សូត្រ ជុំ-វ៉ែន កើតឆ្នាំមមី អាយុ ២៥ វស្សា ៥ នាមឆាយា ធម្មបញ្ញា ជាចៅអធិការវត្តកំពង់ស្ដេច ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្រកំពង់ធំ ។

២៧— សញ្ញាប័ត្រលេខ ១៤០ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូ-សូត្រ គោគ-ធាំង កើតឆ្នាំខាល អាយុ ២៩ វស្សា ៨ នាមឆាយា កេសរ-បុញ្ញា ជាចៅអធិការ វត្តព្រះធាតុ ឃុំពើងដើង ស្រុកបារាយណ៍ ខេត្រកំពង់ធំ ។

២៨- សញ្ញាប័ត្រលេខ ១៤១ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រសំ-សែម កើតឆ្នាំមមែ អាយុ ៣៦ វស្សា ១៩ នាមឆាយា ធម្មជោត ជាចៅអធិការវត្តពណ្ណកយ ឃុំចើងដើង ស្រុកបាភ្នំ ខែត្រកំពង់ធំ ។

២៩- សញ្ញាប័ត្រលេខ ១៤២ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រប៉ុក-អួត កើតឆ្នាំរកា អាយុ ៤៦ វស្សា ២៥ នាមឆាយា ព្រហ្មបញ្ញា ជាចៅអធិការវត្តបាកយណ៍សណ្តែក ឃុំបាឡាំង ស្រុកបាកយណ៍ ខែត្រកំពង់ធំ ។

៣០- សញ្ញាប័ត្រលេខ ១៤៣ ចុះថ្ងៃ ២៣-១២-៤២ តាំងគ្រូសូត្រជួង-កែវ កើតឆ្នាំខាល អាយុ ៦៥ វស្សា ៤៣ នាមឆាយា សុវណ្ណកេសរ ជាចៅអធិការវត្តត្រពាំងវែង ឃុំបាឡាំង ស្រុកបាកយណ៍ ខែត្រកំពង់ធំ ។

## ដំណើរបុណ្យបញ្ចុះសីមា

ក្នុងរវាងខែ ១ ដល់ ៣១ ដេសំប្រឆ្នាំ ១៩៤២

១. មានឲ្យព្រះហស្តលេខាលេខ ៦៨៥ ចុះថ្ងៃ ៤-១២-៤២ ទទួលព្រះរាជានុញ្ញាតយល់ព្រមឲ្យធ្វើបុណ្យបញ្ចុះខណ្ឌសីមាវត្តព្រៃស្មៀត ស្រុកពារាំង ខែត្រព្រៃវែង ជាវេលាចំនួន ៧ ថ្ងៃ គិតតាំងពីថ្ងៃ ១ ៗ ៤ (១៤ មីនា ១៩៤៣) នេះតទៅ ។

២ - មានឡាយព្រះហស្តលេខាលេខ ១៨៩ ចុះថ្ងៃ ១៨ ដេសេមប្រ៍ ឆ្នាំ ១៩៤២ ទ្រង់ព្រះរាជានុញ្ញាតយល់ព្រមឲ្យធ្វើបុណ្យបញ្ចុះខណ្ឌសីមាវត្តសិរីទេវវង្សឃុំតាអូ ស្រុកគិរីវង្ស ខែត្រតាកែវ ជាវេលាចំនួន ៣ ថ្ងៃ គិតតាំងពីថ្ងៃ ៣ ដល់ ៥ អាព្រិលឆ្នាំ ១៩៤៣ នេះ ។

## ការយាងទៅអធិការ

ដែលតាំងថ្មីក្នុងរាជាណាចក្រ ឆ្នាំ ១៩៤៣

១- សញ្ញាប័ត្រលេខ ១ ចុះថ្ងៃ ១១-១-៤៣ តាំងគ្រូស្លូត សួស-ស៊ូ កើតឆ្នាំថោះ អាយុ ៥២ វស្សា ៣១ នាមឆាយា ចន្ទសរ ជាចៅអធិការវត្តបទុមគង្គា ឃុំព្រែកដាច់ ស្រុកលើកដែក ខែត្រកណ្ដាល ។

២- សញ្ញាប័ត្រលេខ ២ ចុះថ្ងៃ ២៧-១-៤៣ តាំងគ្រូស្លូត មាស-គង់ កើតឆ្នាំរកា អាយុ ៧១ វស្សា ៥១ នាមឆាយា សុវណ្ណសរ ជាចៅអធិការវត្តព្រែកតាកែវខាងជើង ស្រុកពញាឮ ខែត្រកណ្ដាល ។

៣- សញ្ញាប័ត្រលេខ ៣ ចុះថ្ងៃ ២៧-១-៤៣ តាំងគ្រូស្លូត អ៊ឹម-សាត កើតឆ្នាំជូត អាយុ ៣០ វស្សា ៩ នាមឆាយា ព្រហ្មសរ ជាចៅអធិការវត្តឈូកក៏ ឃុំគោករកា ស្រុកភ្នំពេញ ខែត្រកណ្ដាល ។

៤- សញ្ញាប័ត្រលេខ ៤ ចុះថ្ងៃ ២៧-១-៤៣ តាំងគ្រូស្លូត ហ៊ឹម-អ៊ាន កើតឆ្នាំជូត អាយុ ៣០ វស្សា ១០ នាមឆាយា ឥន្ទសរ ជាចៅអធិការវត្តដូនល្អ ឃុំសំព្រោច ស្រុកស្ទោង ខែត្រកំពង់ធំ ។

៥- សញ្ញាប័ត្រលេខ ៥ ចុះថ្ងៃ ២៧-១-៤៣ តាំងគ្រូសូត្រ ហួត-គល់ កើតឆ្នាំមមី អាយុ ៣៧ វស្សា ១៧ នាមឆាយា សុវណ្ណកេតុ ជាចៅអធិការវត្តបទុម ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

៦- សញ្ញាប័ត្រលេខ ៦ ចុះថ្ងៃ ២៧-១-៤៣ តាំងគ្រូសូត្រ មួរ-ឌុយ កើតឆ្នាំរោង អាយុ ២៧ វស្សា ៧ នាមឆាយា ពុទ្ធកេតុ ជាចៅអធិការវត្តរំបេក ឃុំសំរោងលើ ស្រុកកំពេញ ខេត្តកណ្ដាល ។

## អំពីដំណឹងអនុញ្ញាតធ្វើបុណ្យបញ្ចុះសីមា

នៅវត្តនានាក្នុងរវាងថ្ងៃ ១ ដល់ ៣១ យ៉ាំងវីយេរ ១៩៤៣

ចុតហ្មាយលេខ ៨[c] ចុះថ្ងៃ ៧-១-៤៣ អនុញ្ញាតឲ្យអាចារ្យកែ-គង់ ធ្វើបុណ្យបញ្ចុះខណ្ឌសីមា វត្តគិរីមហាវ៉ន ហៅស្រុកឃុំត្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចំនួន ៣ ថ្ងៃគិតពីថ្ងៃ ១៦ ដល់ ១៨ ម៉ារ្ស ១៩៤៣ ។

ចុតហ្មាយលេខ ៩[c] ចុះថ្ងៃ ៧-១-៤៣ អនុញ្ញាតឲ្យអាចារ្យម៉ែន-អ៊ឹង ធ្វើបុណ្យបញ្ចុះខណ្ឌសីមា វត្តអំពិលស្អាង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ចំនួន ៤ ថ្ងៃ គិតពីថ្ងៃ ១៧ ដល់ ២០ អាវ្រិលឆ្នាំ ១៩៤៣ ។

ចុតហ្មាយលេខ ១០[c] ចុះថ្ងៃ ៧-១-៤៣ អនុញ្ញាតឲ្យអាចារ្យស្អាត-ប៉ុំ ធ្វើបុណ្យបញ្ចុះខណ្ឌសីមា វត្តជាកវដ្ដី ឃុំតាអូរ ស្រុកគិរីវង្ស ខេត្តតាកែវ ចំនួន ៣ ថ្ងៃ គិតពីថ្ងៃ ១ ទៅដល់ថ្ងៃ ៣ ម៉ារ្ស ១៩៤៣ ។

បុតហ្វាយលេខ ១៤c- ចុះថ្ងៃ១១ -១-៤៣ អនុញ្ញាតឲ្យអាចារ្យអ៊ុង-មិន ធ្វើបុណ្យបញ្ចុះខណ្ឌសីមា វត្តទន្លាយគោង ឃុំល្វេ ស្រុកកោះសុទិន ខេត្តកំពង់ចាម ចំនួន ៤ ថ្ងៃ គិតពីថ្ងៃ ២៥ ដល់ថ្ងៃ ២៨ ម៉ារ្ស ១៩៤៣ ។

បុតហ្វាយលេខ ២៦c- ចុះថ្ងៃ ១៨-១-៤៣ អនុញ្ញាតឲ្យអាចារ្យ សៀក ១ បីង ១ និងពួកឧបាសកធ្វើបុណ្យបញ្ចុះខណ្ឌសីមា វត្តព្រែកអំ-ពិល ស្រុកស្អាង ខេត្តកណ្ដាល ចូលបុណ្យពីថ្ងៃ១៦ រហូតដល់ ២៣ អាព្រិល ១៩៤៣ ។

បុតហ្វាយលេខ៣៩c- ចុះថ្ងៃ ២៦ ១-៤៣ អនុញ្ញាតឲ្យអាចារ្យស្រី-ទេស ធ្វើបុណ្យបញ្ចុះខណ្ឌសីមា វត្តជូនគោក ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ចំនួន ៣ថ្ងៃគិតពីថ្ងៃ១១ ដល់ ១៣ ហ្វេព្រីយេ ១៩៤៣ ។

បុតហ្វាយលេខ ៤២c- ចុះថ្ងៃ២៩ -១-៤៣ អនុញ្ញាតឲ្យអាចារ្យសៅ-គង់ វត្តស្រែង ឃុំស្រែង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ធ្វើបុណ្យបញ្ចុះខណ្ឌសីមាវត្តនេះចំនួន ៥ ថ្ងៃ គិតពីថ្ងៃ២២ដល់២៦ ហ្វេព្រីយេ ១៩៤៣

បុតហ្វាយៈលេខ ៤៣c- ចុះថ្ងៃ២៩-១-៤៣ អនុញ្ញាតឲ្យអាចារ្យអ៊ូ សម្រាប់វត្តកំពង់ទ្រាស ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ធ្វើបុណ្យបញ្ចុះខណ្ឌសីមាចំនួន ៣ ថ្ងៃ គិតពីថ្ងៃ ១៤ ដល់ ១៦ ខែមារ្ស ១៩៤៣ ។

## ប្រវត្តិសង្ខេបនៃបញ្ចមសង្គាយនា

កាលព្រះបាទទេវានម្បិយតិស្សទ្រង់គតទៅហើយ ក្សត្រក្រុងលង្កាបានគ្រងរាជសម្បត្តិ តព្រះរាជវង្សាផាលំដាប់មកមាន ៤ អង្គ តាំងពីនោះទើបខូចខាតរាជសម្បត្តិទៅពួកទមិឡជាបច្ចាមិត្ត រាជវង្សលង្កាបានរាយដណ្តើមមកវិញបានហើយអន្តរាយទៅវិញទៀត ដរាបមកដល់ព្រះបាទទុដ្ឋគាមណីអភ័យ ទើបមានជ័យជំនះពួកទមិឡយ៉ាងដាច់ស្រេច រួបរួមទឹកដីមកនៅក្រោមអំណាច នៃមហាក្សត្រតែមួយព្រះអង្គ ហើយតព្រះរាជវង្សក្រុងលង្កាមកបាន ២ ក្សត្រ ទើបដល់រាជ្យព្រះបាទលជ្ជតិស្សៈ ។ បណ្តាព្រះមហាក្សត្ររាជវង្សលង្កា សុទ្ធតែទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាឲ្យចំរើនរឹងប៉ឹងតៗ មកគ្រប់ៗអង្គ ។ កាលព្រះបាទលជ្ជតិស្សទ្រង់គតហើយ ទើបព្រះបាទខល្លាតនាគបានគ្រងរាជ្យតព្រះវង្ស ។ គ្រានោះ មានសេនាបតីម្នាក់ក្បត់ចាប់ព្រះអង្គឃុំគត់ហើយ ឡើងគ្រប់គ្រងរាជសម្បត្តិ ។ ទើបព្រះបាទវដ្តគាមណីអភ័យ ចាប់សេនាបតីនោះសម្លាប់ចោលហើយ ទ្រង់គ្រងរាជសម្បត្តិបានបន្តិច ស្រាប់តែមានទ័ពចោរនឹងទ័ពទមិឡលើកមកប្រុងរាយព្រះនគរដល់ពីរទ័ព ។ ដំបូងព្រះបាទវដ្តគាមណីអភ័យទ្រង់គិតកលឧបាយឲ្យទ័ពចោរនឹងទ័ពទមិឡច្បាំងគ្នាសិន ។ កាលទ័ពចោរបរាជ័យចាញ់ទ័ពទមិឡហើយ ទើបទ្រង់យាត្រាចេញច្បាំងនឹងទ័ពទមិឡ តែទ្រង់បរាជ័យកងទ័ពទមិឡទៅវិញ ពួកទមិឡលុកយកព្រះនគរបាន

ព្រះអង្គគេចរត់ទៅពួនកៀរគរមនុស្សនៅទីកន្លែងផ្សេង ៗ ជាវេលា ១៤ ឆ្នាំ ។ កាលគ្រាស្តេចទៅគង់នៅព្រៃជិតវេស្សគិរីវិហារ ព្រះតិស្សត្ថេរដែលគង់នៅទីនោះ បានជួយទំនុកបំរុងទ្រង់ឲ្យបានសេចក្តីសុខសប្បាយតាមកម្លាំងរបស់លោក ។ លុះទ្រង់កៀរគរមនុស្សឲ្យចូលមក ជាកម្លាំងបានចំនួនច្រើនហើយ ទើបលើកជាកងទ័ពទៅប្រាបប្រាមពួកទមិឡមានជ័យជំនះ ទ្រង់គ្រប់គ្រងផែនដីក្នុងលង្កាទ្វីបបានទាំងមូល តាំងជាឯក-រាជ្យឡើងបានទៀត កាលព្រះអង្គបានសោយរាជសម្បត្តិ ហើយទ្រង់រលឹកនឹកដល់ឧបការគុណរបស់ព្រះមហាថេរនោះ ទើបទ្រង់កសាងអភយគិរីវិហារប្រគេនព្រះថេរៈ ។ ឯនាយទាហានធំៗ ទាំង ៧ នាក់ក៏នាំគ្នាកសាងព្រះវិហារម្នាក់មួយខ្នង ៗ ប្រគេនព្រះថេរជាជីតុនរបស់ខ្លួនតែរៀងខ្លួនៗដែរ ។ លុះសម្តេចព្រះមហាក្សត្រនឹងពួកអាមាត្យ នាំគ្នាទំនុកបំរុងព្រះសង្ឃក្នុងអាវាសរបស់ខ្លួន ដោយបច្ច័យយ៉ាងបរិបូណ៌ ។ ប៉ែកខាងព្រះសង្ឃមហាវិហារលើកទោសព្រះតិស្សត្ថេរថា ជាអ្នកនៅច្រឡូកច្រឡំនឹងត្រកូលគ្រហស្ថ គិតកំចាត់ចេញចាកពួក ។ តាំងអំពីនោះមកព្រះសង្ឃក៏បែកខ្ញែកគ្នាជា ២ ពួក គឺពួកមហាវិហារ ១ ពួក ពួកអភ័យគិរីវិហារ ១ ពួក ។

កាលគ្រានោះ ព្រះសង្ឃជាថេរានុត្ថេរៈពិចារណាឃើញថា អំ-ណើះកាលទៅមុខ កុលបុត្រនឹងមានសតិបញ្ញា ថយចុះទៅជាលំដាប់

មិនអាចទ្រទ្រង់ព្រះត្រៃបិដក ឲ្យចាំមាត់ស្ទាត់ជំនាញទាំងបាលីទាំងអដ្ឋកថា បានសព្វគ្រប់ទេ ត្រូវតែចារឹកព្រះត្រៃបិដកចុះក្នុងស្លឹករឹតទើបព្រះធម្មវិន័យតាំងនៅស្ថិតស្ថេរចិរកាលតទៅអនាគតបាន ។ ទើបព្រះតិស្សត្ថេរប្រជុំសង្ឃជាមហាសន្និបាតធ្វើសង្គាយនា ដើម្បីចារឹកព្រះធម្ម-វិន័យដាក់ក្នុងស្លឹករឹត ចាត់ជាគ្រាទី ៥ ហៅថាបញ្ចមសង្គាយនា ការក-សង្ឃចំនួន ១.០០០ អង្គ ចាត់ជាគ្រាដំបូងដែលប្រើអក្សរចារឹកព្រះពុទ្ធ-វចនៈ ។ សង្គាយនាគ្រានេះធ្វើនៅក្នុងមហាវិហារនៅលង្កាទ្វីប ព្រះពុទ្ធទត្តត្ថេរជាអ្នកបុច្ឆា ព្រះតិស្សត្ថេរជាអ្នកវិស្សជ្ជនា ព្រះបាទវដ្តគា-មណីអភយ៍ជាសាសនូបត្ថម្ភអស់វេលា ១ ឆ្នាំទើបសម្រេច ។

ចប់ ប្រវត្តិសង្ខេបនៃបញ្ចសង្គាយនាតែប៉ុណ្ណោះ

## ៦៧ ប្រវត្តិនៃព្រះមហាកាច្ចាយនត្ថេរ

ព្រះមហាកច្ចាយនត្ថេរ ជាបុត្រព្រាហ្មណ៍បុរោហិត កច្ចានគោត្រ ឬកច្ចាយនគោត្រ របស់ព្រះបាទចណ្ឌប្បជ្ជោតក្នុងក្រុងឧជ្ជេនី ។ ឈ្មោះរបស់លោកគេហៅថា កញ្ចន: លុះចំរើនវ័យឡើង បានរៀនចេះចប់គម្ពីរត្រៃវេទ ដល់ព្រាហ្មណ៍ជាបិតាធ្វើកាលកិរិយាទៅ ក៏បានទទួលដំណែងជាបុរោហិតជំនួសបិតាតមក ។ ក្នុងកាលជាលំដាប់មក ព្រះបាទចណ្ឌប្បជ្ជោតទ្រង់ជ្រាបថា សម្តេចព្រះបរមសាស្តាបានត្រាស់ដឹងហើយ ស្តេចត្រាច់ចារិកទៅទូន្មានប្រជុំជន ធម៌ដែលទ្រង់ទូន្មាននោះជាធម៌ពិត ញ៉ាំងប្រយោជន៍ឲ្យបានសម្រេចដល់អ្នកប្រតិបត្តិតាម ទើបទ្រង់មានព្រះរាជបំណងចង់អញ្ជើញសម្តេចព្រះបរមសាស្តាទៅប្រកាសព្រះសា-សនា នៅក្រុងឧជ្ជេនី ទើបទ្រង់មានព្រះបន្ទូលនឹងកច្ចាយនបុរោហិតដែលមានចំណេះចេះចប់ត្រៃវេទទៅក្រាបបង្គំទូលអញ្ជើញព្រះអង្គ ។ ឯកច្ចាយនបុរោហិត បានក្រាបទូលលាបួសផង ព្រះអង្គក៏ទ្រង់ព្រះរាជា-នុញ្ញាតឲ្យតាមអធ្យាស្រ័យ ទើបលោកធ្វើដំណើរចេញពីក្រុងឧជ្ជេនីព្រមដោយបរិវារ ៧ នាក់ ។ លុះនាំគ្នាមកកាន់ទីប្រថាប់របស់ព្រះបរម-សាស្តាហើយ ក៏នាំគ្នាចូលទៅគាល់ព្រះអង្គ ។ ក៏ទ្រង់ទេសនាទូន្មានដល់ចប់ព្រះធម្មទេសនា ក៏បានសំរេចព្រះអរហត្តព្រមគ្នាទាំង ៨ នាក់ ទើបក្រាបបង្គំទូលសុំឧបសម្បទ ព្រះអង្គទ្រង់អនុញ្ញាតឲ្យបានជាភិក្ខុ

ដោយវិធី ឯហិភិក្ខុឧបសម្បទា ទើបក្រាបបង្គំទូលអារាធនាឲ្យស្តេចយាង ទៅក្រុងឧជ្ជេនី តាមព្រះរាជតម្រិះរបស់ព្រះបាទចណ្ឌប្បជ្ជោត ៗ ព្រះបរមសាស្តាត្រាស់ថា អ្នកឯងទៅចុះ ព្រះបាទចណ្ឌប្បជ្ជោតនឹងមានព្រះទ័យជ្រះថ្លាមិនខាន ។ ទើបលោកព្រមទាំងភិក្ខុជាបរិវារ ៧ អង្គនាំគ្នាក្រាបថ្វាយបង្គំលាសម្តេចព្រះបរមសាស្តា ត្រឡប់ទៅក្រុងឧជ្ជេនី ប្រកាសព្រះពុទ្ធសាសនា ដល់ព្រះបាទចណ្ឌប្បជ្ជោត ទាំងអ្នកនគរឲ្យមានសទ្ធាជ្រះថ្លាហើយ ទើបលោកត្រឡប់មកកាន់សំណាក់ព្រះបរមសាស្តាវិញទៀត ។ លោកជាអ្នកឈ្លាសវៃ ក្នុងការអធិប្បាយពន្យល់សេចក្តីខ្លីដោយពិស្តារបាន ដូចមានគ្រាមួយ សម្តេចព្រះបរមសាស្តា ទ្រង់សំដែងភទ្ទេករត្តសូត្រដោយសង្ខេប រួចស្តេចក្រោកចូលទៅក្នុងព្រះវិហារ ភិក្ខុទាំងឡាយមិនបានឱកាស ទូលសួរសេចក្តីដែលទ្រង់សំដែងដោយសង្ខេបនោះឡើយ ឃើញថាព្រះកច្ចាយនត្ថេរ លោកមានសេចក្តីអង់អាចក្នុងការអធិប្បាយពន្យល់ ទើបនាំគ្នាសូមអារាធនា ឲ្យលោកសំដែងឲ្យស្តាប់ ។ លោកក៏អធិប្បាយពន្យល់ដោយពិស្តាររួចពោលថា បពិត្រលោកដ៏មានអាយុទាំងឡាយ ខ្ញុំយល់សេចក្តីនៃធម៌ដែលទ្រង់សំដែងដោយសង្ខេបតាមទំនងពិស្តារយ៉ាងនេះ ។ បើលោកទាំងឡាយមានប្រាថ្នាគួរនិមន្តទៅគាល់ព្រះបរមសាស្តា ហើយក្រាបបង្គំទូលសួរសេចក្តីនេះ

ទឹងព្រះអង្គម្តងទៀតចុះ ៗ ភិក្ខុទាំងនោះក៏លាព្រះកច្ចាយនត្ថេរ ត្រឡប់មកគាល់ព្រះអង្គ ក្រាបបង្គំទូលសេចក្តីនោះ ឲ្យទ្រង់ជ្រាបគ្រប់ប្រការ ៗ ព្រះអង្គទ្រង់ត្រាស់សរសើរព្រះកច្ចាយនត្ថេរថា ម្នាលភិក្ខុទាំងឡាយ កច្ចាយនៈជាអ្នកមានប្រាជ្ញា បើអ្នកពល់គ្នាសួរសេចក្តីនេះនឹងតថាគត ៗ ក៏ដោះស្រាយដូច្នេះដែរ ចូរអ្នកទាំងឡាយចាំទុកចុះ ៗ ហេតុនេះបានជាលោកបានទទួលសេចក្តីសរសើរ អំពីព្រះបរមសាស្តាថា ប្រសើរលើសលែងភិក្ខុទាំងឡាយខាងប៉ិនអធិប្បាយសេចក្តីសង្ខេបដោយពិស្តារ ៗ

ព្រះមហាកច្ចាយនត្ថេរនេះ លោកបានក្រាបបង្គំទូលសុំបរមពុទ្ធានុញ្ញាតឲ្យទ្រង់កែខៃព្រះពុទ្ធប្បញ្ញត្តិខ្លះ ដែលជាទំនាស់ទឹងភូមិប្រទេស ដូចគ្រាកាលលោកទៅសំណាក់នៅភ្នំឈ្មោះបវត្តៈស្រុកកុរុរឃរៈ ក្នុងអវន្តិទក្ខិណាបថជនបទ មានឧបាសកជាឧបដ្ឋាករបស់លោកម្នាក់ឈ្មោះសោណកុដិកណ្ណៈ មានបំណងនឹងបួសក្នុងព្រះសាសនា តែបានត្រឹមបព្វជ្ជាប៉ុណ្ណោះ កន្លងកាលវេលានៅដល់ ៣ ឆ្នាំ ទើបបានឧបសម្បទជាភិក្ខុ ព្រោះក្នុងអវន្តិទក្ខិណាបថជនបទ រកភិក្ខុជាគណៈបូរកពុំបាន ៗ កាលលោកសោណកុដិកណ្ណៈបានឧបសម្បទ មានប្រាថ្នានឹងចូលទៅគាល់ព្រះបរមសាស្តា ទើបទៅនមស្ការលាព្រះកច្ចាយនត្ថេរជាឧបជ្ឈាយ៍ ៗ លោកក៏អនុញ្ញាតហើយផ្តាំឲ្យថ្វាយបង្គំព្រះបាទព្រះបរមសាស្តា ដោយសិរសាតាមពាក្យរបស់លោក ហើយផ្តាំឲ្យក្រាបបង្គំទូលសុំព្រះបរមពុទ្ធា-

នុញ្ញាត ឲ្យទ្រង់កែខៃព្រះពុទ្ធបញ្ញត្តិប្រការខ្លះដែលជាទំនាស់ដល់អវន្តិ-ទក្ខិណាបថជនបទ មាន៥ ខ គឺ:

១ ក្នុងអវន្តិទក្ខិណាបថជនបទ មានភិក្ខុតិច សូមព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឧបសម្បទដោយគណសង្ឃតិចជាង ១០ រូប ។ ក្នុងខនេះព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការឧបសម្បទ ក្នុងបច្ចន្តជនបទ ដោយគណៈមានវិន័យធរជាគំរប់ ៥ (សម្រេចដោយគណសង្ឃចំនួន ៥ រូប) ។

២ ក្នុងអវន្តិទក្ខិណាបថជនបទ មានផ្ទៃផែនដីរដិបរដុបមិនរាបស្មើ សូមព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតស្បែកជើងជាជាន់ៗ ក្នុងខនេះមានព្រះពុទ្ធានុញ្ញាតថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្បែកជើងជាជាន់ ៗ" ។

៣ ក្នុងអវន្តិទក្ខិណាបថជនបទ ពួកមនុស្សត្រូវការងូតទឹករាល់ថ្ងៃ សូមព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតការងូតទឹកជានិច្ច ។ ក្នុងខនេះមានព្រះពុទ្ធានុញ្ញាតថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតងូតទឹកបានជានិច្ច ក្នុងបច្ចន្តជនបទ" ។

៤ ក្នុងអវន្តិទក្ខិណាបថជនបទ មានគ្រឿងក្រាលដែលធ្វើដោយស្បែកសត្វ មានស្បែកពពែនឹងស្បែកកែះជាដើម មានគ្រប់គ្រាន់បរិ-

ប្រណាំដូចគ្នានឹងវៀមជនបទដែរ សូមព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតគម្រាលដែលធ្វើដោយស្បែកសត្វ មានស្បែកពពែ និងស្បែកកែះជាដើម ។ គ្រានោះព្រះអង្គទ្រង់អនុញ្ញាតថា " ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រាលដែលធ្វើដោយស្បែកសត្វ មានស្បែកពពែ និងស្បែកកែះជាដើម" ។

៥ ពួកមនុស្សតែងថ្វាយចីវរដល់ភិក្ខុ ដែលចេញទៅក្រៅសីមា ដោយពាក្យថា "ពួកខ្ញុំករុណាសូមថ្វាយចីវរនេះ ដល់ភិក្ខុឈ្មោះនេះ" កាលភិក្ខុអស់នោះត្រឡប់មកវិញ ពួកភិក្ខុនៅក្នុងវត្តបានប្រាប់ឲ្យលោកអស់នោះបានដឹង លោកអស់នោះមិនហ៊ានទទួលដោយយល់ថា សំពត់នោះជានិស្សគ្គិយៈ (ត្រូវតែលះបង់ព្រោះកន្លង ១០ ថ្ងៃទៅ) សូមព្រះដ៏មានព្រះភាគ ត្រាស់បង្គាប់ក្នុងការប្រតិបត្តិនឹងចីវរបែបនេះផង ។ គ្រានោះព្រះអង្គមានព្រះពុទ្ធានុញ្ញាតថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលត្រេកអរ និងចីវរដែលទាយកប្រគេនក្នុងទីមុខនោះបាន សំពត់មិនទាន់ដល់ដៃភិក្ខុដរាបណា និងរាប់ថាភិក្ខុនោះជាអ្នកមានសិទ្ធិអំណាចពេញទីក្នុងសំពត់នោះមិនទាន់បានដរាបនោះ" ។

ព្រះមហាកច្ចាយនត្ថេរនេះ ល្បីថាលោកមានរូបរាងល្អណាស់ មានសំបុរដូចមាស មានសេចក្ដីដំណាលក្នុងគម្ពីរអដ្ឋកថាធម្មបទថា បុត្រ

សេដ្ឋីម្នាក់ឈ្មោះសោរេយ្យៈ នៅក្នុងសោរេយ្យនគរបានឃើញលោកកំពុង
ដំរេកតែកនឹងចិត្តថា ប្រសិនបើអញបានប្រពន្ធ មានរូបឆោមស្រស់ល្អ
ដូចលោកនេះ ជាទីគាប់ចិត្តអញក្រៃពេក ដោយអំណាចអកុសលចិត្ត
ត្រឹមប៉ុណ្ណោះ សេដ្ឋីបុត្រនេះក៏ប្រែត្រឡប់ភេទប្រុសរបស់ខ្លួនទៅជាភេទ
ស្រីមួយរំពេច មានសេចក្តីអៀនខ្មាសពន់ពេក ក៏គេចរត់ទៅនៅនគរ
ដទៃ ហើយមានប្តីបានទាំងកូនពីរនាក់ផង តមកសម័យក្រោយបានសុំ
ខមាទោសនឹងលោករូបត្រឡប់ក្លាយជាភេទប្រុសដូចដើមវិញ ។

កូនមធុរសូត្រមានសេចក្តីដំណាលថា ព្រះមហាកច្ចាយនត្ថេរ មាន
ព្រះជន្មមកដល់ក្រោយព្រះពុទ្ធបរិនិព្វាន ដូចមានរឿងដំណាលថាកាល
លោកនៅឯមធុន្ធាវន ដែនមធុររាជធានី ព្រះបាទមធុររាជអវន្តិបុត្រ
ស្តេចចូលទៅរកលោកហើយ ត្រាស់សួរថា បពិត្រព្រះកច្ចានៈដ៏ចំរើន
ពួកព្រាហ្មណ៍គេប្រកាន់ថា ពួកគេជាមនុស្សប្រសើរបរិសុទ្ធ កើតមក
អំពីព្រហ្ម ចំណែកលោកតើលោកយល់ដូចម្តេច ? លោកទូលសំដែង
អំពីវណ្ណៈទាំង ៤ ពួកមិនមានវិសេសប្លែកគ្នាទេ ។ ព្រះបាទមធុររាជ ទ្រង់
ព្រះសណ្តាប់ហើយ ក៏មានព្រះទ័យសោមនស្ស សំដែងព្រះអង្គជា
ឧបាសក សូមដល់ព្រះថេរៈនឹងព្រះធម៌ជាទីពឹងទីរលឹក ព្រះថេរៈទូល
ហាមថា សូមមហារាជកុំបីយកអាត្មាភាពជាសរណៈឡើយ ចូរទ្រង់

យកព្រះដ៏មានព្រះភាគ ដែលជាសរណៈរបស់លោក ទុកជាសរណៈរបស់ព្រះអង្គចុះ ។ ទើបព្រះបាទមធុរាជត្រាស់សួរថា ចុះព្រះដ៏មានព្រះភាគ ទ្រង់គង់នៅឯណា ។ កាលទ្រង់ជ្រាបថា ព្រះអង្គបរិនិព្វានផុតទៅហើយ ទើបទ្រង់ត្រាស់ថា បើព្រះអង្គទ្រង់ជ្រាបថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅឯណា ទោះបីជិតឆ្ងាយយ៉ាងណាក៏ដោយ ព្រះអង្គនឹងស្តេចទៅគាល់ឲ្យទាល់តែបាន តែព្រះដ៏មានព្រះភាគ បរិនិព្វានហួសទៅហើយ ខ្ញុំព្រះករុណាសូមដល់ព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅហើយ ព្រមទាំងព្រះធម៌ព្រះសង្ឃជាទីពឹងទីរលឹក ។ រឿងនេះចង្អុលឲ្យឃើញថា ព្រះកច្ចាយនត្ថេរ លោកមានជន្មាយុមកដល់ក្រោយព្រះពុទ្ធបរិនិព្វាន តែមិនប្រាកដថា លោកមានអាយុប៉ុន្មាន លុះលោកមានអាយុសង្ខារសមគួរនឹងកាលវេលាហើយក៏បរិនិព្វានទៅ ។

ចប់ប្រវត្តិសង្ខេបព្រះកច្ចាយនត្ថេរតែប៉ុណ្ណេះ ។

# ពុទ្ធឃោសប្រវត្តិ

## លោកអាចារ្យ ឈឹម-ស៊ុម សទ្ធម្មប្បញ្ញា

អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ រៀបរៀងតាមសេចក្ដីបង្គាប់អំពីព្រះតេជព្រះគុណ ព្រះធម្មលិខិត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ (មុន) ដោយសេចក្ដីត្រូវការរបស់លោក ព្យែរ-ឌុយប៊ុងត៍ អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

ព្រះពុទ្ធឃោសាចារ្យ ជាព្រះថេរៈ ១ អង្គ ដែលមានព្រះនាមល្បីល្បាញអស្ចារ្យក្នុងពួកអ្នកកាន់ពុទ្ធសាសនាប៉ែកខាងទក្ខិណនិកាយ, មានប្រវត្តិហេតុដែលព្រះគន្ថរចនាចារ្យទាំងឡាយ បានរៀបរៀងទុកក្នុងគម្ពីរជាច្រើន គឺគម្ពីរមហាវង្ស, ពុទ្ធឃោសនិទាន, វិសមាលនី, ញាណោទយ, សុត្តជាតកនិទានានិសំស និងពុទ្ធឃោសុប្បត្តិកថាជាដើម ។ ទម្រង់សេចក្ដីក្នុងរឿងទាំងនោះ ស្របគ្នារហូតពីដើមដល់ចុងចប់ក៏មាន, ប្លែកគ្នាខ្លះដោយអន្លើ ៗ ក៏មាន ។ ឥឡូវនេះ ខ្ញុំបានពិនិត្យមើលរឿងទាំងនោះ ហើយស្រង់សេចក្ដីមករៀបរៀងជារបៀបមួយដោយឡែកដូចតទៅនេះ ។

ក្នុងកាលដែលព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិនិព្វានកន្លងទៅបាន ៩៥៦ វស្សា មានព្រះរាជា ១ ព្រះអង្គទ្រង់ព្រះនាមព្រះបាទ "មហានាម" សោយរាជសម្បត្តិក្នុងលង្កាទ្វីប ។ សម័យនោះ មានមាណពម្នាក់ឈ្មោះ

ឃោសៈ [១] កើតក្នុងត្រកូលព្រាហ្មណ៍មួយជាកដបុរោហិត នៅនាទីជិតពោធិមណ្ឌល ក្នុងមជ្ឈិមប្រទេស ខាងឯជម្ពូទ្វីប ។

សេចក្ដីក្នុងពុទ្ធឃោសនិទានថា: ក្នុងសម័យមុនដែលមាណពនេះពុំទាន់កើត, មានព្រះអរហន្តមួយអង្គ ពុំប្រាកដជាមានព្រះនាមដូចម្ដេច ជាឥតុខនៃព្រាហ្មណ៍ឈ្មោះកេសីនិងព្រាហ្មណីឈ្មោះកេសិនី លោកតែងចូលទៅកាន់ត្រកូលព្រាហ្មណ៍នោះ ៗ ដោយហេតុតែព្រះអរហន្តអង្គនោះ មានព្រះទ័យឈឺឆ្អាលចំពោះព្រះពុទ្ធសាសនាណាស់ បានជាក្នុងថ្ងៃមួយ លោកមានបរិវិតក្កក្នុងព្រះទ័យថា: អើហ្ន៎! ព្រះពុទ្ធវចនៈគឺព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានចារិកក្នុងស្លឹករឹត មានតែជាភាសាសីហឡៈ នៅឯលង្កាទ្វីបឯណោះ បើដូច្នោះ ធ្វើដូចម្ដេចអេះ ទើបបានព្រះពុទ្ធវចនៈទាំងនោះផ្សាយមកដល់ជម្ពូទ្វីបនេះ ជាភាសាមគធផង ? កាលដែលលោកកំពុងមានបរិវិតក្កដូច្នេះ ក៏ស្រាប់តែលោកនឹកឃើញថា: មានតែឃោសទេវបុត្តដែលនៅឯឋានតុសិតឯណោះ ទើបជាបុគ្គលមានអភិនីហារចាស់ក្លា អាច

---

១ សេចក្ដីក្នុងគម្ពីរវំសមាលិនីថា: ក្នុងកាលដែលកុមារនេះប្រសូតចាកផ្ទៃ, ពួកបរិវារទាំងឡាយរបស់ព្រាហ្មណ៍មានទាសៈនិងកម្មករជាដើម ស្រែកសម្រែកគឹកកងកាន់គ្នាទៅវិញទៅមក, ព្រោះហេតុនោះបានជាជនទាំងឡាយឲ្យឈ្មោះកុមារនោះថា "ឃោសៈ" ។ កន្លែងខ្លះទៀតថា: កុមារនោះបានជាឈ្មោះថា "ឃោសៈ" ព្រោះហេតុតែកើតក្នុងស្រុកឈ្មោះឃោសគ្រាម ។ កន្លែងខ្លះថា កុមារនេះឈ្មោះ "ធម្មឃោស" ដូច្នេះក៏មាន ។

ប្រែព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ដែលជាសីហឡភាសាមកជាមគធ-ភាសាបាន ។

លុះលោកនឹកឃើញដូច្នោះហើយ ក៏និមន្តទៅកាន់ឋានតាវត្តិង្ស, ចូលទៅថ្វាយព្រះពរសម្ដេចអមរិន្ទ្រាធិរាជ សូមឲ្យព្រះអង្គទៅអញ្ជើញឃោសទេវបុត្ត ឲ្យច្យុតមកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងកេសិនីជាភរិយានៃព្រាហ្មណ៍ឈ្មោះកេសី ដែលជាឧបដ្ឋាករបស់លោក ។ ព្រះឥន្ទ្រក៏ទទួលយកភាសា សម្រេចការប្រែគេនបានដូចបំណង ហើយបានទាំងទទួលធានាថានឹងជួយឈឺឆ្អាលក្នុងការប្រែព្រះត្រៃបិដកនោះទៀតផង ។

កាលដែលឃោសទេវបុត្ត ច្យុតមកកើតក្នុងផ្ទៃនៃនាងកេសិនី ប្រសូតចាកផ្ទៃមក បាននាមបញ្ញត្តិថា "ឃោសកុមារ" មានរូបល្អថ្លៃថ្លា មានប្រាជ្ញាមុះមុត អាចរៀនចំណេះចេះចប់ត្រៃវេទ(១) ក្នុងវ័យអាយុ៧ឆ្នាំ ។

---

១ ត្រៃវេទ គឺសេចក្ដីដឹង វិជ្ជា, ចំណេះ, មាន ៣ បែប ឬគម្ពីរដែលសំដែងរបៀបផ្សេងៗខាងសាសនាព្រាហ្មណ៍ មាន ៣ ប្រភេទ ។ ក្នុងសម័យដើម មានត្រឹមតែ ៣ យ៉ាង គឺ ១– ឫគ្វេទ ឬ ឫគុវេទ មានដំណើរសេចក្ដីជាពាក្យឆន្ទ សម្រាប់សូត្រសរសើរព្រះទេវតា; ២– យជុរវេទ ឬ យជ្ជុវេទ មានដំណើរសេចក្ដីជាពាក្យរាយរណ្ដំ សម្រាប់សូត្របូជាឬបួងសួង; ៣– សាមវេទ មានដំណើរសេចក្ដីជាពាក្យឆន្ទ សម្រាប់សូត្រក្នុងពិធីថ្វាយទឹកសោម ។ វេទទាំង ៣ នេះ សុទ្ធតែប្រើភាសាសំស្ក្រឹត; ហៅថា "វេទត្រ័យ ឬ ត្រ័យវេទ្យា" ដូច្នេះក៏មាន ។ ពួកព្រាហ្មណ៍ប្រកាន់ជឿស៊ប់ថា មហាព្រហ្មប្រសិទ្ធិឲ្យកើតឡើង ។ លុះចំណេរៈមក កើតមាន "អថពិវេទ ឬ អថព្វវេទ" សម្រាប់សូត្រហៅឬបណ្ដេញខ្មោចបិសាច ១ ថែមមកទៀតជាវេទ ៤ ។

ថ្ងៃមួយ ឃោសកុមារ បានស្ដាប់ព្រះអភិធម្មក្នុងសំណាក់ព្រះអរហន្ត ដែលជាជីតូននោះ ក៏មានសេចក្ដីជ្រះថ្លា ដោយការយល់ឃើញថាជាវិជ្ជាមួយមានអត្ថរសដ៏ជ្រៅល្អិតជាងវិជ្ជាត្រៃវេទ ដែលខ្លួនធ្លាប់សិក្សាមក, ទើបសួរព្រះអរហន្តនោះថា វិជ្ជានេះឈ្មោះអ្វី? ព្រះអរហន្តឆ្លើយថា វិជ្ជានេះឈ្មោះពុទ្ធមន្ត ។ ខ្ញុំព្រះករុណា សូមសិក្សាផងបានឬទេ? បាន, ប៉ុន្តែត្រូវអ្នកឯងបួសសិន ។ ឃោសកុមារក៏ចូលទៅលាមាតាបិតាចេញទៅបួសដើម្បីរៀនពុទ្ធមន្តនោះ ។ មាតាបិតាអង្វរឃាត់ច្រើនលើក ក៏កុមារនោះនៅតែទទូចលាដោយពាក្យប្ដេជ្ញាថា ខ្ញុំបានទៅបួសគ្រាន់តែរៀនពុទ្ធមន្តចប់ប៉ុណ្ណោះនឹងត្រឡប់មកវិញពុំខាន ។ មាតាបិតាក៏អនុញ្ញាតឲ្យទៅបួសតាមបំណង ។ (សេចក្ដីនេះគួរឲ្យអ្នកមានគំនិតរិះគិតដោយយ៉ាង ព្រោះសំដែងឲ្យឃើញថា ឃោសកុមារនេះមាននិស្ស័យប្លែកជាងមនុស្សឯទៀត) ។

ចំណែកខាងសេចក្ដីក្នុងឃោសប្បវត្តិកថា ថាៈឃោសកុមារនោះក្លៀវក្លាក្នុងសិល្បសាស្ត្រគ្រប់យ៉ាង ចេះចប់ត្រៃវេទ ហើយត្រាច់ទៅកាន់ស្រុកនិគម ជនបទ រាជធានី ក្នុងជម្ពូទ្វីប, តែងចូលទៅធ្វើសាកច្ឆាក្នុងទីដែលមានពួកសមណៈនិងព្រាហ្មណ៍ជាអ្នកប្រាជ្ញនៅគ្រប់ជម្រំ ។ ពួកសមណៈនិងព្រាហ្មណ៍ដទៃ មិនអាចដើម្បីឆ្លើយប្រស្នាដែលឃោសកុមារនោះសួរបានឡើយ ។ ឯឃោសកុមារទើបអាចដោះស្រាយប្រស្នាដែល

ពួកសមណៈនិងព្រាហ្មណ៍ដទៃសួរបានឥតមានទើសទាល់ ។ ឃោស-កុមារនោះ សង្កត់សង្កិននូវឯកសកលជម្ពូទ្វីបដោយចំណេះវិជ្ជាយ៉ាងនេះ ហើយបានទៅដល់វត្តមួយ ។ ក្នុងវត្តនោះមានភិក្ខុជាច្រើនរយរូប ព្រះសង្ឃត្ថេរព្រះនាមរេវតដ៏មានអាយុ ជាមហាខីណាស្រព ដល់នូវបដិ-សម្ភិទា ជាអ្នកញាំញីនូវបរប្បវាទ ។ វេលាពត្រីយប់នោះ ឃោសមា-ណព សូត្រនូវបាតញ្ជលីមន្ត(១) ដ៏ច្បាស់លាស់ត្រឹមត្រូវគប់គ្រាន់ ។ ព្រះថេរៈបានឮសម្លេងឃោសមាណពកំពុងស្វាធ្យាយន៍ ក៏ជ្រាបថា "មាណពនេះមានប្រាជ្ញាច្រើនល្មមអាត្មាអញទូន្មានបាន", ទើបមានថេរ-ដីកាហៅមាណពនោះមកសួរថា: ម្នាលព្រាហ្មណ៍ នរណាស្រែកសម្រែកដូចជាសត្វលា ? ឃោសមាណពសួរតបវិញថា· បពិត្របព្វជិតដ៏ចំរើន, លោកស្គាល់សម្រែកសត្វលាឬ? ចំរើនពរ អាត្មាស្គាល់ ។

សេចក្តីដោយទៀតថា ឃោសមាណពនោះពិចារណារកមិនឃើញនូវហេតុដើមនៃគម្ពីរទាំងឡាយក្នុងត្រៃវេទ ដែលមានឥតិហាសៈជាគម្រប់ ៥ នោះសោះ, ទាំងអាចារ្យរបស់មាណពនោះ ក៏ពិចារណារកមិនឃើញដែរ; ទើបឃោសមាណពនោះសួរព្រះថេរៈចំពោះដើមហេតុនៃគម្ពីរនោះ ៗ ឯព្រះថេរៈជាអ្នកចេះចប់ត្រៃវេទតាមប្រក្រតីមកស្រាប់ ថែមទាំងបានបដិសម្ភិទាទៀត បានជាលោកឥតធុញព្រះទ័យក្នុងការដោះ

(១) ធម៌សម្រាប់សូត្រថ្វាយបង្គំព្រះព្រហ្មជាដើម ។

ស្រាយប្រស្នានោះសោះ, លោកដោះស្រាយប្រស្នាទាំងនោះ មួយរំពេចក្នុងខណៈនោះឯង ហើយមានថេរដីកាចំពោះឃោសមាណពថា ម្នាលព្រាហ្មណ៍ដ៏ចំរើន, អ្នកឯងសួរអាត្មាច្រើនលើកណាស់ហើយ, ឥឡូវនេះត្រូវអាត្មាសួរប្រស្នាតែមួយចំពោះអ្នកឯងវិញ ។ ករុណាបពិត្រដ៏ចំរើន, សូមលោកសួរមកចុះ ។ ព្រះថេរៈសួរប្រស្នាក្នុងចិត្តយមកៈដូច្នេះថា "ចិត្តរបស់បុគ្គលឯណាកើតឡើងមិនរលត់, ចិត្តរបស់បុគ្គលនោះនឹងរលត់ នឹងមិនកើតឡើង; ពុំនោះសោតថា ចិត្តរបស់បុគ្គលឯណានឹងរលត់ នឹងមិនកើតឡើង, ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងមិនរលត់ តើបុគ្គលនោះជាអ្វី? មាណពដោះស្រាយពុំរួច ទើបសួរថា បពិត្របព្វជិតដ៏ចំរើន, ហ្នឹងឈ្មោះអ្វី? ម្នាលព្រាហ្មណ៍, ហ្នឹងឈ្មោះពុទ្ធមន្ត ។ លោកម្ចាស់ អាចឲ្យបានពុទ្ធមន្តនេះដល់ខ្ញុំករុណាបានឬទេ? អាត្មាអាចឲ្យបានចំពោះតែអ្នកកាន់ភេទបព្វជ្ជា ។ លំដាប់នោះ ឃោសមាណពក៏សូមបព្វជ្ជា ដើម្បីរៀនមន្ត ។ ព្រះថេរៈបានបំបួសឃោសមាណពនោះ បានឲ្យឧបសម្បទាហើយបង្រៀនពុទ្ធវចនៈគឺព្រះត្រៃបិដក ។ ឃោសភិក្ខុនោះមានឈ្មោះថា "ពុទ្ធឃោសៈ" ដូច្នេះប្រាកដក្នុងលោក(១) ។

---

១ សេចក្តីរួបផ្តាំខាងចុងនេះ មិនជារឿងគួរអ្នកគិតប្រើគំនិតច្រើនទេ ព្រោះជាសេចក្តីងាយនឹងយល់ថា ឃោសមាណពនេះចប់ត្រៃវេទ មិនមែនក្នុងវ័យអាយុ ៧ ឆ្នាំទេ, តាំងពេលដែលបានបព្វជ្ជានិងឧបសម្បទាក៏គេអាចយល់បានថាក្នុងកំណត់អាយុ ២០ ឆ្នាំឡើងលើ ។

សេចក្តីក្នុងសុត្តជាតកនិទាន និទានសង្សេទនៃពុទ្ធឃោសនិទានថា ឃោសកុមារបានបព្វជ្ជាជាសាមណេរក្នុងសំណាក់ព្រះអរហន្ត ជាឧបជ្ឈាយ៍ ហើយមានកិត្តិស័ព្ទសេចក្តីសរសើរថាជាកុលបុត្រមានវត្តប្រតិបត្តិល្អសំខាន់ គឺសាមណេរនេះមានសេចក្តីព្យាយាមបោសសំអាតទីអារាម, ព្យាយាមដើរបិណ្ឌបាត, ព្យាយាមធ្វើវត្តតូចវត្តធំចំពោះព្រះឧបជ្ឈាយ៍, ព្យាយាមសិក្សាព្រះត្រៃបិដកតពីព្រះឧស្ទព្រះឧបជ្ឈាយ៍ ជាកុលបុត្រប្រកបដោយប្រាជ្ញាឆ្លៀវឆ្លាសវាងវៃ, សេចក្តីដែលព្រះឧបជ្ឈាយ៍ពន្យល់សូម្បីតែមួយបទ ក៏អាចយល់ហេតុផលរយដល់ពាន់បទ, រៀនចាំស្ទាត់ជាប់ដល់ចប់ព្រះត្រៃបិដកទាំង ៨ ហ្មឺន ៤ ពាន់ធម្មក្ខន្ធឥតភាន់ច្រឡំឡើយ ។ កាលដែលលោកចំរើនវ័យដល់ព្រះជន្ម ២០ ឆ្នាំ លោកបានឧបសម្បទាជាភិក្ខុបាននាមថា "ពុទ្ធឃោសៈ" ជាអ្នកល្បីល្បាញខាងឯការសំដែងធម៌ពីរោះក្បោះក្បាយ ប៉ុនប្រសប់ដោះស្រាយអាថ៌ប្រស្នាវិសេសជាងអ្នកប្រាជ្ញទាំងពួង ។ កាលបើសេចក្តីសរសើរកើតឡើងដល់លោកកាន់តែចំរើនច្រើនឡើង ក៏លោកគិតក្នុងព្រះទ័យថា "ព្រះឧបជ្ឈាយ៍របស់អញប្រហែលអស់ចំណេះប៉ុណ្ណឹងហើយដឹង" គ្រាន់តែគិតប៉ុណ្ណោះ ក៏ព្រះឧបជ្ឈាយ៍ជ្រាប ហើយហាមមិនឲ្យព្រះពុទ្ធឃោសាចារ្យធ្វើវត្តប្រតិបត្តិតទៅទៀតដោយសេចក្តីតោទប្រកាន់ថា ព្រះពុទ្ធឃោសាចារ្យមើលងាយឧបជ្ឈាយ៍ ៗ ព្រះពុទ្ធឃោសាចារ្យអង្វរករសូមទោស ទើបព្រះឧបជ្ឈាយ៍

ដាក់ទណ្ឌកម្មថា "លុះតែអ្នកឯងទៅប្រែព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ឯលង្កាទ្វីបដែលជាសីហឡភាសា មកជាមគធភាសាឲ្យចប់សព្វគ្រប់ ហើយនាំត្រឡប់មកជម្ពូទ្វីបវិញទើបរួចទោសនេះ" ។ កិច្ចទណ្ឌកម្មប៉ុណ្ណេះ ក៏មិនជាការធ្ងន់ដល់ព្រះពុទ្ធឃោសាចារ្យនោះ ហាក់ដូចជាគេរុញត្រីធំទម្លាក់ទឹកសមុទ្រ ។ ព្រះពុទ្ធឃោសាចារ្យព្រមទទួលទណ្ឌកម្មដោយសោមនស្សហើយប្រុងប្រៀបនឹងទៅលង្កាទ្វីប ។ ប៉ុន្តែមុននឹងចេញដំណើរទៅនោះលោកលាព្រះឧបជ្ឈាយ៍ ទៅជួនមាតាបិតាឲ្យរក្សាសីល ឲ្យបំពេញកម្មដ្ឋានបានសម្រេចសោតាបត្តិផល ហើយលាមាតាបិតាទៅគាល់ព្រះឧបជ្ឈាយ៍វិញ ដើម្បីនឹងចេញដំណើរទៅលង្កាទ្វីប ។

សេចក្តីក្នុងពុទ្ធឃោសុប្បត្តិកថាថា: ព្រះពុទ្ធឃោសាចារ្យបានឧបសម្បទារួចហើយ នៅក្នុងវត្តនោះ បានធ្វើគម្ពីរមួយឈ្មោះ "ញាណោទយ" រួចស្រេចហើយ កំពុងប្រារព្ធដើម្បីធ្វើគម្ពីរអដ្ឋសាលិនី អដ្ឋកថាអភិធម្មសង្គណី នឹងអដ្ឋកថាបរិត្ត[១] ក៏ស្រាប់តែព្រះមហាថេរ

---

១ ពាក្យត្រង់នេះបុរាណសេចក្តីឲ្យយល់ថា "ព្រះបរិត្តឬភាណវារៈប្រាកដជាព្រះគន្ធរចនាចារ្យ ជាគម្ពីររៀបរៀងខុត ព. ស. ៩៥៦" ។ បំណងរបស់ព្រះពុទ្ធឃោសាចារ្យចំពោះកិច្ចនេះ ប្រ-ហែលជាមិនសម្រេចបានជាត្រឡប់ឃើញឯឈ្មោះព្រះថេរៈអនោមទស្សី ជាអ្នករៀបរៀងអដ្ឋក-ថាភាណវារៈវិញ ។ ព្រះអនោមទស្សីនេះមានព្រះនាមប្រាកដក្នុងសៀវភៅ "រឿងប្រតិស្ឋានព្រះពុទ្ធសាសនាក្នុងលង្កាទ្វីប" របស់ក្រុមព្រះតាំរ៉ុងភាគានុភាព ថាជាព្រះអដ្ឋកថាចារ្យ ១ រូបនៅលង្កាទ្វីប ក្នុងចំណោមព្រះអដ្ឋកថាចារ្យ ៦៧ រូប ។

មានថេរដីកាថា ម្នាលពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានព្រះត្រៃបិដក មិនទាន់គ្រប់គ្រាន់ ក្នុងសីហឡទ្វីប (លង្កាទ្វីប) ទើបមានគ្រប់គ្រាន់ ព្រមទាំងអដ្ឋកថាជាភាសាសីហឡៈ ដែលព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត(១) ជាដើមបានលើកឡើងកាន់ការសង្គាយនាហើយ; ហេតុដូច្នេះ ត្រូវអ្នកឯងទៅឯសីហឡទ្វីប ប្រែអដ្ឋកថាទាំងអស់នោះមកជាមគធភាសា, អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍ដល់សត្វលោកទាំងពួង ។ កាលបើព្រះមហាថេរមានថេរដីកាយ៉ាងនេះ, ព្រះពុទ្ធឃោសៈក៏មានអាយុកមានបីតិសោមនស្សស្រស់ស្រាយរីករាយ ថ្វាយបង្គំលាព្រះឧបជ្ឈាយ៍នឹងភិក្ខុសង្ឃនិមន្តតម្រង់ទៅកាន់កំពង់ ឡើងគង់លើសំពៅ ទៅដល់ពាក់កណ្តាលមហាសមុទ្រ បានឃើញព្រះថេរៈឈ្មោះ "ពុទ្ធទត្ត" ដែលកំពុងនិមន្តមកតាមនាវា ត្រឡប់មកជួបគ្នា ចរចារាក់ទាក់សព្វកិច្ចការ ហើយលោកនិមន្តហួសពីទីនោះទៅដល់កំពង់នៃកោះលង្កា ។

---

១ មិនមែនព្រះសារីបុត្តជាធម្មសេនាបតីទេ, គឺព្រះសារីបុត្តនៅលង្កាទ្វីប ដែលជាក្រុមព្រះសង្គីតិកាចារ្យធ្វើបោត្តការឡើងសង្គាយនាក្នុង ព.ស. ៤៣៣ ។ តក្រោយពីព្រះពុទ្ធឃោសាចារ្យ (ព.ស. ៩៥៦) មក មានព្រះអដ្ឋកថាចារ្យព្រះនាមសារីបុត្ត ១ រូបទៀត ។ ព្រះថេរៈនេះមានសេចក្តីសរសើរក្នុងសៀវភៅ "ស្សាមូបសម្បទវត្ត" ថាមានប្រាជ្ញាណាស់ បើបានស្តាប់ៗសេចក្តីឯណាតែម្តងអាចចាំបានដល់ ១០០០ គាថា ។

សេចក្តីក្នុងពុទ្ធឃោសទិពាន ទីនសុត្តជាតក ដំណាលអំពីការបារ. ជាសំណេះសំណាលរបស់ព្រះពុទ្ធទត្តនឹងព្រះពុទ្ធឃោសៈថា កាលដែលព្រះពុទ្ធឃោសៈចុះសំពៅទៅនោះ មានព្រះឥន្ទជាតៃកុងកាន់ចង្កូតសំពៅ, វេលាដែលជួបនឹងសំពៅព្រះពុទ្ធទត្ត ក៏ព្រះឥន្ទកាច់ចង្កូតឲ្យសំពៅអែបជិតគ្នា; ទើបព្រះពុទ្ធទត្តសួរព្រះពុទ្ធឃោសៈប្រាប់ជាក់ជាទៅប្រែគម្ពីរឯកោះលង្កា ក៏លាន់ព្រះឱស្ឋថា អាវុសោ! បំណងរបស់អ្នកនេះ ក្រែងមិនសម្រេចទេដឹង? លោកប៉ាំងចុះ! ខ្ញុំនេះឯងហើយដែលមានបំណងដូច្នោះ, ខ្ញុំចេញពីជម្ពូទ្វីបទៅលង្កាទ្វីបតាំងពីក្មេង ដរាបដល់ឥឡូវនេះខ្ញុំមានអាយុ ១០០ ឆ្នាំ, ខ្ញុំប្រែបានតែ ១ គម្ពីរ, គម្ពីរនោះ ខ្ញុំសន្មតឈ្មោះថា "ជិនាលង្ការ", កាលបើមិនសម្រេចដូចប្រាថ្នា ក៏ខ្ញុំត្រឡប់មកវិញដោយផុតសង្ឃឹម; អាវុសោ, អ្នកទៅឥតកំពើទេដឹងឬ? ព្រពុទ្ធឃោសៈថាម្តេចក៏ព្រះថេរៈថាដូច្នោះ? ម្នាលអាវុសោ, ព្រោះគម្ពីរភាសាសីហឡៈនោះល្អិតល្អន់ណាស់! មានអក្សរសព្ទទូលាយណាស់! មិនងាយនឹងពិចារណាឲ្យជ្រះស្រឡាយបានទេ ។ ព្រះករុណា, សេចក្តីនេះ ក៏គួរជឿដែរហើយ, ប៉ុន្តែសូមទានអភ័យទោសចុះ ហាក់ដូចជាខ្ញុំព្រះករុណាក៏ជាមនុស្សចេះចេសមុខរឹង, ក្នុងរឿងនេះខ្ញុំព្រះករុណា យល់ឃើញសេចក្តីឧបមាថា: មិនប្រុសម្នាក់ចង់បានប្រពន្ធ, កាលៈបើបានឮគេថា មានកូន

ក្រមុំរបស់ត្រកូលមួយមានរូបល្អ ជាស្រីគ្រប់លក្ខណ៍, បុរសនោះបាន ទៅឃើញជាក់ ហើយមានចិត្តប្រតិព័ទ្ធ អត់ពុំបានក៏ចូលទៅដណ្ដឹង ចំផ្កាប់ផ្គុនយ៉ាងណា ក៏មាតាបិតាពុំព្រមឲ្យកូនក្រមុំនោះដល់បុរសនោះ សោះ; ដល់ថ្ងៃក្រោយទៀត មានបុរសដទៃ បម្រុងទៅស្ដីដណ្ដឹងនាង ក្រមុំនោះដែរ, ស្រាប់តែបុរសមុននោះមកឃាត់ថា កុំទៅ! គេមិនឲ្យ ទេ! ។ ខ្ញុំព្រះករុណាយល់ថា បុរសមុននោះ ពុំគួរឃាត់បុរសឯទៀត ទេ, បាបតែខ្លួនជាមនុស្សឥតគតិ, ម្ដេចក៏ចង់ឲ្យគេឥតគតិដូចខ្លួនដែរ? ។

ព្រះពុទ្ធទត្តស្ដាប់សេចក្ដីឧបមានេះបាន ក៏បញ្ជាក់ថែមទៀតថា "អាវុសោ, អ្នកឯងមិនជឿជាគម្ពីរសីហឡៈ មានសេចក្ដីល្អិតល្អន់ណាស់ ទេតើ! បើដូច្នេះ អ្នកឯងមើលត្រឹមតែគម្ពីរជិនាលង្ការដែលខ្ញុំប្រែមកនេះ ចុះ ក៏អាចដឹងបានថាការនេះក្រមែន," ហើយលោកយកគម្ពីរជិនាលង្ការ នោះ មកឲ្យព្រះពុទ្ធឃោសៈពិនិត្យមើល ។ ព្រះពុទ្ធឃោសៈពិនិត្យ មើលយល់សេចក្ដីច្បាស់លាស់ ហើយឃើញសេចក្ដីខ្វះដែលទាស់ ក៏ជួយ តម្រូវដល់ព្រះពុទ្ធទត្តថែមទៀត ។ ព្រះពុទ្ធទត្តមានអំណរយ៉ាងខ្លាំង ទើបឲ្យសព្ទសាធុការថា "អាវុសោ, អ្នកឯងជាអ្នកប្រាជ្ញពិតប្រាកដមែន លុះមកនៅប្រែគម្ពីរឯលង្កាទ្វីបបានមែន," ហើយលោកប្រគេនថ្ងៃសម៉ឹង ដែកចារ ព្រមទាំងថ្មសំលៀង ដល់ព្រះពុទ្ធឃោសៈថា: វត្ថុទាំងនេះ

ព្រះឥន្ទបានប្រគេនដល់ខ្ញុំ តាំងពីកាលដែលខ្ញុំពេញដំណើរទៅប្រែគម្ពីរឯកោះលង្កា ជាវត្ថុមានអានុភាពវិសេសណាស់, ដ្បិតសម៉ីនេះ បើឆាន់ត្រឹមតែមួយប៉ុណ្ណោះ អាចនឹងបំបាត់រោគគ្រប់យ៉ាងបាន, ដែកបារនេះ បើសំលៀងនឹងថ្មនេះតែម្ដង អាចចារគម្ពីរព្រះត្រៃបិដកបាន ១ ចប់; ឥឡូវនេះ ខ្ញុំប្រគេនទៅលោកទៀត, ប៉ុន្តែសូមលោកយកគម្ពីរជិនាលង្ការរបស់ខ្ញុំ ទៅកែតម្រូវឲ្យខ្ញុំផង ។ ព្រះពុទ្ធឃោសៈ ទទួលកែប្រគេនក្នុងមួយរំពេច ហើយស្រេចបានការជាគម្ពីរត្រឹមត្រូវល្អ ជាងសេចក្ដីដែលព្រះពុទ្ធទត្តធ្វើអស់កាលជាអង្វែងមកហើយ ។ ព្រះពុទ្ធទត្តមានសេចក្ដីកោតស្ញប់ស្ញែង ឲ្យស័ព្ទសាធុការសរសើរសព្វគ្រប់ប្រការ ហើយបែកចាកគ្នាទៅតាមប្រាថ្នារៀងខ្លួនទៅ ។ ព្រះពុទ្ធឃោសៈ បានទៅដល់កំពង់នៃកោះលង្កា ក្នុងរជ្ជសម័យនៃព្រះបាទមហានាមព្រះចៅលង្កាទ្វីប ។

សេចក្ដីដំណាលសរសើរប្រាជ្ញាវាងវៃនឹងការអង់អាចរបស់ព្រះពុទ្ធឃោសៈ ១ លើកទៀតថា: គ្រាដែលលោកទៅចតសំពៅនៅកំពង់លង្កាទ្វីប, មានទាសីរបស់សេដ្ឋីម្នាក់ ចុះទៅដងទឹក, កំពុងកណ្ដៀតក្អមពេញដោយទឹកឡើងមកមិនទាន់ផុតពីមាត់ច្រាំង ជួនជាមានទាសីរបស់សេដ្ឋីដទៃម្នាក់ទៀតជាស្រីកាច មានកិរិយាឆ្កោកឆ្កោះ កាន់ក្អមគ្រីគ្រក់

ចុះទៅដងទឹកដែរ, ក្អមទាសីដែលកំពុងចុះទៅ ប៉ះទង្គិចនឹងក្អមទាសី ដែលកំពុងឡើងមកបែកខ្ចាយអន្តរាយទាំងពីរ, ទាសីក្អមស្រាលក៏ដេរ ដៀលត្នះ ដល់ពូជអំបូរឪពុកម្ដាយមីងចៅហ្វាយរបស់ទាសីក្អមធ្ងន់ដែល កំពុងឡើងមក, នាងនោះដេរតបវិញ ក៏ក្លាយទៅជាជម្លោះយ៉ាងធំ រាយ ដំទាត់ធាក់គ្នាអស់ចិត្ត ទើបត្រឡប់ទៅផ្ទះវិញតែរៀងខ្លួន ៗ

ចំណែកខាងព្រះពុទ្ធឃោសាចារ្យ តាំងពីកាលដែលឃើញទាសី កំណាចកំពុងដើរមក ក៏ចាប់ក្ដីកទឹកឃើញមុនថា "កិរិយាស្រីនេះ ទំង បណ្ដាលឲ្យកើតជាជម្លោះ ឥឡូវនេះពុំខាន; បើស្រីទាំងនេះឈ្លោះគ្នា មែន, ប្រាកដជាអាងដល់អាត្មាអញជាសាក្សី; បើអាត្មាអញឆ្លើយថា មិនដឹង ទំងជាមុសាវាទ, បើឆ្លើយតាមដឹង មិះសមក្រិត្យផ្សិតខ្លួនជាសង្ឃ មិនគួរធ្វើសាក្សីឲ្យគេហស្ថទាស់គ្នាឡើយ; ហ្នើយចុះបើដូច្នេះ គួរអាត្មា អញកត់សំដីដែលវាឈ្លោះគ្នានោះទុកឲ្យហើយ", ទើបលោកលូកយក ស្លឹករឹតទងដែកចារ បានមកដល់ព្រះហស្ដកាលណា ក៏ស្រីទាំង ២ នាក់ នោះឈ្លោះគ្នាក្លាមក្នុងកាលនោះមែន ៗ ឯសំដីអ្នកសីហឡ្ទៈញាប់ស្រាប់ ជាប្រក្រតី ជាងសំដីអ្នកប្រទេសឯទៀត ដល់មានជម្លោះគ្នាទៀត ក៏រឹតតែញាប់ដោយក្រៃលែង ដូចជាស្នាបគង្ហារដែលកំពុងវិលខ្ទាំង ៗ សំដីដែលស្រីទាំងពីរនាក់ឈ្លោះគ្នានោះ រាប់បានចំនួន ២ ពាន់ម៉ាត់ម្នាក់ៗ

ឥតខាក់ឥតអាក់អួលសោះ, ដល់ម្ល៉ោះ ក៏គង់តែព្រះពុទ្ធឃោសាចារ្យ កត់ត្រាទាន់ឥតភាន់ច្រឡំ[1] ។

ឯតាសិក្ខមស្រាល ជាស្រែកំណាច បានត្រឡប់ទៅដល់ផ្ទះហើយ ក៏ចូលទៅលំអុកឲ្យសេដ្ឋីជាចៅហ្វាយរបស់ខ្លួន ក្លែងសំដីនិយាយបន្តាច់ថា "ខ្ញុំកំពុងដើរជាសុខស្រាប់តែមេតាសីឈ្មោះនោះ របស់សេដ្ឋីឯណោះ ស្ទុះមកប៉ះទង្គិចឲ្យបែកក្អមខ្ញុំ ហើយក៏ជេរដៀលតូចប្រដូចសន្តានចំពោះមកលោកជាចៅហ្វាយឯណោះផងទៀត, មេតាសីនោះមិនគួរបើបានមើលងាយដល់ម្ល៉ោះសោះ នេះព្រោះតែក៏អាងដល់ចៅហ្វាយក៏ជាប្រាកដ" ។

សេដ្ឋីនោះឮដូច្នោះហើយ ក៏ខឹងក្រញើគឡើងថា "មែនហើយហ្នឹ! បើដូច្នោះ អញនឹងប្តឹងឲ្យវិនាសខ្លួនក៏ព្រមទាំងម្ចាស់ក៏ផង"

---

១ សេចក្តីត្រង់នេះ បើគិតតាមផ្លូវច្បាស់ហែង ក៏គួរឲ្យកោតដោយយ៉ាង ។ រឿងនេះ បើគិតតាមផ្លូវធម៌ គេអាចយល់ថាសេចក្តីប៉ិនប្រសប់បែបនេះ កើតដោយអំណាចបុណ្យនឹងដោយអំណាចនៃការរៀន ។ បើគិតតាមផ្លូវលោក គេអាចយល់ថា សេចក្តីប៉ិនប្រសប់បែបនេះ កើតដោយអំណាចនៃការរៀន, គឺព្រះពុទ្ធឃោសាចារ្យនេះ ជាមនុស្សម្នាក់ដែលបារាំងសែសហៅថា Sténographe ចេះវិជ្ជាម្យ៉ាងដែលហៅថា "Sténographie" សញ្ញាលេខនវិជ្ជា" គឺវិជ្ជាខាងការសរសេរឲ្យរហ័សស្មើនឹងសំដីនិយាយ ដោយប្រើគ្រឿងសំគាល់ ។ ប៉ុន្តែបើព្រះពុទ្ធឃោសាចារ្យកត់ពាក្យមនុស្សឈ្លោះគ្នានោះពេញសេចក្តីទាំងអស់ នោះមិនមែនប្រើ Sténographie នោះទេ; ប្រាកដជាមានវិជ្ជាម្យ៉ាងដែលពុទ្ធសាសនាហៅថា "កម្មវិបាកជាវិជ្ជា" ចំណេះឬសេចក្តីឆ្លាតដែលជាផលរបស់បុញ្ញកម្ម ។

ហើយសេដ្ឋីនោះនៅក្រាបបង្គំទូលព្រះរាជាចោទប្រកាន់តាសក្អមធ្ងន់ជាប់ដល់សេដ្ឋីជាហៅហ្វាយផង ។ ព្រះរាជាត្រាស់ឲ្យប្រជុំគូវិវាទទាំងសងខាងសួរបញ្ជាក់សព្វគ្រប់សេចក្តី ក៏វិនិច្ឆ័យសេចក្តីដោយយុត្តិធម៌ពុំទាន់បាន ព្រោះគូវិវាទនៅតែមានពាក្យដោះសារទៅរួច ; ព្រះរាជាត្រាស់សួររកសាក្សី ក៏តាសក្អមទាំងពីរនាក់ឆ្លើយអាងថា "កាលដែលខ្ញុំម្ចាស់ប្រកែកគ្នា មានតែព្រះសង្ឃ ១ អង្គគង់នៅលើសំពៅ បានឃើញបានឮផង" ។ ទើបព្រះរាជាត្រាស់បង្គាប់ឲ្យអាមាត្យម្នាក់ ទៅនិមន្តព្រះពុទ្ធឃោសាចារ្យមក ដោយទ្រង់ពុំទាន់ជ្រាបថាព្រះសង្ឃអង្គណាសោះ ។ កាលរាជ-អាមាត្យបាននាំដល់សំពៅ ក្រាបបង្គំទូលតាមព្រះរាជបញ្ជា, ព្រះពុទ្ធ-ឃោសាចារ្យដំរាបសេចក្តីតាមគំនិតរបស់ខ្លួនហើយ ឲ្យកំណត់ដែលកត់ពាក្យស្រីឈ្លោះគ្នានោះ ទៅថ្វាយព្រះរាជាជាជំនួសខ្លួន ។ ព្រះមហា-ក្សត្រទ្រង់ទស្សនាកំណត់នោះហើយជ្រាបក្នុងព្រះរាជហឫទ័យថា នេះពិតជាស្នាព្រះហស្តរបស់ព្រះសង្ឃជាអ្នកប្រាជ្ញ, ទើបទ្រង់វិនិច្ឆ័យសេចក្តីថា "មេតាសក្អមស្រាល ជាស្រីអន្ធពាល នាំបណ្តាលហេតុឲ្យកើតកោលាហលដល់អ្នកផង ហើយមើលងាយដល់អ្នកមានបណ្តាសក្តិផង, ហងឯងត្រូវចាញ់! បើតាមកំហុសនេះ ហងឯងត្រូវបង់ពិន័យតាមព្រះច្បាប់, ប៉ុន្តែដោយរឿងនេះជាប់ទាក់ទងដល់ព្រះសង្ឃផង ហងឯងត្រូវសងត្រឹមតែក្អមគេ មួយគុណជាប៉ុណ្ណោះចុះ" ។

ទាសីកម្មស្រោលនោះ ក៏ទូលទាស់ព្រះរាជឱង្ការថា "ម្ដេចក៏ព្រះអង្គជឿតាមកំណត់របស់លោកសង្ឃគម្រក់នោះ? លោកសង្ឃនោះ មិនមែនជាអ្នកកាន់ក្រិត្យវិន័យទេ! ប្រាកដជាអ្នកជំនួញ ចុះសំពៅមកជួញ. ខ្ញុំម្ចាស់ឃើញលោកអង្គុយសំកុកជ្រប់មើលតែផ្លូវអ្នកទិញទំនិញ; សូមព្រះអង្គបដិសេធពាក្យនោះចេញ កុំយកជាប្រមាណឡើយ ។ ព្រះរាជាត្រាស់ថា យីអើ! មេទាសីនេះមាត់រឹង, ហ៊ានមើលងាយដល់ព្រះសង្ឃទៀត; បើដូច្នេះ ត្រូវហែងឯងទៅសូមទោសចំពោះព្រះភក្ត្រលោកទៀត! ទើបរួចទោសនេះបាន ។

ចំណែកខាងព្រះពុទ្ធឃោសាចារ្យ មានប្រាថ្នាទឹងទៅថ្វាយបង្គំព្រះមហាថេរដែលជាអធិបតីលើសង្ឃក្នុងលង្កាទ្វីប, ទើបឡើងពីសំពៅសំដៅទៅវត្តមហាវិហារក្នុងអនុរាធបុរី ។ សម័យនោះ ព្រះសង្ឃបាលត្ថេរនាទីជាសម្ដេចព្រះមហាសង្ឃរាជ កំពុងបង្រៀនធម៌វិន័យដល់ព្រះសង្ឃជាច្រើនរូប, ព្រះពុទ្ធឃោសាចារ្យឃើញកិច្ចនោះ ទើបគិតថា "បើអាត្មាអញចូលទៅ, សមជាទឹងសាក់ការបង្រៀន", ហើយលោកទៅអែបនៅទី ១ ជ័សមគួរ មិនឲ្យព្រះសង្ឃបាលត្ថេរឃើញឡើយ ។ ឯព្រះសង្ឃបាលត្ថេរកាលដែលព្រះពុទ្ធឃោសាចារ្យចូលទៅដល់ ក៏ស្រាប់តែភ្លេចបាត់សេចក្ដីទឹងទឹករកពាក្យអ្វីពន្យល់សិស្សតទៅទៀតពុំឃើញ; មានសេចក្ដីអៀនអន់

ក្នុងព្រះទ័យណាស់ ក៏ចូលទៅសម្ងំក្នុងបន្ទប់ ដែលព្រះភក្ត្រហាក់ដូចជាជ្រុះបេះដូងថ្លើមប្រមាត់បាត់ពីកន្លែង ។

សេចក្តីត្រង់នេះ មានពាក្យអ្នកប្រាជ្ញទៀតចោទសួរគ្នាថា: ចុះហេតុដូចម្តេចបាន ជាគ្រាន់តែព្រះពុទ្ធឃោសាចារ្យចូលមកដល់ ក៏ព្រះសង្ឃបាលត្ថេរភ្លេចបាត់ស្មារតីសូន្យឈឹងដូច្នោះ? អាចារ្យដែលបានបុព្វេ-និវាសវិជ្ជាឆ្លើយថា ដោយអំណាចកម្មពីព្រេង ។ កម្មពីព្រេងដូចម្តេច? កម្មពីព្រេង គឺអំពើផ្តាំផ្គងដែលព្រះសង្ឃបាលត្ថេរនោះធ្វើពីជាតិមុនមក, ព្រោះកាលពីដើមព្រះសង្ឃបាលត្ថេរនេះ កើតជាអ្នកគង្វាលគោ ឈ្មោះគោបាលមាណព តែងកៀងគោទៅឃ្វាលជិតវត្ត ។ កាលនោះ ព្រះពុទ្ធឃោសាចារ្យកើតជាភិក្ខុ ១ រូបកំពុងស្វាធ្យាយទន្ទេញធម៌ ក៏ភ្ញាក់ភាន់ច្រឡំធម៌ដែលកំពុងទន្ទេញនោះបាត់ពីមាត់ ដោយហេតុតែឮសន្ធឹកគោនិងសូរសព្ទនៃគោបាលមាណពនោះ; បានជាមកដល់ឥឡូវនេះ ព្រះសង្ឃ-បាលត្ថេរនោះភ្លេចធម៌ពីមាត់វិញ និងពន្យល់សិស្សតទៅទៀតពុំកើត ដោយត្រឹមតែដំណើរចូលមកនៃព្រះពុទ្ធឃោសាចារ្យប៉ុណ្ណោះ ។

ចំណែកខាងព្រះពុទ្ធឃោសាចារ្យ បានឃើញកិរិយានោះហើយ ក៏ជ្រាបថា "ព្រះសង្ឃបាលត្ថេរនេះភ្លេចគណ្ឋី" ទើបលោកសរសេរសេចក្តីក្នុងគណ្ឋីត្រង់កន្លែងដែលព្រះសង្ឃបាលត្ថេរភ្លេចនោះ ទុកនៅកន្លែងបង្រៀន ហើយចៀសចេញទៅ ។

ព្រះសង្ឃបាលត្ថេរ ចេញពីក្នុងបន្ទប់មកវិញ បានឃើញសេចក្តី នោះក៏ភ្លឺច្បាស់ឡើងមួយរំពេច ហើយសួរសិស្សថា ទេវតាឬមនុស្ស ណា មកសារសេរអក្សរទុកនៅទីនេះ ល្អល្អះច្បាស់សេចក្តីដល់ម្ល៉េះ? សិស្សទូលតបថា ខ្ញុំព្រះករុណាបានឃើញលោកសង្ឃ ១ អង្គប្លែក មាន រូបល្អចំឡែកមកឈរក្បែរជិតទីនេះ, ប្រហែលជាលោកសង្ឃនោះទេដឹង ដែលសារសេរអក្សរនេះ ។ ព្រះសង្ឃបាលត្ថេរស៊ើបសួរសព្វគ្រប់ជ្រាបថា លោកសង្ឃនោះគឺព្រះពុទ្ធឃោសាចារ្យ ដែលគង់នៅឯសំណាក់ដ៏កំពង់, គឺប្រើភិក្ខុសង្ឃជាសិស្សរបស់ខ្លួនឲ្យតាមទៅនិមន្តមក ។ ព្រះពុទ្ធ-ឃោសាចារ្យបានមកដល់ ថ្វាយបង្គំព្រះសង្ឃបាលត្ថេរដោយគោរព; កាលបើព្រះសង្ឃបាលត្ថេរសួរ, ក៏ក្រាបទូលសព្វគ្រប់ថា ពីវេលាមុន ខ្ញុំព្រះករុណាបានមកដល់ទីនេះ, បានដឹងជាព្រះមហាថេរមានសេចក្តី គាន់ច្រឡំ ក៏ខ្ញុំព្រះករុណាគិតនឹងទូលឲ្យជ្រាបក្នុងទីចំពោះព្រះភក្ត្រភ្លាមៗ ប៉ុន្តែបាក់ដូចជាអួតអាងចំពោះវិជ្ជាខ្លាំងពេក; បើមិនពិតទូលសោះ, បាក់ដូចជាមើលបំណាំដល់ព្រះពុទ្ធសាសនា; ហេតុដូច្នេះ បានជាខ្ញុំ ព្រះករុណាសារសេរដើម្បីកែសេចក្តីភ្ញាក់ភ្ញាំង, សូមទានព្រះមហាថេរ អភ័យទោសឲ្យទាន ។ ព្រះសង្ឃបាលត្ថេរទទួលអំណរថា ម្នាលអាវុសោ! លោកជាអ្នកប្រាជ្ញ, ខ្ញុំមានសេចក្តីត្រេកអរក្រៃពេកចំពោះកិច្ចដែល

លោកបានជួយបំពេញ, ហើយខ្ញុំមានសេចក្ដីស្រឡាញ់ពេញចិត្តចំពោះលោក ដែលមានសេចក្ដីចេះដឹងច្រើន, ហេតុដូច្នេះ ខ្ញុំសូមអារាធនានិមន្តលោកឲ្យនៅក្នុងវត្តរបស់ខ្ញុំ ដើម្បីជួយបង្រៀនព្រះត្រៃបិដកដល់ភិក្ខុសង្ឃ, សូមលោកទទួលព្រមដោយសេចក្ដីអនុគ្រោះដល់ព្រះពុទ្ធ-សាសនា ។ ព្រះពុទ្ធឃោសាចារ្យប្រកែកថា សូមមានមេត្តាប្រោស, ខ្ញុំព្រះករុណាមកកាន់ទីនេះ ដោយព្រះឧបជ្ឈាយ៍ចាត់ប្រើឲ្យមកប្រែព្រះត្រៃបិដកព្រមទាំងអដ្ឋកថាភាសាសីហឡ: ជាភាសាមគធ: រួចស្រេចហើយក៏ត្រឡប់ទៅវិញភ្លាម ; បើខ្ញុំព្រះករុណានៅជួយបង្រៀនព្រះត្រៃ-បិដកក្នុងទីនេះ, ឃើញជាខុសទាស់នឹងអាជ្ញាព្រះឧបជ្ឈាយ៍ខ្ញុំករុណាស់ ។

ព្រះសង្ឃបាលត្ថេរឮដូច្នោះហើយ ក៏រឹតតែមានសេចក្ដីពេញព្រះទ័យខ្លាំងឡើងដោយយល់ឃើញថា លោកនេះប្រហែលជាចេះដឹងជ្រៅជ្រះណាស់បានជាព្រះឧបជ្ឈាយ៍ហ៊ានប្រើឲ្យមកប្រែគម្ពីរសីហឡភាសាជាមគធភាសា, ប៉ុន្តែព្រះសង្ឃបាលត្ថេរពុំទាន់ជឿស៊ប់ថា ប្រាកដជាប្រែបានឬពុំបាននៅឡើយ, ទើបលោកដំណាលប្រាប់ថា ម្នាលអាវុសោ! ការដែលអ្នកមានបំណងនឹងធ្វើនេះក្រៃណាស់! ដែលមានបំណងដូច្នេះមិនត្រឹមតែអ្នកម្នាក់ឯងប៉ុណ្ណោះទេ, ពីមុនមកមានព្រះថេរ: ១ អង្គឈ្មោះពុទ្ធទត្ត បានមកប្រែគម្ពីរសីហឡភាសាជាមគធភាសាដែរ, លោកធ្វើអស់

វេលាជាច្រើនឆ្នាំ បានត្រឹមតែមួយគម្ពីរហើយទើបនឹងត្រឡប់ទៅវិញក្នុងវេលាមុននេះថ្មីៗ ។ ព្រះពុទ្ធឃោសាចារ្យថា ព្រះករុណា, ពិតដូច្នោះមែនហើយ, តាំងព្រះពុទ្ធទត្តសោត ក៏ខ្ញុំព្រះករុណាបានជួបដែរ, ខ្ញុំព្រះករុណាបានតាំងជួយកែសេចក្តីនៃគម្ពីរជិនាលង្កា ដែលព្រះពុទ្ធទត្តធ្វើមិនទាន់ត្រឹមត្រូវនោះទៀតផង ។

ព្រះសង្ឃបាលត្ថេរឮហើយ ត្រេកអរព្រឺព្រួចក្នុងព្រះទ័យនឹកថា លោកនេះប៉ិនប្រសប់ក្រាន់បើ ប្រហែលជាចេះដឹងច្រើនមែន, បើដូច្នេះអាត្មាអញសួរប្រស្នាដ៏ល្អិតល្អន់ មានអត្ថរសជ្រៅទូលាយ ចំពោះលោកនេះមើលអេះ, ហើយលោកលើកប្រស្នាដែលទេវតាសួរព្រះសម្មាសម្ពុទ្ធមកសួរព្រះពុទ្ធឃោសាចារ្យតាមពាក្យទេវតាថា

អន្តោជដា ពហិជដា ជដាយ ជដិតា បជា
តំ តំ គោតម បុច្ឆាមិ កោ ឥមំ វិជដយេ ជដំ?

សេចក្តីថា: បណ្តាញគឺតណ្ហាខាងក្នុងក៏មាន, បណ្តាញគឺតណ្ហាខាងក្រៅក៏មាន, ពពួកសត្វសុទ្ធតែត្រូវបណ្តាញគឺតណ្ហារួបរឹត (ឥតសល់-រូបណា); បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំសូមសួរព្រះអង្គចំពោះរឿងនោះថា នរណាទើបកាប់ផ្តាច់នូវបណ្តាញគឺតណ្ហានេះបាន?

ព្រះពុទ្ធឃោសាចារ្យ តបតាមព្រះពុទ្ធដីកាដែលព្រះសាស្ដាឆ្លើយ តបទៅគាថា:

សីលេ បតិដ្ឋាយ នរោ សបញ្ញោ
ចិត្តំ បញ្ញញ្ច ភាវយំ អាតាបី និបកោ ភិក្ខុ
សោ ឥមំ វិជដយេ ជដំ ។

សេចក្ដីថា នរជនឯណា ជាអ្នកខ្លាចភ័យក្នុងវដ្ដសង្សារ តបដោយបញ្ញា គឺបដិសន្ធិជាត្រៃហេតុកៈ ដែលកើតអំពីកុសលកម្ម[១] ហើយដំកល់ខ្លួននៅក្នុងសីលផង ចំរើននូវចិត្តគឺសមាធិផង ចំរើននូវបញ្ញា[២] គឺវិបស្សនាផង ជាអ្នកមានព្យាយាមដុតកំដៅនូវកិលេស មានបញ្ញាចាស់ក្លា[៣] នរជននោះ ទើបកាប់ផ្តាច់នូវបណ្ដាញគឺតណ្ហានេះបាន ។

(សេចក្ដីនៃប្រស្នានេះជ្រៅទូលាយណាស់ ជាគោលនៃសេចក្ដីប្រតិបត្តិ១ចប់ព្រះពុទ្ធសាសនា; បើសំដែងដោយពិស្ដារ ត្រូវគ្នានឹងព្រះត្រៃបិដក៨ហ្មឺន៤ពាន់ព្រះធម្មក្ខន្ធ) ។ កាលបើព្រះពុទ្ធឃោសាចារ្យវិសជ្ជនាដូច្នេះស្រេចហើយ, សម្ដេចព្រះសង្ឃរាជលោកមានសេចក្ដីជ្រះថ្លាពេញព្រះទ័យណាស់ ហើយមានថេរដីកាថា ហៃលោកអ្នកប្រាជ្ញ!

---

១ ប្រាជ្ញាទី ១ នេះ ហៅថា សជាតិបញ្ញា ។ ២ ប្រាជ្ញាទី ២ នេះ ហៅថា វិបស្សនាបញ្ញា ។
៣ ប្រាជ្ញាទី ៣ នេះ ហៅថា បារិហារិកបញ្ញា ។

លោកអាចដោះស្រាយប្រស្នានេះត្រូវតាមពុទ្ធភាសិតឥតមានខ្វះ, ជាហេតុឲ្យខ្ញុំករុណាជឿថា ព្រះពុទ្ធវចនទាំងអស់ លោកម្ចាស់ចាំបានឥតមានសល់; ហេតុដូច្នេះ ខ្ញុំករុណាសូមអារាធនា សូមឲ្យលោកម្ចាស់មេត្តារចនាគម្ពីរ សំដែងអំពីសីល សមាធិ បញ្ញា ដែលជាគោលដើមនៃព្រះពុទ្ធសាសនា ឲ្យខ្ញុំករុណាមួយចប់ កំណត់វេលាបីខែ តើលោកម្ចាស់អាចធ្វើឲ្យបានឬទេ ? ព្រះពុទ្ធឃោសាចារ្យទទួលថេរដីកាថា សូមពានមេត្តាប្រោស, ខ្ញុំព្រះករុណាជានារចនាប្រគេនបាន, ហើយទឹងយកមកប្រគេនក្នុងវេលាព្រឹកស្អែកនេះជាប្រាកដ ។ សម្តេចព្រះសង្ឃបាលត្ថេរ មហាសង្ឃរាជ នឹកកោតក្នុងព្រះរាជហឫទ័យ ហើយមានថេរដីកាថា ខ្ញុំករុណាមានសេចក្តីសង្ឃឹមមាំថា មុខជាទឹងបានឃើញស្នាដៃដែលសម្រេច ដោយបញ្ញាបារមីនៃលោកម្ចាស់ជាអ្នកប្រាជ្ញក្នុងវេលាឆាប់ៗ នេះពុំខាន ។

ព្រះពុទ្ធឃោសាចារ្យ កាលបើបានទទួលការចាត់ទម្ងន់ដូច្នេះហើយ ក៏ក្រាបបង្គំលាសម្តេចព្រះសង្ឃបាលត្ថេរ ត្រឡប់ទៅកាន់សំពៅនៅមាត់កំពង់វិញ ចាប់យកដែកចារនឹងស្លឹករឹត មកគង់លើក្បាលសំពៅ ដើម្បីរៀបរៀងគម្ពីរ ក្នុងវេលាបឋមយាមរាត្រីនៃថ្ងៃពេញបូណ៌មីនោះ ។

គ្រានោះ សម្ដេចអមរិន្ទ្រាធិរាជ បានប្រាប់ដល់ចន្ទទេវបុត្រឲ្យបញ្ចេញពន្លឺឲ្យភ្លឺអស្ចារ្យ, ប្រាប់វលាហកទេវបុត្រឲ្យបក់ផាត់ពពកកុំឲ្យបាំងរស្មីព្រះចន្ទ្រ ។

ព្រះពុទ្ធឃោសាចារ្យ ចាប់ការរៀបរៀងគម្ពីរ ចប់ក្នុងវេលាបឋមយាមរាត្រីនោះសន្មតឲ្យឈ្មោះ "វិសុទ្ធិមគ្គ(១)" សំដែងអំពីសីល សមាធិ បញ្ញា ហើយចូលកាន់ទីសយនាសន៍លក់មួយស្របក់ ក៏ព្រះឥន្ទ្រលួចឆក់

---

១ គម្ពីរវិសុទ្ធិមគ្គនេះ ជាទីនិយមប្រើការរបស់អ្នកកាន់ពុទ្ធសាសនាប៉ែកខាងទក្ខិណនិកាយរហូតមកដល់សម័យនេះ, ដែលឃើញមានបោះពុម្ពហើយ ចំនួនជាង ៨២០ ទំព័រអក្សរញឹកល្អិត បើពិតជាព្រះពុទ្ធឃោសាចារ្យរៀបរៀងចប់ក្នុងរវាង ១ យាមដូច្នេះមែន ជាហេតុឲ្យតឹងគំនិតរបស់អ្នកល្ងង់ហើយប្រឹងតែគិតនោះខ្លាំងណាស់ ។ ព្រោះអោនមនុស្សខ្លះ មិនព្រមជឿសេចក្ដីអស្ចារ្យរបស់អ្នកមានបុណ្យបែបនេះទេ ដោយអាងថាខ្លួនធ្វើដូច្នោះដែរហើយ នៅតែមិនកើតម្ល៉ោះហើយក៏ទាញឈ្មោះអ្នកដែលធ្វើកើតនោះមកដាក់ថាមិនកើតដូចខ្លួនផង ។

ខ្ញុំក៏មិនជាមនុស្សដេកធ្មេចចាំតែជឿទេ ប៉ុន្តែពុំហ៊ានបដិសេធសេចក្ដីដែលគេបានចារិកទុកមកហើយនោះសោះ ដោយយល់ឃើញថា មនុស្សយើង បើឥតអានុភាពប្លែកពីគេដូច្នោះម្ដេចនឹងឲ្យគេហៅថា អ្នកមានបុណ្យកើត! មនុស្សមានបុណ្យចំឡែក មិនត្រឹមតែព្រះពុទ្ធឃោសៈនេះទេ គង់មានមនុស្សឯទៀតជាច្រើនឈ្មោះ ប៉ុន្តែខុសគ្នាត្រឹមតែអ្នកខ្លះមានបុណ្យបែបនេះ ខ្លះបែបនោះប៉ុណ្ណោះ; ដូចពន្លុលសេនាបតី អាចកាប់តែ ១ ដាវឲ្យដាច់ឫស្សី ៦០ ដើមដែលគេដាក់ស្នូលដែកពេញខាងក្នុង, អាចបាញ់តែ ១ ព្រួញឲ្យមុតធ្លុះបន្ទោលរទេះ ៤០០ និងដាច់កមនុស្ស ៥១០ នាក់ទៀតបាន, នេះក៏ជាមនុស្សមានបុណ្យចំឡែកក៏មិនគួរឲ្យជឿសោះដែរ ប៉ុន្តែកាលបើនឹកឃើញពុទ្ធភាសិតថា "នត្ថិ កម្មពលំ សមំ ឥតកម្លាំងអ្វីស្មើនឹងកម្លាំងកម្ម" តែប៉ុណ្ណោះ ក៏ជាហេតុឲ្យខានជឿពុំកើត ។ មនុស្សដូចព្រះពុទ្ធឃោសៈនេះ គេហៅថា "អច្ឆរិយត្ថតបុរស" ឬ "អច្ឆរិយត្ថតបុគ្គល" ត្រូវគ្នានឹងភាសាបារាំងសែសថា «génie» ។

យកគម្ពីរនោះទៅលាក់បាត់ ដើម្បីនឹងប្រកាសបុញ្ញានុភាពរបស់ព្រះថេរៈ អង្គនេះ ។ ព្រះពុទ្ធឃោសាចារ្យតើនឡើងក្នុងវេលាមជ្ឈិមយាម, រកគម្ពីរពុំឃើញ ក៏ចារមួយគម្ពីរទៀត ចប់ក្នុងវេលាមជ្ឈិមយាម ហើយសរសេរមួយស្របក់ទៀត, ព្រះឥន្ទ្រលបយកទៅទៀត នាំគម្ពីរទាំងពីរចប់នោះទៅឋានតាវត្តិង្ស បង្គាប់ឲ្យពួកទេវតាអប្សរធ្វើខ្សែរដោត ធ្វើសំពត់រុំ ។ ព្រះពុទ្ធឃោសាចារ្យ តើនឡើងចារគម្ពីរដដែលបានមួយចប់ទៀត ក្នុងវេលាបច្ចិមយាមទើបឃើញព្រះឥន្ទ្រនាំគម្ពីរពីរចប់មុននោះ មកប្រគេនវិញ ហើយលោកដាក់ទណ្ឌកម្មឲ្យព្រះឥន្ទ្រថា ដោយកំហុសដែលទេវរាជបានធ្វើហើយនេះ ត្រូវទេវរាជទទួលទណ្ឌកម្ម លីគម្ពីរទាំងបីចប់នេះទៅប្រគេនសម្តេចព្រះសង្ឃបាលត្ថេរ កុំគេចវេះខ្លួនទៅណាឡើយ គ្រាន់អាត្មានឹងកាន់ជាសាក្សី ដើម្បីកុំឲ្យព្រះសង្ឃបាលត្ថេរកេះគន់ថ្កោលទោសដល់អាត្មាបាន ។ ព្រះឥន្ទ្រក៏យល់ព្រមនឹងទទួលទណ្ឌកម្មដោយសេចក្តីសោមនស្ស ហើយទៅបបួលពួកចាតុម្មហារាជិកាទេវតាឲ្យចុះមកជួយហែរគម្ពីរឡើងពីកំពង់ត្រមង់ទៅវត្តមហាវិហារ, តួអង្គព្រះឥន្ទ្រឯងលីគម្ពីរទៅជាខាងមុខ, ព្រះពុទ្ធឃោសាចារ្យនិមន្តតាមជាប់ពីខាងក្រោយ, ពួកចាតុម្មហារាជិកាទេវតាខ្លះកាន់ទង់ ខ្លះកាន់ឆ័ត្រ ខ្លះកាន់ផ្កាដ៏វិចិត្រ ដោយពណ៌ផ្សេងៗ ហែហមពីខាងស្តាំខាងឆ្វេង ចូលទៅក្នុងវត្តមហាវិហារ,

អស់ពួកមហាជនបានឃើញទេវតាដោយជាក់ច្បាស់ ហើយហោមរោមដួយហៃហាមត្រៀបត្រា ៗ ព្រះពុទ្ធឃោសាចារ្យបានលើកគម្ពីរទាំងបីចប់ប្រគេនថ្វាយសម្តេចព្រះសង្ឃរាជថេរ ៗ ព្រះសង្ឃរាជថេរបានទទួលដោយអំណរណាស់ ហើយមានថេរដីកាថា ខ្ញុំករុណាមានសេចក្តីត្រេកអរច្រើន ដោយបានជួបនឹងលោកម្ចាស់ជាអ្នកប្រាជ្ញអាចធ្វើការមានថ្មីដែលពូកែ ប៉ុន្តែខ្ញុំករុណាឃើញថាលោកម្ចាស់ហាក់ដូចជាបញ្ចេញអំនួតបន្តិច ព្រោះខ្ញុំករុណាសូមឲ្យរៀបរៀងគម្ពីរត្រឹមតែមួយចប់ ឥឡូវនេះ លោកម្ចាស់បំផ្លើសឲ្យលើសពីរចប់ទៀត ឡើងចំនួនដល់បីចប់ នាំមកបង្អួតពួកយើងអ្នកលង្កា, កិរិយានេះក្រែងមិនសមជាគតិអ្នកប្រាជ្ញទេដឹងលោកម្ចាស់? ព្រះពុទ្ធឃោសាចារ្យនឹកក្នុងព្រះហឫទ័យថា, អ៊ុញហ្ន៎! រឿងនេះមកដល់ហើយតើ! ពីដើមមក អាត្មាអញបារម្ភណាស់ក្នុងរឿងនេះ, ឥឡូវនេះ បានព្រះសង្ឃរាជថេរចោទចំដូច្នេះ ជាហេតុឲ្យស្អាតខ្លួនមិនឲ្យមានទំនាស់ទៅទៀតបាន, ទើបលោកទូលតបថេរដីកាថា សូមទ្រង់ព្រះមេត្តាប្រោស! អំពើនេះមិនមែនខ្ញុំព្រះករុណាធ្វើដើម្បីអួតអាងឲ្យអ្នកលង្កាគោរពទេ, ប្រាកដជាធ្វើដោយសុទ្ធចិត្ត; គម្ពីរនេះបានជាឡើងចំនួនដល់បីចប់ដូច្នេះ ព្រោះចោរពីឋានសួគ៌ចេះតែមកលួចយកបាត់ៗទៅ, ខ្ញុំព្រះករុណានឹងរង់ចាំរកគម្ពីរដែលបាត់ទៅឲ្យឃើញសិនសឹមយក

មកប្រគេន, ក្រែងជួនជាពុំទាន់វេលាដែលសន្មត, ហេតុដូច្នេះ បានជាខ្ញុំព្រះករុណាចំចារមួយចប់ហើយមួយចប់ទៀត ដើម្បីជំនួសគម្ពីរដែលបាត់ទៅនោះ, ចប់គម្ពីរទីបី ស្រាប់តែព្រះឥន្ទនាំយកគម្ពីរពីរចប់មុននោះមកឲ្យវិញ, សូមទ្រង់ព្រះមេត្តាប្រោស! នេះព្រះឥន្ទ! ដែលជាអ្នកលួចគម្ពីរយកទៅ, ឥឡូវនេះ ខ្ញុំព្រះករុណា សូមនាំយកមកប្រគេនជាបន្ទាល់សាក្សី; រឿងនេះដូច្នេះទេតើ សូមទ្រង់អភ័យទោស ។

គ្រានោះ ភិក្ខុសង្ឃប្រជុំគ្នាអានគម្ពីរទាំងបីចប់នោះព្រមជាមួយគ្នា, ឥតមានដំណើរផ្សេងគ្នាដោយគន្ថៈ ដោយអក្ខរៈ ដោយបទ ដោយព្យញ្ជនៈ ដោយអត្ថ ដោយពាក្យដើមពាក្យចុង ដោយថេរវាទ ឬដោយព្រះពុទ្ធដីកាឡើយ ។ កាលបើគម្ពីរទាំងបីចប់ដែលព្រះពុទ្ធឃោសាចារ្យធ្វើឲ្យសម្រេចយ៉ាងនេះហើយ, ទេវតាទាំងឡាយ ក៏ធ្វើស័ព្ទសាធុការគង់រំពង, ទាំងពួកភិក្ខុសង្ឃជាច្រើនពាន់អង្គក្នុងវត្តមហាវិហារ ក៏បានមូលមកប្រជុំគ្នា ឃើញហេតុអស្ចារ្យដូច្នោះ ក៏មានចិត្តរីករាយជាសោមនស្ស ឲ្យស័ព្ទសាធុការឮសំឡេងខ្ទរខ្ទារថា លោកនេះឯងប្រាកដជាតួអង្គព្រះមេត្តេយ្យពោធិសត្វ ទ្រង់ចុះមកបំភ្លឺសត្វលោកឥតសង្ស័យឡើយ ។

លំដាប់នោះ ព្រះបាទមហានាម មហារាជ ក្នុងលង្កាទ្វីប ទ្រង់ព្រះសវនាការឮសំឡេងអស្ចារ្យនោះហើយ ទ្រង់ចេញចាកព្រះបរមរាជវាំង.

ដោយព្រះយសសិរីថ្កើងថ្កាន មានពួកពលបរិស័ទ្យហោមរោមហែហមជាបរិវារ ក្សត្រាទ្រង់ស្តេចចូលទៅក្នុងវត្តមហាវិហារ ថ្វាយបង្គំព្រះភិក្ខុសង្ឃហើយ ថ្វាយបង្គំចំពោះព្រះពុទ្ធឃោសាចារ្យថា សូមព្រះគុណទទួលចង្ហាន់ក្នុងដំណាក់ខ្ញុំករុណា ត្រាតែប្រែព្រះធម៌ចប់ កុំឲ្យព្រួយបារម្ភឡើយ ។ ព្រះពុទ្ធឃោសាចារ្យ បានទទួលបវារណាដោយតុណ្ហីភាព ។

គ្រានោះ ភិក្ខុសង្ឃបានប្រគល់គម្ពីរព្រះត្រៃបិដកទាំងឡាយជាភាសាបាលី ព្រមទាំងគម្ពីរអដ្ឋកថាទាំងឡាយជាភាសាសីហឡៈ ឲ្យមកព្រះពុទ្ធឃោសាចារ្យ ។ ព្រះពុទ្ធឃោសាចារ្យទទួលយកគម្ពីរទាំងអស់នោះ យកទៅគង់នៅក្នុងប្រាសាទមួយឈ្មោះ បធានឃរៈ[១] ក្នុងភាគខាងត្បូងនៃវត្តមហាវិហារ ប្រែអដ្ឋកថាភាសាសីហឡៈទាំងអស់មកជាភាសាមគធៈដែលជាមូលភាសា ។

សេចក្តីពិតថា អដ្ឋកថាភាសាសីហឡៈ មាន ៣ បែបគឺ មហាអដ្ឋកថា ១ បែប, បច្ចរិយអដ្ឋកថា ១ បែប, កុរុន្ទីអដ្ឋកថា ១ បែប ។

---

១ ក្នុងរឿងពុទ្ធឃោសនិទាន នឹងគម្ពីរសុត្តជាតក មានសេចក្តីថា ព្រះសង្ឃបាលត្ថេរ បានប្រគល់លោហប្រាសាទឲ្យជាទីគង់ធ្វើការដល់ព្រះពុទ្ធឃោសាចារ្យ ។ បធានឃរៈនេះ ជាសាលារៀនជាន់ខ្ពស់ ដែលព្រះសង្ឃបាលត្ថេរទ្រង់បង្រៀនសិស្សដោយព្រះអង្គឯង ។ សេចក្តីសន្និដ្ឋានថា បធានឃរៈនេះប្រហែលជាសាលារៀន ១ ក្រុមមានច្រើនខ្នង, ប្រាសាទ ១ ខ្នងដែលនៅក្នុងចំណោមបធានឃរៈនោះ ឈ្មោះលោហប្រាសាទ ។ ប្រវត្តិនៃលោហប្រាសាទនេះមានសេចក្តីពិស្តារក្នុងគម្ពីរមហាវង្ស ។

អដ្ឋកថាដែលព្រះមហាមហិន្ទ លើកឡើងកាន់មហាសង្គិតហើយនាំទៅធ្វើជាសីហឡភាសាឈ្មោះថា មហាអដ្ឋកថា ។ តាមភាសាសីហឡៈហៅក្បួនថា "បច្ចរិយ", អដ្ឋកថាដែលព្រះអដ្ឋកថាចារ្យទាំងឡាយគង់លើក្បួនហើយធ្វើ ឈ្មោះបច្ចរិយអដ្ឋកថា ។ មានវត្តមួយឈ្មោះកុរុន្ទ-វេឡុវិហារ, អដ្ឋកថាដែលព្រះអដ្ឋកថាចារ្យទាំងឡាយគង់ក្នុងវត្តនោះហើយធ្វើ ឈ្មោះកុរុន្ទីអដ្ឋកថា ។ វាទៈដែលអាចារ្យទាំងឡាយអ្នកមានមតិស្របគ្នានឹងក្រមព្រះសង្គីតិកត្តោរជាន់មុន កាន់យកនូវទំនងនៃព្រះពុទ្ធដីកាមកធ្វើនោះឈ្មោះថាថេរវាទ ។

មុនដំបូងព្រះពុទ្ធឃោសាចារ្យ ប្រែកុរុន្ទីអដ្ឋកថាពីភាសាសីហឡៈធ្វើអដ្ឋកថាព្រះវិន័យឈ្មោះសមន្តបាសាទិកា ដោយភាសាមគធៈដែលជាមូលភាសា ។ លំដាប់ពីនោះ លោកប្រែមហាអដ្ឋកថាក្នុងព្រះសុត្តន្តបិដកពីភាសាសីហឡៈ រៀបរៀងអដ្ឋកថានៃគម្ពីរទីឃនិកាយឈ្មោះសុមង្គលវិលាសិនី, រៀបរៀងអដ្ឋកថានៃគម្ពីរមជ្ឈិមនិកាយឈ្មោះបបញ្ច-សូទនី, រៀបរៀងអដ្ឋកថានៃគម្ពីរសំយុត្តនិកាយឈ្មោះសារត្ថប្បកាសិនី, រៀបរៀងអដ្ឋកថានៃគម្ពីរអង្គុត្តរនិកាយឈ្មោះមនោរថបូរណី ។ លំដាប់ពីនោះ លោកប្រែបច្ចរិយអដ្ឋកថាក្នុងអភិធម្មបិដកពីភាសាសីហឡៈ រៀបរៀងអដ្ឋកថានៃគម្ពីរធម្មសង្គណិប្បករណ៍ឈ្មោះអដ្ឋសាលិនី, រៀប

រៀនអដ្ឋកថានៃវិភង្គប្បករណ៍ឈ្មោះសម្មោហវិនោទនី , រៀបរៀនអដ្ឋកថានៃបញ្ចប្បករណ៍ (គម្ពីរអភិធម្មទាំង ៥ ខាងចុង) ឈ្មោះបរមត្ថទីបនី ។ ព្រះពុទ្ធឃោសាចារ្យ បានធ្វើអដ្ឋកថាព្រះត្រៃបិដកដែលជាភាសាសីហឡៈទាំងអស់ឲ្យជាភាសាមគធៈដែលជាមូលភាសា យ៉ាងនេះ ។ អដ្ឋកថាព្រះត្រៃបិដកដែលព្រះពុទ្ធឃោសាចារ្យធ្វើនេះសម្រេចក្នុងរវាង ១ ឆ្នាំ ។

ក្នុងកាលដែលព្រះពុទ្ធឃោសាចារ្យប្រែអដ្ឋកថាព្រះត្រៃបិដកចប់សព្វគ្រប់ ក៏កើតមានហេតុអស្ចារ្យ គឺក្រឡាមហាប្រថពីកក្រើករំពើកញាប់ញ័រ ឮសូរស័ព្ទហាក់ដូចជាសម្រែកស្រែកទទួលអំណរ ខ្ទរខ្ទរ ពេញទាំងលោកសន្និវាស ។

ព្រះពុទ្ធឃោសាចារ្យ ធ្វើការប្រែគម្ពីរអដ្ឋកថាព្រះត្រៃបិដកគ្រានេះ លោកសម្រិតសម្រាំងធម៌វិន័យត្រឹមត្រូវបរិសុទ្ធគ្រប់អក្ខរ ចាត់ជាសង្គាយនាទី ៣ ក្នុងលង្កាទ្វីប ឬចាត់ជាសង្គាយនាទី ៦ រាប់ពីបឋមសង្គាយនាក្នុងជម្ពូទ្វីបមក ។

ព្រះពុទ្ធឃោសាចារ្យ កាលបើប្រែគម្ពីរអដ្ឋកថាចប់ស្រេចហើយ ក៏ក្រាបបង្គំលាសម្ដេចព្រះសង្ឃបាលតេរជាមហាសង្ឃរាជ ទាំងភិក្ខុសង្ឃ ថ្វាយព្រះពរលាព្រះបាទមហានាម ម្ចាស់ផែនដីលង្កាទ្វីប ព្រមទាំងព្រះ

រាជសេវកៈនឹងអ្នកដែលគួរណាទាំងអស់ ហើយនាំគម្ពីរចុះកាន់សំពៅ ដើម្បីត្រឡប់ទៅកាន់ជម្ពូទ្វីបវិញ ។ គ្រានោះ ពួកពុទ្ធបរិសទ្យអ្នកលង្កាទ្វីប មានព្រះបាទមហានាមនឹងព្រះសង្ឃបាលត្ថេរជាដើម បានជូនដំណើរចុះទៅកាន់សំពៅ បានថ្លែងធម្មវោហារពីរោះពីសាគួរឲ្យជាប់ចិត្តជាច្រើនប្រការ ។ ព្រះពុទ្ធឃោសាចារ្យមានសេចក្ដីសោមនស្សអស់ពីព្រះទ័យទើបថ្វាយព្រះគាថាឈ្មោះ អដ្ឋុត្តសេតមង្គល[១] ចំពោះព្រះរាជាថា "បពិត្រមហារាជ, អាត្មាភាពមានអំណរក្រៃពេកចំពោះបដិសណ្ឋារកិច្ចរបស់ព្រះអង្គនឹងព្រះសង្ឃទាំងអស់, ទីបំផុតនៃដំណើរមកនេះ អាត្មាភាពឥតវត្ថុអ្វីថ្វាយទុកជាទីរលឹកទេ, មានតែព្រះគាថានេះជាបទនមស្ការចំពោះព្រះបាទទាំងគូនៃព្រះសព្វញ្ញុពុទ្ធជាម្ចាស់ សូមព្រះអង្គស្វាធ្យាយសូត្រឲ្យរឿយៗចុះ ព្រះអង្គនឹងបានសុគតិសួគ៌ជាសម្បរាយភពពុំខាន" ។ លំដាប់នោះ នាយកេត្រាចាត់ការបើកសំពៅនាំព្រះពុទ្ធឃោសាចារ្យត្រឡប់ទៅកាន់ជម្ពូទ្វីបវិញ ។ ព្រះពុទ្ធឃោសាចារ្យឡើងទៅនមស្សការប្រគេនគម្ពីរដល់ព្រះមហាថេរជាឧបជ្ឈាយ៍ បានទទួលពរសព្វសាធុការនឹងសេចក្ដីសរសើរច្រើនប្រការអំពីសំណាក់ឧបជ្ឈាយ៍ បានកិត្តិនាម

---

១ ធម៌សរសើរព្រះបាទ ដែលមានបាលីថា "យស្ស បាទេ សុជាតានិ ទ្វេ ចក្កានិ មហេសិនោ នានាការេហិ បុណ្ណានិ តំ វន្ទេ បរិសុទ្ធិទំ" ដូច្នេះជាដើម ដែលព្រះសង្ឃប្រទេសយើងច្រើនតែសូត្រក្នុងរដូវភ្ជុំបិណ្ឌ ។

ល្បីល្បាញប្រាកដក្នុងលោក ថាជាអ្នកប្រាជ្ញចម្បងក្នុងពុទ្ធសាសនាប៉ែកខាងទក្ខិណនិកាយ បានជាព្រះគន្ថរចនបណ្ឌិតទាំងឡាយ ក្នុងនានាប្រទេសអត់ទ្រាំពុំបាន បានតែងរឿងសរសើរព្រះពុទ្ធឃោសាចារ្យជាច្រើនបែប[១] ។

រឿងប្រវត្តិព្រះពុទ្ធឃោសាចារ្យមានសេចក្តីផ្សេងៗ ជាច្រើនបែបដល់ម្ល៉េះ បានជានាំឲ្យអ្នកមើលមានទិដ្ឋិផ្សេងគ្នាជាច្រើន គឺអ្នកខ្លះដែលសម្បូណ៌ដោយសទ្ធាយល់ថា រឿងព្រះពុទ្ធឃោសាចារ្យទាំងប៉ុន្មាន សុទ្ធតែពិតទាំងអស់; អ្នកខ្លះដែលប្រាសចាកសទ្ធាពុំជឿថាពិតទេ, ព្រោះរឿងទាំងនោះសំដែងសេចក្តីសរសើរព្រះពុទ្ធឃោសាចារ្យលើសលុបពេក ឃើញថាព្រះពុទ្ធឃោសាចារ្យអង់អាចហួសវិស័យមនុស្សធម្មតាដែលគេធ្លាប់ឃើញនឹងភ្នែក, អ្នកខ្លះដែលមានសទ្ធាប្រកបដោយប្រាជ្ញាយល់ថា

---

១ រឿងមហាវង្សពង្សាវតារលង្កាទ្វីប, ពុទ្ធឃោសនិទាន, វិសមាលិនី ញាណោទ័យ, សត្ថុជាតកនិទានានិសង្ស, ពុទ្ធឃោសុប្បត្តិកថា, ស្យាមូបសម្បទវត្ត, រឿងប្រតិស្ឋានព្រះសង្ឃស្យាមវង្សក្នុងលង្កាទ្វីបជាដើម; រឿងទាំងនេះ ជាភាសាបាលីក៏មាន ភាសាសៀម ភាសាខ្មែរដែលប្រែពីបាលីក៏មាន ភាសាសៀមដែលគេតែងសេចក្តីវិនិច្ឆ័យ និងសេចក្តីសន្និដ្ឋានក៏មាន ។ ក្នុងពុទ្ធឃោសនិទាន មានសេចក្តីមួយកន្លែងថា ព្រះពុទ្ធឃោសាចារ្យនេះជាតួអង្គអគ្គសាវកនៃព្រះអរិយមេត្តេយ្យ, ប៉ុន្តែខ្ញុំស្រាវជ្រាវរកដើមហេតុនៃពាក្យនេះ ឲ្យឃើញថាជាព្យាករណ៍របស់ព្រះអរហន្តអង្គណាពុំឃើញសោះ ។ ក្នុងរឿងពុទ្ធឃោសុប្បត្តិកថាថា ព្រះពុទ្ធឃោសាចារ្យបិតនៅជាសុខដរាបដល់អស់ព្រះជន្មបានទៅកើតក្នុងឋានតុសិត ។

រឿងនោះពិតដោយច្រើន, ប៉ុន្តែគង់មានសេចក្តីលើសលុបហួសទំនងខ្លះក៏មាន; ដូចរឿងដែលបានថ្លែងមកហើយនេះ ហុចសេចក្តីឲ្យឃើញថា "ព្រះពុទ្ធឃោសាចារ្យប្រែអដ្ឋកថា ព្រះត្រៃបិដកមួយចប់តែម្នាក់ឯងគត់, ធ្វើហើយស្រេច ក្នុងរវាង ១ ឆ្នាំ សន្នតការនោះហៅថា "តតិយសង្គាយនាក្នុងលង្កាទ្វីប" ។ សេចក្តីនេះពុំសមបុងសមដើមទេ, ព្រោះទំនៀមការសង្គាយនាតាំងពីបឋមសង្គាយនា ទុតិយសង្គាយនា តតិយសង្គាយនាក្នុងជម្ពូទ្វីប ដែលព្រះអរហន្តទាំងឡាយ មានព្រះមហាកស្សបជាដើមបានធ្វើរឿងមក លោកតែងប្រជុំព្រះអរហន្តច្រើនរយអង្គណាស់ ក្នុងគ្រាដែលធ្វើសង្គាយនាម្តង ៗ, ចុះប្លែកអ្វីតែសង្គាយនារបស់ព្រះពុទ្ធ-ឃោសាចារ្យនេះ លោកជាបុថុជ្ជនសោះទេ ម្តេចក៏ធ្វើត្រមោចត្រមង់តែមួយអង្គឯងដូច្នេះ ។

សេចក្តីសន្និដ្ឋានថា ព្រះពុទ្ធឃោសាចារ្យជាអ្នកប្រាជ្ញចម្បងពិតមានបុញ្ញារិទ្ធិលើសវិស័យមនុស្សធម្មតាមែន ប៉ុន្តែគ្រាដែលធ្វើការនេះប្រាកដជាលោកប្រជុំអ្នកប្រាជ្ញជាតិសីហឡៈជាច្រើនរូបមកធ្វើរួមផង, ដូច្នេះទើបការនេះគេចាត់ជាសង្គាយនាបាន ។

មានភស្តុតាងមួយកន្លែងទៀតដែលល្មមឲ្យសន្និដ្ឋានថា ការនេះ អ្នកប្រាជ្ញច្រើនរូបប្រជុំគ្នាធ្វើ គឺគេសង្កេតឃើញគម្ពីរអដ្ឋកថាដែលមានឈ្មោះ

ថាព្រះពុទ្ធឃោសាចារ្យធ្វើតាំងពីមុននោះ ប្លែកគ្នាដោយរបៀបពាក្យ និងអត្ថាស្រ័យជាច្រើនអន្លើ, កន្លែងខ្លះមានរបៀបពាក្យល្អល្អះលះសេចក្តីបន្តុលប្រាប់ហេតុផលធំៗ គួរឲ្យសន្និដ្ឋានថាជាស្នាដៃព្រះពុទ្ធឃោសាចារ្យមែនៗ កន្លែងខ្លះមានសេចក្តីរាំសៗ ពុំសូវបន្តុលប្រាប់ហេតុផលចំៗទេ; គួរឲ្យសន្និដ្ឋានថាពុំមែនស្នាដៃព្រះពុទ្ធឃោសាចារ្យឡើយ ។ មួយក៏ព្រះពុទ្ធឃោសាចារ្យ ធ្វើតែមួយអង្គឯងពិត គង់វេលាដែលលោកស្រួលក្នុងអង្គបែកប្រាជ្ញា លោកធ្វើការបានល្អ, ដល់ជាវេលាដែលលោកពុំស្រួលក្នុងអង្គគុះប្រាជ្ញាបន្តិច លោកធ្វើត្រឹមស្រេកស់ឲ្យតែរួចៗ ទៅដូច្នេះទេដឹង! ប៉ុន្តែ បើយ៉ាងនេះ ការនេះមិនមែនជាសង្កាយនាទេ ។

ចប់ពុទ្ធឃោសប្បវត្តិតែប៉ុណ្ណេះ ។

ក្នុងសៀវភៅស្យាមូបសម្បទវគ្គ មានសេចក្តីថា តាំងពីព្រះពុទ្ធឃោសាចារ្យចេញទៅធ្វើសង្គាយនាកាល ព.ស. ៩៥៦ ក្នុងផែនដីព្រះបាទមហានាម តមកមានព្រះមហាថេរ ដែលបានតែងគម្ពីរក្នុងផ្លូវព្រះពុទ្ធសាសនាទំនងជាមួយគ្នាប្រាប់នាមទុក ២៧ រូបគឺៈ

១- ព្រះពុទ្ធទត្ត
២- ព្រះធម្មបាល
៣- ព្រះជោតិបាល
៤- ព្រះខេម
៥- ព្រះធម្មសិរី
៦- ព្រះនន្ទ
៧- ព្រះកាខន្ទ
៨- ព្រះអនុរុទ្ធ
៩- ព្រះឧបតិស្ស
១០- ព្រះពុទ្ធរក្ខិត
១១- ព្រះមោគ្គល្លាន
១២- ព្រះហេរីបុត្ត (ព្រះសារីបុត្តនេះមានសេចក្តីដែលគេសរសេរទុកមកថាលោកមានការចេះចាំយ៉ាងវិសេសណាស់ បើបានស្តាប់ឮសេចក្តីណា សូម្បីតែមួយក៏អាចចាំបានដល់ ១០០០ គាថា) ។
១៣- ព្រះសង្ឃរក្ខិត
១៤- ព្រះសុមង្គល
១៥- ព្រះវង្គិស
១៦- ព្រះធម្មកិត្តិ
១៧- ព្រះនាគសេន
១៨- ព្រះកាខន្ទ
១៩- ព្រះវិទេហ:
២០- ព្រះពុទ្ធវិរិយ:
២១- ព្រះអនោមទស្សី
២២- ព្រះសោលកសិក្ខាថ
២៣- ព្រះសហិតវិតមុល

២៤– ព្រះអនុរុទ្ធ | ២៦– ព្រះមោឃរាជ
២៥– ព្រះទីបង្ករ | ២៧– ព្រះធម្មសេន

ក្រៅពីនេះ មានពួកបណ្ឌិតជាគ្រហស្ថ ដែលបានធ្វើការជាមួយគ្នា ៩ នាក់ទៀតគឺ:

១– សទ្ទបេទ | ៦– បុរុលុគេម៍
២– ធម្មកិត្តិបទ | ៧– ភាគមបក្កន្តិ
៣– ធីរនោគបាល | ៨– បរក្កមបណ្ឌិត
៤– ពដមុទារ | ៩– ភាគរបណ្ឌិត
៥– គវិពដសេខរ:

ព្រះសង្ឃនិងគ្រហស្ថជាបណ្ឌិត ដែលមានសំដែងនាមខុកក្នុងសៀវភៅវិស្សរាមូបសម្បទវគ្គទាំងនេះ ពុំប្រាកដជាលោកណា បានតែងគម្ពីរអ្វីខ្លះ ពីក្នុងកាលណាខ្លះសោះឡើយ ។ ប៉ុន្តែបើខុកជាដូច្នោះ ក៏គង់មានអ្នកខ្លះយល់ថា "ប្រហែលជាលោកអ្នកប្រាជ្ញទាំងនេះហើយ ដែលធ្វើសង្គាយនាជាមួយនឹងព្រះពុទ្ធឃោសាចារ្យ" ។ សេចក្តីយល់ស្មានដូច្នេះ ខ្ញុំមិនចុះអនុមតិផងទេ ។

ស៊ុមង៍

# សេចក្ដីជូនដំណឹង

## អំពីពុទ្ធសាសនបណ្ឌិត្យ

# នឹងជូនរង្វាន់ជាទីពេញចិត្ត

ដោយក្រសួងពុទ្ធសាសនបណ្ឌិត្យ ត្រូវការរឿងពិធីបុណ្យចូលឆ្នាំតាមរបៀបទម្លាប់ខ្មែរ ដែលគេធ្វើជាសណ្ដាប់រឿងមក, ទើបសូមប្រកាសដល់អស់លោក-អ្នកដែលមើលទស្សនាវដ្ដីកម្ពុជសុរិយារបស់យើង ឬអ្នកណាមួយក៏ដោយ ដែលមានសេចក្ដីចេះចាំរឿងនេះច្បាស់លាស់ សុំឲ្យតែងជាសេចក្ដីរាយការដោយល្អិតពិស្ដារតាមរបៀប តាំងអំពីដើមហេតុដល់ចប់ដោយន័យកំណត់ដូចនេះ :

១– ការផ្ដើមបុណ្យ មានរបៀបដូចម្ដេចខ្លះ?

២– គឺពិធីបុណ្យទាំង ៣ ថ្ងៃ គេមានកិច្ចដែលត្រូវធ្វើដូចម្ដេចខ្លះ? ចូររៀបរៀងដោយពិស្ដារ តាមលំដាប់មុនក្រោយដោយយ៉ាងរៀងៗទៅ ។

៣– របៀបធ្វើនៅផ្ទះ ដូចម្ដេចខ្លះ? ធ្វើនៅទីវត្តដូចម្ដេចខ្លះ? ចូរអធិប្បាយឲ្យសព្វគ្រប់ ។

៤– គឺពិធីបុណ្យនេះ មានលេងល្បែងប្រៀង អ្វីខ្លះ របៀបលេងនោះដូចម្ដេច? មានគ្នាលេងច្រើនប៉ុន្មាននាក់? សូមឲ្យអធិប្បាយ

ដោយល្អិត ព្រមទាំងកត់ឈ្មោះល្បែងទីងទំនុកច្រៀងអំបាលនោះឲ្យសព្វគ្រប់ផង ។

៥- គប្បីតែងតាមពិត តាមដែលខ្លួនបានដឹង បានឃើញរបៀបដែលគេធ្វើក្នុងស្រុករបស់ខ្លួនឬក្នុងតំបន់នានា ? ឃើញពីកាលណា ? ឲ្យកត់ផង កុំឲ្យខ្វះ កុំឲ្យបំផ្លើសលើស ។ បើមានពាក្យសុភាសិត ឬពាក្យប្រដៅ ឬទំនុកច្រៀង ដែលគេតែងច្រៀងក្នុងឱកាសចូលឆ្នាំ ឲ្យកត់បម្លងដាក់ទៅផង ។

ក្នុងកិច្ចនេះ ក្រសួងពុទ្ធសាសនបណ្ឌិត្យបានតាំងជារង្វាន់ទុក ៣ ជាន់ គឺរង្វាន់លេខ ១ លេខ ២ លេខ ៣ សម្រាប់ជូនដល់អ្នកតែងល្អយ៉ាងលេខ ១- លេខ ២- លេខ ៣ ។ ហេតុនេះលោក-អ្នកដែលស្ម័គ្រតែងរឿងនេះ កាលតែងចប់ហើយ សុំឲ្យបញ្ជូនទៅក្រសួងពុទ្ធ-សាសនបណ្ឌិត្យនៅភ្នំពេញ ក្រសួងនេះបានទទួលហើយ នឹងដាក់ឲ្យក្រុមជំនុំពិនិត្យ ហើយនឹងជូនរង្វាន់ដល់លោក-អ្នកដែលតែងល្អ ដូចបានកំណត់ខាងលើនេះជាពិតប្រាកដ ។ ការតែងរឿងនេះ មិនមែនត្រូវការដល់ទៅសរសេរឲ្យល្អ ឬដាក់អក្សរឲ្យត្រឹមត្រូវនោះទេ ត្រូវការតែឲ្យបានសព្វគ្រប់ ហើយជាសេចក្តីពិតផង អ្នកណារួបរួមបានសព្វគ្រប់ ទុកជាបានការ ហើយឲ្យបានយ៉ាងយូរត្រឹមថ្ងៃ ១ កើតខែជេស្ឋ

ឆ្នាំមមែបញ្ចស័ក ។ ក្រុមជំនុំពិនិត្យហើយ ឃើញថារបស់អ្នកណាល្អ ទីងនាំចុះផ្សាយក្នុងកម្ពុជសុរិយា ។

សូមឲ្យលោក-អ្នក មើលសៀវភៅកម្ពុជសុរិយា ជួយផ្សាយដំ-ណឹងនេះ ទៅៈដោយស្រពន់ផង ។

សូមអរគុណទុកជាមុន

ថ្ងៃ ២៩ ខែម៉ារ្ស ឆ្នាំ ១៩៤៣

ពុទ្ធសាសនបណ្ឌិត្យ

# សេចក្តីជូនដំណឹង

តាំងអំពីឆ្នាំ ១៩៤៣ នេះជាដើមទៅ យើងបានចាត់រៀបចំទស្សនាវដ្តី "កម្ពុជសុរិយា" តាមរបៀបថ្មី ដូចជាទស្សនាវដ្តី (Revue) ទាំងឡាយរបស់នានាប្រទេស លោក-អ្នកគ្រាន់តែក្រឡេកមើលក្របសៀវភៅខាងមុខបង្អស់នេះ ក៏អាចជ្រាបបានមួយរំពេចថា ខាងក្នុងសៀវភៅនេះមានរឿងអ្វីខ្លះ ព្រមទាំងនាមអ្នករៀបរៀងរឿងនោះៗ ។

ដោយហេតុមានឧបសគ្គនឹងក្រក្រដាសបោះពុម្ពជាបំផុតក្នុងសម័យសព្វថ្ងៃនេះ នាំឲ្យទស្សនាវដ្តីកម្ពុជសុរិយា កម្របានចេញផ្សាយទាំងយឺតយូរខុសធម្មតាសព្វដងផង ទើបយើងរួបរួមរឿងរ៉ាវផ្សេងៗក្នុងរវាង ៣ ខែនោះមកបញ្ចូលក្នុងមួយសៀវភៅនេះ ដែលមានចំនួនដល់ ១៨០ ទំព័រ សម្រាប់ខែយ៉ាំងវិយេរ ហ្វេវ្រិយេរនឹងម៉ារ្ស ហេតុនេះ យើងសូមទោសអស់លោក-អ្នកជាវ ដែលទស្សនាវដ្តីរបស់យើង ចេញផ្សាយយឺតយូរមិនទាន់កំណត់ក្នុងឱកាសនេះផង ប៉ុន្តែយើងសូមជំរាបទុកជាមុនថា បើមិនមានឧបសគ្គអ្វីទេ ចាប់តាំងពីខែអាវ្រិលនេះតទៅ ទស្សនាវដ្តីកម្ពុជសុរិយានឹងចេញផ្សាយក្នុងកំណត់ ១ ខែ ១ ក្បាលដូចសព្វដងរៀងទៅ ។

មួយវិញទៀត យើងសូមជូនដំណឹងថា សាសនកិច្ចានុក្រមដែលធ្លាប់បោះចេញផ្សាយរាល់ៗខែនោះ ឥឡូវត្រូវឈប់មានបោះពុម្ពតទៅទៀត តែយើងនឹងប្រមូលយករឿងផ្សេងៗក្នុងសាសនកិច្ចានុក្រមនោះមកដាក់ក្នុងទស្សនាវដ្តីនេះវិញ ខាងចុងភាគសៀវភៅនេះ ហេតុនេះតាំងពីឥឡូវនេះទៅ កម្ពុជសុរិយានឹងមានរឿងរ៉ាវខាងសាសនកិច្ចានុក្រមមកបញ្ចូលខ្លះផង ដូចមានដំណឹងតាំងចៅអធិការនឹងបុណ្យបញ្ចុះសីមាជាដើម ។

## សៀវភៅបោះពុម្ពចេញថ្មី អំពីពុទ្ធសាសនបណ្ឌិត្យ

១ — គំរូក្បាច់ចាក់ខ្មែរ សម្តេចព្រះបិតុច្ឆារស្មីសោភ័ណឧភោគ ទ្រង់រៀបរៀង សៀវភៅនេះមានប្រយោជន៍ដល់ស្ត្រីជាតិខ្មែរទូទៅ ព្រោះគំរូក្បាច់ដែលមាននៅក្នុងសៀវភៅនេះ មានបែបផ្សេងៗជាច្រើនរាប់រយមុខ គួរតែកុមារីជាតិខ្មែរទិញទុកប្រើការផ្ទាល់ខ្លួនរាល់គ្នា ។ សៀវភៅនេះដំឡៃ ១ ក្បាល ៣រ.៦០ ។

២ — មិលិន្ទប្បញ្ហាភាគ ១ បោះពុម្ពឡើងវិញហើយ ដំឡៃថ្មី ១ ក្បាល ១រ.៥០ ។

៣ — អភិធម្មត្ថសង្គហៈសម្រាយចំណាយអស់យូរហើយ ឥឡូវចាប់បោះពុម្ពឡើងវិញ ដំឡៃថ្មី ១ ក្បាល ១រ.៥០ ។